# ពន្ធ័កិច្ច អាន អធិស្ឋាន រីកចម្រើន

កូនសៀវភៅសម្រាប់អាននាពេលស្ងៀមស្ងាត់ **អាន អធិស្ឋាន រីកចម្រើន** (RPG) ជាព័ន្ធកិច្ចបោះពុម្ពផ្សព្វផ្សាយ របស់ព្រះវិហារ**កាល់វ៉ារី ផាន់ដិន ព្រះគម្ពីរប្រេ៍សប៊ីធីរាន**។ ការប្រែសម្រួលជាភាសាខ្មែរក្រោមពន្ធ័កិច្ចនៃ **ព្រះវិហារ ប៊ីភី ដំណឹងល្អពិត** ខេត្តកំពត ប្រទេសកម្ពុជា។

**អាន អធិស្ឋាន រីកចម្រើន** (អ.អ.រ) **មគ្គុទេសក៏សម្រាប់ការអានព្រះគម្ពីរប្រចាំថ្ងៃ** គឺត្រូវបោះពុម្ពជារៀងរាល់ត្រីមាសម្តង ដោយរោងពុម្ព **ថេប៊ីណិខល ប៊ុកស៍** (Tabernacle Books) ប្រទេសសឹង្ហបូរី។

បច្ចុប្បន្ន ដោយសារព្រះគុណនៃព្រះ **អ.អ.រ** កំពុងជួយគ្រីស្ទបរិស័ទទូទាំងពិភពលោកអានព្រះបន្ទូលយ៉ាងទៀតទាត់និងប្រកបដោយអត្ថន័យ។ អ្នកនិពន្ធសៀវភៅនេះគឺសុទ្ធតែជាគ្រូគង្វាលនិងសាស្ត្រាចារ្យព្រះគម្ពីរដែលប្រកាន់ខ្ជាប់ខ្ជួនតាម គោលជំនឿគ្រីស្ទបរិស័ទបែបអភិរក្សនិយម និងជាអ្នកលើកកំពស់ព្រះគម្ពីរផងដែរ។ **អ.អ.រ** ភាសាអង់គ្លេសប្រើព្រះគម្ពីរឃីង ចែមស៍ (King James Version) សម្រាប់អាន ជាព្រះគម្ពីរនៃចលនាកែទម្រង់ និងភាសាខ្មែរ ប្រើព្រះគម្ពីរខ្មែរបរិសុទ្ធ ១៩៥៤។ ការទ្រទ្រង់សម្រាប់បោះគឺបានមកតាមរយៈដង្វាយក្តីស្រឡាញ់និងដង្វាយស្ម័គ្រពីចិត្តរបស់រាស្ត្រនៃព្រះ។ យើងខ្ញុំអរព្រះគុណព្រះជាអនេកដោយបានបង្កើតពន្ធ័កិច្ចនេះឡើងហើយរក្សាវាជានិរន្តតាំងពីឆ្នាំ១៩៨២។

**អ.អ.រ** បោះពុម្ពជាភាសាអង់គ្លេស។ ក្រុមអ្នកបកប្រែដែលមានឆន្ទះខ្ពស់សម្រាប់កូនសៀវភៅនេះបានខិតខំព្យាយាមប្រែសម្រួល**មគ្គុទេសក៏សម្រាប់ការអានព្រះគម្ពីរប្រចាំថ្ងៃ**ពីភាសាអង់គ្លេសមកភាសាខ្មែរប្រយោជន៍ឲ្យគ្រីស្ទបរិស័ទកម្ពុជាមានធុនធានជំនួយសម្រាប់ការសិក្សាព្រះបន្ទូលផ្ទាល់ខ្លួន។ យើងខ្ញុំសូមលើកទឹកចិត្តលោកអ្នក បងប្អូនចុះឈ្មោះសម្រាប់កូនសៀវភៅ ក៏ដូចជាជួយណែនាំមិត្តភក្តិឲ្យបានស្គាល់សៀវភៅនេះផងដែរ។ បើព្រះទ្រង់សព្វព្រះហឫទ័យ យើងខ្ញុំនឹងផ្ញើ **អ.អ.រ** ជូនសម្រាប់អ្នកដែលចង់ប្រើប្រាស់វា។ សូមឲ្យយើងជួយអធិស្ឋានសម្រាប់ពន្ធ័កិច្ចពាក្យបន្ទូលនេះបន្តទៀត។

**អ.អ.រ** ក៏ត្រូវបានបកប្រែជាច្រើនភាសា មានដូចជា ភាសាចិន ភាសាឥណ្ឌូនេស៊ី ភាសាភូមា ជាដើម ។ល។ សូមផ្ញើសាអេឡិចត្រូនិក មកយើងខ្ញុំ ប្រសិនបើលោកអ្នកចង់ចុះឈ្មោះទិញសម្រាប់មិត្តភក្តិ ឬ ក្នុងបំណងផ្សេងៗ។

**អ.អ.រ** ភាសាអង់គ្លេស តាមប្រពន្ធ័អ៊ីធឺណែតមាននៅលើគេហទំព័រ www.calvarypandan.sg/rpg

**អ.អ.រ** ក៏មានជាឯកសារដែលអាចទាយយកសម្រាប់ប្រើប្រាស់តាមប្រពន្ធ័កុំព្យូទ័រ ទូរសព្ទ័ដៃ ឬ ឧបករណ៍អេឡិចត្រូនិកផ្សេងៗទៀតពីគេហទំព័រ www.truthbpc.com/rpg.html

ភាសាអង់គ្លេស៖ សូមទាក់ទងយើងខ្ញុំតាមសាអេឡិចត្រូនិក៖ rpg@calvarypandan.sg (ភាសាអង់គ្លេស)
ភាសាខ្មែរ៖ 012383513/069567990។

## ខែ កក្កដា-កញ្ញា ២០២១

# «ដំណឹងល្អនៃជីវិត»

## *The Gospel of Life*

*ការអត្ថាធិប្បាយបែបអនុវត្តន៍ពីដំណឹងល្អយ៉ូហាន*

**ដោយ**

**បណ្ឌិត ធីម៉ូធី ថូវ**

( *Rev Dr. Timothy Tow* )

---

### អំពីអ្នកនិពន្ធ៖



បណ្ឌិត **ធីម៉ូធី ថូវ** (១៩២០-២០០៩) ជាបិតាស្ថាបនិកចលនាគណៈនិកាយព្រះគម្ពីរប្រ៉េស ប៊ីធីរាននៅ អាស៊ីអាគ្នេយ៍ បន្ទាប់ពីលោកបានត្រឡប់មកប្រទេសសឹង្ហបុរីក្នុងឆ្នាំ ១៩៥០ ដោយសារលោកប្រកាន់តាមចលនាកែទម្រង់សតវត្សទី២០ នៅពេលទទួលការសិក្សានា សាកលវិទ្យាល័យទេវសាស្រ្តជាន់ខ្ពស់ហ្វាត្យ (*Faith Theological Seminary*)។ បណ្ឌិត ថូ ជាអតីតគ្រូគង្វាលពួកជំនុំព្រះគម្ពីរប្រ៉េស ប៊ីធីរានជីវិត (*Life BPC*, ១៩៥០-២០០៣) និងពួកជំនុំព្រះគម្ពីរប្រ៉េសប៊ីធីរានជីវិតពិត (*True Life BPC*, ២០០៣-២០០៩) ហើយជានាយកមហាវិទ្យាល័យព្រះគម្ពីរហ្វាអ៊ីស្ទឺន (*Far Eastern Bible College*, ១៩៦២-២០០៩)។ ក្នុងនាម ជាអ្នកផ្គត់ផ្គង់អត្ថបទដ៏ទៀងទាត់សម្រាប់ការបោះពុម្ព អធិស្ឋាន និង រីករាយចម្រើន (RPG) លោកក៏បាននិពន្ធសៀវភៅ ជាង ៣៥ក្បាល។ «**ដំណឹងល្អនៃជីវិត**» គឺជាស្នាដៃនិពន្ធរបស់លោកដែលបានបោះពុម្ពក្នុងឆ្នាំ ១៩៨៣ បច្ចុប្បន្ន ត្រូវបានប្រែសម្រួលជាភាសាខ្មែរដោយសង្ឃឹមថាមិត្តអាននឹងស្វែងរកដំណោះស្រាយសម្រាប់បញ្ហាជាច្រើនក្នុងជីវិតក៏ដូច ជាការរកឃើញនូវសេចក្តីអំណរក្នុងជីវិតដ៏ពេញបរិបូរដែរ។ សូមឲ្យព្រះនាមនៃព្រះយេស៊ូវគ្រីស្ទបានដំកើងឡើងតាមរយៈជីវិតគ្រីស្ទបរិស័ទកម្ពុជា។ អាមែន!

# មុខកថា

**អ.អ.រ** ឬ **អាន អធិស្ឋាន រីកចម្រើន**! កូនព្រះគ្រប់រូបត្រូវរីកចម្រើន។ រីកចម្រើនទាល់តែអ្នកញ៉ាំអាហារ! លុះត្រាលោកអ្នកញ៉ាំទឹកដោះដែលជាពាក្យបន្ទូល ជាពាក្យបន្ទូលព្រះ អ្នកនឹងមិនរីកចម្រើនដូចបំណងឡើយ។

ចំណង់ស្រេកឃ្លានខាងផ្នែកព្រលឹងវិញ្ញាណមិនមែនជាធម្មតាកើតឡើងទេ តែដោយការខិតខំលត់ដំនិងការអប់រំដ៏អត់ធ្មត់ប៉ុណ្ណោះ។ គ្រីស្ទបរិស័ទជាច្រើនបានបរាជ័យព្រោះតែពួកគាត់គ្មានវិធីសាស្ត្រ។ ចេតនាល្អគឺមិនទាន់គ្រប់គ្រាន់ឡើយ។ ប្រពន្ធ័និងវិធីសាស្ត្រជួយឲ្យមានការលត់ដំនិងចំណង់ស្រេកឃ្លាន (ផ្នែកព្រលឹងវិញ្ញាណ)។

អត្ថបទ **អ.អ.រ** បង្កើតឲ្យមានការអានព្រះគម្ពីរប្រចាំថ្ងៃតាមវិធីសាស្ត្រនិងបែបជាប្រពន្ធ័។ រយះពេលដប់ប្រាំនាទីក្នុងមួយថ្ងៃនឹងធ្វើឲ្យអ្នកអានស្ថិតនៅលើដងវិថីសុខមាលល្អនិងព្រលឹងវិញ្ញាណរីកចម្រើនយ៉ាងរស់រវើក។ ក្នុងនាមជាគ្រូគង្វាល គ្រូបង្រៀនពាក្យបន្ទូល និងជាអ្នកទេវសាស្ត្រ បណ្ឌិត ធីម៉ូធី ថូវ មានបទពិសោធន៍និពន្ធជាងសាមសិបឆ្នាំ។ ដូចជាចុងភៅចិនចម្អិនអាហារសម្រាប់ភោជនីដ្ឋានដ៏ល្បីម្នាក់ គាត់ផ្តល់អាហារដ៏ឱជារសដែលមានរសជាតិប្លែកៗគ្នាគួរឲ្យចង់បរិភោគជាច្រើនដល់ផ្នែកព្រលឹងវិញ្ញាណរបស់យើង។ សូមអញ្ជើញលោកអ្នកក្រេបរសជាតិពីទំព័រទាំងឡាយនៃកូនសៀវភៅនេះចុះ។

ពាក្យក្នុងបុព្វកថាមុខនេះបោះពុម្ពទៅដោយការអធិស្ឋានសូមឲ្យព្រះវិញ្ញាណបរិសុទ្ធនៃព្រះចិញ្ចឹមបីបាច់និងចម្រើនកម្លាំងជីវិតជាគ្រីស្ទបរិស័ទរបស់អ្នកនៅពេលលោកអ្នកអានសៀវភៅ **អ.អ.រ** នេះ!

**បណ្ឌិត ថូវ ស៊ាង ហ៊ា** (Rev. Dr. Tow Siang Hwa)

## អារម្ភកថា

កម្រងអត្ថាធិប្បាយបែបអនុវត្តន៍ពីដំណឹងល្អនិងសំបុត្ររបស់យ៉ូហានគឺជាការងារដោយក្ដីស្រឡាញ់រយៈពេលប្រាំខែសម្រាប់សៀវភៅ **អាន អធិស្ឋាន រីកចម្រើន** (**អ.អ.រ**) ជាសៀវភៅលំហាត់នៃ**ការអាន ព្រះគម្ពីរប្រចាំថ្ងៃ**សម្រាប់មនុស្សគ្រប់រូប បោះពុម្ពលេខ ៨-១៣។

គោលបំណងចម្បងនៃសៀវភៅលំហាត់ទាំងនេះគឺដើម្បីបញ្ជ្រាបទឹកចិត្តគ្រីស្ទបរិស័ទឲ្យអានព្រះគម្ពីររបស់ខ្លួនជាប្រចាំថ្ងៃ។ តាមរយៈការពន្យល់បកស្រាយពាក្យពីជំពូកមួយទៅជំពូកមួយ ពីផ្នែកមួយទៅផ្នែកមួយ ជាពិសេសនូវខគម្ពីរពិបាកៗប្រយោជន៍ឲ្យបានយល់និងប្រតិបត្តិតាមក្នុងជីវិតប្រចាំថ្ងៃរបស់យើង មេរៀនពន្យល់បកស្រាយទាំងនេះនឹងក្លាយជាអាហារផ្នែកព្រលឹងវិញ្ញាណដែលមនុស្សជាច្រើនបានបរិភោគដោយអំណររីករាយ។

ភ្ជាប់ជានឹងមូលហេតុដែលដំណឹងល្អនិងសំបុត្រយ៉ូហានត្រូវបានក្លាយជាកំណប់គឺក្នុងសេចក្ដីផ្ដើមរបស់វាដែលប៊ីហ្សប ជេ ស៊ី រ៉ៃល (Bishop J.C. Ryle) បានផ្ដល់ចំណាប់អារម្មណ៍ថាជាសៀវភៅដ៏វិសេសនៅក្នុងព្រះគម្ពីរទាំងមូល។ ពីព្រោះនៅក្នុងដំណឹងល្អនិងនៅក្នុងបណ្ដាសំបុត្រនេះសាវ័កនៃសេក្ដីស្រឡាញ់បានដឹកនាំយើងចូលទៅក្នុងការប្រកបគ្នាដ៏ជិតស្និទ្ធនឹងព្រះដ៏ជាម្ចាស់ដែលគ្មានសាវ័កឬហោរាណាម្នាក់ពីមុនធ្លាប់បានដឹកនាំយើងយ៉ាងដូច្នេះឡើយ។ ហើយការប្រកបគ្នាដ៏ស្និទ្ធស្នាលនេះគឺអាចកើតឡើងបានលុះត្រាតែបន្ទាប់ពីលោកអ្នកបានជ្រួតជ្រាបនឹងពាក្យបន្ទូលជីវិត ព្រមទាំងបានទទួលជីវិតដ៏អស់កល្បតាមរយៈការជឿប៉ុណ្ណោះ។ តើអ្នកជឿព្រះយេស៊ូវជាព្រះគ្រីស្ទជាព្រះរាជបុត្រានៃព្រះ?

នេះគឺជា**សៀវភៅនៃជីវិត**ប្រទានដល់មនុស្សជាតិដែលកំពុងស្លាប់។ បើមាននូវការសហការរបស់អ្នកជួយណែនាំកូនសៀវភៅនេះដល់ព្រលឹងវិញ្ញាណដែលបាត់នោះគេនឹងស្វែងរកជីវិតដ៏អស់កល្បឃើញដូចលោកអ្នកដែរ ហើយការចងក្រងអត្ថបទ **អ.អ.រ** ជាសៀវភៅមួយក្បាលនេះនឹងមិនជាអសារឥតការឡើយ។ អាម៉ែន!

**ធីម៉ូធី ថូវ** (T.T)

## ជំពូកទី១

## ព្រះយេស៊ូវគ្រីស្ទជាព្រះបន្ទូលនៃជីវិតចំពោះអ្នកស្វែងរកឡូហ្គូស(*Logos*)ដ៏អស់កល្ប

គ្រប់ជំនាន់ទាំងអស់ ទោះបីអ្នកទស្សនៈវិទូលោកខាងលិចនិងខាងកើតបានព្យាយាមស្វែងយល់ពីអាថ៌កំបាំងរបស់សាកលលោក។ ការស្វែងរកដ៏កំពូលរបស់ពួកគេត្រូវបញ្ចប់ដោយអំណាច ឬដោយអង្គបុគ្គលខុសពីធម្មតាម្នាក់។

នៅអំឡុងសម័យដែលដំណឹងល្អទីបួនត្រូវបានសរសេរពាក្យ «ព្រះបន្ទូល» ក្នុងភាសាទស្សនវិទ្យាត្រូវបានឆ្លងកាត់ប្រវត្តិសាស្ត្រដ៏យូរលង់។ លោកហ្វីឡូ (*Philo*) ជាទស្សនៈវិទូតំណាងឲ្យសាសនាយូដាក្នុងស្រុកអាឡិចសាន់ឌឺរ យល់ថាពាក្យ «ឡូហ្គូស (*Logos*)» ក្នុងភាសាក្រេកមានន័យថា «ពាក្យ» ឬ «ហេតុផល» សំដៅទៅលើប្រភេទតួនាទី ឬជាការបើកសម្ដែងរបស់ព្រះដែលតាមរយៈការបើកសម្ដែងនេះពិភពលោកត្រូវបានបង្កើតឡើង (លោកគ្រូ មេឈិន)។

នៅអាស៊ីបូព៌ាមានអ្នកប្រាជ្ញដ៏ឆ្នើមម្នាក់មកពីប្រទេសចិននាសតវត្សទី៦ មុន គ.ស ឈ្មោះឡៅស៊ឺ (*Laotse*) និងសៀវភៅរបស់គាត់មានចំណងជើងថា តៅ ដឺ ឈីង (*Tao-the-ching*) តាមរយៈកម្រងសៀវភៅនេះមានទស្សនវិទ្យាមួយកើតឡើងដែលត្រូវបានគេហៅថាលទ្ធិតៅ (*Taoism*)។

«តៅ 道 (*Tao*) គឺជាគោលការណ៍ជាសាកលមួយដែលវគ្រប់សារពើកកើតមកនិងហើយវាជាធាតុ នៃអ្វីដែលមានជីវិត គឺជាសេចក្ដីដែលបុគ្គលម្នាក់គិតត្រឡប់ថយក្រោយនាពេលស្វែងរកប្រភពមិនច្បាស់លាស់ដែលអ្វីៗទាំងអស់បានកើតមានឡើងនាដើមដំបូងបង្អស់។ ដោយបានកកើតឡើងដោយឯកឯង ធាតុដ៏សំខាន់ នេះ គឺជាកម្លាំងប្រតិបត្តិការក្នុងពិភពលោកយ៉ាងស្ងៀមស្ងាត់។ ចេញពីតៅសាយភាយពាសពេញចក្រវាឡ នូវ វត្ថុជាច្រើនហើយតាមរយៈកម្លាំងចលកររបស់វាជីវិតទាំងឡាយក៏បានកកើតឡើងជារូបរាងពេញលក្ខណៈយ៉ាង ល្អប្រពៃ» (កូឡុំប៊ៃ មគ្គុទេសក៏កូឡុមប៊ែរ *"Columbia Encyclopedia"*)។

ដើម្បីឆ្លើយតបនឹងគំនិតរបស់ជនជាតិចិន អ្នកបកប្រែព្រះគម្ពីរជាភាសាចិនបានជ្រើសយកពាក្យដ៏ត្រឹម ត្រូវគឺ 道 «តៅ» ដែលមានន័យថា «ផ្លូវ» «សេចក្ដីពិត» «គោលលទ្ធិ» ដើម្បីបកប្រែពាក្យក្រេក «ឡូហ្គូស (*Logos*)» ហើយនៅក្នុងកំណែព្រះគម្ពីរ យីង ចែមស៍ (*King James*) បកប្រែពាក្យក្រេកនេះថាជា «*Word*» ជាភាសាខ្មែរ «ព្រះបន្ទូល»។

តាមរយៈការអង្កេតត្រួសៗនេះ យើងឃើញថាទោះបីជ្រុងគំនិតអ្វីមួយដែលអ្នកប្រាជ្ញអាស៊ីយ៍ឬអឺរ៉ុបរកឃើញអំពីអំណាចឬជីវិតដ៏សំខាន់នោះក៏មិនអាចស្មើនឹងអ្វីដែលសាវ័កយ៉ូហានប្រកាសប្រាប់ពី*ឡូហ្គូស*ជាព្រះបន្ទូលបានដែរ។

ដោយគិតត្រឹមតែសាវ័កយ៉ូហាន «ព្រះបន្ទូល» ជាឃ្លាសំដៅទៅលើព្រះរាជសាររបស់ព្រះដែលសម្ដែងមកតាមរយៈបទគម្ពីរ ឬបបូរមាត់របស់ហោរា ឬសាវ័ក។ ប៉ុន្តែព្រះជាម្ចាស់មិនត្រឹមតែបានមានបន្ទូលនៅក្នុងសំណេរ ឬពាក្យបន្ទូលផ្ទាល់ឡើយ។ ព្រះអង្គក៏បានមានបន្ទូលតាមរយៈអង្គបុគ្គលព្រះយេស៊ូវគ្រីស្ទផងដែរ។ នេះគឺជាសំណេរនិងជាពាក្យដែលបានបន្ទូល ហើយនេះក៏ជាព្រះបន្ទូលដែលបានត្រឡប់ជាសាច់ឈាម ជាអ្នក នាំពាក្យរបស់ព្រះ។

សាវ័កយ៉ូហានជាអ្នកអាចប្រាប់យើងថាព្រះបន្ទូលគឺជាអង្គបុគ្គល ជាអង្គបុគ្គលទីពីរនៃព្រះត្រៃយ៍ឯកជាព្រះអាទិករនៃពិភពលោក ជាអង្គបើកសម្ដែងនៃព្រះវរបិតា «គ្មានអ្នកណា ដែលឃើញព្រះឡើយ មានតែ ព្រះរាជបុត្រាតែដែលគង់នៅក្នុងឱរាព្រះវរបិតាប៉ុណ្ណោះ ទ្រង់បានសំដែងឲ្យស្គាល់ព្រះអង្គ» (យ៉ូហាន ១:១៨)។

**ការពិចារណា៖** តើខ្ញុំកំពុងស្វែងរកអត្ថន័យ ឡូហ្គូស ឬ ព្រះបន្ទូល?

**ការអធិស្ឋាន៖** ឱព្រះជាម្ចាស់អើយ សូមបើកភ្នែកឲ្យខ្ញុំយល់ន័យនិងទទួល «ព្រះបន្ទូល» ផង។

ថ្ងៃទី ២ កក្កដា
យ៉ូហាន ១:១-៥

*«កាលដើមដំបូងមានព្រះបន្ទូល...*
*ព្រះបន្ទូលនោះឯងជាព្រះ»*

## ភាពដ៏អស់កល្បនិងនិស្ស័យជាព្រះរបស់ព្រះបន្ទូលនៃជីវិត

«***កាលដើមដំបូង***» (ខ ១) សំដៅទៅអតីតកាលដ៏អស់កល្ប ជាអតីតកាលដើមដំបូងដូចរៀបរាប់ក្នុងលោកុប្បត្តិ ១:១ ជាពេលពិភពលោកត្រូវបានបង្កើតឡើង។ វាជាដើមដំបូងដែលមនុស្សទន់ទាបមិនអាចយល់ ព្រោះវាស្ថិតនៅក្នុងពិភពនៃលំហរនិងពេល។ ភាពដ៏អស់កល្បគឺជាលក្ខណៈនៃការមានព្រះជន្មរស់នៅរបស់ព្រះជាម្ចាស់ដែលមិនអាចវាស់ដោយពេលវេលា។ ព្រះគ្រីស្ទជា**ព្រះបន្ទូល**គង់ជាមួយនឹងព្រះ ដែលព្រះអង្គផ្ទាល់ ក៏ជាព្រះ! នេះគឺជាអាថ៌កំបាំងនៃភាពដ៏អស់កល្បរបស់ទ្រង់ និងជាអាថ៌កំបាំងនៃនិស្ស័យជាព្រះរបស់ទ្រង់ដែរ។ ខទី៣ ប្រាប់យើងថា**ព្រះបន្ទូល**គឺជាសហអាទិករនៃភពសាកលជាមួយនឹងព្រះវរបិតា។ **ព្រះបន្ទូល**ក៏បានរួមចំណែកក្នុងការបង្កើតពិភពលោក (*ដ្បិតទ្រង់បានចេញបង្គាប់ ហើយរបស់ទាំងនោះបានកើតមក*។ ទំនុកដំកើង ១៤៨:៥) ដូចជាព្រះវិញ្ញាណបរិសុទ្ធផងដែរ (លោកុប្បត្តិ ១:២)។

យ៉ាងណាមិញ **ព្រះបន្ទូល**គឺមិនមែនជាព្រះអាទិករប៉ុណ្ណោះទេ តែក៏ជាប្រភពនៃជីវិតដែរ។ ពាក្យដែលសាវ័កប៉ុលធ្វើបន្ទាល់ថាដោយសារទ្រង់យើងរាល់គ្នាបានរស់កំរើក ហើយមាននៅ (កិច្ចការ ១៧:២៨) សាវ័កយ៉ូហានប្រកាសថាសេចក្ដីទាំងនោះបានសំរេចជោគជ័យដោយសារការប្រទានពររបស់**ព្រះបន្ទូល** (ខាល់វីន)។ ជីវិតដែល**ព្រះបន្ទូល**បានប្រទានមកជាពន្លឺរបស់មនុស្ស ជាពន្លឺប្រទានដល់យើងល្អប្រសើរជាង ពន្លឺដែលទ្រង់ប្រទានដល់សត្វទាំងឡាយ ព្រោះវាគឺជាពន្លឺនៃវិចារណញាណ។ ពន្លឺនេះគួរតែជាកញ្ចក់សម្រាប់ ឲ្យយើងឆ្លុះមើលនូវព្រះចេស្ដានៃ**ព្រះបន្ទូល**។

ក៏ប៉ុន្តែសេចក្ដីងងឹតនៃអំពើបាបដែលប្រៀបដូចជាអ័ក្រដ៏ក្រាស់បណ្ដាលឲ្យពន្លឺនោះប្រែទៅជាស្រអាប់។ នៅមានផ្កាភ្លើងនៃពន្លឺដើមខ្លះៗកំពុងចាំងក្នុងភាពស្រអាប់នៃចិត្តគំនិតរបស់មនុស្ស។ លទ្ធផលចុងក្រោយគឺសេចក្ដីងងឹតនៃចិត្តគំនិតរបស់យើងនឹងបណ្ដាលឲ្យផ្កាភ្លើងដែលនៅសេសសល់ក្នុងយើងប្រែជាឈប់ភ្លឺ។ យើងមិនអាចយល់ ឬយល់ពីពន្លឺបានទេ ដូចជាព្រះគម្ពីរចែងមកថា៖ «*មើលផង តែឥតឃើញឡើយ* » (អេសាយ ៦:៩)។ ការបកប្រែជាភាសាចិនសម្រាប់ពាក្យ «យល់» គឺ «ទទួល»។

**ការពិចារណា៖** «កាលដើមដំបូងឡើយ ព្រះបានបង្កើតផ្ទៃមេឃនិងផែនដី» (លោកុប្បត្តិ ១:១)
**ការអធិស្ឋាន៖** ឱព្រះអង្គអើយ សូមអរព្រះគុណទ្រង់ហើយការប្រទានជីវិតនេះដល់ខ្ញុំ។

ថ្ងៃទី៣ កក្កដា
យ៉ូហាន ១:៦-៨

*«...ទាំងរំពឹងមើលដល់ព្រះយេស៊ូវដ៏ជាមេផ្តើម ហើយជាមេសម្រេចសេចក្តីជំនឿរបស់យើង»។*

## អ្នករៀបចំផ្លូវថ្វាយព្រះបន្ទូល

មនុស្សដែលព្រះបានបញ្ជូនមក ជាអ្នករៀបចំផ្លូវថ្វាយព្រះបន្ទូលនៃព្រះ គឺយ៉ូហាន។ លោកយ៉ូហាននេះគឺមិនមែនជាសាវ័កយ៉ូហាន ជាអ្នកសរសេរដំណឹងល្អទីបួនទេ តែជាលោកយ៉ូហាន-បាទីស្ទ។ តើអ្នកអាចរកខគម្ពីរណាដែលទាក់ទងនឹងយ៉ូហាន-បាទីស្ទដែរទេ? (ជំនួយដ៏ល្អបំផុតដើម្បីសិក្សាព្រះគម្ពីរគឺសៀវភៅសមោធាន (Concordance)។ សូមស្វែងរកពាក្យ «បាទីស្ទ» ឬ «យ៉ូហាន» ឬក៏ «ជ្រមុជ»។ នោះអ្នកនឹងឃើញបញ្ជីខយោងទាំងអស់ទាក់ទងនឹងឈ្មោះលោកយ៉ូហានបាទីស្ទ! ដូចជាម៉ាស៊ីនកុំព្យូទ័រ!)។

ការអធិប្បាយពាក្យបន្ទូលរបស់យ៉ូហាន-បាទីស្ទគឺពិតជាល្អអស្ចារ្យរហូតបណ្តាលឲ្យអ្នកខ្លះគិតថាគាត់គឺជាព្រះមែស៊ី (លូកា ៣:១៥)។ ប្រហែលមានអ្នកខ្លះបានប្រែចិត្តក្រោមពន្ធកិច្ចរបស់យ៉ូហាន ជាអ្នកបន្តស្តាប់តាមការបង្រៀនរបស់គាត់នាពេលដំណឹងល្អយ៉ូហានស្ថិតក្នុងដំណាក់កាលសរសេរចងក្រង។ (អ័ប៉ុឡូសជាគំរូ។ កិច្ចការ ១៨:២៥។ សូមអាន កិច្ចការ ១៩:១-៤ ផងដែរ)។ នេះនឹងជួយទៅនឹងទឹកចិត្តនៃការបន្ទាបខ្លួនរបស់អ្នករៀបចំផ្លូវឬអ្នកធ្វើទីបន្ទាល់ថ្វាយព្រះគ្រីស្ទ។ សមាជិកពួកជំនុំម្នាក់ៗគួរមើលរំលងគ្រូគង្វាលរបស់ខ្លួនទៅឯព្រះសង្គ្រោះ។ គ្រូអធិប្បាយពាក្យបន្ទូលម្នាក់ៗមិនត្រូវប្រកាសប្រាប់ពីខ្លួនឯងទេ តែពីព្រះគ្រីស្ទជាម្ចាស់វិញ (២ កូរិនថូស ៤:៥)។

មានយ៉ូហាន-បាទីស្ទសម័យទំនើបម្នាក់ នោះគឺជាលោកគ្រូ ចន ស៊ុង នៃប្រទេសចិន។ គាត់បានមកប្រទេសសឹង្ហបុរី និងអាស៊ីអគ្នេយ៍នាអំឡុងទសវត្សសាមសិប។ លោកគឺជាគ្រូអធិប្បាយដូចជាយ៉ូហាន-បាទីស្ទ។ ជាលទ្ធផលនៃកម្មវិធីប្រជុំផុសផុលខាងព្រលឹងវិញ្ញាណរបស់គាត់គឺទទួលបានផលផ្លែច្រើនជាងពន្ធកិច្ចរបស់យ៉ូហានទៀតផង។ ជោគជ័យនេះនាំឲ្យអ្នកដើរតាមគាត់ខ្លះមើលទៅគាត់ហើយមិនសម្លឹងទៅព្រះគ្រីស្ទ។ តើនេះគឺជាការត្រឹមត្រូវដែរទេ?

**ការពិចារណា៖** តើខ្ញុំកំពុងមើលទៅកាន់មនុស្សឬព្រះយេស៊ូវគ្រីស្ទ?
**ការអធិស្ឋាន៖** ព្រះវរបិតាអើយ សូមឲ្យព្រះយេស៊ូវលើកដំកើងក្នុងជីវិតនិងពន្ធកិច្ចរបស់ខ្ញុំផង។

ថ្ងៃទី ៤ កក្កដា
យ៉ូហាន ១:៩-១៣

*«ប៉ុន្តែអស់អ្នកណាដែលទទួលទ្រង់ គឺអស់អ្នកដែលជឿដល់ព្រះនាមទ្រង់ នោះទ្រង់បានប្រទានអំណាច ឲ្យបានត្រឡប់ជាកូនព្រះ»។*

## ពាក្យបន្ទូលជីវិតគឺជាពន្លឺដ៏ពិត

បើយ៉ូហាន-បាទីស្ទ ជាហោរាដ៏ធំរបស់ព្រះមិនធ្លាប់មានពីមុន (ម៉ាថាយ ១១:១១) លោកមិនមែនជាពន្លឺ តែគ្រាន់ជាទីបន្ទាល់ពីពន្លឺ ចុះចំណែកយើងគឺតូចទាបប៉ុណ្ណាប្រៀបនឹងពន្លឺដែលយល់ថាបានប្រទានដល់អ្នកខាងក្រៅព្រះគ្រីស្ទ។ វាជាការដឹកនាំដ៏ខុសឆ្គងសម្រាប់សេចក្ដីបង្រៀននៃអ្នកទេវសាស្ត្រសម័យទំនើបនិងសហានិកាយនិយម (*ecumenical*) ដែលអះអាងថាមានពន្លឺនៃសេចក្ដីសង្គ្រោះនាបណ្ដាសាសនាឯទៀត។ សម្ដេចប៉ាបពិតជាខ្វះមិនយល់ដែលមិនដឹកនាំមនុស្សទៅរកព្រះគ្រីស្ទ តែទៅឯនាងម៉ារានិងខ្លួនគាត់ទៅវិញ!

ព្រះយេស៊ូវគឺត្រូវបានហៅថាជា**ពន្លឺ**ដ៏ពិត ព្រោះទ្រង់គឺវិសេសជាងគេ ជាពន្លឺតែមួយគត់សម្រាប់សេចក្ដីសង្គ្រោះ។ ដូច្នេះ ដំណឹងល្អក៏វិសេស ព្រះគម្ពីរក៏វិសេស ពួកជំនុំគ្រីស្ទបរិស័ទ រូបកាយរបស់ព្រះគ្រីស្ទ គឺសុទ្ធតែវិសេស ពីព្រោះដំណឹងល្អគឺជាដំណឹងពីកិច្ចការប្រោសលោះរបស់ព្រះគ្រីស្ទ ព្រះគម្ពីរគឺពាក្យបន្ទូលសរសេរចងក្រងពួកជំនុំគ្រីស្ទបរិស័ទគឺបានសង់លើថ្មដា ដ៏ជាព្រះគ្រីស្ទ។

ថ្វីដ្បិតពន្លឺដ៏ពិតនេះបានរះបំភ្លឺនៅក្នុងលោកីយ៍ តាំងពីមុនពេលព្រះគ្រីស្ទយកនិស្ស័យជាមនុស្ស ក៏លោកីយ៍នៅតែបន្តរឹងចចេសដោយចេតនានឹងភាពខ្វះងងឹតរបស់ខ្លួនដដែល។ លោកកាល់វិនមានប្រសាសន៍ថា «យើងដឹងថាមនុស្សមានលក្ខណះពិសេសខ្ពង់ខ្ពស់ជាងសត្វ ដោយមនុស្សត្រូវបានប្រទានឲ្យមានអំណះអំណាងនិងប្រាជ្ញាឆ្លាតវ៉ៃដែលអាចវិភាគបែងចែករវាងត្រូវនិងខុសនៅក្នុងមនសិការរបស់គេ។ ដូចនេះគ្មានបុគ្គលណាម្នាក់ឥតមានពន្លឺដ៏អស់កល្បជ្រួតជ្រាបក្នុងចិត្តគាត់ឡើយ»។

ហើយទោះបីព្រះគ្រីស្ទបានយាងមកជាពិសេសសម្រាបសាសន៍យូដា ព្រោះព្រះអង្គបានប្រសូត្រមកក្នុងខ្សែរាជវង្សហ្លួងដាវីឌ ក៏ញាតិជិតជិតទ្រង់បដិសេធទ្រង់ជាងគេដែរ។

ដូចជាព្រះឥតយល់មុខអ្នកណាម្នាក់ទេ។ អស់អ្នកណាដែលទទួលទ្រង់ជាព្រះសង្គ្រោះ តាមរយះមានជឿលើព្រះនាមទ្រង់ នោះនឹងបានសង្គ្រោះ។ បើអ្នកអាចថ្លែងនៅក្នុងចិត្តរបស់ខ្លួនផ្ទាល់ថាព្រះយេស៊ូវជាព្រះសង្គ្រោះនិងជាអម្ចាស់ រូបអ្នកគឺជាមនុស្សបានកើតជាថ្មី។ អ្នកបានត្រឡប់ជាកូនព្រះដោយមានទាំងអំណាចនិងអភ័យឯកសិទ្ធិជាកូន។ លោកអ្នកពិតជាទទួលបាននូវកំណើតថ្មីមួយដោយសារព្រះចេស្ដានៃព្រះជាម្ចាស់។ វាជាកិច្ចការដ៏អស្ចារ្យខុសពីធម្មតានៃព្រះជាម្ចាស់ដែលទ្រង់បានបង្កើតឡើងនាពេលអ្នកទទួលព្រះគ្រីស្ទធ្វើជាព្រះសង្គ្រោះ។ ពន្លឺដ៏ពិតបានរះបំភ្លឺយ៉ាងច្បាស់នៅក្នុងចិត្តរបស់អ្នក ខណះពេលអ្នកឯទៀត ជាសាសន៍ដទៃនិងសាសន៍យូដារឹងចចេសមិនទទួលទ្រង់។ តើអ្នកបានទទួលពន្លឺដ៏ពិត ឬ អ្នកបិទទ្វារចិត្តមិនទទួលទ្រង់?

**ការពិចារណា៖** សូមទន្ទេញ កិច្ចការ ៤:១២។

**ការអធិស្ឋាន៖** ឱព្រះយេស៊ូវដ៏ជាពន្លឺពិត សូមបំភ្លឺចិត្តនិងជីវិតឲ្យខ្ញុំបានដើរតាមផ្លូវទ្រង់ផង។

## ព្រះបន្ទូលក៏ត្រឡប់ជាសាច់ឈាម

ព្រះបន្ទូលបានប្រទានដល់មនុស្សក្នុងទម្រង់ជាព្រះរាជសារដូចពួកហោរាបានប្រកាស។ ក្រោយមករាជសារដែលហោរាប្រកាសប្រាប់នោះត្រូវបានកត់ត្រាទុកហើយបានទទួលស្គាល់ជាព្រះគម្ពីរសញ្ញាចាស់។ ពេលនេះ ព្រះបន្ទូលបានយាងមកផ្ទាល់ដោយការយកនិស្ស័យជាមនុស្ស។ នេះហើយជាអត្ថន័យ នៃឃ្លាដែលបានចែងថាព្រះបន្ទូលក៏ត្រឡប់ជាសាច់ឈាម ឬព្រះបន្ទូល**យកនិស្ស័យជាមនុស្ស** (ពាក្យ *«incarnation»* មកពីពាក្យឡាទីនមានន័យថា **នៅក្នុងសាច់ឈាម**)។

ព្រះទ្រង់មិនសព្វព្រះទ័យឲ្យហោរាប្រកាសពាក្យបន្ទូលទ្រង់ជានិច្ចទេ គឺដូចជាព្រះរាជាទ្រង់មិនសព្វព្រះទ័យឲ្យអ្នកបំរើរបស់ទ្រង់ធ្វើជាតំណាងរហូតដែរ។ ព្រះមានព្រះហឫទ័យចង់ឲ្យព្រះរាជបុត្រារបស់ទ្រង់យាងមកពិភពលោកមានបន្ទូលដល់យើង ដូចជាព្រះរាជាបញ្ជូនព្រះបុត្រាស្នងរាជបល្ល័ង្កជាព្រះតំណាងរបស់ទ្រង់ទៅដល់ប្រជារាស្ត្រដូច្នោះដែរ។

នៅក្នុងន័យនេះព្រះអាចសំដែងអង្គទ្រង់យ៉ាងជាក់ច្បាស់និងប្រកបដោយសិរីរុងរឿងនៅពេលយើងឃើញនិងស្ដាប់ទ្រង់ ជា**អ្នកថ្លែងប្រាប់**ពាក្យបន្ទូលរបស់ព្រះអង្គ (យ៉ូហាន ១:១៨)។ ហោរាគឺជាមនុស្សបរិសុទ្ធ តែព្រះយេស៊ូវគ្រីស្ទជាព្រះរាជបុត្រាតែ១នៃព្រះ! ខណៈហោរាប្រកាសពីសេចក្ដីពិត គេអាចនឹងខ្វះភាពទន់ភ្លន់។ (សូមប្រៀបធៀបពន្ធ័កិច្ចរបស់យ៉ូហាន-បាទីស្ទ និងពន្ធ័កិច្ចរបស់ព្រះគ្រីស្ទ។ ព្រះយេស៊ូវគ្រីស្ទជាសេចក្ដីពិតនិងតំណាងដោយព្រះគុណ!)។

យ៉ូហាន-បាទីស្ទគឺជាហោរាចុងក្រោយដែលបម្រើការនៅចន្លោះសម័យសញ្ញាចាស់និងសញ្ញាថ្មី។ គាត់ជាអ្នកបិទទំព័រសម័យសញ្ញាចាស់និងជាអ្នកបើកទំព័រនៃសម័យសញ្ញាថ្មីផងដែរ។

ពេលនេះ សាវ័កយ៉ូហានបង្អាក់ការសរសេរនៅខទី ១៦ ដោយការបន្ថែមទីបន្ទាល់របស់គាត់។ លោកប៉ះពាល់ចិត្តយ៉ាងខ្លាំងព្រោះតែព្រះគុណថែមលើព្រះគុណនៃព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ គាត់ប៉ះពាល់ចិត្តដោយសារក្រិត្យវិន័យថ្មីនៃព្រះគុណដែលអ្នកនៅក្រោមក្រិត្យវិន័យលោកម៉ូសេតបានទទួលបទពិសោធន៍។ តើហេតុដូចម្ដេចបានយ៉ូហានប៉ះពាល់ចិត្ត? ដោយសារតែព្រះរាជបុត្រានៃព្រះបានយាងមក និងដោយសារតែទំនាក់ទំនងជាឯកជនរបស់គាត់នឹងទ្រង់។ ការពិតនៃទំនាក់ទំនងនេះគឺត្រូវបានផ្ដល់ជាភស្តុតាងបន្ថែមនៅក្នុង ១ យ៉ូហាន ១:១ «ឯសេចក្ដីដែលមានតាំងពីដើមមក ដែលយើងខ្ញុំបានឮ ហើយភ្នែកបានឃើញ ក៏បានមើល ហើយដៃបានប៉ះពាល់ ខាងឯព្រះបន្ទូលនៃជីវិត...»។

ហេព្រើរ ១:១-២ ប្រហែលជាសេចក្ដីសង្ខេបនូវប្រធានបទថ្ងៃនេះ «ឯព្រះ ដែលពីដើម ទ្រង់មានបន្ទូលនឹងពួកឰយុកោដោយពួកហោរា ជាច្រើនដងច្រើនបែប។ នៅជាន់ក្រោយបង្អោះនេះ ទ្រង់បានមានបន្ទូលនឹងយើងរាល់គ្នា ដោយសារព្រះរាជបុត្រាវិញ ដែលទ្រង់បានដំរូវឲ្យបានគ្រងរបស់ទាំងអស់ ទុកជាមរដក ព្រមទាំងបង្កើតលោកីយ ដោយសារព្រះរាជបុត្រានោះដែរ»។

**ការពិចារណា៖** តើ *អេម៉ាញូអែល* ទ្រង់ជាមួយនឹងយើងខ្ញុំ (ម៉ាថាយ ១:២៣)?
**ការអធិស្ឋាន៖** សូមអរព្រះគុណ ព្រះជាម្ចាស់សម្រាប់ព្រះបន្ទូលដែលបានបំផ្លាស់ប្រែជីវិតខ្ញុំ។

ថ្ងៃទី ៦ កក្កដា
យ៉ូហាន ១:១៩-៣៤

*«...នេះគឺជាកូនស្ងួនភ្ងារបស់អញ ជាទីពេញចិត្តអញណាស់» (ម៉ាថាយ ៣:១៧)។*

## អ្នករៀបចំថ្វាយព្រះបន្ទូលទាំងពាក្យសំដីនិងទង្វើ

យ៉ូហាន-បាទីស្ទលោកគឺជាហោរាពិត ពីព្រោះគាត់មិនប្រកាសពីខ្លួនគាត់ទេ តែព្រះពីព្រះគ្រីស្ទវិញ។ សូមអានអត្ថបទដ៏វែងនេះពីវិធីគាត់លើកដំកើងព្រះគ្រីស្ទ ពីវិធីគាត់ប្រាប់អ្នកនឹងខ្ញុំឲ្យទៅស្វែងរកព្រះគ្រីស្ទដើម្បីទទួលសេចក្តីសង្គ្រោះ។

លោកយ៉ូហាន-បាទីស្ទគឺជាហោរាពិត ពីព្រោះគាត់មិនមែនជានិម្មិតរូបហោរាអេលីយ៉ា (ភាសាក្រិកអានថា *អេឡាយ៉ា*) ជាអ្នករៀបចំផ្លូវថ្វាយព្រះគ្រីស្ទនាដំណើរ**យាងមកលើកទីពីរ**របស់ទ្រង់។ យ៉ូហាន គាត់ក៏មិនមែនជានិម្មិតរូបព្រះគ្រីស្ទដែរព្រោះគាត់បដិសេធថាខ្លួនគាត់មិនជា**ហោរានោះ** (ខ ២១)។ **ហោរានោះ**គឺជាព្រះគ្រីស្ទដែលលោកម៉ូសេបានព្យាករណ៍ក្នុងចោទិយកថា ១៨:១៥ និងត្រូវបានសាវ័កពេត្រុសប្រាប់អត្តសញ្ញាណថាជាព្រះគ្រីស្ទនាថ្ងៃបុណ្យទី៥០ (កិច្ចការ ៣:២២)។

បើយ៉ូហាន-បាទីស្ទ ជាហោរាពិត ដូចនេះពាក្យដែលគាត់បានប្រកាសគឺជាពាក្យពិតដែរ។ សេចក្តីដែលគាត់បានធ្វើទីបន្ទាល់អំពីព្រះគ្រីស្ទគឺជាពាក្យពិត។

តើទីសំគាល់អ្វីខ្លះអំពីព្រះគ្រីស្ទពិត? គឺទ្រង់ជាកូនចៀមនៃព្រះដែលដោះបាបមនុស្សលោក។ ជាកូនចៀមដែលធ្វើជាដង្វាយតាំងពីដើមដំបូងនៃទំព័រប្រវត្តិសាស្ត្រ ជាដំណោះស្រាយផ្សះផ្សា តែមួយគត់រវាងព្រះនឹងមនុស្សដែលបានធ្លាក់ក្នុងបាបកម្ម (លោកុប្បត្តិ ៤:៤)។

ព្រះគ្រីស្ទគឺជាអង្គបុគ្គលនៃព្រះជាម្ចាស់ពិត ពីព្រោះតែព្រះវិញ្ញាណបរិសុទ្ធដែលដូចជាសត្វព្រាបចុះមកសណ្ឋិតលើទ្រង់។ ព្រឹត្តិការណ៍នេះកើតឡើងនាពិធីទទួលបុណ្យជ្រមុជរបស់ព្រះយេស៊ូវនៅទន្លេយ័ដាន់ ដែលត្រូវបានកត់ត្រាទុកជាពិស្តារនៅក្នុងម៉ាថាយ ៣:១៦។ ចំណុចនេះ ប៊ី ប៊ី វ៉ារៀល (B.B. Warfield) លោកបានសម្គាល់ឃើញថាព្រះត្រៃឯកស្ថិតក្នុងការបើកសម្តែងយ៉ាងពេញលេញ៖ «ព្រះឯនៅស្ថានសួគ៌ (កំពុងមានបន្ទូល) ព្រះនៅផែនដី (កំពុងឈរ) និងព្រះកំពុងយាងចុះពីស្ថានសួគ៌ មកផែនដី»។

ពិតមែនហើយ លោកយ៉ូហានមិនអាចលុបនូវទីបន្ទាល់របស់ព្រះដល់គាត់ដែលប្រាប់ថាព្រះយេស៊ូវគ្រីស្ទគឺពិតជាព្រះរាជបុត្រានៃព្រះ ជាព្រះសង្គ្រោះនៃពិភពលោកបានឡើយ។ តើអ្នកយល់ដូចម្តេចអំពីទីបន្ទាល់របស់យ៉ូហាន?

ចំពោះបុណ្យជ្រមុជរបស់ព្រះយេស៊ូវ វាគឺជាពិធីដ៏ពិសេសមួយ គឺខុសគ្នាទាំងស្រុងពីបុណ្យជ្រមុជរបស់យើង។ បុណ្យជ្រមុជរបស់យើងគឺក្នុងភាពជាទីបន្ទាល់ពីការប្រែចិត្តពីបាប និងមានជំនឿ លើព្រះអម្ចាស់យេស៊ូវគ្រីស្ទ (កិច្ចការ ២:៣៨)។ បុណ្យជ្រមុជរបស់ព្រះយេស៊ូវគឺជាពិធីមួយនៃការតែងតាំងដូចជាការលាងសំអាតរបស់ពួកសង្ឃក្នុងសម័យសញ្ញាចាស់ (និក្ខមនំ ២៩:៤) មុនពេលទ្រង់ចូលបម្រើក្នុងពន្ធកិច្ចជាសាធារណៈរបស់ទ្រង់ (លោក ស្កូហ្វៀ Scofield)។

ដើម្បីបំពេញរាល់សេចក្តីសុចរិត៖ «ដើម្បីថ្វាយដល់ព្រះវរបិតានូវការស្តាប់បង្គាប់ដ៏គ្រប់លក្ខណ៍ ខណៈដែលហេតុផលដោយឡែកមួយទៀតដើម្បីញែកពិធីបុណ្យជ្រមុជជាបរិសុទ្ធក្នុងរូបកាយរបស់ទ្រង់ផ្ទាល់ គឺដើម្បីឲ្យវាក្លាយជាសាមញ្ញរវាងព្រះអង្គនឹងយើងជាមនុស្ស» (កាល់វីន)។

**ការពិចារណា៖** តើខ្ញុំជាអ្នកនាំពាក្យបន្ទូលដ៏ពិត?
**ការអធិស្ឋាន៖** សូមឲ្យខ្ញុំបានធ្វើជាអ្នកផ្តល់ទីបន្ទាល់ពីទ្រង់ផង ឱព្រះអង្គអើយ!

ថ្ងៃទី ៧ កក្កដា
យ៉ូហាន ១:៣៥-៥១

*«...នុះន៍ កូនចៀមនៃព្រះ»។*

## អ្នកស្វែងរកព្រះបន្ទូលជីវិត

មនុស្សជាច្រើនពាន់នាក់បានឮយ៉ូហាន-បាទីស្ទកំពុងតែប្រកាសប្រាប់ពីកូនចៀមនៃព្រះដែលដោះបាបមនុស្សលោក។ ប៉ុន្តែ តើមានមនុស្សប៉ុន្មាននាក់ជាអ្នកស្វែងរកព្រះបន្ទូលពិតប្រាកដ? តើប៉ុន្មាននាក់ដែលបានរកព្រះមេស៊ីជាព្រះសង្គ្រោះឃើញ?

មានតែពីរនាក់នាថ្ងៃទីពីរនៃហ្វូងមនុស្សដ៏ធំប៉ុណ្ណោះ។ លោកអនទ្រេនិងម្នាក់ទៀតប្រាកដជាសាវ័កយ៉ូហានជាអ្នកសរសេរដំណឹងល្អយ៉ូហាននេះតែម្តង (លោក មេធិន)។ អនទ្រេជាអ្នកព្រះជ្រើសរើសដ៏ល្អម្នាក់។ គាត់បាននាំស៊ីម៉ូនជាបងប្រុសរបស់គាត់ដែលក្រោយមកជាអ្នកដឹកនាំក្រុមសាវ័ក។ ស៊ីម៉ូនគាត់ជាអ្នកនេសាទសាមញ្ញម្នាក់គឺត្រូវបានហៅថាពេត្រុស ឬកេផាស (នៅក្នុងភាសាអារាមេក) មានន័យថាថ្ម។ លោកអ្នកប្រហែលជានឹងមិនក្លាយជាអ្នកអធិប្បាយដ៏អស្ចារ្យ តែអ្នកអាចដឹកនាំដែលអាចនឹងជឿព្រះនិងថែរក្សាព្រលឹងវិញ្ញាណអ្នកដែលបានទទួលទ្រង់។ តើអ្នកធ្លាប់បានឮពីអូធីរេស្សិន អែនដ្រូ (*Operation Andrew*) ដែរទេ? សូមនាំមិត្តភក្តិមិនទាន់បានសង្គ្រោះមកព្រះវិហារ! សូមជូនខិតប័ណ្ណដល់ពួកគាត់!

អ្នកបន្ទាប់ទៀតដែលត្រូវបានព្រះយេស៊ូវហៅផ្ទាល់គឺ ពីលីព ហើយគាត់ក៏បានរកណាថាណែល (ឈ្មោះមួយទៀតគឺ បារថូឡូមេ)។ ដូចជាបានសង្កេតមើល សាវ័កម្នាក់ៗមានលក្ខណៈពិសេសពីកំណើតរៀងខ្លួន តែពួកគេម្នាក់ៗជួយបំពេញភាពខ្វះខាតគ្នាទៅវិញទៅមក។ សម្រាប់ណាថាណែល គាត់មានជំនឿដូចជាកូនក្មេងក្នុងការជឿលើព្រះយេស៊ូវថាជាព្រះរាជបុត្រានៃព្រះជាស្តេចអ៊ីស្រាអែល។ នេះគឺពិតជាគួរឲ្យសរសើរខ្លាំងណាស់ ព្រោះវាគឺជាជំនឿដ៏សាមញ្ញនិងដូចជាជំនឿរបស់កូនក្មេង! សេចក្តីជំនឿរបស់គាត់នឹងចម្រើនរឹងមាំបន្ថែមទៀតនៅពេលគាត់បានឃើញកិច្ចការដ៏អស្ចារ្យជាច្រើនរបស់ព្រះយេស៊ូវ។ ពិតមែនហើយ ពួកសិស្សគឺត្រូវបានបង្ហាត់បង្រៀនឲ្យក្លាយជាសាវ័កដ៏អស្ចារ្យដូច្នោះដែរតាមរយៈការស្តាប់ការអធិប្បាយរបស់ព្រះយេស៊ូវនិងការឃើញនូវការអស្ចារ្យជាច្រើនទៀតរបស់ទ្រង់ រហូតដល់ថ្ងៃព្រះរាជបុត្រានៃព្រះត្រូវបានជាប់ឆ្កាងជំនួសបាបរបស់គេនិងការមានព្រះជន្មរស់ពីស្លាប់ឡើងវិញរបស់ព្រះអង្គ។

មិត្តអ្នកអាន តើអ្នកជឿដូចជាលោកណាថាណែលដែរទេ? តើអ្នកបាននាំមនុស្សជាទីស្រឡាញ់របស់អ្នកមកព្រះគ្រីស្ទដូចជាលោកអនទ្រេដែរទេ? តើអ្នកសរសេរទៅមិត្តភក្តិដែលទើបតែបានរកព្រះសង្គ្រោះដូចជាសាវ័កយ៉ូហានសរសេរសម្រាប់អ្នកនឹងខ្ញុំដែរទេ? តើលោកអ្នកព្យាយាមស្គាល់ព្រះសង្គ្រោះបន្ថែមទៀតតាមរយៈការអានពាក្យបន្ទូលនិងកិច្ចការរបស់ទ្រង់ដែរទេ? សូមឲ្យអ្នកស្វែងរកព្រះបន្ទូលនៃជីវិតម្នាក់ៗចែករំលែកកំណប់របស់ខ្លួនជាមួយអ្នកដទៃទៀត។

**ការពិចារណា៖** តើខ្ញុំនឹងជួបមនុស្សជាទីស្រឡាញ់របស់ខ្ញុំម្តងទៀតនានគរស្ថានសួគ៌?

**ការអធិស្ឋាន៖** ឱព្រះអង្គអើយ សូមឲ្យខ្ញុំចូរស្តាប់តាមទ្រង់ ព្រោះគ្មានផ្លូវណាទៀតសោះ ឲ្យបានព្រះយេស៊ូវស្ថិតនៅ មានតែស្តាប់តាមទាំងអស់។ (ចម្រៀងទំនុកដំកើង ៩១)។

# យ៉ូហាន ២

## ចំពោះអ្នកចាប់ដៃគ្នាជាស្វាមីភរិយាក្នុងវិវាហមង្គលការបរិសុទ្ធ ព្រះយេស៊ូវគ្រីស្ទជាស្រាទំពាំងបាយជូរនៃជីវិត

ជំពូកនេះតាមការពិតត្រូវបានសរសេរឡើងជាពីរផ្នែក។ ផ្នែកទី១គឺជាការអស្ចារ្យដំបូងនៃព្រះគ្រីស្ទដែលទ្រង់ធ្វើក្នុងភូមិកាណា ស្រុកកាលីឡេ ដោយការធ្វើទឹកឲ្យក្លាយជាស្រាទំពាំងបាយជូរ ជាការអស្ចារ្យដូចបានផ្តល់ជាចំណងជើងខាងលើសម្រាប់យើង។ ផ្នែកទី២រៀបរាប់ប្រាប់យើងពីការសំអាតព្រះវិហារជាលើកទីមួយរបស់ទ្រង់ដោយ ការច្រានឲ្យតុរបស់អ្នក ប្តូរប្រាក់រលំនិងការបណ្តេញពួកអ្នកលក់សត្វពាហនៈនិងស្លាបពីសំណាក់នៃព្រះវរបិតា ទ្រង់។ សម្រាប់ជាការសង្ខេបបែបលម្អិតយើងគ្រាន់តែអាចលើកនាមព្រះយេស៊ូវគ្រីស្ទថាជាស្រាទំពាំងបាយជូរនៃជីវិត ប៉ុណ្ណោះ តែសូមកុំឲ្យយើងភ្លេចផ្នែកទី២។

សំរាប់ជាការសិក្សាលក្ខណៈអង្គតនៃជំពូកនេះ ប្រហែលជាចាំបាច់ត្រូវចាប់ផ្តើមនូវផ្នែកចុងក្រោយ។ ចំណុចនេះយើង ឃើញព្រះយេស៊ូវប្រសើរជាងអាកប្បកិរិយារិះគន់ចំៗរបស់យ៉ូហាន-បាទីស្ទ។ យ៉ូហានត្រូវបានគេចាត់ទុកថាជាអ្នកបំផុស ព្រលឹងវិញ្ញាណរិះគន់សាសន៍យូដាឥតញញើតព្រោះតែអំពើបាប និងការពុករលួយ ហើយនិងការបំពានក្រិត្យវិន័យរបស់គេ។ តើព្រះយេស៊ូវជាអ្នករិះគន់ពីអំពើបាបតិចជាង? មិនដូច្នោះទេ យើងឃើញព្រះគ្រីស្ទគឺពិតជាក្លាហានខ្លាំងណាស់! ទ្រង់មិនទុកមុខឲ្យអ្នកណាម្នាក់ដែលរឹងចចេសមិនព្រមប្រែចិត្តឡើយ។ ការយកព្រះទ័យទុកដាក់របស់ទ្រង់សម្រាប់សំណាក់នៃព្រះវរបិតាបណ្តាលឲ្យទ្រង់បញ្ចេញសេចក្តីកំហឹងដ៏សុចរិតរបស់ទ្រង់យ៉ាងក្រេវក្រោធចំពោះពួកឈ្មួញទុច្ចរិតនៅ ក្នុងបរិវេណព្រះវិហារ។ ទ្រង់ធ្វើរំពាត់ពីខ្សែក្រវាត់ចង្កេះវាយបណ្តេញពួកអ្នកយកសំណាក់ព្រះធ្វើជាកន្លែងជំនួញឲ្យរត់ខ្ចាត់ខ្ចាយ។ ព្រះអង្គការពារទង្វើដ៏តឹងរឹងរបស់ ទ្រង់ទាស់នឹងសេចក្តីសុចរិតផ្ទាល់ខ្លួនរបស់សាសន៍យូដាដែលបានជំទាសនឹងអំណាចរបស់ទ្រង់។ ព្រះគ្រីស្ទគឺជាអ្នក បំផុសព្រលឹងវិញ្ញាណកិនអ្នកបដិសេធការជំនុំជំរះដ៏សុចរិតរបស់ព្រះជាម្ចាស់ឲ្យម៉ត់ដូចជាម្សៅ។

ផ្នែកទីមួយនៃជំពូកទី២នេះប្រាប់ពីព្រះអម្ចាស់របស់យើងនូវភាពម៉ឺងម៉ាត់គ្រប់ជ្រុងជ្រោយជាព្រះរាជអជ្ញានិងជាចៅក្រម (ហើយលក្ខណៈបែបនោះយើងឃើញនៅក្នុងយ៉ូហាន-បាទីស្ទ) នៅក្នុងបំណែកទីមួយនៃជំពូកនេះយើងបានឃើញព្រះយេស៊ូវក្នុងនិស្ស័យជាមនុស្សដ៏គ្រប់លក្ខណ៍របស់ទ្រង់។ ចំណុចណាទ្រង់អាចអនុគ្រោះនិងចំណុចណាទ្រង់អាចធ្វើឲ្យជាប់កាតព្វកិច្ច នោះទ្រង់នឹងមិនស្ទាក់ស្ទើរនឹងធ្វើនោះឡើយ។ នៅក្នុងការអស្ចារ្យនៃការធ្វើទឹកឲ្យក្លាយជាស្រាទំពាំងបាយជូរ ចូរយើងកុំភ្លេចថាទ្រង់ក៏សម្តែងវាឡើងដើម្បីបំពេញចិត្តនាងមារាជាព្រះមាតាទ្រង់ដែរ។ ព្រះអង្គប្រតិបត្តិតាមបញ្ញត្តិទីប្រាំ។ ចូរយើងកុំភ្លេចថាទ្រង់សំដែងវាឡើងដើម្បីសម្រួលនូវក្តីអាម៉ាស់របស់ម្ចាស់ដើមការដែរ។ ទ្រង់ស្រឡាញ់អ្នកជិតខាងរបស់ទ្រង់ដូចជាអង្គផ្ទាល់។ សូមកុំឲ្យយើងភ្លេចថាទ្រង់ចំណាយពេលចូលរួមកម្មវិធីអាពាហ៍ពិពាហ៍ជាពិធីចំណាយពេលជាច្រើនម៉ោងនាសម័យនោះ គឺមានរយៈពេលយូរជាងការចូលរួមបរិភោគអាហារពេលល្ងាចនៃពិធីជប់លៀងមង្គលការរបស់ជនជាតិចិននាបច្ចុប្បន្នទៅទៀត។ ទ្រង់មានវត្តមានក្នុងកម្មវិធីនោះពេញមួយចប់តែម្តងប្រយោជន៍ប្រទានពរដល់ភាពស្អាតស្អំនៃវិវាហមង្គលបរិសុទ្ធ គឺដើម្បីប្រទានព្រះពរបន្ថែមដល់ព្រះគុណនៃជីវិត (១ ពេត្រុស ៣:៧)។ ខណៈពេលយើងឃើញនូវនិស្ស័យជាព្រះរបស់ទ្រង់បើកសម្តែងដំបូងឯភូមិកាណា សូមកុំឲ្យយើងភ្លេចនូវនិស្ស័យគ្រប់លក្ខណ៍ជាមនុស្សរបស់ទ្រង់។ ព្រះយេស៊ូវជាមនុស្ស។

តើអ្នកមានកង្វះខាតនៅក្នុងជីវភាពរបស់អ្នកដែរទេ? តើអំពីគូអនាគតរបស់អ្នក អំពីជីវិតអាពាហ៍ពិពាហ៍របស់អ្នកអំពីកូនចៅរបស់អ្នក អំពីហេរញ្ញវត្ថុរបស់អ្នក អំពីបញ្ហាប្រចាំថ្ងៃរបស់អ្នក? ព្រះយេស៊ូវយកព្រះទ័យទុកដាក់។ ព្រះយេស៊ូវត្រៀមជាស្រេចដើម្បីជួយលោកអ្នក។ តើហេតុអ្វីអ្នកមិនទូលសូមជំនួយនេះពីទ្រង់? ចូរអធិស្ឋាន!

**ការពិចារណា៖** បើមានពិធីមង្គលការនៅក្នុងគ្រួសាររបស់ខ្ញុំ តើខ្ញុំនឹងយាងព្រះយេស៊ូវជាភ្ញៀវពិសេសដែរទេ?

**ការអធិស្ឋាន៖** សូមឲ្យវត្តមានព្រះយេស៊ូវជាភ្ញៀវពិសេសមិនត្រឹមតែនាពិធីមង្គលការទេ តែក្នុងជីវិតនេះរហូតតទៅ។

*«ចូរអរសប្បាយ ជាមួយនឹងអ្នកណាដែលអរសប្បាយ
ហើយយំជាមួយនឹងអ្នកណាដែលយំផង»។*

## ស្រាទំពាំងបាយជូរនៃជីវិតយាងមកភូមិកាណា

តើលោកអ្នកចេះភូមិវិទ្យានៃព្រះគម្ពីររបស់អ្នកដែរឬទេ? សូមទិញព្រះគម្ពីរធំមួយក្បាលដែលមានផែនទីនៅពីខាងក្រោយទំព័របង្អស់។

សូមរកពាក្យកាណានៅលើទំព័រផែនទីដែលមានអក្សរសរសេរថា៖ «ប៉ាឡេស្ទីនក្នុងសម័យព្រះគ្រីស្ទ»។ អ្នកនឹងឃើញភូមិកាណាមានទីតាំងនៅលើដងផ្លូវឆ្ពោះចុះទៅភាគខាងត្បូង ពីស្រុកកាពើណិម នៅភាគខាងជើងនៃសមុទ្រកាលីឡេ ឆ្លងកាត់ស្រុកម៉ាក់ដាឡា។ ផ្លូវនេះ បន្ទាប់ពីនាំអ្នកទៅដល់ភូមិកាណា នឹងនាំឆ្ពោះទៅឯស្រុកណាសារ៉ែត ជាស្រុកកំណើតរបស់ព្រះយេស៊ូវ។ យើងសន្និដ្ឋានថាព្រះអម្ចាស់នៃយើងស្គាល់ភូមិកាណាច្បាស់ដូចជាស្រុកណាសារ៉ែតដែរព្រោះតែតំបន់ទាំងពីរនេះនៅក្បែរគ្នា។

ព្រះអម្ចាស់នៃយើងប្រាកដជាមានមិត្តភក្តិនិងញាតិសន្តានជាច្រើននាក់នៅស្រុកទាំងពីរនេះ។ ដូច្នេះសិស្សរបស់ទ្រង់ លើកលែងតែយូដាស-អ៊ីស្ការីយ៉ុត ពួកគេជាអ្នកស្រុកកាលីឡេ។

ព្រះគម្ពីរចែងថា៖ «ចូរអរសប្បាយ ជាមួយនឹងអ្នកណាដែលអរសប្បាយ ហើយយំជាមួយនឹងអ្នកណាដែលយំផង» (រ៉ូម ១២:១៥)។ ខណៈពេលយើងឃើញវត្តមានព្រះគ្រីស្ទនៅក្នុងឱកាសទុក្ខព្រួយជាច្រើន ដូចនេះយើងមិនអាចមានរូបភាពទាំងស្រុងអំពីអង្គទ្រង់ដោយគ្មានកំណត់ត្រានៃវត្តមានចូលរួមរបស់ទ្រង់នាពិធីមង្គលការនេះបានឡើយ! ហើយនៅទីណាមានព្រះយេស៊ូវ នោះទ្រង់នឹងនាំនូវព្រះពរមកជានិច្ច។

ខ្ញុំជឿថាការយាងមករបស់ព្រះយេស៊ូវមកឯពិធីមង្គលការនេះទាក់ទាញចំណាប់អារម្មណ៍ភ្ញៀវពិសេសៗឯទៀតមិនតិចទេ។ សម្រាប់ពួកអ្នកដែលបានស្តាប់ពីពាក្យយ៉ូហាន-បាទីស្ទបានធ្វើបន្ទាល់ពីទ្រង់ប្រាកដជានឹងចង់ស្គាល់ទ្រង់បន្ថែមទៀត គឺដូចជាគេចង់ឃើញគូស្វាមីភរិយាថ្មោងថ្មីដូច្នោះដែរ។ មូលហេតុនេះហើយទើបស្រាទំពាំងបាយជូរអស់។ ពិតជាការអាម៉ាស់ដល់ម្ចាស់កម្មវិធី តែបែរជាកិត្តិយស! ជារឿយៗយើងសម្គាល់ឃើញនាពិធីជប់លៀងអាពាហ៍ពិពាហ៍នាពេលល្ងាចនៅមានកន្លែងទំនេរដោយសារភ្ញៀវអញ្ជើញអវត្តមាន។ សូមអនុញ្ញាតឲ្យព្រះគ្រីស្ទយាងចូលមកក្នុងរាល់ស្ថាន ភាពទាំងអស់នៃជីវិតរបស់អ្នក ព្រោះពេលនោះអ្នកនឹងឃើញមានអ្នកគាំទ្រជាច្រើនពីសំណាក់កូនៗរបស់ទ្រង់។

នៅពេលយើងយាងព្រះគ្រីស្ទមកទីវេទិកាអធិប្បាយដោយការលើកដំកើងនាមទ្រង់ យើងនឹងទាក់ទាញមនុស្សជាច្រើនមកកម្មវិធីថ្វាយបង្គំនៅព្រះវិហារ។ នៅពេលយើងយាងព្រះគ្រីស្ទមកក្នុងរបរពាណិជ្ជកម្មរបស់យើងដោយការប្រកបអាជីវកម្មសុចរិតត្រឹមត្រូវ យើងនឹងទទួលបាននូវអតិថិជនជាច្រើននាក់។ នៅពេលយើងថ្វាយកិត្តិយសដល់ព្រះគ្រីស្ទជាមួយនឹងទ្រព្យសម្បត្តិរបស់យើង ព្រះអង្គនឹងប្រទានព្រះពរដល់យើងជាច្រើនអនេកថែមទៀត។ សំណួរគឺថា តើអ្នកនឹងយាងព្រះគ្រីស្ទដែរទេ? តើព្រះគ្រីស្ទមិនត្រឹមជាភ្ញៀវកិត្តិយសរបស់អ្នកនាថ្ងៃមង្គលការ តែក៏ភ្ញៀវនារាល់ពេលបរិភោគអាហារនិងការសន្ទនារបស់អ្នកដែរ?

**ការពិចារណា៖** ព្រះយេស៊ូវគង់នៅទីណា ទីនោះមានក្តីសុខសាន្ត (ស្ងួន) -- *ទំនុកខ្មែរបរិសុទ្ធ ១២២*
**ការអធិស្ឋាន៖** ឱភ្ញៀវដ៏ពិសេសអើយ សូមទ្រង់គង់នៅបង្កើយនឹងខ្ញុំជានិច្ចផង។

ថ្ងៃទី១០ កក្កដា
យ៉ូហាន ២:៤-៨



**«អំណោយពរនៃព្រះយេហូវ៉ា នោះធ្វើឲ្យទៅជាមាន**
**ហើយទ្រង់មិនបន្ថែមសេចក្តីទុក្ខព្រួយផងទេ»។**
(សុភាសិត ១០:២២)

តើព្រះយេស៊ូវធ្វើស្រាទំពាំងបាយជូរចំណុះប៉ុន្មាន? ពីបរិបទនៃពាក្យរបស់នាងម៉ារាទៅកាន់អ្នកបម្រើនិងការដាក់ពាងទឹកចំនួនប្រាំមួយ គឺអាចសន្និដ្ឋានថាវាចំនួនដែលព្រះអម្ចាស់នៃយើងទ្រង់បានបង្គាប់។ ពាងទាំងនេះគឺជាពាងថ្មមានទំហំដ៏ធំដែលសាសន៍យូដាប្រើប្រាស់សម្រាប់អនាម័យ ដូចជាការលាងដៃមុនបរិភោគអាហារជាដើម។ ពាងនិមួយៗមាន «ចំណុះទឹក ២ ឬ ៣ អម្រែក»។ បើតាមលោកស្កូហ្វីល ១ អម្រែក= ៩ ហ្គាលុន និង ១ ហ្គាលុន = ៤,៥ លីត្រ យើងមានពាងនិមួយៗផ្ទុកទឹកជាធម្យមចំនួន ១០០ លីត្រ។ គុណនឹង៦នោះអ្នកទទួល ៦០០លីត្រ! តើចំណុះស្រាទំពាំងបាយជូរនោះថ្លៃប៉ុន្មាននាសព្វថ្ងៃ?

ព្រះអម្ចាស់នៃយើងគឺជាព្រះអាទិករនៃស្ថានសួគ៌និងផែនដី។ ក្នុងន័យនោះ ចំណុះនេះគឺគ្រាន់តែជាមួយដំណក់ទឹកទៅក្នុងសមុទ្រប៉ុណ្ណោះ។ បើព្រះយេស៊ូវគ្មានបញ្ហានឹងបង្កើននំប៉័ងប្រាំដុំនិងត្រីពីរកន្ទុយសម្រាប់ផ្តល់អាហារដល់បុរស៥,០០០ (មិនរាប់ស្ត្រីនិងកុមារ) ទ្រង់ក៏មិនចាំបាច់ប្រឹងប្រែងដើម្បីធ្វើ (ស្រាទំពាង់បាយជូរ) ចំណុះ ៦,០០ លីត្រសំរាប់ចំអែតភ្ញៀវដ៏គួរឲ្យចាប់អារម្មណ៍ប្រហែល ៦,០០០នាក់ដែរ។ សូមចងចាំថាទ្រង់គឺប្រសើរជាងលោកយ៉ូហាន-បាទីស្ទ។ ព្រះអង្គគឺជាព្រះអាទិត្យដែលទើបតែរះថ្មី។ សូមកុំលាក់បាំងក្តីស្រមើស្រមៃរបស់អ្នកអំពីបរិមាណហួងមនុស្ស។ ទ្រង់បំពេញនូវរាល់តម្រូវការរបស់គេ ដោយ (ស្រាទំពាំងបាយជូរ) បម្រុងទុកជាច្រើនទៀត ដូចជាក្នុងការផ្តល់អាហារដល់មនុស្សទាំង ៥,០០០នាក់ផងដែរ។

**ការពិចារណា៖** ព្រះយេស៊ូវបានមានបន្ទូលថា ទឹកបានក្លាយជាស្រាទំពាំងបាយជូរ ព្រះយេស៊ូវ ព្រះយេស៊ូវ សូមមានបន្ទូលមកខ្ញុំផង ថ្មីឡើងៗ សូមមានបន្ទូលមកខ្ញុំផង!
**ការអធិស្ឋាន៖** «ខ្ញុំអរណាស់ដោយចេះទុកចិត្តទ្រង់ ព្រះយេស៊ូវជាមិត្តមេត្រី.. ខ្ញុំក៏ដឹងថាទ្រង់ចេះតែគង់ ជាមួយខ្ញុំកាលនៅលោកីយ»។ *(ចម្រៀងទំនុកដំកើង ១៦៩)*។

ថ្ងៃទី ១១ កក្កដា
យ៉ូហាន ២:៩-១១

*«កុំឲ្យស្រវឹងស្រាដែលនាំឲ្យព្រើលចិត្តឡើយ តែចូរឲ្យបានពេញជាព្រះវិញ្ញាណវិញ» (អេភេសូរ ៥:១៨)។*

## ស្រាទំពាំងបាយជូរនៃជីវិតមិនមែនជាស្រាវីស្គីនៃសេចក្ដីស្លាប់ទេ

ព្រោះតែស្រាទំពាំងបាយជូរដែលព្រះអម្ចាស់នៃយើងបានធ្វើនៅភូមិកាណានៃស្រុកកាលីឡេ គ្រីស្ទបរិស័ទមួយចំនួនបានផឹកស្រានិងបំពីគ្រឿងស្រវឹងដែលមានជាតិអាកុលខ្លាំងនាពិធីជប់លៀងមង្គលការពេលល្ងាចដោយអះអាចជាសាធារណៈថាជា «ស្រាយិន ស៊ិន (*yam seng*)»។ ហេតុផលនេះគឺជាការយល់ច្រឡំនិងជាការអនុវត្តន៍មួយផ្ទុយពីសេចក្ដីពិត។

បើតាមវចនានុក្រមព្រះគម្ពីរហេស្ទីង (*Hastings Bible Dictionary*) ស្រាទំពាំង បាយជូរដែលព្រះយេស៊ូវបានធ្វើគឺកម្រិតអាកុលខ្សោយដូចជាស្រាទំពាំងបាយជូរជនជាតិហេព្រើដែរ។ ចំណុចនេះ គឺ ត្រូវបានបណ្ឌិត អ អែល ហារីស (Dr. R. L. Harris) យល់ព្រមនៅក្នុងអត្ថបទមួយនៃព្រឹត្តិប័ត្រព្រះគម្ពីរថ្ងៃនេះ (*Bible Today*) ជាអត្ថបទដែលគាត់បកស្រាយបង្ហាញនូវភាពខុសប្លែកគ្នាដ៏ធំធេងរវាងកម្រិត សារជាតិអាកុលនៃស្រាទំពាំងបាយជូរបែបនេះហើយនឹងស្រាវីស្គី និងស្រាគោញាក់សព្វថ្ងៃ។ បណ្ឌិត បាស្វែល (Dr. Buswell) បានផ្ដល់កំណត់សម្គាល់ដោយកំប្លែងថាស្រា «យិន ស៊ិន» ជាប្រភេទស្រាទំពាំង បាយជូរទាន់សម័យទាំងនេះ ដូចជាល្បាយឧស្ម័ននិងប្រេងអាចនឹងប្រើសម្រាប់ដំណើរការរថយន្តដូច្នោះដែរ។ ក៏ប៉ុន្តែ លោកបានបន្ថែមទៀតថា «ក្រពះរបស់យើងគឺមិនមែនជាម៉ាស៊ីនចំហេះទេ»។

ម្យ៉ាងវិញទៀត ស្រាទំពាំងបាយជូរនៅតំបន់ប៉ាឡេស្ទីនដែលគេផឹកក្នុងការបរិភោគអាហាររបស់សាសន៍ហេព្រើ គឺជាប្រភេទស្រាទំពាំងបាយជូរលាយទឹក។ ស្រាទំពាំងបាយជូររបស់ស្រុកសារ៉ុន (wine of Sharon) ត្រូវគេបានលាយជាមួយទឹកពីរភាគ គឺមានកម្រិតខ្សោយជាងស្រាទំពាំងបាយជូរដទៃទៀត។ ចំពោះស្រាទំពាំងបាយជូរឯទៀត គិតជាប្រភាគគឺទំពាំងបាយជូរមួយភាគនិងទឹកបីភាគ។

គ្រោះថ្នាក់នៃស្រាទំពាំងបាយជូរបណ្ដាលឲ្យមនុស្សស្រវឹងគឺគ្មានអ្នកណាបានដាស់រំឭកក្រៅពីស្ដេចសាឡូម៉ូនទេ (សូមអាន សុភាសិត ២៣:២៩-៣៥)។ ដូច្នេះ វាជាការប្រសើរសម្រាប់គ្រីស្ទបរិស័ទត្រូវរក្សាខ្លួនពីគ្រឿងស្រវឹងគ្រប់ប្រភេទ ចូរធ្វើជាអ្នកមិនសេពគ្រឿងស្រវឹង!

លោកប៉ុល ជាអ្នកបរិសុទ្ធប៉ូលមានប្រសាសន៍ថា៖ «ដ្បិតនគរព្រះមិនសំរេចនឹងការស៊ី ឬផឹកនោះទេ គឺស្រេចនឹងសេចក្ដីសុចរិត សេចក្ដីមេត្រី នឹងសេចក្ដីអំណរ ដោយនូវព្រះវិញ្ញាណបរិសុទ្ធវិញទេតើ...។ គួរតែកុំឲ្យបរិភោគសាច់ ឬស្រាទំពាំងបាយជូរ ឬអ្វីដែលនាំឲ្យបងប្អូនអ្នកជំពប់ ឬរវាតចិត្ត ឬធ្វើឲ្យខ្សោយនោះឡើយ» (រ៉ូម ១៤:១៧,២១)។

**ការពិចារណា៖** ចូរទន្ទេញ អេភេសូរ ៥:១៨។
**ការអធិស្ឋាន៖** ឱសូមឲ្យខ្ញុំពេញដោយព្រះវិញ្ញាណ តែកុំឲ្យខ្ញុំពេញដោយគ្រឿងញៀននិងគ្រឿងស្រវឹង។

ថ្ងៃទី ១២ កក្កដា
យ៉ូហាន ២:១២

*«...ឯបណ្តាជន ដែលអង្គុយក្នុងសេចក្តីងងឹត គេបានឃើញពន្លឺយ៉ាងធំ...»។*

**ពីភូមិកាណាទៅស្រុកកាពើណិម**

នេះគឺជាកំណត់ត្រានូវការពិតពីព្រះយេស៊ូវនិងពួកសិស្សទ្រង់ហើយនិងសាច់ញាតិរបស់ព្រះអង្គដែលកំពុងធ្វើដំណើរទៅឯស្រុកកាពើណិម ជាភូមិនេសាទមួយនាភាគឥសាន្តនៃសមុទ្រកាលីឡេ បង្កប់នូវដំណើរដ៏សំខាន់មួយក្នុងជីវភាពនៃព្រះអម្ចាស់របស់យើង។ អ្នករួមដំណើរជាមួយទ្រង់ប្រហែលជាទៅស្រុកនោះដើម្បីហែរកូនក្រមុំនិងកូនកំលោះចូលទៅគេហដ្ឋានរបស់របស់ពួកគេ។ មូលហេតុជាចម្បង ដរាបណាយើងគិតពីព្រះអម្ចាស់នៃយើង គឺទ្រង់ទៅយាងទៅដើម្បីបង្កើតមជ្ឈមណ្ឌលកណ្តាលនៅស្រុកនោះសម្រាប់ការផ្តើមព័ន្ធកិច្ចនាស្រុកកាលីឡេរបស់ទ្រង់។ ហេតុការណ៍នេះត្រូវបានកត់ត្រាលម្អិតក្នុងម៉ាថាយ ៤:១២-១៧៖ «រួចទ្រង់ចេញពីណាសារ៉ែត ទៅគង់នៅឯក្រុងកាពើណិមវិញ ជាក្រុងនៅមាត់សមុទ្រ ត្រង់ព្រំប្រទល់ដែនខេត្តសាប់យូល៉ូន នឹងណែបថាលី...ឯបណ្តាជន ដែលអង្គុយក្នុងសេចក្តីងងឹត គេបានឃើញពន្លឺយ៉ាងធំ...»។

មានការអះអាងមួយទៀតពីមូលហេតុព្រះយេស៊ូវយាងមកស្រុកកាពើណួមឆ្ងាយពីណាសារ៉ែតជាស្រុកកំណើតរបស់ទ្រង់។ គឺដូចជាសុភាសិតថ្លែងថា៖ «ស្គាល់គ្នាខ្លាំង យកដៃលេងក្បាល» ព្រះអម្ចាស់នៃយើងជ្រាបឃើញនូវការ ងារឥតប្រយោជន៍ជាមួយនឹងអ្នកស្រុករបស់ទ្រង់។ ព្រះអង្គមានបន្ទូលឆ្លើយទៅពួកអ្នកចំអកដាក់ទ្រង់ថា៖ «គ្មានហោរា ណាដែលគេរាប់អាននៅក្នុងស្រុករបស់ខ្លួនទេ» (លូកា ៤:២៤)។ បើឆ្លើយនឹងពួកគេជាភាសាចិនកាតាំងគឺ «ខ្ញីក្នុងស្រុកមិនហឹរទេ»។

មិនមែនស្រុកណាសារ៉ែតទេ តែជាកាពើណួមវិញដែលបានទទួលព្រះអម្ចាស់ដោយសេចក្តីអំណររីករាយ។ តាំងពីដំបូងមកម្ល៉េះ គឺជាស្រុកកាពើណួម។ ក្រោយមក នៅពេលទ្រង់មានភាពស្និទ្ធិស្នាលនឹងអ្នកស្រុកកាពើណួម ពួកអ្នកស្រុកនោះប្រែជាមិនផ្តល់តំលៃ ព្រះអង្គក៏ប្រកាសបដិសេធពួកគេផងដែរ។ សូមអាន ម៉ាថាយ ១១:២៣-២៤។

នៅក្នុងការធ្វើដំណើរនៃព្រះអម្ចាស់ តើអ្នកអាចរកស្រុកណាសារ៉ែត ភូមិកាណា និងកាពើណួមនៅលើផែនទីដែរទេ? តើចម្ងាយពីក្រុងមួយទៅក្រុងមួយទៀតមានចំនួនប៉ុន្មានគីឡូម៉ែត។

**ការពិចារណា៖** «ខ្ញីក្នុងស្រុកមិនហឹរទេ!»។
**ការអធិស្ឋាន៖** ឱព្រះអង្គអើយ សូមបង្ហាញគោលដីជីវិតឲ្យខ្ញុំផង។

*«...កុំឲ្យយកដំណាក់នៃព្រះវរបិតាខ្ញុំ ធ្វើជាផ្ទះជំនួញឡើយ»។*

## ពីភូមិកាពើណូមទៅទីក្រុងយេរូសាឡឹម

ព្រះអង្គបន្តស្នាក់នៅភូមិកាពើណិម តែពីរឬបីថ្ងៃប៉ុណ្ណោះព្រោះពិធីបុណ្យរំលងខិតជិតមកដល់។ ដោយសារតែជាកាតព្វកិច្ចរបស់សាសន៍យូដាគ្រប់រូបត្រូវមានវត្តមានរបស់ខ្លួននារាល់ពិធីបុណ្យរំលង (និក្ខមនំ ២៣:១៤-១៧) ព្រះយេស៊ូវក៏បានយាងចូលរួមទៅដើម្បីបំពេញនូវកាតព្វកិច្ចនេះដូចកាលទ្រង់បានយាងទៅទីឯក្រុងយេរូសាឡឹមកាលពេលទ្រង់មានព្រះជន្មដប់ពីរឆ្នាំដែរ។ វាគឺជាកាតព្វកិច្ចរបស់យើងដើម្បីចូលរួមថ្វាយបង្គំនៅឯព្រះវិហារ ដូចជាព្រះអង្គជាម្ចាស់នៃយើងបានធ្វើជាគំរូដូច្នោះដែរ!

បញ្ហាមួយដែលបានរំខានទ្រង់នាពេលប៉ុន្មានឆ្នាំនោះគឺជាពួកឈ្មួញលក់សត្វពាហនៈនិងស្លាបសម្រាប់ធ្វើជាដង្វាយយញ្ញបូជានៅក្នុងបរិវេណព្រះវិហារ។ ពួកអ្នកលក់ទាំងនេះមិនសូវលុកលុយខ្លាំងខាងផ្នែកសាច់ឈាមដូចជាខាងផ្នែកសីលធម៌ប៉ុន្មានទេ។ បណ្ឌិតកាល់វិនធ្វើអត្ថាធិប្បាយថា៖ «ពួកសង្ឃប្រើប្រាស់ទំនិញមិនត្រឹមត្រូវសម្រាប់បំពេញប្រយោជន៍និងការលោភលន់ផ្ទាល់ខ្លួន ហើយទង្វើប្រមាថដល់ព្រះបែបនេះគឺមិនអាចលើកលែងបានឡើយ។ ជាថ្មីម្ដងទៀតទោះបីមនុស្សមានពាក្យអង្វរតវ៉ា ព្រោះតែខ្លួនបានឃ្លាតចេញបន្តិចបន្តួចពីបទបញ្ញត្តិរបស់ព្រះ ក៏ពួកគេសាកសមនឹងទទួលនូវការថ្កោលទោសនិងការកែតម្រូវដែរ»។ នៅក្នុងការសំអាតព្រះវិហារជាលើកទីពីរបន្ទាប់ពីដំណើរយាងចូលក្រុងយេរូសាឡឹមដោយជោគជ័យ ព្រះយេស៊ូវប្រកាសថ្កោលទោសពួកឈ្មួញនៅក្នុងបរិវេណព្រះវិហារថា «បានធ្វើ (*ព្រះវិហារ*) ជារោងចោរ» (ម៉ាថាយ ២១:១៣)។

តើហេតុអ្វីបានជាព្រះគ្រីស្ទមិនអប់រំពួកអ្នកមានកំហុសទាំងនេះ តែប្រើអំណាចដូច្នេះ? បណ្ឌិតកាល់វិនក៏បានអត្ថាធិប្បាយទៀតថា៖ «ដោយសារពេលវេលាបានមកដល់សម្រាប់ទ្រង់យាងចេញជាសាធារណៈបំពេញពន្ធកិច្ចដែលព្រះវរបិតាបានប្រទានដល់ទ្រង់ ព្រះអង្គចង់បានវិធីដែលអាចចូលយកព្រះវិហារជាកម្មសិទ្ធិនិងសំដែងឲ្យឃើញនូវភស្តុតាងពីអំណាចជាព្រះរបស់ទ្រង់។ តាមរយៈការអនុវត្តវិតាមជីនោះគ្រប់គ្នានឹងយកចិត្តទុកដាក់នឹងសេចក្ដីបង្រៀនរបស់ទ្រង់ ឯចំណែកចិត្តគំនិតខ្ជិលច្រអូសនិងងោកងុយរបស់គេត្រូវជាចាំបាច់តែដាស់ឲ្យភ្ញាក់រឭកដោយសារអ្វីមួយដែលថ្មីនិងចម្លែកខុសពីធម្មតាដែរ។ ព្រះអង្គត្រូវតែសម្ដែងឲ្យឃើញអង្គទ្រង់ជាម្ចាស់ព្រះវិហារ។ កិច្ចការទ្រង់បានធ្វើនាពេលនោះគឺហាក់ដូចជាការចាប់ផ្ដើមទុកជាមុនឆ្ពោះទៅរកការកែទម្រង់ដែលព្រះវរបិតាតម្រូវឲ្យទ្រង់សម្រេចលទ្ធផល»។ ដូចយើងអាចសម្គាល់ឃើញកិច្ចការព្រះយេស៊ូវធ្វើគឺចេញពីមូលហេតុដ៏ស្មោះត្រង់មួយគឺដោយ «សេចក្ដីក្រោធដ៏សុចរិត» ទាស់នឹងពួកអ្នកគ្មានការកោតខ្លាចព្រះ តែជាអ្នករិះរកមធ្យោបាយយ៉ាងណាឲ្យតែបានកំរៃ បើទោះបីត្រូវបាត់បង់សិរីល្អរបស់ព្រះក៏ដោយ។

នេះពិតជាពាក្យរំឭកដាស់តឿនដ៏ម៉ត់ចត់ចំពោះយើងជាអ្នកចាត់ចែងទ្រព្យសម្បត្តិព្រះវិហារ គឺចំពោះយើងដែលប្រើប្រាស់ទ្រព្យសម្បត្តិរបស់ព្រះវិហារតែម្ដង។ តើយើងជាអ្នកប្រើប្រាស់ដំណាក់របស់ព្រះ នាំមកនូវសិរីល្អថ្វាយដល់ព្រះ ឬជាក្ដីអាម៉ាស់ដល់ព្រះនាមទ្រង់?

**ការពិចារណា៖** តើខ្ញុំយកការបម្រើព្រះជាឆ្នាំបាយរបស់ខ្ញុំ?
**ការអធិស្ឋាន៖** ឱព្រះអង្គអើយ សូមបង្រៀនឲ្យខ្ញុំស្មោះត្រង់ចំពោះពន្ធកិច្ចទ្រង់ទោះតូចឬធំក្ដីផង។

ថ្ងៃទី ១៤ កក្កដា
យ៉ូហាន ២:១៧-២៥

*«កាលទ្រង់មានព្រះជន្មរស់ឡើងវិញ...ហើយគេក៏ជឿគម្ពីរ នឹងព្រះបន្ទូលរបស់ព្រះយេស៊ូវ»។*

## ពួកសិស្ស និងជនជាតិយូដា ហើយនឹងអ្នកជឿការអស្ចារ្យ

នាពេលធ្វើការណែនាំលើកដំបូងអំពីព្រះមេស៊ីដល់សាសន៍យូដានេះ យើងអាចសម្គាល់ឃើញមានមនុស្សចំនួនបីប្រភេទខុសៗគ្នា។ ចូរយើងពិនិត្យមើលផ្ទុយពីលំដាប់លំដោយនៃប្រភេទមនុស្សទាំងបីប្រភេទនេះ។

**អ្នកជឿលើការអស្ចារ្យ**។ ពួកអ្នកមានជំនឿលើការបែបនេះមានចំនួនច្រើន ជាមនុស្សមួយហ្វូងធំ ជាអ្នកដែលងាយនឹងប៉ះពាល់ចិត្តដោយទីសម្គាល់ខាងក្រៅ។ ពួកអ្នកទាំងនេះអាចតំណាងឲ្យដីរឹងនៅដងផ្លូវនិងដីមានបន្លាដែលគ្រាប់ពូជល្អធ្លាក់លើបង្កើតផលបានរយៈដ៏ខ្លី។ (សូមអានរឿងប្រៀបប្រដូចអំពីអ្នកព្រោះគ្រាប់ពូជក្នុងម៉ាថាយ ១៣: ១-៩)។ ទោះបីអ្នកទាំងនេះបានផ្តុំគ្នាជាហ្វូងមនុស្ស «បានជឿដល់ព្រះនាមទ្រង់ដោយឃើញទីសំគាល់ដែលទ្រង់ធ្វើមក» ក៏ព្រះយេស៊ូវមិនទុកចិត្តគេទេ។ «ពីព្រោះទ្រង់ស្គាល់ដល់គ្រប់ទាំងមនុស្ស» (ខ ២៤)។ ព្រះអម្ចាស់នៃយើងមានគ្រប់ទាំងការសុភវិនិច្ឆ័យនៃភាពជាព្រះអំពីស្ថានភាពគ្រប់កាលៈទេសៈក្នុងជីវិត។ ការអះអាងពីការដែលយើងជឿមិនទាន់គ្រប់គ្រាន់នៅឡើយ។ តើជំនឿរបស់យើងត្រូវមានធំប៉ុណ្ណា? សូមកុំឲ្យយើងជឿតែបបូរមាត់និងក្នុងគិតរបស់យើងឡើយ ប៉ុន្តែនៅក្នុងចិត្តរបស់យើងផង ជាការពិតណាស់ត្រូវឲ្យយើងជឿចាក់ឫសពីខាងក្នុង (ពោះរបស់យើង បើមិត្តអ្នកអានដំណឹងល្អយ៉ូហានជំពូក៦!)។

**ជនជាតិយូដា**។ គេជាអ្នកមិនចង់ផ្លាស់ប្តូរគំនិត ជាអ្នកប្រកាន់ភ្ជាប់តាមជំនឿសាសនាយូដា ដោយការបដិសេធដាច់ខាតមិនទទួលសេចក្តីណាដែលហួសពីក្រិត្យវិន័យរបស់លោកម៉ូសេ។ ទោះជាយ៉ាងណា ព្រះយេស៊ូវមិនបានយាងមកដើម្បីបំផ្លាញក្រិត្យវិន័យលោកម៉ូសេទេ តែដើម្បីសម្រេចវិញ។ ដើម្បីបង្កផលលំបាកដល់ព្រះអម្ចាស់នៃយើង ពួកគេសួររកទីសម្គាល់។ នេះគឺជាកំហុសឆ្គងមួយ ព្រោះព្រះគ្រីស្ទឥតបានប្រទានគុណសម្បត្តិរបស់ទ្រង់ដោយសម្តែងការអស្ចារ្យតាមបង្គាប់របស់អ្នកស្វែងរកប្រភេទនេះទេ។

ប៉ុន្តែដោយសារគេសុំ ទើបព្រះអង្គមានបន្ទូលប្រាប់អំពីការអស្ចារ្យចុងក្រោយដ៏ធំមួយដល់ពួកគេ គឺជារូបអង្គទ្រង់ផ្ទាល់ក្នុងការសុគតនិងការរស់ឡើងវិញរបស់ទ្រង់។ នេះគឺជាមូលដ្ឋាននៃព្រះគម្ពីរសញ្ញាថ្មី ជាជំនឿគ្រីស្ទបរិស័ទដែលសាសន៍យូដាត្រូវតាំងជំនឿលើមូលដ្ឋានគ្រឹះលើដើម្បីទទួលបានសេចក្តីសង្គ្រោះ។ ដោយហេតុតែគេជាពួកអ្នកជំរុញព្រះអម្ចាស់របស់យើងមិនសមនឹងទទួលចម្លើយ ព្រះអម្ចាស់នៃយើងផ្តល់ចម្លើយដល់ពួកគេដ៏ពិបាកយល់ ដូចជាទ្រង់បង្រៀនក្នុងរឿងប្រៀបប្រដូចដែរ។ មានតែអ្នកដែលមានត្រចៀកស្តាប់ទេទើបអាចយល់។ បើអ្នកគឺជាអ្នកអានជនជាតិយូដា យើងគ្មានភស្តុតាងណាប្រសើរណាបញ្ជាក់ជាងក្រៅអំពីព្រះគ្រីស្ទយេស៊ូវជាព្រះមេស៊ី និងពីការសុគតហើយនឹងការរស់ឡើងវិញរបស់ទ្រង់ឡើយ។ តើសេចក្តីអ្វីដែលអ្នកនឹងអះអាង?

**ពួកសិស្ស**។ អ្នកទាំងនេះគឺអ្នកជឿពិតប្រាកដដើម្បីទទួលសេចក្តីសង្គ្រោះ ជាពួកអ្នកបានអានព្រះគម្ពីរសញ្ញាចាស់ដោយការយល់ដឹង។ «ពួកគេតាមការណែនាំរបស់ព្រះគម្ពីរដើម្បីស្វែងយល់ដឹងពីព្រះគ្រីស្ទត្រឹមត្រូវ»។ គេក៏ចេះបទគម្ពីរច្បាស់លាស់រហូតដល់ពួកគេអាចនឹកឃើញនូវសេចក្តីដែលបានព្យាករណ៍ទុកអំពីព្រះមេស៊ីដែលនឹងត្រូវយាងមកទៀតដែរ។ សូមសម្គាល់មើលកិរិយាស័ព្ទ «នឹកឃើញ» នៅក្នុងខទី ១៧ និងខទី ២២ «ហើយគេក៏ជឿគម្ពីរ នឹងព្រះបន្ទូលរបស់ព្រះយេស៊ូវ»។ លោកកាល់វីនសន្និដ្ឋានថា៖ «ជាការពិតមែនហើយគ្មានអ្នកណាម្នាក់នឹងស្គាល់ព្រះគ្រីស្ទថាជាអ្វី ឬពីគោលបំណងនៃសកម្មភាពនិងទុក្ខលំបាករបស់ទ្រង់បានទេ លើកលែងតែមានការណែនាំនិងការបង្រៀន

របស់ព្រះគម្ពីរប៉ុណ្ណោះ»។ តើមិនមែនជាសេចក្តីថ្លែងការណ៍ដ៏ខ្ពង់ខ្ពស់អំពីព្រះគម្ពីរនេះនាំឲ្យមានការព្យាយាមបង្កើតកូនសៀវភៅសំរាប់ការស្ញៀមស្ងាត់ (RPG) នេះទេឬអី?

**ការពិចារណា៖** ខ្ញុំជឿលើការរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ?
**ការអធិស្ឋាន៖** ឱព្រះជាម្ចាស់អើយ សូមប្រទានជំនឿឲ្យខ្ញុំជឿលើការរស់ឡើងវិញដូចជាពួកសិស្សទ្រង់ផង។

*«ប៉ុន្តែ បើអ្នកណាគ្មានព្រះវិញ្ញាណរបស់ព្រះគ្រីស្ទ អ្នកនោះមិនមែនជារបស់ផងទ្រង់ទេ»។*

## ជំពូកទី ៣
## ព្រះយេស៊ូវគឺជាដង្ហើមជីវិតដល់អ្នកមិនទាន់កើតជាលើកទីពីរ

យ៉ូហាន ៣:១៦ ដែលត្រូវបានចាត់ទុកជាខមានប្រជាប្រិយភាពជាងគេទូទាំងព្រះគម្ពីរ គឺឃើញនៅក្នុងជំពូកទីបីនេះ។ បើដំណឹងល្អយ៉ូហានគឺត្រូវបានគេចាត់ទុកជាដំណឹងល្អនៃជីវិត ខមួយនេះក៏អាចនឹងចាត់ទុកជាខនៃជីវិតផងដែរ។

តើយើងត្រូវធ្វើដូចម្តេចនឹងដឹងថាមនុស្សម្នាក់នៅរស់? ពេលគាត់នៅមានខ្យល់ដង្ហើមនៅ ក្នុងរន្ធច្រមុះរបស់គាត់។ តើមនុស្សក្លាយជាបុគ្គលមានជីវិតដោយរបៀបណា? ពេលព្រះជាម្ចាស់ «ទ្រង់ផ្លុំខ្យល់ដង្ហើមជីវិតបញ្ចូលទៅក្នុងរន្ធច្រមុះ» (លោកុប្បត្តិ ២:៧)។ ជីវិតនេះដែលព្រះទ្រង់បានប្រទានឲ្យមនុស្សមិនមែនគ្រាន់តែសំដៅទៅលើជីវិតផ្នែកសារពាង្គកាយប៉ុណ្ណោះទេ តែជាសំខាន់នោះ គឺសំដៅលើជីវិតផ្នែកព្រលឹងវិញ្ញាណរបស់គាត់ផងដែរ។ ចំណុចនេះបណ្តាលឲ្យមនុស្សមានកម្រិតខ្ពស់ប្រសើរ ជាសត្វស្វាឪ ពីព្រោះស្វានិងពពួកសត្វឯទៀតគឺគ្រាន់តែជាស្នាព្រះហស្តត្រូវបានបង្កើតមកពីធូលីដីប៉ុណ្ណោះ ប៉ុន្តែមានតែមនុស្សទេដែលត្រូវបានបង្កើតមកពី «ធូលីដី» ហើយរួមនឹងដង្ហើមឬជីវិតដែលព្រះផ្លុំបញ្ចូលដ៏ពិសេសសម្រាប់គាត់។ ដូច្នេះមនុស្សត្រូវបានប្រកាសឲ្យដឹងថាបានបង្កើតឲ្យដូចជារូបអង្គទ្រង់។

ក៏ប៉ុន្តែជីវិតផ្នែកព្រលឹងវិញ្ញាណដែលមនុស្សទទួលមកពីព្រះគឺបានបាត់បង់នៅពេលគាត់មិនស្តាប់បង្គាប់ទ្រង់ «ដ្បិតនៅថ្ងៃណាដែលឯងស៊ី នោះនឹងត្រូវស្លាប់ជាមិនខាន» (លោកុប្បត្តិ ២:១៧)។ ហេតុនេះ ឬក៏មនុស្សរស់នៅជីវិតដែលព្រះប្រទានដល់គាត់គឺកម្រិតខ្ពស់ជាងសត្វ មនុស្សត្រូវតែស្តារ (កែជីវិត) ឡើងវិញ។ មនុស្សលង់ទឹកអាចធ្វើឲ្យដឹងខ្លួនឡើងវិញតាមរយៈការផ្តល់ ខ្យល់ដង្ហើមជំនួយ។ មនុស្សដែលស្លាប់ក្នុងសេចក្តីរំលងនិងអំពើបាបអាចនឹងធ្វើឲ្យមានជីវិតឡើងវិញមានតែតាមរយៈដង្ហើមនៃជីវិតដែលជាព្រះរាជបុត្រានៃព្រះប្រទានឲ្យប៉ុណ្ណោះ។ នេះហើយគឺជាការពិពណ៌នាអំពីការកើតជាថ្មី គឺមិនមែនជាការប្រើពាក្យដ៏ធូររលង់ដូចជាលោកីយចាប់តាំងពីសម័យប្រធានាធិបតីសហរដ្ឋអាមេរិក ជីមី កាទឺរ (Jimmy Carter) នោះឡើយ។ ដំណាក់កាលនៃការផ្លុំខ្យល់ដង្ហើមថ្មីទៅក្នុងមនុស្សដែលស្លាប់ខាងផ្នែក ព្រលឹងវិញ្ញាណគឺជាការងារនៃព្រះវិញ្ញាណបរិសុទ្ធ។ ព្រះវិញ្ញាណត្រូវតែធ្វើការនៅក្នុងចិត្ត របស់មនុស្សដើម្បីជំនុំជំរះគាត់នូវអំពើរបស់គាត់ អំពីតម្រូវនៃការប្រែចិត្តចេញ ពីបាបរបស់គាត់ និងបណ្តាលឲ្យគាត់សម្លឹងទៅកាន់ព្រះអង្គសង្គ្រោះដែលបានជាប់ឆ្កាងសម្រាប់សេចក្តីសង្គ្រោះ។

ទេវសាស្ត្រនៃកំណើតទីពីរនេះគឺត្រូវបានព្រះអម្ចាស់ជជែកជាមួយនឹងលោកនីកូដេម ជា «ចៅ ហ្វាយ» សាសន៍យូដាដ៏មានចំណេះដឹងខ្ពង់ខ្ពស់។ គាត់គឺជាសមាជិកសានហិដ្រិន (*Sanhedrin*) ជាតុលាការនៃជនជាតិយូដា ជាចាស់ទុំនៃព្រះវិហារ។ និកូដេម លោកមានសំបកក្រៅរបស់សាសនា តែគតមានស្នូលឬជីវិតរបស់សាសនានោះទេ។ ដូច្នេះគាត់ត្រូវតែកើតជាថ្មី។ មិត្តអ្នកអានអើយ! អស់ទាំង «ការចូលរួម ព្រះវិហារ» ដែលអ្នកទទួលមរតកពីឪពុកម្តាយជាគ្រីស្ទបរិស័ទតរៀងមកជំនាន់ទីបីឬទីបួននឹងមិនអាចជួយឲ្យអ្នកទៅស្ថានសួគ៌បានឡើយ។ សេចក្តីសង្គ្រោះគឺលក្ខណៈបុគ្គលរៀងៗខ្លួន។ សំណួរគឺ តើអ្នកបានកើតជាថ្មី? តើអ្នកមានដង្ហើមនៃជីវិតនៅក្នុងអ្នកដែរទេ? លោកប៉ុល ជាអ្នកបរិសុទ្ធថ្លែងថា៖ «ប៉ុន្តែ បើអ្នកណាគ្មានព្រះវិញ្ញាណរបស់ព្រះគ្រីស្ទ អ្នកនោះមិនមែនជារបស់ផងទ្រង់ទេ» (រ៉ូម ៨:៩)។

**ការពិចារណា៖** ជាគ្រីស្ទបរិស័ទដោយពាក្យបន្ទូលនិងព្រះវិញ្ញាណបរិសុទ្ធ។

**ការអធិស្ឋាន៖** ឱព្រះវរបិតាអើយ សូមឲ្យខ្ញុំបានប្រែចិត្តពីបាបដើម្បីទទួលបានកំណើតទីពីរខាងឯវិញ្ញាណផង។

ថ្ងៃទី ១៦ កក្កដា
យ៉ូហាន ៣:១-១៣

*«ប៉ុន្តែមនុស្សខាងសាច់ឈាម គេមិនទទួលសេចក្តីខាងឯព្រះវិញ្ញាណនៃព្រះទេ»។*

## ដង្ហើមនៃជីវិតបើកភ្នែករបស់យើងនិងធ្វើអោយជើងយើងកំរើក

ខទី៣ចែងថាៈ «បើមិនបានកើតជាថ្មី នោះគ្មានអ្នកណាអាចនឹងឃើញនគរព្រះបានទេ»។ បើអ្នកមិនបានកើតជាថ្មីទេ អ្នកគឺជាមនុស្សខ្វាក់ម្នាក់។ គ្រប់ទាំងសេចក្តីអាថ៌កំបាំងនៃព្រះ អំពីស្ថានសួគ៌ អំពីជីវិតដ៏នៅអស់កល្បនិងសេចក្តីក្តីអំណរនៃជីវភាពគ្រីស្ទបរិស័ទគឺគ្មានអត្ថន័យចំពោះអ្នកឡើយ។ ព្រះគម្ពីរ ១ កូរិថូស ២:១៤ សំដែងថាៈ «ប៉ុន្តែមនុស្សខាងសាច់ឈាម គេមិនទទួលសេចក្តីខាងឯព្រះវិញ្ញាណនៃព្រះទេ ពីព្រោះជាសេចក្តីល្ងង់ល្ងើដល់គេ ក៏រកស្គាល់មិនបានដែរ ដ្បិតត្រង់ឯសេចក្តីទាំងនោះ ត្រូវពិចារណាយល់ខាងវិញ្ញាណវិញ»។ អ្នកប្រហែលជាអញ្ជើញមកព្រះវិហារនិងបានស្តាប់ការអធិប្បាយព្រះបន្ទូលជាច្រើនដង ប៉ុន្តែអ្នកនឹងមិនអាចយល់នូវសេចក្តីបង្រៀនរបស់ព្រះគម្ពីរនិងមិនអាចថ្លែងអំណរគុណនូវសេចក្តីដែលគ្រូអធិប្បាយបកស្រាយប្រាប់ពីព្រះគម្ពីរបានទេ។ សេចក្តីខាងព្រះវិញ្ញាណដែលបានលើកឡើងមកពិភាក្សាគឺមិនវ៉ៃឆ្លាតចំពោះរូបអ្នក។ អ្នកមិនអាចមើលឃើញពណ៌ឥន្ទធនូសេចក្តីពិត នៃស្ថានសួគ៌បានទេបើអ្នកមិនបានកើតជាថ្មី។ ដោយមិនចាំបាច់ឆ្ងល់ទើបបានជាមិនយូរប៉ុន្មានអ្នកឈប់មកព្រះវិហារ ពីព្រោះអ្នកនិយាយថា កម្មវិធីថ្វាយបង្គំនិងការអធិប្បាយគឺគ្មានន័យទាល់តែសោះ។ សូមឲ្យដង្ហើមជីវិតនៃព្រះអម្ចាស់យេស៊ូវគ្រីស្ទបើកភ្នែកទាំងគូររបស់អ្នកដោយព្រះវិញ្ញាណបរិសុទ្ធរបស់ទ្រង់។

ខទី៥ចែងថាៈ «បើមិនបានកើតអំពីទឹក ហើយអំពីព្រះវិញ្ញាណ នោះគ្មានអ្នកណាអាចនឹងចូលទៅក្នុងនគរព្រះបានទេ»។ នេះគឺជាប្រធានបទដ៏សំខាន់មួយៈ ការចូលទៅក្នុងនគរស្ថានសួគ៌! មិនមែនដោយសារអំពើល្អ កំរិតវប្បធម៌ សេចក្តីថ្លៃថ្នូរ តួនាទីនៅក្នុងព្រះវិហារ ដែលធ្វើអោយមនុស្សម្នាក់មានលក្ខណៈសម្បត្តិសំរាប់ស្ថានសួគ៌ទេ តែតាមរយៈការកើតជាថ្មីដោយសារដង្ហើមជីវិតនៃព្រះយេស៊ូវគ្រីស្ទវិញ។

ដំណាក់ការនៃកំណើតថ្មីគឺពឹងផ្អែកទាំងស្រុងលើកិច្ចការនៃព្រះវិញ្ញាណរបស់ព្រះ។ ខទី៨ប្រាប់អំពីអាថ៌កំបាំងរបស់ការងារនៃព្រះវិញ្ញាណលើព្រលឹងវិញ្ញាណរបស់អ្នកមិនទាន់បានសង្គ្រោះ។ ដូចជាខ្យល់បក់ទៅឯណាក៏ចេះតែបាន ពេលខ្លះបក់ខ្លាំង ពេលខ្លះទៀតបក់រំភើយ ព្រះក៏យាងមកយើងតាមតែទ្រង់សព្វព្រះទ័យយ៉ាងដូច្នោះដែរ។ អ្នកខ្លះបានកើតជាថ្មីក្នុងបទពិសោធន៍ដ៏ភ័យរន្ធត់ ដូចជាសូលនៅលើដងផ្លូវទៅក្រុងដាម៉ាស ខ្លះទៀតបានកើតជាថ្មីដូចជាករណីលោកធីម៉ូថេតាមរយៈការអប់ក្នុងសេចក្តីជំនឿស្មោះត្រង់ដោយជីដូនឈ្មោះឡូអ៊ីសនិងម្តាយឈ្មោះអើនីស។ ដោយសារកំណើតថ្មី យើងរស់ឡើងភ្លាម ជើងក៏ប្រញាប់ប្រញាល់ចូលទៅក្នុងស្ថានសួគ៌។

ទឹកដែលបានសម្តែងប្រាប់នៅអត្ថបទព្រះគម្ពីរនេះគឺមិនមែនជាការកើតជាថ្មីដោយពិធីបុណ្យជ្រមុជទឹកដូចបានបង្រៀនដោយព្រះវិហាររ៉ូម៉ាំងកាតូលិកទេ។ ទឹកនៅខនេះគឺប្រាកដជាទឹកនៃព្រះវិញ្ញាណបរិសុទ្ធ ដោយសារពាក្យក្រិក **ខាយ** (*kai*) ស្មើនឹងពាក្យ **ហើយ** (*and*) ក៏អាចបកប្រែថា**សូម្បី** (*even*) ផងដែរ។ ពិតណាស់ មិនមែនជាទឹកធម្មតាដែលប្រើក្នុងពិធីព្រះអំណោយទានបរិសុទ្ធឬពិធីបុណ្យពិសិដ្ឋទេ តែជាទឹកខាងព្រលឹងវិញ្ញាណ ដូចចែងក្នុង ១កូរិនថូស ១២:១៣ «យើងបានទទួលបុណ្យជ្រមុជចូលក្នុងរូបកាយតែ១ ដោយសារព្រះវិញ្ញាណតែ១...»។ បើគ្មានបុណ្យជ្រមុជខាងក្នុងនៃព្រះវិញ្ញាណទេ ទឹកបុណ្យជ្រមុជរបស់អ្នកនឹងមិនធ្វើឲ្យអ្នកមានលក្ខណៈសម្បត្តិសម្រាប់ស្ថានសួគ៌ឡើយ!

**ការពិចារណាៈ** ធ្វើដូចម្តេចទើបអាចយល់សេចក្តីខាងឯព្រះវិញ្ញាណ?
**ការអធិស្ឋានៈ** សូមបំភ្លឺភ្នែកទូលបង្គំ ឲ្យបានឃើញសេចក្តីអស្ចារ្យនៅក្នុងក្រិត្យវិន័យរបស់ទ្រង់។

*«ដើម្បីឲ្យអ្នកណាដែលជឿដល់កូនមនុស្សនោះមិនត្រូវវិនាសឡើយ គឺឲ្យមានជីវិតអស់កល្បជានិច្ចវិញ»។*

# ដង្ហើមនៃជីវិតប្រទានដល់យើងដោយព្រះអង្គ ដែលបានសុគតជំនួសយើង

នៅក្នុងមេរៀនមុនយើងបានពិភាក្សាអំពីតួនាទីនៃព្រះវិញ្ញាណបរិសុទ្ធក្នុងការបណ្តាលឲ្យយើងបានកើតជាថ្មី ជាកំណើតថ្មីខាងព្រលឹងវិញ្ញាណ។ ព្រះវិញ្ញាណបរិសុទ្ធទ្រង់គឺជា**ភ្នាក់ងារ**នៃការប្រោសលោះរបស់យើង។

នៅក្នុងបីខខ្លីៗនេះប្រាប់ពីការងារនៃព្រះរាជបុត្រា ជាកិច្ចការ**ដ៏សំខាន់**នៃសេចក្តីសង្គ្រោះរបស់យើង។ ព្រះវិញ្ញាណមិនបានធ្វើឲ្យយើងកើតជាថ្មីទេ ទ្រង់គ្រាន់តែដឹកនាំយើងទៅរកឈើឆ្កាងប៉ុណ្ណោះ។ ព្រះអង្គនាំយើងទៅរកឈើឆ្កាងនៃការសុគតជំនួសរបស់ព្រះយេស៊ូវដើម្បីសងថ្លៃលោះបាបយើង ជាសេចក្តីវេទនានៅក្នុងឋាននរក។

អ្នកផ្តោតធ្ងន់លើសេចក្តីបង្រៀននេះគឺគ្មានអ្នកណាក្រៅពីព្រះអង្គដែលរងទុក្ខទោសឡើយ។ ដូច្នេះព្រះយេស៊ូវបានបង្វែរលោកនីកូដេមឲ្យសម្លឹងមើលទៅរូបពស់លង្ហិនដែលព្រះបង្គាប់លោកម៉ូសេធ្វើឡើងសម្រាប់ឲ្យអ្នកណាសម្លឹងមើលរូបនោះដោយក្តីជំនឿនឹងរស់មានជីវិត។ បុគ្គលដែលសម្លឹង ទៅរូបនោះនឹងជាសះស្បាយពីពស់ចឹកនិងរួចពីស្លាប់។

មនុស្សម្នាក់នឹងមិនអាចទទួលដង្ហើមជីវិតបានទេ លុះត្រាតែគាត់ចូលមកដោយការបន្ទាបខ្លួននិងការលន់តួបាបដូចជាចោរទូលសូមសេចក្តីមេត្តាករុណាពីព្រះអង្គដែលរៀបនឹងសុគតនៅលើឈើឆ្កាងដូច្នេះដែរ។

ដូច្នេះ ពេលសាវ័កប៉ុលនាំដំណឹងល្អមកក្រុងកូរិន គាត់មិនបានសង្កត់ធ្ងន់ទៅលើការនិយាយភាសាដទៃ ឬការប្រោសជំងឺដល់មនុស្សឬ «កម្មវិធីប្រជុំធ្វើការអស្ចារ្យ» ឬក៏ដោយការព្យាយាមរបស់មនុស្សក្នុងការរៀបចំកម្មវិធីប្រជុំផ្សព្វផ្សាយដំណឹងល្អដល់មនុស្សដ៏ច្រើនសន្ធឹកសន្ធាប់នោះដែរ។ លោកប៉ុលមានប្រសាសន៍ប្រាប់ដល់ពួកជំនុំក្រុងកូរិន និងយើងសព្វថ្ងៃថា៖ «រីឯខ្ញុំ បងប្អូនអើយ កាលខ្ញុំបានមកឯអ្នករាល់គ្នា នោះមិនបានមកដោយប្រើពាក្យវោហារ ឬប្រាជ្ញាឧត្តម ដើម្បីនឹងប្រាប់ សេចក្តីបន្ទាល់ពីព្រះដល់អ្នករាល់គ្នាទេ។ ដ្បិតខ្ញុំបានផ្តាច់ចិត្តថា នៅក្នុងពួកអ្នករាល់គ្នា នោះខ្ញុំមិនព្រម ស្គាល់រឿងអ្វីទៀតក្រៅពីព្រះយេស៊ូវគ្រីស្ទទេ ហើយគឺដែលទ្រង់ត្រូវឆ្កាងផង» (១កូរិនថូស ២:១-២)។

ចំណុចនេះគឺជាការល្បងលពីគ្រូផ្សព្វផ្សាយដំណឹងល្អ។ ប្រសិនបើគាត់គ្រាន់តែអធិប្បាយពីអភិសមាចារ (សីលធម៌) ដោយទាមទារឲ្យអ្នកធ្វើកិច្ចការនេះ ឬកិច្ចការនោះ គាត់គ្រាន់តែបន្ថែមបន្ទុកលើអ្នកទៀតប៉ុណ្ណោះ។ បើគាត់អធិប្បាយពីព្រះវិញ្ញាណបរិសុទ្ធ តែមិនលើកដំកើងព្រះគ្រីស្ទ ព្រះវិញ្ញាណនឹងមិនមានបន្ទូលថាអាម៉ែននៅក្នុងចិត្តអ្នកឡើយ។ នៅពេលអធិប្បាយពីព្រះគ្រីស្ទនិងការសុគតហើយនិងការរស់ពីស្លាប់ឡើងវិញរបស់ទ្រង់ ផលផ្លែនឹងកើតមានឡើង!

*ក្នុងឈើឆ្កាង ក្នុងឈើឆ្កាង*
*ជាក្តីរុងរឿងខ្ញុំ អស់ កល្ប*
*បាបខ្ញុំក៏បានបាត់បង់ទៅ*
*ដោយលោហិតព្រះយេស៊ូវ*។ (*និពន្ធដោយ ចន ស៊ុង*)។

**ការពិចារណា៖** តើខ្ញុំត្រូវរំដួតពីអ្នកណា? ពីខ្លួនខ្ញុំ? ពីការល្អខ្ញុំបានធ្វើ? ពីព្រះយេស៊ូវគ្រីស្ទ? តើហេតុអ្វី?

**ការអធិស្ឋាន៖** «ចូរសរសើរព្រះនាមវិសេស ចូរសរសើរព្រះនាមវិសេស ឈាមទ្រង់បានលាងខ្ញុំឲ្យឥតសៅហ្មង សរសើរព្រះនាមទ្រង់» (ចម្រៀងទំនុកដំកើង ១៣១)

ថ្ងៃទី ១៨ កក្កដា
យ៉ូហាន ៣:១៧-២១

*«ដើម្បីឲ្យអ្នកណាដែលជឿដល់កូនមនុស្សនោះមិនត្រូវវិនាសឡើយ គឺឲ្យមានជីវិតអស់កល្បជានិច្ចវិញ»។*

## ដំណឹងល្អគឺជាពន្លឺនៃជីវិត

ខទី១៧ សម្ដែងប្រាប់ពីសេចក្ដីសង្គ្រោះដែលព្រះប្រទានដល់លោកីយមានបាប តាមរយៈព្រះគ្រីស្ទជាព្រះរាជបុត្រានៃទ្រង់។ ព្រះយេស៊ូវយាងមកសង្គ្រោះ មិនមែនមកផ្ដន្ទាទោសទេ គឺប្រៀបដូចជាតួនាទីរបស់វិជ្ជបណ្ឌិតដែលត្រូវព្យាបាលនិងមិនស្ដីបន្ទោសដូច្នោះដែរ។ គ្រូពេទ្យល្អនឹងមិនបន្ទោសអ្នកជម្ងឺព្រោះតែធ្លាក់ខ្លួនឈឺ ចំណែកឯអ្នកជម្ងឺនឹងអាចជាសះស្បើយបានលុះត្រាតែទុកចិត្តទាំងស្រុងលើគ្រូពេទ្យដែរ។ បើអ្នកជម្ងឺចាប់ផ្ដើមសួរពីលក្ខណៈសម្បត្តិ និងចំនួនឆ្នាំនៃ បទពិសោធន៍វិជ្ជាជីវៈរបស់គ្រូពេទ្យ នោះប្រាកដជាគ្មានគ្រូពេទ្យណាព្យាបាលគាត់ឡើយ។ វាគឺជាជំនឿរបស់មនុស្សជាតិ ដែលទទួលបានសេចក្ដីសង្គ្រោះ មិនមែនជាការមិនជឿនិងការជជែករែកញែកទេ។

តើហេតុអ្វីបានជាមនុស្សមួយចំនួនធំក្នុងពិភពលោកបដិសេធព្រះគ្រីស្ទដោយចិត្តមិនជំនឿ? ពីព្រោះភាពងងឹត និងភាពសប្បាយភ្លើតភ្លើននៃអំពើបាប ហើយនិងកម្រៃទុច្ចរិតរបស់សេចក្ដីទាំងនោះ។ ស្បែងងងឹតមិនទទួលពន្លឺទេ។ នៅពេលណាពន្លឺចាំងរស្មីចូលមកស្បែងងងឹតនឹងរលាយបាត់អស់។ អ្នកស្រឡាញ់សេចក្ដីងងឹតគឺរឹងមានះចង់រស់នៅក្នុងទីងងឹត។ ពួកគេនឹងមិនចូលមកក្នុងទីពន្លឺទេ។ ដូចជា សត្វទីទុយនិងសត្វស្វាំងពេលរាត្រីដែលចាប់សត្វឯទៀតជារំពាដែរ។ សត្វទាំងនេះគឺជាពពួកបក្សីរាត្រី។ ពួកវាមិនអាចនៅជាមួយសត្វពេលថ្ងៃបានទេ។ ពួកវាពួនលាក់ខ្លួនដើម្បីប្រមាញ់តែក្នុងពេលយប់ប៉ុណ្ណោះ។

ប៉ុន្តែបក្សីពេលថ្ងៃទទួលពន្លឺព្រះអាទិត្យយ៉ាងរីករាយដោយសំលេងចេចចាយនាព្រឹកព្រលឹម។ តើអ្នកគឺជាបក្សីពេលរាត្រីឬជាបក្សីពេលថ្ងៃ? បើអ្នកស្រឡាញ់ការអាក្រក់អ្នកនឹងរស់នៅក្នុងទីងងឹត។ បើអ្នកស្រឡាញ់សេចក្ដីពិត អ្នកនឹងចូលមកក្នុងទីពន្លឺ។ អ្នកនឹងឯព្រះយេស៊ូវគ្រីស្ទដ៏ជាពន្លឺ។ អ្នកនឹងមកព្រះវិហារថ្វាយបង្គំទ្រង់ដោយក្ដីអំណររីករាយ។

តើនៅផ្នែកណាទៀតនៃដំណឹងល្អដែលព្រះគ្រីស្ទថ្លែងប្រាប់ថាទ្រង់ថាជាពន្លឺ?

**ការពិចារណា៖** ហេតុអ្វី «មនុស្សលោកចូលចិត្តនឹងសេចក្ដីងងឹតជាងពន្លឺ..?» (យ៉ូហាន ៣:១៩)។
**ការអធិស្ឋាន៖** ឱអម្ចាស់អើយ សូមឲ្យខ្ញុំបន្តដើរក្នុងពន្លឺ ដើរក្នុងពន្លឺនៃព្រះយេស៊ូវផង។

*«ដ្បិតព្រះគ្រីស្ទមិនបានចាត់ខ្ញុំឲ្យមកធ្វើបុណ្យជ្រមុជទឹកទេ គឺឲ្យមកផ្សាយដំណឹងល្អប៉ុណ្ណោះ...»។*

## តើទឹកនៃពិធីបុណ្យជ្រមុជចែកបក្សពួក

ខទី ២៥ ចែងថាទឹកនៃបុណ្យជ្រមុជបែងចែកមនុស្ស! នេះគឺជាជម្លោះអំពីសពីបុណ្យជ្រមុជជាពិធីបុណ្យសម្អាតជាបរិសុទ្ធរវាងសិស្សរបស់យ៉ូហាននិងពួកសាសន៍យូដា។ កាល់វីន លោកមានប្រសាសន៍ថាពួកសិស្សទាំងនេះគឺអវិជ្ជា និងគ្មានការពិចារណាក្នុងការពិភាក្សានូវប្រធានបទដែលហួសកម្រិតយល់ដឹងរបស់ខ្លួន ហើយអាក្រក់ជាងនោះទៀតគឺអសមត្ថភាពបញ្ជាក់វិធីប្រើស្របតាមក្រិត្យវិន័យនៃពិធីបុណ្យជ្រមុជ គឺជាមហិច្ឆិតានៃអំពើបាបដោយហេតុតែពួកគេបានបណ្តាលឲ្យបុព្វហេតុរបស់គ្រូខ្លួនទាស់នឹងព្រះគ្រីស្ទ។ ដោយសារមានវិវាទអំពីបុណ្យជ្រមុជនាសម័យព្រះយេស៊ូវ និងសម័យសាវ័កប៉ូល (១ កូរិនថូស ១:១១-១៧) ហេតុនេះហើយទើបមានកំណើនជម្លោះពីបញ្ហាដដែលនេះនាសម័យបច្ចុប្បន្នរបស់យើង។

បើសិនវាជាបញ្ហាបែបបទ លោកកាល់វីនមានប្រសាសន៍ថា ទោះបីវាជាការជ្រមុជលិចទៅក្នុងទឹក «យើងមិនចាំបាច់បារម្ភខ្លាំងពេកអំពីពិធីខាងក្រៅទេដរាបណាវាស្របនឹងសេចក្តីពិតខាងឯព្រលឹងវិញ្ញាណនិងការតែងតាំងនិងច្បាប់របស់ព្រះអម្ចាស់»។ ពោល សារៈសំខាន់ពីខាងក្នុងបែបព្រលឹងវិញ្ញាណ នៃបុណ្យជ្រមុជគឺសំខាន់ជាបែបបទនៃការរៀបចំពិធីខាងក្រៅ។

នៅក្នុងបណ្តាពួកជំនុំ ការជ្រមុជលិចក្នុងទឹក ការចាក់ទឹក ការប្រោសទឹកនិងការលាងដោយទឹកគឺជាវិធីអនុវត្តន៍ខុសៗគ្នា។ វិធីណាណាមួយត្រឹមត្រូវមិនផ្តល់នូវក្តីកង្វល់ដល់យើងឡើយ។ យើងទទួលទាំងអស់ ពីព្រោះពិធីខាងក្រៅគឺជាបញ្ហាសំខាន់បន្ទាប់បន្សំប៉ុណ្ណោះ។ យើងយកតម្រាប់តាមសាវ័កប៉ុលក្នុងសេចក្តី សន្និដ្ឋាននៃការជជែកពិភាក្សារបស់គាត់ក្នុង ១ កូរិនថូស ១:១១-១៧។ នៅក្នុងខទី១៧ គាត់ថ្លែងថា៖ «ដ្បិតព្រះគ្រីស្ទមិនបានចាត់ខ្ញុំឲ្យមកធ្វើបុណ្យជ្រមុជទឹកទេ គឺឲ្យមកផ្សាយដំណឹងល្អប៉ុណ្ណោះ...»។

ដើម្បីពង្រីកគណៈនិកាយនៃការអនុវត្តន៍បុណ្យជ្រមុជទឹកហើយក្លាយជាឧបសគ្គដល់ការចម្រើនលូតលាស់នៃដំណឹងល្អនោះនឹងមិនអាចទទួលយកបានឡើយ។ ដូចជានៅក្នុងស្រុកកូរិន មានអ្នកខ្លះថ្លែងថាពួកគេជាសិស្សរបស់ប៉ុល ខ្លះជារបស់អ័ប៉ុឡូស ខ្លះជារបស់កេផាស អ្នកខ្លះទៀតរបស់ព្រះគ្រីស្ទ (ប្រើព្រះនាមទ្រង់)។ យើងសូមជម្រាបជាថ្មីម្តងទៀតថា ក្រុមសាសនាបក្សពួកនិយមនេះគឺជាអំពើបាប។

**ការពិចារណា៖** ខ្ញុំបានទទួលបុណ្យជ្រមុជដោយក្តីជំនឿស្របតាមការតែងតាំងនៃព្រះយេស៊ូវគ្រីស្ទ។
**ការអធិស្ឋាន៖** «គ្រាន់តែជឿតាម គ្រាន់តែជឿតាម ចូរអ្នកជឿតឡូវ ទ្រង់នឹងអត់ទោស ទ្រង់នឹងអត់ទោស បើជឿព្រះយេស៊ូវ» (ចម្រៀងទំនុកដំកើង១៩៩)។

*«...ដើម្បីឲ្យទ្រង់បានជាប្រធានក្នុងគ្រប់ទាំងអស់»។*

## «បើព្រះគ្រីស្ទទីមួយ យើងត្រូវតែទីចុងក្រោយ»

កាលៈទេសៈដែលយ៉ូហាន-បាទីស្ទបានប្រកាសនូវសេចក្តីថ្លែងការណ៍ដ៏ល្បីល្បាញ «ត្រូវឲ្យព្រះអង្គនោះបានចំរើនឡើង ហើយខ្ញុំត្រូវថយវិញចុះ» (ខ ៣០)។ ដែលបានបំលែងជាចំណងជើងខាងលើ គឺដោយសារ សិស្សរបស់យ៉ូហានជាធម្មតានៅជិតស្និទ្ធនឹងគាត់ជាងជិតស្និទ្ធនឹងព្រះគ្រីស្ទ។ បើមិនសម្លឹងទៅរកព្រះគ្រីស្ទជាកូននៃព្រះទេ ពួកគេត្រូវតែទទួលការកែតម្រូវ។ បក្សពួកនិយមគឺជាអំពើបាបដ៏ពោរពេញ។

លោកយ៉ូហានគឺគ្រាន់តែជាហោរា ជាអ្នកតំណាងនៃព្រះជាម្ចាស់ ដែលព័ន្ធកិច្ចរបស់គាត់គឺធ្វើជាអ្នករៀបចំផ្លូវនៃដំណើរយាងមករបស់ព្រះសង្គ្រោះតែប៉ុណ្ណោះ។ នៅក្នុងតួនាទីនេះ ជាចាំបាច់ទើបគាត់ប្រកាសពីបុណ្យជ្រមុជនៃការប្រែចិត្ត តែទំនាក់ទំនងដោយលែកពីការប្រែចិត្តនេះគឺជាការមានជំនឿលើព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ ពួកសិស្សគាត់បានប្រែចិត្តពីបាបហើយបានទទួលបុណ្យជ្រមុជធ្វើដោយយ៉ូហាន-បាទីស្ទ ជាគ្រូរបស់ពួកគេ។ ប៉ុន្តែពួកគេទទួលបានតែប៉ុណ្ណឹង។ ពួកគេបន្តប្រតិបត្តិតាមការបង្រៀនពីបុណ្យជ្រមុជរបស់យ៉ូហាន-បាទីស្ទ តែមិនបានសម្លឹងទៅរកព្រះយេស៊ូវគ្រីស្ទជាអ្នកធ្វើបុណ្យជ្រមុជដោយភ្លើងនោះឡើយ។ ដូច្នេះជាចាំបាច់លោកត្រូវតែបញ្ជាក់ដល់សិស្សរបស់គាត់ថាខ្លួនគាត់មិនមែនជាព្រះគ្រីស្ទ តែជាអ្នករៀបចំផ្លូវថ្វាយដល់ទ្រង់វិញ។ គាត់មិនមែនជាកូនកម្លោះ តែជាអ្នកកំដរ។ អ្នកកំដរគឺឈរអមកូនកម្លោះ។ ដូចនេះសិស្សរបស់គាត់ក៏ឈប់បន្តដើរតាមគាត់។ វត្តមានរបស់គាត់ចាប់ផ្តើមឃ្លាតចេញបន្តិចម្តងៗដូចជាអ្នកកំដរដែលបានបញ្ចប់ភារកិច្ចរបស់ខ្លួនដែរ ប្រយោជន៍ឲ្យគេឃើញមិត្តសម្លាញ់ជាកូនកម្លោះដ៏ជាព្រះគ្រីស្ទពីសិរីរុងរឿងដ៏ត្រចះត្រចង់របស់ទ្រង់។ បាវបម្រើដ៏ស្មោះត្រង់របស់ព្រះយេស៊ូវគ្រីស្ទនឹងបន្ទាបខ្លួននាទៀបព្រះបាទនៃចៅហ្វាយរបស់ខ្លួនដើម្បីឲ្យទ្រង់ទទួលបាននូវភាពឧត្តុងឧត្តម។

លោកយ៉ូហាន-បាទីស្ទជាគំរូដ៏ល្អដល់អ្នកបម្រើព្រះគ្រប់រូប។ គាត់មិនខ្វល់នូវអ្វីមនុស្សនិយាយពីរូបគាត់ទេដរាបណាព្រះគ្រីស្ទបានដំកើងឡើង។ ដូចជាសត្វលាដែលដឹកព្រះគ្រីស្ទចូលទៅទីក្រុងយេរូសាឡឹមដែរ គាត់មិនរវល់មើលឆ្វេងឬស្តាំទេ ដរាបណាគាត់អាចយកម្ចាស់របស់គាត់ចូលទៅទីក្រុងនោះ។

មូលហេតុដែលព្រះជាម្ចាស់មិនអាចប្រទានពរដល់ពន្ធ័កិច្ចគ្រីស្ទបរិស័ទមួយចំនួនគឺព្រោះតែពន្ធ័កិច្ចទាំងនោះតាំងខ្លួនគេទីមួយនិងព្រះគ្រីស្ទជាចុងក្រោយ។ តើអ្នកគិតដូចម្តេចចំពោះសត្វលាព្យាយាមជិះចៅហ្វាយខ្លួនវិញ? ប៉ុន្តែសូមស្តាប់ពាក្យរបស់សាវ័កប៉ុលៈ «ទ្រង់ជាសិរសាររបស់រូបកាយ គឺជាពួកជំនុំ ទ្រង់ជាដើម ក៏បានរស់ពីស្លាប់ឡើងវិញមុនគេបង្អស់ ដើម្បីឲ្យទ្រង់បានជាប្រធានក្នុងគ្រប់ទាំងអស់» (កូឡូស ១:១៨)។ «បើព្រះគ្រីស្ទទីមួយ យើងត្រូវតែទីចុងក្រោយ!»។

**ការពិចារណា៖** គ្រីស្ទបរិស័ទត្រូវទុក ព្រះយេស៊ូវទី១ អ្នកដទៃទី២ ហើយខ្លួនអ្នកចុងក្រោយ (J.O.Y)។
**ការអធិស្ឋាន៖** ឱព្រះអម្ចាស់អើយ សូមឲ្យខ្ញុំបន្ទាបខ្លួននៅចំពោះទ្រង់និងមនុស្សដទៃទៀតផង។

## ព្រះគ្រីស្ទគឺខ្ពង់ខ្ពស់លើទាំងអស់ព្រោះទ្រង់យាងមកពីស្ថានសួគ៌

នៅផ្នែកនេះហាក់ដូចជាទីបន្ទាល់របស់អ្នកនិពន្ធដល់ព្រះគ្រីស្ទក្នុងអត្ថន័យគាំទ្រចំពោះការចាត់ខ្លួនគាត់ជាយ៉ូហាន-បាទីស្ទទៅជាមោឃះ។

តើហេតុអ្វីបានជាព្រះគ្រីស្ទត្រូវតែបានលើកដំកើងខ្ពស់លើទាំងអស់? តើហេតុអ្វីបានជាសិស្សលោក យ៉ូហាន-បាទីស្ទមកតាមព្រះគ្រីស្ទ ដែលនាពេលនោះទ្រង់បានបង្ហាញលវត្តមានជាសាធារណៈ? ពីព្រោះទ្រង់មកពីស្ថានលើ។ ព្រះជាម្ចាស់បានបញ្ជូនទ្រង់មក។ ទ្រង់គឺជាព្រះរាជបុត្រាតែមួយរបស់ព្រះវរបិតា។ ព្រះអង្គគឺជាព្រះជាបុត្រស្ងួន ភ្ងាដែលព្រះវរបិតាបានប្រទាននូវអំណាចលើគ្រប់ទាំងអស់។ ទ្រង់ព្រះសង្គ្រោះដែលបានជ្រើស តាំងប្រយោជន៍ ឲ្យយើងបានជឿដើម្បីបានសង្គ្រោះ។ ផ្ទុយទៅវិញ បើយើងបដិសេធទ្រង់ យើងបានត្រឹមតែបង្កើននូវក្រោធរបស់ជារៀងរហូតប៉ុណ្ណោះ!

ពិតមែនហើយ ព្រះយេស៊ូវគឺជាពាក្យបន្ទូលនៃព្រះ ជាអ្នកនាំសាររបស់ទ្រង់។ បណ្តាពួកហោរាបាន ព្យាករណ៍នូវអ្វីដែលព្រះវិញ្ញាណនៃព្រះយេស៊ូវបានបង្គាប់ឲ្យពួកគេប្រកាសប្រាប់ តែព្រះយេស៊ូវទ្រង់ មានបន្ទូលដោយព្រះអង្គផ្ទាល់។ ទោះបានប្រទានឲ្យពួកសាវ័កមានអំណាច តែអំណាចនោះគឺមកពីព្រះគ្រីស្ទ។ ព្រះគ្រីស្ទ ជាព្រះរាជបុត្រា បានទទួលអំណាចដែលគ្មានដែនកំណត់។ ទ្រង់មានគ្រប់ទាំងអស់ នូវ កិច្ចការនៃព្រះវិញ្ញាណនៅក្នុងអង្គទ្រង់។ នេះជាមូលហេតុមួយផ្សេងទៀតពីមូលហេតុព្រះអង្គគឺខ្ពស់លើទាំងអស់។

ដូច្នេះ យើងឃើញថាពួកសិស្សកំពុងឈរក្នុងក្តីអាម៉ាស់និងគ្មានទីពឹងនៅចំពោះព្រះអម្ចាស់នៅពេលឪពុកក្មេងប្រុសមានជម្ងឺឆ្កួតជ្រូកទូលទ្រង់ថា «ទូលបង្គំបាននាំវាមកឯពួកសិស្សទ្រង់ដែរ តែគេមើលមិនជាសោះ» (ម៉ាថាយ ១៧:១៦)។ ព្រះគ្រីស្ទដែលទ្រង់ខ្ពង់ខ្ពស់លើទាំងអស់ក៏បានសង្គ្រោះស្ថានភាពអាក្រក់នោះ។ ការនោះគឺសម្រាប់ថ្វាយសិរីរុងរឿងដល់ព្រះក៏ជាការរំឭកដល់អ្នកដែលហាក់ដូចជាជោគជ័យក្នុងពន្ធ័កិច្ចឲ្យមានការខ្មះអៀននៅពេលគេមិនផ្តល់ការថ្វាយបង្គំដែលសាកសមសម្រាប់តែព្រះអម្ចាស់របស់ខ្លួន។

សូម្បីលោកយ៉ូហាន-បាទីស្ទជាអ្នកលើកដំកើងព្រះគ្រីស្ទនាពេលដ៏ជោគជ័យក្នុងពន្ធ័កិច្ចរបស់គាត់ ក៏បានសង្ស័យចំពោះព្រះអម្ចាស់របស់ខ្លួននាគ្រាជួបការល្បួងល្បងផងដែរ (សូមអាន ម៉ាថាយ ១១:២-៦, លូកា ៧:១៩-២៣)។ យ៉ូហានសង្ស័យព្រោះគាត់ជាមនុស្ស និងទោះរូបគាត់បានគេស្គាល់ថាជាហោរាដ៏ល្បីល្បាញ តែព្រះវិញ្ញាណប្រទានដល់គាត់គឺមានកម្រិតដែន។ សូម្បីលោកម៉ូសេជាអ្នកផ្តល់ក្រិត្យវិន័យក៏មិនអាចចូលទៅក្នុងដែនដីសន្យាដោយសារគាត់មិនបានប្រតិបត្តិតាមសេចក្តីដែលព្រះបានបង្គាប់ឲ្យគាត់ធ្វើក្នុងការយកទឹកចេញពីថ្មដាដែរ។ ព្រះគ្រីស្ទគឺជាអង្គតែមួយគត់ដែលគ្មានបាប ឥតមានអ្នកប្រៀបផ្ទឹមនឹងទ្រង់បាន ទ្រង់បរិសុទ្ធឥតខ្ចោះ ពីព្រោះទ្រង់មានព្រះវិញ្ញាណគង់ជាមួយទ្រង់ឥតមានកម្រិត។

តើភាពបរាជ័យរបស់អ្នកបម្រើដ៏ល្បីល្បាញនៃព្រះនាំឲ្យយើងបាក់ទឹកចិត្ត? ប៉ុលជាអ្នកបរិសុទ្ធមានប្រសាសន៍ថា៖ «រីឯការទាំងនោះបានកើតមកដល់គេទុកជាគំរូ ហើយបានកត់ទុកសម្រាប់ជាសេចក្តីទូន្មាន ប្រដៅដល់យើងរាល់គ្នាដែល យើងនៅគ្រាចុងបំផុតនៃអស់ទាំងកល្ប» (១ កូរិនថូស ១០:១១)។

ជាចុងក្រោយ សូមអាននូវពាក្យសាវ័កចំពោះអ្នកជឿសាសន៍ហេព្រើរក្នុងន័យប្រៀបធៀបរវាងព្រះរាជបុត្រានៃព្រះនិងលោកម៉ូសេជាបាវបម្រើ៖ «ហើយលោកម៉ូសេក៏ស្មោះត្រង់ នៅក្នុងដំណាក់នៃទ្រង់ទាំងមូលមែន ទុកដូចជាអ្នកបំរើសំរាប់ជា ទីបន្ទាល់ ពីការដែលត្រូវថ្លែងប្រាប់មកតាមក្រោយ» (ហេព្រើរ ៣:៥)។

**ការពិចារណា៖** «ហើយឲ្យគ្រប់ទាំងអណ្តាតបានថ្លែងប្រាប់ថា ព្រះយេស៊ូវគ្រីស្ទទ្រង់ជាព្រះអម្ចាស់ សម្រាប់ជាសិរីល្អដល់ព្រះដ៏ជាព្រះវរបិតា» (ភីលីព ២:១១)។

**ការអធិស្ឋាន៖** «រីឯស្តេចនៃអស់ទាំងកល្ប ដែលទ្រង់មិនចេះសុគតហើយមើលទ្រង់មិនឃើញ គឺជាព្រះតែ១ព្រះអង្គនោះសូមឲ្យទ្រង់បានល្បីព្រះនាម និងសិរីល្អអស់កល្បជានិច្ចរៀងរាបតទៅ អាម៉ែន» (១ ធីម៉ូថេ ២:១៧)។

## ជំពូកទី ៤

### ព្រះយេស៊ូវគ្រីស្ទជាទឹកនៃជីវិតសម្រាប់នាងដែលមិនស្កប់ចិត្តព្រោះតែព្រាននារីទាំងប្រាំនាក់

ដូចក្នុងយ៉ូហានជំពូក៣ ដែរ ជំពូកនេះមានពីរផ្នែក៖ ព្រឹត្តិការណ៍អំពីស្ត្រីសាសន៍សាម៉ារី បន្ទាប់បកអំពីការប្រោសជម្ងឺកូនប្រុសរបស់នាម៉ឺន។ ដើម្បីទុកជាការពន្យល់លក្ខណៈបែបសង្ខេប យើងបានថ្វាយនាមដល់ព្រះយេស៊ូវថាជាទឹកនៃជីវិត។

តើស្រុកសាម៉ារីនៅទីណា? នៅលើផែនទីរបស់អ្នកនឹងឃើញហើយវានៅចន្លោះកណ្តាលស្រុកណាសារ៉ែតនាភាគខាងជើងនិងទីក្រុងយេរូសាឡឹមនាភាគខាងត្បូង។ សាម៉ារីក្លាយជារាជធានី នៃអាណាចក្រភាគខាងជើងរបស់ កុលសម្ព័ន្ធទាំងដប់ជាច្រើនទសវត្សបន្ទាប់ពីស្រុកនេះបានផ្តាច់ចេញពីស្រុកយូដាក្នុងភាគខាងត្បូង។ ស្រុកនេះត្រូវបានកសាងឡើងដោយរាជវង្សអ័ហាប់ជាស្តេចអាក្រក់។ នៅក្នុងសម័យព្រះអម្ចាស់នៃយើងឈ្មោះសាម៉ារីត្រូវបានគេសំដៅថាជាខេត្ត។

តើអ្នកណាជាអ្នកស្រុកសាម៉ារី? ពួកគេគឺជាសាសន៍កូនកាត់មួយរវាងបរទេសនិងអ្នកសាសន៍ក្នុងស្រុក។ សាសន៍សាម៉ារីប្រតិបត្តិជំនឿចម្រុះសាសនា ជាលទ្ធផល «គេបានកោតខ្លាចដល់ព្រះយេហូវ៉ា ហើយគោរពប្រតិបត្តិតាមព្រះរបស់ខ្លួនផង» (២ ពង្សាវតារក្សត្រ ១៧:៣៣)។ ដូចនេះទើបអ្នកស្រុក សាម៉ារីត្រូវបានសាសន៍យូដាសប្រមាថមើលងាយ។ ដើម្បីជាការបមាថព្រះអម្ចាស់នសយើង ពួកសាសន៍យូដាហៅទ្រង់ថាជាសាសន៍សាម៉ារី (យ៉ូហាន ៤:៤៨)។

ប៉ុន្តែព្រះអម្ចាស់នៃយើងមិនធីសអើងនឹងសាសន៍សាម៉ារីឡើយ។ ផ្ទុយទៅវិញ ទ្រង់បានស្តីបន្ទោសភាពពុតត្បុតរបស់អ្នកដឹកនាំសាសនាយូដាតាមរយៈរឿងប្រៀបប្រដូចអំពីសាសន៍សាម៉ារីចិត្តល្អ (លូកា ១០:៣០-៣៧)។ ទ្រង់បានធ្វើជាគំរូដល់យើងដោយការមានបន្ទូលយ៉ាងទន់សន្តោសដល់ស្ត្រីសាសន៍សាម៉ារី។ នេះធ្វើឲ្យស្ត្រីនោះភ្ញាក់ផ្អើលហើយបន្លឺសួរថា៖ «លោកជាសាសន៍យូដា ម្តេចឡើយក៏លោកសូមទឹកខ្ញុំពិសា ដែលខ្ញុំជាស្រីសាសន៍សាម៉ារីដូច្នេះ?»។

ការដែលស្ត្រីសាសន៍សាម៉ារីមានប្តីប្រាំនាក់បង្ហាញឲ្យឃើញនូវនិស្ស័យពោរពេញដោយបាបរបស់មនុស្ស។ ពិតណាស់ករណីរបស់នាងមិនមែនការរៀបការជាថ្មីបន្ទាប់មរណៈភាពរបស់ប្តីមុនៗទេ។ ស្ថិតនៅចំណុចនេះពាក្យអង់គ្លេស «*philander*» បើតាមវចនានុក្រមឆាមបឺរ (*Chamber Dictionary*) ផ្តល់អត្ថន័យថា «បង្កើតស្នេហា» «ចែចង»។

ព្រោះតែវាកន្សោមពាក្យនៃពាក្យភាសាក្រិកពីរគឺ «ស្រឡាញ់» និង «មនុស្ស» យើងប្រើវាក្នុងន័យសម្រាប់ការមានចំណង់ហួសហេតុពីសំណាក់ភេទទន់ខ្សោយធម្មតា។

សូមចងចាំថាស្ត្រីសាសន៍សាម៉ារីមានចំណេះដឹងជ្រាលជ្រៅផ្នែកទេវសាស្ត្រ តែក្នុងស្ថានភាពនៃអំពើបាបរបស់នាងចំណេះដឹងត្រឹមទ្រឹស្តីអំពីព្រះរបស់នាងមិនបានសង្គ្រោះឡើយ។ នាងត្រូវតែការកើតជាថ្មីគឺជាការផ្លាស់ប្រែពីជីវិត អសីលធម៌ដោយអំណាចនៃព្រះវិញ្ញាណបរិសុទ្ធ។ ការអធិប្បាយពាក្យបន្ទូល របស់ព្រះគ្រីស្ទនាំមកនូវការប្រែចិត្តបែបនោះនៅ ក្នុងចិត្តរបស់នាងនិងភាពជាព្រះរបស់ព្រះគ្រីស្ទជ្រួតជ្រាបក្នុងចិត្តនាងជាហេតុនាំបណ្តាលឲ្យនាងចាំបាច់ធ្វើបន្ទាល់ដល់ លោកីយអំពីជំនឿថ្មោងថ្មីដែលទើបតែរកឃើញ។

គ្រីស្ទបរិស័ទទើបបានកើតជាថ្មីគឺជាគ្រីស្ទបរិស័ទចង់ឲ្យគេដឹងហើយគាត់មានក្តីអំណរពីសេចក្តីសង្គ្រោះដ៏ពោរពេញហូរចេញទៅគ្រប់ទីកន្លែងដូចជាព្រះអម្ចាស់នៃយើងក្រោយមកថ្លែងថា៖ «នោះនឹងមានទន្លេទឹករស់ហូរចេញពីពោះខ្លួនមក» (យ៉ូហាន ៧:៣៨)។ បើព្រះយេស៊ូវជាទឹកនៃជីវិតដែលហូរចូលទៅក្នុងជីវិតរបស់អ្នក នោះក៏នឹងត្រូវហូរចេញដែរ។ តើអ្នកមានបទពិសោធន៍នៃទឹកហូរចូលនិងទឹកហូរចេញនេះដែរទេ?

**ការពិចារណា៖** ខ្ញុំចូលចិត្តនឹងថ្លែងប្រាប់រឿង ពីព្រះយេស៊ូវស្រឡាញ់ស្មោះ នៅស្ថានសួគ៌នឹងថ្លែងប្រាប់រឿង ពីព្រះអង្គមេត្តាប្រោស។ (ចម្រៀងទំនុកដំកើង ១៨២)។

**ការអធិស្ឋាន៖** ព្រះអង្គអើយ សូមឲ្យខ្ញុំមានចំណេះដឹងពីទ្រង់ហើយនិងការស្គាល់ទ្រង់ជាព្រះសង្គ្រោះផង។

## ទឹកដែលបំបាត់ភាពស្រេកឃ្លានរបស់ព្រលឹងមនុស្សគ្រប់រូប

មានអណ្តូងពីបូរាណនៅជិតក្រុងស៊ីខារដែលបន្សល់ទុករហូតដល់បច្ចុប្បន្ន។ ព្រះវិហារអូតូដក្សជនជាតិក្រេក (Greek Orthodox Church) ត្រូវបានគេសាងសង់នៅលើអណ្តូងទឹកនោះ ជាហេតុនាំឲ្យព្រះវិហារនេះក្លាយជាតំបន់ទាក់ទាញអ្នកទេសចរណ៍។ វាគឺជាអណ្តូងទឹកដ៏ជ្រៅមួយដែលមានបន្ទះគំរបថ្មគ្របពីលើ។

គ្រានោះ វាគឺ «វេលាម៉ោងទីប្រាំមួយ (ប្រហែលជាថ្ងៃត្រង់)» នៅពេលព្រះអម្ចាស់នៃយើងគង់នៅលើមាត់អណ្តូងនោះ ពីព្រោះទ្រង់ «អស់កំឡាំង» ពីការធ្វើដំណើរ។ ខណៈពេលពួកសិស្សបានចេញទៅទីក្រុងដើម្បីទិញអាហារសម្រាប់ទ្រង់ មានស្ត្រីសាសន៍សាម៉ារីម្នាក់មកដងទឹក។ តាមរយៈការប្រើភាសាដែលស្ត្រីនេះអាចយល់បាន ព្រះយេស៊ូវបានផ្តល់ទឹករស់ដល់នាងដែលរក្សាទឹកឲ្យផុសហូរចេញដូចជាចេញពីអណ្តូង ដូច្នេះនាងមិនចាំបាច់ស្រេកទឹកតទៅទៀត។ នេះពិតជាមេរៀនក្នុងការអធិប្បាយពាក្យបន្ទូល ក្នុងសិល្បៈថ្លែងសុន្ទរកថាដ៏មានប្រសិទ្ធិភាព!

នៅខណៈពេលស្ត្រីខ្វល់ខ្វាយតែតម្រូវការខាងផ្នែករូបកាយ ព្រះអម្ចាស់នៃយើងដឹកនាំនាងទៅរកតម្រូវការខាងផ្នែកព្រលឹងវិញ្ញាណម្តង។ ដូចនេះ សំណួរផ្តើមដឹកនាំអំពីស្វាមីរបស់នាងដែលបើកឲ្យឃើញនូវភាពមិនស្កប់ស្កល់ចិត្តនូវចំណង់តណ្ហារបស់នាង។ រាល់ការប៉ងប្រាថ្នាអាក្រក់ អាកប្បកិរិយាមិនត្រឹមត្រូវ ការបណ្តោយតាមសេចក្តីត្រេកត្រអាលនៃកាមតណ្ហា គឺសុទ្ធជារោគសញ្ញានៃអំពើបាប។ មានតែព្រះអង្គដែលមានទឹករស់ ជាទឹកនៃជីវិតទេ ដែលអាចបំបាត់នូវភាពត្រេកត្រអាលដែលមានឫសគល់ពីបាបបាន!

សូមសង្កេតមើលពីរបៀបព្រះយេស៊ូវដោះស្រាយដ៏ទន់ភ្លន់ចំពោះស្ត្រីភេទ ព្រោះព្រះអង្គយល់ពីគ្មានទីពឹងពំនាក់របស់នាង។ «ពីព្រោះព្រះទ្រង់មិនបានចាត់ព្រះរាជបុត្រាទ្រង់ ឲ្យមកក្នុងលោកីយ ដើម្បីនឹងជំនុំជំរះលោកីយនោះទេ គឺឲ្យលោកីយបានសង្គ្រោះដោយសារទ្រង់វិញ» (យ៉ូហាន ៣:១៧)។ ទ្រង់គឺពិតជាព្រះសង្គ្រោះដ៏ស្រទន់មែន។ ឱពិតជាគួរឲ្យរូបអ្នកនិងខ្ញុំ ជាអ្នកមានបាបហើយបានសង្គ្រោះដោយសារព្រះគុណ ត្រូវស្រឡាញ់ទ្រង់មែន។ ឱក៏សូមឲ្យស្ត្រីសាសន៍សាម៉ារីស្រឡាញ់ទ្រង់ដែរ ពីព្រោះនៅពេលនាងសារភាពបាបរបស់នាងចំពោះទ្រង់ នាងទទួលបាននូវការអត់ទោសបាប។ គ្មានអំពើបាបដ៏ធំណាមួយដែលព្រះគ្រីស្ទមិនអាចអត់ទោសបានឡើយ!

**ការពិចារណា៖** ខ្ញុំស្រឡាញ់ព្រះយេស៊ូវ ព្រោះទ្រង់ស្រឡាញ់ខ្ញុំជាមុន ក៏សងថ្លៃលោះបាបខ្ញុំ ហើយដោយសារព្រះគុណ។ (ចម្រៀងទំនុកដំកើង ១៤០)។

**ការអធិស្ឋាន៖** ឱសូមឲ្យខ្ញុំស្រឡាញ់ព្រះយេស៊ូវដ៏អស់ពីចិត្ត អស់ពីគំនិត និងអស់ពីកម្លាំងផងដែរ។

យ៉ូហាន ៤:២០-៣០

*«...នោះត្រូវតែថ្វាយបង្គំ ដោយវិញ្ញាណ នឹងសេចក្តីពិតដែរ»។*

## តើជាភ្នំមួយណា?

ដោយហេតុថាសាសន៍យូដានិងសាសន៍សាម៉ារីគ្មានទំនាក់ទំនងនឹងគ្នា ព្រោះតែភាពខុសគ្នានៃជាតិសាសន៍និងសាសនារបស់ពួកគេ ទើបគេមានទីកន្លែងថ្វាយបង្គំខុសគ្នាផងដែរ។ ចំពោះសាសន៍យូដា លោកម៉ូសេបានបង្គាប់ពួកគេឲ្យថ្វាយបង្គំតែនៅទីកន្លែងណាដែលព្រះជាម្ចាស់នឹងជ្រើសតាំងសម្រាប់ពួកគេប៉ុណ្ណោះ (ចោទិយកថា ១២:១៥, ជំពូក ១១)។ នៅពេលចូលមកក្នុងដែនដីសន្យាកន្លែងថ្វាយបង្គំគឺនៅក្រុងស៊ីឡូ (យ៉ូស្វេ ១៨:១)។ តាំងពីក្នុងរជ្ជកាលស្តេចដាវីឌ រហូតដល់សម័យព្រះយេស៊ូវ ទីក្រុងយេរូសាឡឹមត្រូវបានកំណត់ជាកន្លែងសម្រាប់ថ្វាយបង្គំ។

ទោះជាយ៉ាងណា សាសន៍សាម៉ារីអាចអួតអំពីបណ្តាភ្នំបរិសុទ្ធនានាជាកន្លែងបុព្វបុរសទាំងឡាយរបស់ខ្លួនធ្លាប់ថ្វាយបង្គំ។ ដោយសារមានតែភ្នំភ្លោះកេរ៉ាស៊ីមនិងភ្នំអ៊ីបាលដែលនឹងត្រូវលើកពិភាក្សាជាភ្នំដែលលោកយ៉ូស្វេបានដឹកនាំជនជាតិអ៊ីស្រាអែលឲ្យបានខិតខំប្រឹងប្រែងក្នុងការថ្វាយបង្គំ។ ទីនោះប្រាកដជាភ្នំកេរ៉ាស៊ីមដែលស្ត្រីចង់និយាយក្នុងនាមជាសាសន៍សាម៉ារី ជាកន្លែងថ្វាយបង្គំ។ សព្វថ្ងៃ ជនជាតិសាម៉ារីថ្វាយបង្គំនិងថ្វាយយញ្ញបូជានៅលើភ្នំនេះ។

សាសន៍យូដាថ្វាយបង្គំយ៉ាងត្រឹមត្រូវនៅក្រុងយេរូសាឡឹមជាកន្លែងជ្រើសតាំងកាលពីសម័យស្តេចដាវីឌដូចបានជម្រាបខាងលើ។ គាប់ជួននឹងដំណើរយាងមករបស់ព្រះមែស៊ី គឺជាព្រះយេស៊ូវ ពួកគេត្រូវបានដឹកនាំចូលទៅក្នុងសម័យសញ្ញាថ្មី។ គ្មានភាពរឹតបន្តឹងសម្រាប់ថ្វាយបង្គំតែមួយកន្លែងទៀតហើយ (ចោទិយកថា ១២:១៥)។ ពីព្រោះដំណឹងល្អត្រូវតែផ្សព្វផ្សាយប្រាប់ដល់ប្រជាជាតិទាំងអស់ គឺទូទាំងពិភពលោក តែម្តង។ ថ្វាយបង្គំតែមួយកន្លែងនឹងមិនអាចប្រព្រឹត្តទៅបានទេ្បីយ។

អ្វីដែលសំខាន់ជាងនោះគឺជា «វិញ្ញាណនិងសេចក្តីពិត» នៅក្នុងការថ្វាយបង្គំ។ វិធីនៃការថ្វាយ បង្គំតាមរយៈព្រះយេស៊ូវគ្រីស្ទគឺបើកចំហរដល់មនុស្សជាតិទាំងអស់។ តើភ្នំមួយណា? អ្នកមានចម្លើយដែរទេ?

គ្មានតម្រូវការបន្តថ្វាយបង្គំនៅទីក្រុងយេរូសាឡឹម ឬនៅភ្នំកេរ៉ាស៊ីមទៀតហើយ។ នៅទីណាដែលអ្នកបានរកឃើញព្រះសង្គ្រោះ ទីនោះហើយជាកន្លែងអ្នកចាប់ផ្តើមថ្វាយបង្គំព្រះវរបិតាក្នុងព្រះនាមនៃព្រះរាជបុត្រារបស់ទ្រង់។

**ការពិចារណា៖** តើអ្វីទៅជាការថ្វាយបង្គំព្រះជាម្ចាស់ដ៏ពិតប្រាកដ?

**ការអធិស្ឋាន៖** ព្រះអម្ចាស់អើយសូមឲ្យខ្ញុំមានដៃស្អាតនិងចិត្តបរិសុទ្ធនៅក្នុងព្រះវត្តមានទ្រង់។

ថ្ងៃទី ២៥ កក្កដា
យ៉ូហាន ៤:៣១-៣៨

*«ម្នាក់ព្រោះ ម្នាក់ទៀតច្រូត»។*

## បេសកកម្មនិងនិម្មិត

នៅពេលសាវ័កត្រឡប់មកវិញជាមួយនឹងអាហារដែលពួកគេបានទិញសម្រាប់ថ្វាយព្រះអង្គ ពួកគេបាននឹកប្លែកក្នុងចិត្តដោយសារពាក្យដែលទ្រង់មានបន្ទូលថា៖ «ខ្ញុំមានអាហារសំរាប់ទទួលទានហើយ គឺជាអាហារដែលអ្នករាល់គ្នាមិនស្គាល់»។ ពន្ធកិច្ចនៃព្រះមិនអាចនឹងរាស់ដោយខ្វាតរង្វាស់របស់សង្គមលក្ខណៈជាអាជីពបានឡើយ។ វាគឺជាបេសកកម្មដែលត្រូវសម្រេចជោគជ័យក្នុងទីរត់ប្រណាំងនឹងពេលវេលាដ៏វែងឆ្ងាយ។ នៅវេលាស្ថិតក្នុងដំណើរយកព្រះទ័យទុកដាក់នៃការធ្វើបន្ទាល់ពីអង្គទ្រង់ដល់ស្ត្រីសាសន៍សាម៉ារី ព្រះអម្ចាស់ភ្លេចពីភាពហត់ហេវ។ ការមានសេចក្តីអំណររីករាយពីការឃើញព្រលឹងវិញ្ញាណរបស់នាងបានសង្គ្រោះប្រែជាកម្លាំងរបស់ទ្រង់។ នោះជាអាថ៌កំបាំងដែលពេលនេះព្រះអង្គប្រទានដល់ពួកសិស្សទ្រង់។ ការបម្រើព្រះដោយសុឆន្ទៈគឺជាព្រះពរ។ ឯការបម្រើព្រះដោយគ្មានសុឆន្ទៈគឺជាបន្ទុកវិញ។ ចាប់ពីពេលនេះតទៅ ចូរឲ្យបន្ទុកនៃកិច្ចបម្រើរបស់អ្នកក្លាយជាព្រះពរវិញចុះ!

ព្រះអម្ចាស់មិនត្រឹមតែមានព្រះទ័យទុកដាក់ខ្ពស់អំពីបេសកកម្មទេ តែទ្រង់ក៏ភ្ញាក់ផ្អើលដោយសារវិសាលភាពនៃនិម្មិតរបស់ទ្រង់ផងដែរ។ ទ្រង់មាននិម្មិតទតវែងឆ្ងាយជាងពួកសិស្ស។ ពួកសាវ័កឃើញស្រូវនៅក្នុងស្រែថាទើបតែលាស់។ ព្រះអម្ចាស់ទតឃើញថាជាចម្រូតនៃព្រលឹងវិញ្ញាណត្រូវច្រូតភ្លាមៗ នោះគឺជាសាសន៍សាម៉ារីដែលគេប្រមាថមើលងាយ។ ចូរយើងសម្លឹងមើលឲ្យបានឆ្ងាយពីស្រែរបស់យើងទៅឯស្រែដែលព្រះទ្រង់នឹងបញ្ជូនយើងចេញទៅ។ សូមកុំឲ្យយើងកំណត់ដែនត្រឹមតែប្រយោជន៍គណៈនិកាយរបស់យើងឡើយ តែត្រូវសហការជាមួយអ្នកដទៃក្នុងទីចម្រូតរបស់ព្រះផងដែរ។ អ្នកណាដែលច្រូត នោះបានរង្វាន់(ខ ៣៦)!

**ការពិចារណា៖** ចូរកាត់យកកណ្តាប់ ប្រមូលមកឲ្យគ្រប់ ចូរយើងយកកណ្តាប់មក ដោយចិត្តអរសប្បាយ។
**ការអធិស្ឋាន៖** សូមព្រះអង្គបង្ហាញទីចម្រូត ហើយប្រទានកម្លាំងឲ្យខ្ញុំចេញទៅច្រូតថ្វាយទ្រង់ផង។

**ជីវិតអស់កល្បជាវន្ធទឹកផុសបន្តហូរជានិច្ច**

នៅក្នុងខទី១៤ ព្រះអម្ចាស់នៃយើងទ្រង់មានបន្ទូលថា៖ «តែអ្នកណាដែលផឹកទឹកខ្ញុំឲ្យ នោះនឹងមិនស្រេកទៀតឡើយ ទឹកដែលខ្ញុំឲ្យនឹងត្រឡប់ជាវន្ធទឹកនៅក្នុងអ្នកនោះ ដែលផុសឡើងដល់ទៅបានជីវិតអស់កល្បជានិច្ច»។ ជីវិតអស់កល្បដែលយើងទទួលពីព្រះគ្រីស្ទមិនគ្រាន់តែបានបំបាត់នូវភាពស្រេកឃ្លានខាងឯវិញ្ញាណរបស់យើងប៉ុណ្ណោះទេ តែក៏បានបំបាត់នូវភាពស្រេកឃ្លានរបស់អ្នកដទៃផងដែរ។ សេចក្ដីពិតដ៏អស្ចារ្យនេះគឺត្រូវបានថ្លែងជាថ្មីម្ដងទៀតនៅក្នុង យ៉ូហាន ៧:៣៨ «អ្នកណាដែលជឿដល់ខ្ញុំ នោះនឹងមានទន្លេទឹករស់ហូរចេញពីពោះខ្លួនមក ដូចជាព្រះគម្ពីរសំដែងហើយ»។ អ្នកបានសង្គ្រោះគឺជាអ្នកមានជីវិតរស់នៅជានិច្ច គាត់មិនគ្រាន់តែរស់នៅសម្រាប់ខ្លួនគាត់ទេ ប៉ុន្តែសម្រាប់សេចក្ដីសង្គ្រោះរបស់អ្នកដទៃផងដែរ។ សេចក្ដីសង្គ្រោះគឺបង្កបង្កើនពីរូបគាត់ដូចជាទឹកទន្លេហូរ ឯទន្លេដែលហូរមិនអាចស្តុកទឹកទុកតែក្នុងទន្លេនោះបានឡើយ។

ស្ត្រីសាសន៍សាម៉ារីបានទទួលនូវបទពិសោធន៍នៃសេចក្ដីពិតនេះដែលអ្នកដទៃពុំធ្លាប់មានពីមុនមក ខ៣០-៤២។ មហាចលនាផុសផុលខាងឯវិញ្ញាណបានកើតឡើង។ ទីក្រុងទាំងមូលត្រូវបាននាំមកក្នុងនគរព្រះ ហើយមនុស្សម្នាទាំងឡាយបានបាត់ភាពស្រេកឃ្លានដោយទឹកភ្លៀងខាងឯវិញ្ញាណដែលកន្លងមកពួកគេឥតបានដឹង។ ស្នាកស្នាមដ៏ជ្រៅនៃការប្រែចិត្តជាគំរូពីការផ្លាស់ប្រែចិត្តពីព្រាននារីទាំង៥នាក់ក្នុងជីវិតស្ត្រីសាសន៍សាម៉ារីត្រូវបានដឹកជារណ្ដៅដែលពេលនេះទទួលទឹកនៃព្រះវិញ្ញាណ។ គ្មានយុទ្ធនាការផ្សព្វផ្សាយដំណឹងល្អណាអាចស្ថិតនៅយូរជាងរយៈពេលរបស់វាបានទេ ដរាបណាបញ្ហាអំពើបាបមិនទាន់បានដោះស្រាយ។ នោះហើយជាភាពខុសប្លែកគ្នារវាងព័ន្ធកិច្ចដ៏ស៊ីជម្រៅរបស់បណ្ឌិតចន ស៊ុងនិងព័ន្ធកិច្ចដ៏រាក់កំផែលនាពេលបច្ចុប្បន្ន។ ព័ន្ធកិច្ចមួយហូរដូចជាវន្ធទឹករស់ ឯមួយទៀតរីងស្ងួតបន្ទាប់ពីការផ្ដើមឡើងចេញដោយភាពខុសឆ្គង។

**ការពិចារណា៖** ជាសង្ខេប តើការប្រែចិត្តគឺជាអ្វី?
**ការអធិស្ឋាន៖** ឱព្រះអង្គអើយ សូមឲ្យការផុសផុលខាងឯវិញ្ញាណកើតមានឡើងដល់ខ្ញុំផង។

*«ដ្បិតយើងខ្ញុំពុំអាចនឹងធ្វើអ្វី ទាស់នឹងសេចក្តីពិតបានទេ
ធ្វើបានតែអ្វីដែលសំរាប់សេចក្តីពិតវិញ»។*

## ហោរាមកស្រុកកំណើត

«ស្គាល់គ្នាច្បាស់ពេកទៅជាលែងមានការគោរព» គឺជាសុភាសិតដែលបានដកស្រង់ក្នុង មេរៀនសំរាប់ជំពូកទីពីររបស់យើង។ សុភាសិតជនជាតិអង់គ្លេសនេះមានអត្ថន័យស្របនឹងពាក្យថ្លែងការណ៍របស់ព្រះយេស៊ូវអំពីហោរាដែលអ្នកស្រុកខ្លួនមិនរាប់អាន (ម៉ាថាយ ៦:៤ លូកា ៤:២៤)។ យ៉ូហាន ៤:៤៤៖ «ដ្បិតទ្រង់ធ្វើបន្ទាល់ដោយព្រះអង្គថា គេមិនរាប់អានហោរា នៅក្នុងស្រុករបស់ខ្លួនទេ»។ ដូច្នេះយើងអាចសន្និដ្ឋានបានថាការយាងមកស្រុករបស់ទ្រង់គឺជា ដំណើរខកចិត្តប្រៀបនឹងព័ន្ធកិច្ចដ៏ល្បីខ្ចរខ្ចាររបស់ទ្រង់នៅស្រុកសាម៉ារី។ ជារឿយៗអ្នកបម្រើយល់ថាខ្លួនស្ថិតក្នុងស្ថានភាពពិបាកដូចនេះដែរ។ គ្រូគង្វាលត្រូវបានសមាជិកពួកជំនុំរបស់ខ្លួនមិនផ្តល់តម្លៃឲ្យ។ ប៉ុន្តែនោះវាគឺជាផ្នែកមួយនៃពន្ធ័កិច្ចគ្រីស្ទបរិស័ទដែលព្រះអម្ចាស់នៃយើងធ្លាប់ទទួលបានបទពិសោធន៍ ហើយវាជាឈើឆ្កាងយើងត្រូវលី។

ទោះជាយ៉ាងណា ដូចជាយើងឃើញក្នុងម៉ាកុស ៦:៤-៦ ការយាងមកកាលីឡេជាស្រុករបស់ទ្រង់មិនមែនឥតប្រយោជន៍ទាំងស្រុងឡើយ។ នៅទីនោះយើងឃើញព្រះអង្គឥតបានធ្វើការអស្ចារ្យទេ ព្រោះតែញាតិសន្តានរបស់ទ្រង់គ្មានជំនឿ។ នៅក្នុងយ៉ូហាន ៤:៤៥ យើងឃើញនូវករណីលើកលែងរបស់សុភាសិតខាងលើព្រោះតែការទទួលរាក់ទាក់របស់ពួកគេ៖ «ដូច្នេះ កាលទ្រង់បានយាងមកដល់ស្រុកកាលីឡេហើយ នោះពួកអ្នកនៅស្រុកនោះក៏ទទួលទ្រង់»។ មូលហេតុ? មានពួកអ្នករួមដំណើរជាមួយនឹងព្រះគ្រីស្ទទៅចូលរួមពិធីបុណ្យរំលងក្នុងទីក្រុងយេរូសាឡឹមហើយពួកគេចាប់អារម្មណ៍នឹងការសំអាតព្រះវិហារនិងពីការអស្ចារ្យទាំងឡាយរបស់ទ្រង់ (យ៉ូហាន ២:១៣-២៥)។ «ដ្បិតយើងខ្ញុំពុំអាចនឹងធ្វើអ្វី ទាស់នឹងសេចក្តីពិតបានទេ ធ្វើបានតែអ្វីដែលសំរាប់សេចក្តីពិតវិញ» (២ កូរិនថូស ១៣:៨)។ តើអ្នកនៅតែព្យាយាមច្រានចោលអ្នកដែលព្រះប្រើប្រាស់ប្រកបដោយប្រសិទ្ធិភាពទៀតឬ?

**ការពិចារណា៖** «ដ្បិតខ្ញុំគ្មានសេចក្តីខ្មាស់ចំពោះដំណឹងល្អនៃព្រះគ្រីស្ទទេ ពីព្រោះជាព្រះចេស្តានៃព្រះ សម្រាប់នឹងជួយសង្គ្រោះដល់អ្នកណាដែលជឿ...» (រ៉ូម ១:១៦)។
**ការអធិស្ឋាន៖** ព្រះវរបិតាអើយ សូមឲ្យខ្ញុំដឹងថាខ្ញុំជាព្រោះគ្រាប់ពូជដំណឹងល្អ តែព្រះអង្គជាអ្នកប្រទានជំនឿ។

ថ្ងៃទី ២៨ កក្កដា
យ៉ូហាន ៤:៤៦-៥៤

*«ហើយលោកក៏ជឿ ព្រមទាំងពួកផ្ទះលោកទាំងអស់ដែរ»។*

## ការអស្ចារ្យទីពីរនៅស្រុកកាណា ទឹកនៃជីវិតបំបាត់ការស្រេកឃ្លានជាដរាប

ទង្វើល្អមួយនឹងនាំមកនូវទង្វើល្អមួយទៀត។ ការអស្ចារ្យពីការប្រែទឹកជាស្រាទំពាំងបាយជូនៅភូមិកាណាបានក្លាយជាចំណាប់អារម្មណ៍នៅក្នុងបណ្ដាពួកអ្នកជឿហើយក៏ត្រូវបាននិយាយតៗគ្នានៅគ្រប់ទីកន្លែង។ កិត្តិស័ព្ទបានផ្សព្វផ្សាយនៅស្រុកកាពើណិម ជាស្រុករបស់សាវក័ពេត្រុស។ នៅស្រុកនោះមាននាម៉ឺនម្នាក់មានកូនប្រុសឈឺជម្ងឺគ្រុនក្ដៅ។ លោកបានទៅជួបព្រះយេស៊ូវសូមទ្រង់ ឲ្យយាងចុះទៅប្រោសកូនឲ្យជា ដ្បិតកូនគាត់ «ជិតស្លាប់ហើយ» (យ៉ូហាន ៤:៤៧)។ បើតាមលោកគ្រូ ចន ស៊ុង មានសុភាសិតមួយនៅទីក្រុងប៉េកាំងថ្លែងថា៖

*ពេលឈឺស្រាលៗ ទៅជួបគាយហ្វូ (វេជ្ជបណ្ឌិត)*
*ពេលឈឺធ្ងន់យូរអ្នកត្រូវទៅជួបព្រះយេស៊ូវ*

នាម៉ឺនម្នាក់នោះគ្មានដំណោះស្រាយសម្រាប់ស្ថានភាពដ៏ធ្ងន់ធ្ងរនេះក្រៅពីរកព្រះយេស៊ូវឡើយ។ គាត់មិនអាចរកគ្រូពេទ្យណាពូកែជាងព្រះអម្ចាស់ដើម្បីជួយគាត់នោះឡើយ។ តើហេតុអ្វីបានជាអ្នកមិនសូមឲ្យព្រះអម្ចាស់ជួយដោះស្រាយបញ្ហារបស់អ្នក?

សូមចងចាំថាព្រះយេស៊ូវមានបន្ទូលតែមួយពាក្យប្រោសក្មេងប្រុសឈឺឲ្យបានជាភ្លាមមួយរំពេច គឺដោយគ្រាន់តែមានបន្ទូលពីចម្ងាយប៉ុណ្ណោះ។ តើអ្នកណាអាចធ្វើការនេះបាន ក្រៅពីព្រះជាម្ចាស់? តើអ្វីអាចពន្លត់ជម្ងឺគ្រុនជិតស្លាប់បានក្រៅពីទឹកនៃជីវិត?

**ការពិចារណា៖** ជំនឿជាជ័យជំនះ។
**ការអធិស្ឋាន៖** «ហើយចូរផ្ទេរគ្រប់ទាំងសេចក្ដីទុក្ខព្រួយរបស់អ្នករាល់គ្នាទៅលើទ្រង់ ដ្បិតទ្រង់តែងយកព្រះទ័យទុកដាក់នឹងអ្នករាល់គ្នា» (១ពេត្រុស ៥:៧)។

*«ឥឡូវអ្នកបានជាហើយ កុំឲ្យធ្វើបាបទៀតក្រែងអ្នកកើតមាន សេចក្ដីអាក្រក់ជាងនេះទៅទៀត» (យ៉ូហាន ៥:១៤)។*

## ជំពូក ៥

## ព្រះយេស៊ូវគឺជាផ្នូបណ្ឌិតនៃជីវិតដល់ជនពិការ អ្នកជំងឺ និងអ្នកត្រូវគេបោះបង់ចោល

នៅជុំវិញស្រះទឹកបេសែសដាជិតផ្សារឬទ្វារចៀមក្នុងទីក្រុងយេរូសាឡឹម «មានមនុស្សសន្ធឹក ដេកនៅក្នុងសាលាទាំងនោះ ខ្លះឈឺ ខ្លះខ្វាក់ ខ្លះខ្វិន ខ្លះស្វិត» ព្យាបាលមិនជា។ ពួកជនពិការ មានជំងឺ ទាំងនេះត្រូវបានសាច់ញាតិរបស់គេបោះបង់ចោល តែគេបានរកឃើញរស្មីនៃក្ដីសង្ឃឹមដើម្បីទទួលការព្យាបាលពីទឹកកំរើកក្នុងស្រះនេះ។ ព្រោះគេជឿថាអ្នកដែលចុះទៅក្នុងស្រះមុនគេ គឺនៅពេលទេវតាកូរ ទឹកអោយកំរើក នោះគេនឹងបានជាសះស្បើយ។ ទឹកស្រះ «កំរើក» ញឹកញាប់យ៉ាងណានោះគ្មានអ្នក ណាដឹងទេ ព្រោះព្រះគម្ពីរមិនបានកត់ត្រាទុក ឬក៏ថាមនុស្សប៉ុន្មាននាក់ជាសះស្បើយក៏គ្មានអ្នកណាម្នាក់ដឹងដែរ។ ទិដ្ឋភាពជាក់ស្ដែងគឺថាមានហ្វូងមនុស្សដេកនៅមាត់ស្រះបញ្ជាក់ថាទីនោះមិនមែនជាកន្លែង «កម្មវិធីសម្ដែងការអស្ចារ្យ» ដោយសារកិច្ចការរបស់ទេវតា ឬដោយព្រះអម្ចាស់ផ្ទាល់ឡើយ។

ព្រឹត្តិការណ៍ដ៏សំខាន់គឺនាពេលនោះព្រះអម្ចាស់នៃយើងបានប្រោសជំងឺមនុស្សតែម្នាក់គត់ក្នុងចំណោមអ្នកជំងឺជាច្រើនរយនាក់ គឺជាបុរស «ឈឺ» ៣៨ឆ្នាំ។ ហើយទ្រង់ផ្ទាល់ដែលបានមានបន្ទូលសួរ ជនពិការនេះបើគាត់ពិតជាចង់ជាសះស្បើយ។ ដោយហេតុថាបុរសកំសត់នេះបានបោះបង់ចោលក្ដីសង្ឃឹមថា ខ្លួននឹងអាចដើរសារជាថ្មីឡើងវិញ ហើយគាត់ក៏មិនបានដឹងថាមានព្រះសង្គ្រោះមួយដែលអាចប្រោសឲ្យគាត់ជាដែរ។

ជាការពិត ព្រះគ្រីស្ទយាងមកសម្រាប់ពួកអ្នកដែលគ្មានក្ដីសង្ឃឹម។ ព្រះអង្គស្វែងរកយើងជា មនុស្សទុរគតនិងជាអ្នកត្រូវគេបោះបង់ចោល។ ទ្រង់សម្ដែងអង្គទ្រង់ជាព្រះសង្គ្រោះនៃព្រះតាមរយៈការរំដោះយើងចេញពីស្ថានភាពដ៏អស់សង្ឃឹមរបស់យើង។

ព្រះអង្គសម្ដែងការនេះសម្រាប់ជាការល្អរបស់យើងផ្ទុយនឹងឱកាសធម្មតានៅជុំវិញទ្រង់ គឺជាទំនៀមទម្លាប់និងក្រិត្យវិន័យដ៏តឹងរ៉ឹងរបស់សាសន៍យូដាក្នុងការរក្សាថ្ងៃសប្ប័ទ(ថ្ងៃឈប់សម្រាក)។ វិន័យនិយមរបស់គណៈផារីស៊ីគឺដូចជាក្រណាត់រុំសពដែលត្រូវតែហែកចេញពីសាសនាពិតដើម្បីឲ្យវាបានចំរើនឡើង គឺសម្រាប់សេចក្ដីសង្គ្រោះព្រលឹងវិញ្ញាណ និងរូបកាយ។ ចំពោះសាសន៍យូដា ពួកគេមិនបានលូកម្រាមដៃជួយសម្រាលក្ដីឈឺចាប់របស់ជនពិការ អ្នកជំងឺ និងពួកអ្នកត្រូវគេបោះបង់ចោលទាំងនេះឡើយ។

វាគឺជាការដ៏គួរឲ្យចាប់អារម្មណ៍នឹងកត់សម្គាល់ផ្តេកលើការពិភាក្សាអំពីថ្ងៃឈប់សម្រាកដែលសាសន៍យូដាឈានដល់ការបញ្ចេញកំហឹងទាស់នឹងព្រះអម្ចាស់ទាក់ទងនឹងអង្គបុគ្គលនិងកិច្ចការរបស់ទ្រង់។ នេះនាំយើងដល់មេរៀនអំពីទេវសាស្ត្រដ៏អស្ចារ្យនិងដ៏ស៊ីជម្រៅមួយ! តើអ្នកចាប់ផ្ដើមចូលចិត្តការសិក្សាពីទេវសាស្ត្រហើយឬនៅ?

**ការពិចារណា៖** «ចូរអរសប្បាយ ជាមួយនឹងអ្នកណាដែលអរសប្បាយ ហើយយំជាមួយនឹងអ្នកណាដែលយំផង» (រ៉ូម ១២:១៥)។

**ការអធិស្ឋាន៖** អរព្រះគុណព្រះអម្ចាស់យេស៊ូវ ដែលទ្រង់ប្រោសឲ្យចិត្តបានធូរ។

ថ្ងៃទី ៣០ កក្កដា
យ៉ូហាន ៥:១

*«ឥតលែងប្រជុំគ្នា ដូចជាអ្នកខ្លះធ្លាប់នោះឡើយ...»(ហេព្រើរ ១០:២៥)។*

## ព្រះយេស៊ូវមានវត្តនៅរាល់ពិធីបុណ្យ

មិនថាបុណ្យនេះគឺជាពិធីបុណ្យថ្ងៃទី៥០ ឬជាពិធីបុណ្យរំលងទេ ព្រះយេស៊ូវមានវត្តមាននៅរាល់ពិធីដែលតម្រូវឲ្យបុរសជនជាតិយូដាទាំងអស់ចូលរួមស្របទៅតាមក្រិត្យវិន័យម៉ូសេ។ បើតាម ចោទិយកថាជំពូក ១៦ មានពិធីបុណ្យបី គឺបុណ្យរំលង បុណ្យថ្ងៃទី៥០ និងបុណ្យបារាំ។ ព្រះគម្ពីរចោទិយកថា ១៦:១៦-១៧ ចែងថា៖ «ត្រូវឲ្យគ្រប់ទាំងប្រុសៗក្នុងពួកឯង មកនៅចំពោះព្រះយេហូវ៉ា ជាព្រះនៃឯង៣ដងក្នុង១ឆ្នាំ ត្រង់កន្លែងដែលទ្រង់នឹងរើស គឺនៅពេលបុណ្យនំបុ័ងឥតដំបែម្តង បុណ្យអាទិត្យទី៧ម្តង (បុណ្យថ្ងៃទី៥០) នឹងបុណ្យបារាំម្តង ក៏មិនត្រូវមកនៅចំពោះព្រះយេហូវ៉ា ដោយដៃទទេដែរ គឺត្រូវឲ្យគ្រប់គ្នាថ្វាយតាមកំឡាំងរៀងខ្លួន គឺតាមព្រះពរដែលព្រះយេហូវ៉ា ជាព្រះនៃឯង បានប្រទានពរឲ្យ»។

ដូច្នេះ នៅពេលព្រះយេស៊ូវមានព្រះជន្ម ១២ឆ្នាំ ជាវ័យរបស់ក្មេងប្រុសសាសន៍យូដាត្រូវបញ្ចូលទៅក្នុងព្រះវិហារ ពេលនោះគេឃើញទ្រង់មានព្រះវត្តមាននាពិធីបុណ្យរំលងជាមួយនឹងមាតានិងយ៉ូសែបជាឪពុកចិញ្ចឹមរបស់ទ្រង់ ហើយ «ទ្រង់គង់នៅកណ្តាលពួកអាចារ្យក្នុងព្រះវិហារ»។ អាចនឹងសន្មត់ថាចាប់តាំងពីថ្ងៃបុណ្យរំលងនោះមក ព្រះអម្ចាស់បានយាងទៅទីក្រុងយេរូសាឡឹមជារៀងរាល់ឆ្នាំ ពីព្រោះទ្រង់មិនបានមកដើម្បីនឹងបំផ្លាញក្រិត្យវិន័យម៉ូសេទេ តែដើម្បីឲ្យបានសម្រេចវិញ (ម៉ាថាយ ៥:១៧)។

នេះបានពិតជាគំរូធ្វើឡើងសម្រាប់យើងក្នុងការមានវត្តមានចូលរួមថ្វាយបង្គំនៅព្រះវិហារមែន! ខណៈសម័យនេះយើងមិនរក្សាពិធីបុណ្យនានាចែងក្នុងក្រិត្យវិន័យរបស់ម៉ូសេ ដោយសារបុណ្យទាំងនេះសម្រេចនៅក្នុងអង្គព្រះគ្រីស្ទ គឺមានតែថ្ងៃនៃព្រះអម្ចាស់ ជាថ្ងៃយើងគ្រប់រូបទៅព្រះវិហារនាថ្ងៃអាទិត្យប៉ុណ្ណោះ (ហេព្រើរ ១០:២៥)។ មានពិធីលៀងព្រះអម្ចាស់ដែលត្រូវបានធ្វើឡើងស្ទើរគ្រប់ក្នុងបណ្តាព្រះវិហារទាំងអស់នាសប្តាហ៍ដំបូងនៃខែនិមួយៗ ជាពិធីដែលយើងមិនគួរខកខានចូលរួម។ ហើយនៅមានកម្មវិធីអធិស្ឋានប្រចាំសប្តាហ៍ដែរ «ដ្បិតនៅកន្លែងណាដែលមាន២ ឬ ៣នាក់ប្រជុំជាមួយគ្នាដោយនូវឈ្មោះខ្ញុំ នោះខ្ញុំក៏នៅកណ្តាលចំណោមអ្នកទាំងនោះដែរ» (ម៉ាថាយ ១៨:២០)។

មានពាក្យនិយាយតៗគ្នាមកថាសមាជិក (ព្រះវិហារ) ខ្លះជួបគ្រូគង្វាលរបស់ខ្លួនត្រឹមតែបីដងប៉ុណ្ណោះក្នុងមួយជីវិតរបស់គេ គឺនៅថ្ងៃទទួលបុណ្យជ្រមុជទឹកកាលទារកភាព ថ្ងៃរៀបអាពាហ៍ពិពាហ៍នាពេលពេញវ័យ និងថ្ងៃបុណ្យសពក្នុងវ័យជរាភាព។ ទេ មិនត្រូវ (ធ្វើបែបនេះ) ឡើយ!

**ការពិចារណា៖** «ដ្បិត១ថ្ងៃនៅក្នុងព្រះលាននៃទ្រង់ នោះវិសេសជាង១ពាន់ថ្ងៃណាទៀត ទូលបង្គំស៊ូធ្វើជាអ្នកឆ្មាំទ្វារនៅក្នុងដំណាក់របស់ព្រះនៃទូលបង្គំ ជាជាងនៅក្នុងលំនៅនៃសេចក្តីអាក្រក់» (ទំនុកដំកើង ៨៤:១០)។
**ការអធិស្ឋាន៖** ព្រះអង្គអើយ សូមឲ្យខ្ញុំចូលរួមថ្វាយបង្គំទ្រង់នាព្រះវិហារដោយក្តីអំណរ។

## ទេវតាកំពុងធ្វើការ!

ផ្សារលក់សត្វចៀមគឺត្រូវបានអ្នកសិក្សាព្រះគម្ពីរយល់ថាជាទ្វារចៀម (នេហេមា ៣:១ ១២:៣៩)។ បេថែសដាគឺជាឈ្មោះស្រះទឹកក្នុងភាសាអារ៉ាម (*Aramaic*)។ វាមានន័យថា «សំណាក់មេត្តាករុណា» ព្រោះស្រះនេះបានរចនាលំអរ និងសង់ជម្រកដោយសរសរប្រាំដើមធំៗ ដែលផ្តល់ជាម្លប់សម្រាប់ជ្រក។

អ្នកអត្ថាធិប្បាយសម័យទំនើប ជជែកវែកញែកពីការលប់ឃ្លា «កូរទឹកក្នុងស្រះនោះ» នៅក្នុងខ ៣ និង ខ៤ ដែលមាននៅក្នុងបទគម្ពីរបុរាណ យកន័យត្រង់ពីការការប្រោសជម្ងឺបែបធម្មជាតិ។ ពួកគេចាត់ទុកស្រះបេថែសដាមិនខុសពីកន្លែងស្ប៉ា ឬ អាងទឹកសុខភាពនោះឡើយ។ ប៉ុន្តែផលលំបាំកនៃការអះអាងនេះគឺថាកន្លែងស្ប៉ា ឬអាងទឹកសុខភាពអាចនឹងជួយព្យាបាលជម្ងឺបានបន្តិចបន្តួចដែរ។ ដើម្បីការប្រោសជម្ងឺព្យាបាលមិនជាឲ្យមានប្រសិទ្ធភាពទាមទានូវអំណាចមកពីព្រះជាម្ចាស់។ ក្នុងករណីនេះ ពួកជំនុំសម័យបុរាណជឿថា បណ្តាទុព្វលជន ជាជនពិការមានជម្ងឺដែលត្រូវបានគេទុកនាស្រះទឹកបេថែសដា ត្រូវបានប្រោសឲ្យជាដោយភ្នាក់ងារទេវតា។ មានតែពួកអ្នកស្មោះត្រង់និងអត់ធ្មត់ ហើយព្យាយាមអស់ពីចិត្តទេ ទើបអាចចុះទៅក្នុងស្រះទឹកមុនគេទេហើយបានជាពីជម្ងឺរោគាពាធ។ ព្រះជាម្ចាស់ត្រូវតែកំណត់ព្រះគុណចំពោះមនុស្សពីរបីនាក់ដើម្បីស្វែងរកពួកអ្នកដែលស្មោះត្រង់នឹងទទួលនូវការប្រោសឲ្យជាពីជម្ងឺ។ នៅក្នុង ម៉ាថាយ ១១:១២ ព្រះយេស៊ូវមានបន្ទូលថាគឺជាអ្នកខំប្រឹងពិតដែលចាប់បាននគរស្ថានសួគ៌។ លោកស្កូហ្វីលដ៍ អត្ថាធិប្បាយថា៖ «មានតែអ្នកប្តេជ្ញាចិត្តខិតខំទេទើបនឹងបន្តឆ្ពោះទៅមុខ»។ បើតាមការស្មាន បុរសជាជនពិការមានជម្ងឺ ៣៨ឆ្នាំនោះគឺបានទឹកចិត្តប្តេជ្ញាខ្ពស់ ប៉ុន្តែបាត់បង់ឱកាសព្រោះតែអ្នកដទៃ ព្រោះគាត់ជាមនុស្សពិការខាងផ្នែកកាយសម្បទា។ តើនេះមិនមែនជាហេតុផលដែលព្រះគ្រីស្ទបានយាងមកដើម្បីសង្គ្រោះគាត់? «ត្រូវតែអធិស្ឋានជានិច្ច ឥតរសាយចិត្តឡើយ» (លូកា ១៨:១)។

ប្រសាសន៍ពីលោកគ្រូ កាល់វិន ទាក់ទងនឹងការប្រោសឲ្យជាដ៏អស្ចារ្យតាមរយៈអំណាចទេវតានេះគឺ៖ «តែជាការទុកទីបន្ទាល់សម្រាប់ព្រះវិហារនិងដង្វាយយញ្ញបូជាហើយនិងការថ្វាយបង្គំទាំងមូលពីសេចក្តីសង្គ្រោះនឹងប្រកាសដល់លោកីយ ព្រះបានរក្សាទុកនូវអំណោយទាននៃការប្រោសជម្ងឺនេះនៅជាមួយសាសន៍យូដា ប្រយោជន៍ឲ្យពួកគេដឹងថាព្រះជាម្ចាស់មិនបានញែកគេចេញពីបណ្តាប្រជាជាតិផ្សេងៗជាអសាឥតការឡើយ។ តាមរយៈការប្រោសអ្នកឈឺ ព្រះទ្រង់បានបើកសម្តែងឲ្យឃើញច្បាស់ ដូចជាដៃដាក់ចុះមកពីស្ថានសួគ៌ បញ្ជាក់ថាទ្រង់បានទទួលការថ្វាយបង្គំទាំងឡាយណាដែលគេបានទទួលមកពីការប្រតិបត្តិតាមក្រិត្យវិន័យ»។

ស្របតាមវិទ្យាសាស្ត្រសុខាពិបាលដ៏ជឿនលឿននាសម័យបច្ចុប្បន្នតាមរយៈព្រះគុណសមញ្ញរបស់ព្រះចំពោះមនុស្សជាតិ តើមិនជាវេជ្ជបណ្ឌិត និងគ្រូពេទ្យគ្រីស្ទបរិសទ័ជាទេវតា? មានទេវតាមួយអង្គទៀតឈ្មោះថា ណៃធីងហ្គេល! អ្នកគ្រូពេទ្យ ហ្វូលរិនស៍ ណៃធីងហ្គេល (*Florence Nightingal—1820-1910*) គាត់ជាស្ថាបនិកមណ្ឌលថែទាំសុខភាពសម័យទំនើប ហើយគាត់ផ្តល់ការថែទាំអ្នកជម្ងឺជាច្រើននាសម័យសង្គ្រាមគ្រីមា (*Crimean War--Oct 5, 1853-Mar 30, 1856*)។

**ការពិចារណា៖** ការអស្ចារ្យដ៏ធំបំផុតគឺ «*ព្រះបានប្រោសឲ្យទ្រង់រស់ពីស្លាប់ឡើងវិញ*» (រ៉ូម ១០៩)។
**ការអធិស្ឋាន៖** ព្រះអម្ចាស់អើយ សូមឲ្យខ្ញុំ «អធិស្ឋានឥតឈប់ឈរ» (១ ថែស្សាឡូនីច៥:១៧)។

*«ថ្ងៃឈប់សំរាកបានតាំងសំរាប់ឲ្យមនុស្ស
មិនមែនជាមនុស្សសំរាប់ថ្ងៃឈប់សំរាកទេ»។*

## ព្រះយេស៊ូវសង្គ្រោះថ្ងៃឈប់សម្រាកពីការប្រកាន់សាសនាជ្រុលនិយម

បញ្ញត្តិមួយដែលព្រះបានប្រទានដល់មនុស្សសម្រាប់ផ្នែកព្រលឹងវិញ្ញាណនិងសុខមាលភាពផ្នែករូបកាយរបស់គេនៅក្នុងជីវភាពនៃការងារដ៏គ្មានទីបញ្ចប់គឺជាថ្ងៃឈប់សម្រាក ឬថ្ងៃសប្ប័ទ។ មួយថ្ងៃក្នុងមួយសប្តាហ៍សម្រាកពីបម្រើការផ្សេងៗជាប្រយោជន៍ខ្លួនអាចរក្សាថ្ងៃនោះនិងការថ្វាយបង្គំឲ្យបានបរិសុទ្ធ។

នៅក្នុងបរិបទបច្ចុប្បន្ន គណៈផារីស៊ីជាពួកអ្នកមានមនសិការក្នុងការប្រតិបត្តិតាមបញ្ញត្តិទាំងឡាយរបស់ព្រះបានប្រែទៅជាជ្រុលហួសក្នុងក្រិតក្រមរបស់គេរហូតដល់មិនអនុញ្ញាតឲ្យអ្នកបើក ឬបិទកុងតាក់ភ្លើងនាអំឡុងថ្ងៃឈប់សម្រាកថែមទៀតផង។ ហេតុផលបែបនេះគឺគេដកស្រង់ករណីបុរសម្នាក់ដែលត្រូវបានគេចោលដុំថ្មសម្លាប់តាមបញ្ញត្តិលោកម៉ូសេ ព្រោះតែគាត់ទៅរកអុសនាថ្ងៃឈប់សម្រាក (ប្រហែលដើម្បីយកទៅដុតភ្នក់ភ្លើង) ជនគណនា ១៥:៣២។ សម្រាប់ករណីបុរសពិការឈឺ ៣៨ ដែលបានប្រោសឲ្យជានៅក្នុងអត្ថបទព្រះគម្ពីរនេះ ឲ្យគាត់យក «គ្រែ» គាត់ ឬ លីគ្រែទៅពីមាត់ស្រះទឹកអ្នកជម្ងឺគឺស្មើរតែចាត់ទុកថាជាអំពើបាបដ៏មិនអាចអត់ទោសដូច្នេះដែរ។

ហេតុនេះនៅពេលពួកសិស្សដែលហេវហត់បូតគួរស្រូវបរិភោគនាថ្ងៃឈប់សម្រាក ពួកផារីស៊ីចោទគេថាបានបំពានថ្ងៃថ្ងៃឈប់សម្រាក។ ពួកគេជាមនុស្សប្រកាន់ត្រូវទៅតាមគំនិតគ្មានហេតុផលរបស់ខ្លួន ដោយឥតបានពិចារណាពីភាពដ៏ចាំបាច់នៃបញ្ញត្តិសម្រាប់មនុស្សជាតិដែលប្រសើរជាងបញ្ញត្តិនៃការប្រតិបត្តិថ្ងៃឈប់សម្រាក។ «ថ្ងៃឈប់សំរាកបានតាំងសំរាប់ឲ្យមនុស្ស មិនមែនជាមនុស្សសំរាប់ថ្ងៃឈប់សំរាកទេ» (ម៉ាកុស ២:២៧)។ ឯអ្នកដែលប្រទានបញ្ញត្តិនៃថ្ងៃឈប់សម្រាកគឺជាព្រះអម្ចាស់នៃថ្ងៃឈប់សម្រាក! ប្រសិនព្រះយេស៊ូវប្រោសជម្ងឺនាថ្ងៃឈប់សម្រាកដូចនេះទាក់ទងនឹងការងារដោយកម្លាំង ដូច្នេះវាគឺជាកិច្ចការបរិសុទ្ធដែល «បំពាន» ថ្ងៃឈប់សម្រាកសម្រាប់ការល្អ!

សំណួរចម្លើយនៃគោលជំនឿគ្រីស្ទបរិស័ទខ្នាតធំបង្រៀនថា៖ «ថ្ងៃឈប់សម្រាក ឬថ្ងៃនៃព្រះអម្ចាស់ជាចាំបាច់គឺត្រូវតែញែកឲ្យបានបរិសុទ្ធតាមរយៈការសម្រាក់ដ៏បរិសុទ្ធពេញមួយថ្ងៃ គឺមិនត្រឹមសម្រាកពីកិច្ចការណាដែលមានពោរពេញដោយអំពោះបាបទេ តែរួមទាំងមុខរបរនិងល្បែងកំសាន្តបែបលោកីយ៍ដែលស្របច្បាប់នាថ្ងៃឯទៀត ហើយត្រូវរាប់ថ្ងៃឈប់សម្រាកនោះជាថ្ងៃមានអំណរអររបស់យើង ដើម្បីប្រើប្រាស់ពេលវេលានោះទាំងអស់ (**លើកលែងតែកិច្ចការដ៏ចាំបាច់និងការប្រោសប្រណីមួយចំនួនប៉ុណ្ណោះ**) ក្នុងការប្រតិបត្តិថ្វាយបង្គំព្រះជាម្ចាស់លក្ខណៈសារធារណៈនិងជាឯកជន..»។ តើកិច្ចការដ៏ចាំបាច់និងការប្រោសប្រណីអ្វីខ្លះដែលអនុគ្រោះយើងពីការរក្សាថ្ងៃឈប់សម្រាក? (ថ្ងៃនៃព្រះអម្ចាស់គឺត្រូវបានហៅថាថ្ងៃឈប់សម្រាកគ្រីស្ទបរិស័ទ)។

**ការពិចារណា៖** តើពេលវេលាដ៏សំខាន់របស់ខ្ញុំគឺនៅព្រះវិហារ ឬនៅកន្លែងកំសាន្តនាថ្ងៃឈប់សម្រាក?

**ការអធិស្ឋាន៖** ឱព្រះអម្ចាស់អើយ សូមឲ្យខ្ញុំ «នឹកចាំថ្ងៃឈប់សម្រាក ដើម្បីញែកថ្ងៃនោះចេញជាបរិសុទ្ធ» (និក្ខមនំ ២០:៨)។

ថ្ងៃទី ២ សីហា
យ៉ូហាន ៥:១៧-១៨

*«ព្រះវរបិតាខ្ញុំ ទ្រង់ធ្វើការដរាបមកដល់ឥឡូវនេះ ហើយខ្ញុំក៏ធ្វើការដែរ»។*

## កិច្ចការខ្ពង់ខ្ពស់ធ្វើដោយឥស្សរជនខ្ពង់ខ្ពស់

ដូចជាព្រះគ្រីស្ទទ្រង់បានថ្លែងថាទ្រង់ជាម្ចាស់លើថ្ងៃឈប់សម្រាកនៅក្នុងខគម្ពីរផ្សេងទៀត មកដល់ខនេះទ្រង់បានប្រកាសប្រាប់ថាការងាររបស់ទ្រង់គឺជាកិច្ចការរបស់ព្រះ។ បណ្ឌិត កាល់វិនមានប្រសាសន៍ថា៖ «អ្វីដែលព្រះគ្រីស្ទបន្តធ្វើព្រោះតែកិច្ចការរបស់ព្រះមិនប៉ះពាល់ដល់ការសម្រាកបរិសុទ្ធបង្គាប់ក្នុងក្រិត្យវិន័យលោកម៉ូសេ។ ហេតុនេះទ្រង់មិនត្រឹមតែបានអនុគ្រោះដល់ទង្វើរបស់ទ្រង់ផ្ទាល់នោះទេ តែក៏ផ្តល់អនុគ្រោះដល់បុរសយកគ្រែ (លីគ្រែ) ដែលជាការបន្ថែមហើយនិងជាចំណែកនៃការអស្ចារ្យ និងជាភស្តុតាងដ៏សាមញ្ញពីការអស្ចារ្យនោះផងដែរ។ បន្ថែមលើនេះ បើការអរព្រះគុណនិងសម្តែងប្រាប់ពីសិរីរុងរឿងរបស់ទ្រង់ត្រូវបានបញ្ចូលក្នុងបណ្តាការផ្សេងៗទៀតនៃព្រះជាម្ចាស់ នោះមិនមែនជាការប្រមាថដល់ថ្ងៃឈប់សម្រាកក្នុងការធ្វើទីបន្ទាល់ពីព្រះគុណនៃព្រះដោយដៃនិងជើងឡើយ។ ប៉ុន្តែព្រះគ្រីស្ទទ្រង់មានបន្ទូលពីព្រះអង្គទ្រង់ ព្រោះសម្រាប់ជនជាតិយូដាពួកគេប្រឆាំងនឹងទ្រង់។ ព្រះអង្គមានបន្ទូលប្រាប់ថាសុខភាពដែលទ្រង់ប្រោសបុរសឈឺឲ្យជាគឺជាភស្តុតាងអំពីភាពជាព្រះរបស់ទ្រង់។ ទ្រង់ប្រកាសថាទ្រង់ជាព្រះរាជបុត្រានៃព្រះហើយក៏អះអាងថាកិច្ចការដែលទ្រង់សម្តែងធ្វើគឺដូចជាព្រះវរបិតាធ្វើផងដែរ...។

«ការការពារនៃទ្រង់បានរំខានជាជាងនាំឲ្យកំហឹងរបស់គេចុះត្រជាក់....។ តាមរយៈគំរូរបស់ទ្រង់ ព្រះអង្គបានបង្រៀនយើងកុំឲ្យទន់ទោរតាមកំហឹងរបស់មនុស្សអាក្រក់តែត្រូវព្យាយាមការពារសេចក្តីពិតនៃព្រះនៅវេលាណាដែលកើតមានឡើង»។

នៅក្នុង ខ១៨ យើងពីកំហឹងរបស់សាសន៍យូដាកំពុងពុះកញ្ជ្រោលឡើងនៅក្នុងទឹកមុខរបស់គេបើតាមសាវ័កយ៉ូហានជាអ្នកនិពន្ធដំណឹងល្អទីបួនបានសង្កេតមើលនាខណៈពេលនោះ។ «ដោយហេតុពាក្យនោះ បានជាពួកសាសន៍យូដា គេរកសំឡាប់ទ្រង់រឹតតែខ្លាំងឡើង ពីព្រោះទ្រង់មិនមែនគ្រាន់តែរំលងច្បាប់នៃថ្ងៃឈប់សំរាកតែប៉ុណ្ណោះ គឺបានទាំងហៅព្រះ ថាជាព្រះវរបិតានៃទ្រង់ថែមទៀត ហើយលើកអង្គទ្រង់ស្មើនឹងព្រះផង»។ ខនេះគឺជាបទគម្ពីរមួយបញ្ជាក់អំពីភាពស្មើគ្នារវាងព្រះយេស៊ូវគ្រីស្ទនិងព្រះវរបិតា ដែលជាចម្លើយតបទៅការជំនឿខុសឆ្គងនៃក្រុមស្មរបន្ទាល់ព្រះយេហូវ៉ាដែលប្រានចោលនូវនិស្ស័យជាព្រះដ៏គ្រប់លក្ខណ៍នៃអង្គបុគ្គលទីពីររបស់ព្រះត្រីឯកដ៏បរិសុទ្ធ។

ទាក់ទងនឹងព្រះត្រីឯកដ៏បរិសុទ្ធ សំណួរចម្លើយនៃគោលជំនឿគ្រីស្ទបរិស័ទខ្នាតធំបង្រៀនថា៖ «មានអង្គបុគ្គលចំនួនបីនៅក្នុងព្រះត្រីឯក គឺព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ អង្គបុគ្គលទាំងបីនេះគឺជាព្រះពិតតែមួយ ជាព្រះដ៏មានព្រះជន្មអស់កល្ប មាននិស្ស័យជាព្រះដូចគ្នា មានឫទ្ធានុភាពនិងសិរីរុងរឿង**ស្មើគ្នា** ទោះបីជាអង្គបុគ្គលទាំងនេះមានលក្ខណៈខុសគ្នាក៏ដោយ»។

**ការពិចារណា៖** សេចក្តីជំនឿរបស់ខ្ញុំនិងមិនគ្រប់លក្ខណៈបើខ្ញុំបដិសេធព្រះគ្រីស្ទជាព្រះស្មើនិងព្រះវរបិតា។
**ការអធិស្ឋាន៖** ខ្ញុំជឿលើព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ ទាំងបីអង្គបុគ្គលថាជាព្រះតែមួយ។

ថ្ងៃទី ៣ សីហា
យ៉ូហាន ៥:១៩-៣០

*«អ្នកណាដែលមិនគោរពប្រតិបត្តិដល់ព្រះរាជបុត្រា នោះក៏មិនគោរពប្រតិបត្តិដល់ព្រះវរបិតា...»។*

## ភាពតែមួយនៃព្រះរាជបុត្រានិងព្រះវរបិតាក្នុងការសម្រេចព្រះហឫទ័យនិងប្រតិបត្តិការ

ការចោទប្រកាន់របស់ជនជាតិយូដាចំពោះព្រះយេស៊ូវពីការទ្រង់តាំងអង្គទ្រង់ស្មើនឹងព្រះបានប្រែជាឱកាសសម្រាប់ព្រះអម្ចាស់សម្ដែងប្រាប់ពីទំនាក់ទំនងរបស់ទ្រង់នឹងព្រះវរបិតា។ តើជាទំនាក់ទំនងអ្វី? សេចក្ដីស្រឡាញ់ដ៏គ្រប់លក្ខណ៍ (ខ ២០)? សេចក្ដីស្រឡាញ់ដ៏គ្រប់លក្ខណ៍នាំមកនូវភាពតែមួយនៃព្រះរាជបុត្រានិងព្រះវរបិតាក្នុងការសម្រេចព្រះហឫទ័យនិងប្រតិបត្តិការ។ ភាពស្មើគ្នានេះសំដៅទៅលើឋានៈ (ឬតំណែង) ព្រោះសម្រាប់ព្រះរាជបុត្រាទទួលយកតួនាទីបែបនោះគឺមិនមែនជាការដណ្ដើមយកមកជារបស់ទ្រង់ឡើយ (ភីលីព ២:៦) ពីព្រោះព្រះរាជបុត្រាគឺជាព្រះដូចជាព្រះវរបិតាក៏ជាព្រះនោះដែរ។ គ្រីស្ទបរិស័ទដែលបានថ្វាយបង្គំព្រះបុត្រារួចក៏បានថ្វាយបង្គំព្រះវរបិតា ព្រោះទ្រង់បានទទួលស្គាល់តួនាទីដ៏រុងរឿងនៃព្រះបុត្រា។ «អ្នកណាដែលមិនគោរពប្រតិបត្តិដល់ព្រះរាជបុត្រា នោះក៏មិនគោរពប្រតិបត្តិដល់ព្រះវរបិតា ដែលចាត់ឲ្យទ្រង់មកដែរ» (ខ ២៣)។ តាមរយៈពាក្យអះអាងនេះគ្រីស្ទបរិស័ទគឺត្រូវបាន (ព្រះ)ទទួល ឯជនជាតិយូដាដែលបដិសេធព្រះគ្រីស្ទគឺត្រូវបានថ្កោលទោសវិញ។

អ្វីដែលគួរឲ្យចាប់អារម្មណ៍ជាងគេនៅក្នុង ខ ១៧-៣៩ ដ៏វែងនេះ គឺជាទំនាក់ទំនងរវាងព្រះបុត្រានិងព្រះវរបិតាដូចបានកត់សម្គាល់ខាងលើ។ ហេតុតែព្រះវរបិតាស្រឡាញ់ព្រះបុត្រាហើយព្រះបុត្រាស្រឡាញ់ព្រះវរបិតា យើងឃើញនូវភាពតែមួយនៃការសម្រេចព្រះហឫទ័យនិងប្រតិបត្តិការងាររវាងអង្គបុគ្គលទាំងពីរ។ បន្ថែមលើនេះ ព្រះវរបិតាបានប្រទានសិទ្ធិដល់ព្រះបុត្រា (ខ ២២និង២៧) បើកសម្ដែងផែនការដល់ព្រះបុត្រា (ខ ២០) និង «ទ្រង់នឹងបង្ហាញឲ្យឃើញការធំលើសជាងការទាំងនេះទៅទៀត ដើម្បីឲ្យអ្នករាល់គ្នាមានសេចក្ដីអស្ចារ្យ»។ ម្យ៉ាងវិញទៀត យើងឃើញព្រះបុត្រាអនុវត្តតាមគ្រប់ផែនការរបស់ព្រះវរបិតាយ៉ាងល្អប្រពៃស្របតាមបំណងព្រះហឫទ័យរបស់ទ្រង់ (ខ ៣០)។

តើការធំលើសជាងការទាំងនេះអ្វីដែលព្រះបុត្រានឹងធ្វើនៅពេលព្រះវរបិតាបង្ហាញឲ្យទ្រង់ឃើញ? តើជាការធំជាងការប្រោសបុរសមានជម្ងឺពិការ៣៨ឆ្នាំ? ការធំនោះគឺជាការប្រោសព្រលឹងវិញ្ញាណរបស់យើង ការប្រោសរូបកាយរបស់យើងពីស្លាប់ឲ្យមានជីវិតអស់កល្បនិងការថ្កោលទោសពួកមនុស្សអាក្រក់។

ព្រះគ្រីស្ទជាព្រះសង្គ្រោះចំពោះអស់អ្នកជឿ (ខ ២៤) និងជាចៅក្រមចំពោះអ្នកមិនជឿ។ ព្រះអង្គមានភាពតែមួយក្នុងការសម្រេចព្រះហឫទ័យនិងប្រតិបត្តិការដ៏គ្រប់លក្ខណ៍នឹងព្រះវរបិតា។ បើសាសន៍យូដាដឹងពីការនេះពួកគេនឹងអាក់អន់ចិត្តទេនៅពេលព្រះយេស៊ូវតាំងអង្គទ្រង់ស្មើនឹងព្រះដ៏ជាព្រះវរបិតា។ សូមទន្ទេញចាំ យ៉ូហាន ៥:២៤។

សំណួរចម្លើយនៃគោលជំនឿគ្រីស្ទបរិស័ទខ្នាតធំ សំណួរទី ១១៖ តើធ្វើយ៉ាងឲ្យព្រះរាជបុត្រានិងព្រះវិញ្ញាណបរិសុទ្ធជាព្រះស្មើគ្នានឹងព្រះវរបិតា?

ចម្លើយ៖ បទគម្ពីរបើកសម្ដែងថាព្រះរាជបុត្រានិងព្រះវិញ្ញាណបរិសុទ្ធគឺជាព្រះស្មើនឹងព្រះវរបិតា ដោយការទទួលស្គាល់អង្គបុគ្គលទាំងពីរនូវព្រះនាម លក្ខណះនិស្ស័យជាព្រះរបស់ទ្រង់ កិច្ចការ និងការថ្វាយបង្គំ ដែលសាកសមសម្រាប់តែព្រះ។

**ការពិចារណា៖** តើខ្ញុំប្រតិបត្តិដល់ព្រះរាជបុត្រាដែរទេ?
**ការអធិស្ឋាន៖** ព្រះជាម្ចាស់អើយ សូមបំបាត់នូវការសង្ស័យនៅក្នុងចិត្តខ្ញុំអំពីភាពជាព្រះនៃព្រះយេស៊ូវផង។

## ការបកស្រាយពីភស្តុតាងនៃផ្លូវច្បាប់

គោលការណ៍ដ៏ចាំបាច់របស់ក្រិត្យវិន័យលោកម៉ូសេក្នុងការជំនុំជំរះមនុស្សទាក់ទិននឹងការស្លាប់និងរស់គឺតម្រូវឲ្យមានអំណះអំណាងជាសាក្សីពីរឬបីនាក់ (ចោទិយកថា ១៧:៦)។ គោលការណ៍នេះបានក្លាយជា ភស្តុតាងនៃផ្លូវច្បាប់ជាសាកល។ ព្រះយេស៊ូវប្រើភស្តុតាងនៃផ្លូវច្បាប់នេះដើម្បីបិទមាត់ ពួកសាសន៍យូដាជាអ្នកបដិសេធនូវភាពជាព្រះរាជបុត្រានិងភាពស្មើគ្នារវាងទ្រង់នឹងព្រះវរបិតា ដោយសារតែពួកគេមិនព្រមជឿថាទ្រង់ជាជាព្រះ។

ព្រះយេស៊ូវបញ្ជាក់ពីភាពជាព្រះរាជបុត្រានិងភាពស្មើគ្នាជាមួយនឹងព្រះវរបិតា ហេតុដូចនេះបញ្ជាក់ថាទ្រង់គឺពិតជាព្រះតាមរយៈសាក្សីទាំងបួនធ្វើទីបន្ទាល់ប្រាប់។ (នេះជាតម្រូវការទ្វេរដងអាស្រ័យតាមភស្តុតាងនៃផ្លូវច្បាប់)។

១. លោក យ៉ូហាន-បាទីស្ទ៖ បើជនជាតិយូដាជឿតាមសេចក្ដីបង្រៀនរបស់លោកយ៉ូហានបាទីស្ទ តើហេតុអ្វីទើបពួកគេសង្ស័យពាក្យរបស់គាត់ប្រកាសថាព្រះគ្រីស្ទថាជាកូនចៀមនៃព្រះដែលដោះបាបមនុស្សលោក? (ខ ៣៣-៣៥)។

២. ការអស្ចារ្យរបស់ទ្រង់ ដែលមានលក្ខណះវិសេសជាងទីបន្ទាល់លោកយ៉ូហាន (ខ ៣៦)។

៣. ព្រះវរបិតា៖ (នាពិធីបុណ្យជ្រមុជរបស់ព្រះយេស៊ូវ ព្រះវរបិតាបានមានបន្ទូលពីស្ថានសួគ៌ខណះពេលព្រះវិញ្ញាណនៃព្រះបានយាងចុះមកដូចជាសត្វព្រាប។ ម៉ាថាយ ៣:១៧)។

៤. បទគម្ពីរ៖ ព្រះគម្ពីរសញ្ញាចាស់សរសេរដោយម៉ូសេនិងបណ្ដាហោរាជាសំណេរដ៏បរិសុទ្ធចំពោះជនជាតិយូដាដែលពួកគេជឿថាជាបទគម្ពីរដ៏គ្មានការភាន់ច្រឡំនិងគ្មានកំហុសឆ្គង។ លោកម៉ូសេបានកត់ត្រាប្រាប់ពីដំណើរកើតមកនៃហោរាដ៏ធំដែលជាព្រះគ្រីស្ទ។ តើហេតុអ្វីទើបគេមិនជឿទីបន្ទាល់របស់ម៉ូសេអំពីព្រះគ្រីស្ទ?

ពិតជាពាក្យដាស់តឿនដល់យើងគ្រប់ៗរូប ដែលជាគ្រីស្ទបរិស័ទតាមទំនៀមទម្លាប់ពីបីនិងបួនជំនាន់ តែមិនបានកើតជាថ្មី។ «បើមិនបានកើតជាថ្មីទេ គ្មានអ្នកណាអាចទៅនគរស្ថានសួគ៌បានឡើយ» (យ៉ូហាន ៣:៣)។

ទីបន្ទាល់មួយផ្សេងទៀតចំពោះព្រះយេស៊ូវគ្រីស្ទ ជាព្រះរាជបុត្រាតែ១នៃព្រះ គឺដំណឹងល្អទាំងបួន ដែលមានម៉ាថាយ ម៉ាកុស លូកា និងយ៉ូហាន។ (ដំណឹងល្អបីដំបូងត្រូវបានហៅជាភាសាអង់គ្លេសថា *«Synoptic Gospel»* ឬជាដំណឹងល្អសង្ខេប។ ពាក្យ *Synoptic* (ដែលជាសង្ខេប) មកពីពាក្យ *Synopsis* (សង្ខេប) ដែលមានន័យថា ប្រមូលផ្ដុំ ឬទស្សនះទូទៅអំពីប្រធានបទអ្វីមួយ។ ហេតុនេះដំណឹងល្អ យ៉ូហាន គឺត្រូវបានសរសេររៀបរៀងឡើងពីទស្សនះផ្ទាល់ខ្លួនរបស់គាត់។ លោកយ៉ូហាន ជាសិស្សដែលទ្រង់ស្រឡាញ់និងជាមនុស្សចំណោម «សាវ័កបីនាក់» ផ្ដល់ឲ្យយើងនូវទីបន្ទាល់ផ្ទាល់ខ្លួនអំពីព្រះគ្រីស្ទពីជម្រើសដ៏ហ្មត់ចត់បំផុត)។

**ការពិចារណា៖** មូលហេតុនៃការបដិសេធព្រះយេស៊ូវគ្រីស្ទរបស់មនុស្សជាតិ។
**ការអធិស្ឋាន៖** ឱព្រះអង្គអើយ ទោះមានគេបដិសេធទ្រង់ច្រើនយ៉ាង កុំឲ្យខ្ញុំបដិសេធទ្រង់ឡើយ។

*«មនុស្សមិនមែនរស់ ដោយសារតែនំបុ័ងប៉ុណ្ណោះទេ គឺរស់ដោយសារគ្រប់ទាំងព្រះបន្ទូល ដែលចេញពីព្រះឱស្ឋព្រះមកដែរ» (ម៉ាថាយ ៤:៤)។*

# ជំពូក ៦

## ចំពោះមនុស្សលោកីយ៍ដែលស្រេកឃ្លាន ព្រះយេស៊ូវគ្រីស្ទជានំបុ័ងជីវិត

ការប្រទានអាហារដល់មនុស្សប្រាំពាន់នាក់គឺសុទ្ធតែត្រូវបានកត់ត្រានៅក្នុងដំណឹងល្អទាំងបួនទាំងអស់។ សូមប្រៀបធៀប ម៉ាថាយ ១៤:១-១២ ម៉ាកុស ៦:៣០-៤៤ លូកា ៩:១០-១៧។ នេះជាការអស្ចារ្យមួយដែលមហាជនទទួលបទពិសោធន៍ហើយចងចាំឥតភ្លេច ដូចជាអាហារលើចានដ៏មានឱជារសជាប់មាត់ អស់រយះពេលដ៏យូរៗលង់។ ម្តាយនិងកូនទាំងឡាយប្រហែលនឹងអាចនិយាយពីនំបុ័ងដាក់សាច់ដែលពួកគេបរិភោគនៅឯជំរាលភ្នំស្រុកកាលីឡេនោះរហូតដល់ច្រើនឆ្នាំក្រោយមកទៀតជាមិនខាន។ ខណះពេលដំណឹងល្អណែនាំទៅឯសេចក្តីសង្គ្រោះផ្នែកព្រលឹងវិញ្ញាណដោយសារតែ «មនុស្សមិនមែនរស់ ដោយសារតែនំបុ័ងប៉ុណ្ណោះទេ គឺរស់ដោយសារគ្រប់ទាំងព្រះបន្ទូល ដែលចេញពីព្រះឱស្ឋព្រះមកដែរ» (ម៉ាថាយ ៤:៤) វាក៏មិនយឺតក្នុងការផ្គត់ផ្គង់សម្រាប់រូបកាយរបស់យើងនាពេលត្រូវការបន្ទាន់ដែរ។ ការប្រទានអាហារដល់មនុស្សទាំងប្រាំពាន់នាក់គឺជាការអស្ចារ្យនៃជំនួយដល់មនុស្សអត់ឃ្លាន ដែលមនុស្សទាំងនេះជាអ្នកស្រេកឃ្លានជាដំបូងនូវសេចក្តីសុច្ចរិត។ ការប្រទានអាហារដល់មនុស្សទាំងប្រាំពាន់នាក់បង្រៀនពួកជំនុំឲ្យបានបន្តបោះជំហានទៅមុខក្នុងការចែករំលែកសម្ភារះដើម្បីជួយដល់បងប្អូនដែលកំពុងរងទុក្ខលំបាកទាំងក្នុងបណ្តាពួកជំនុំ (កិច្ចការ ១១:២៧-៣០) និង «ពួកបងប្អូន» ដែលនៅខាងក្រៅពួកជំនុំផងដែរ (ម៉ាថាយ ២៥:៣១-៤៦)។ ប៉ុន្តែជំនួយត្រូវផ្តល់ឲ្យតែក្នុងគ្រាមានវិបត្តិប៉ុណ្ណោះ។

ជំនួយមិនត្រូវជួយនៅពេលគ្រាអាសន្នបានកន្លងផុតទេ ព្រោះពន្ធ័កិច្ចនៃព្រះអម្ចាស់ជាចម្បងគឺផ្តោតទៅលើផ្នែកព្រលឹងវិញ្ញាណ។ ដូច្នេះនៅពេលអ្នកខ្លះក្នុងបណ្តាមនុស្សប្រាំពាន់នាក់បានស្វែងរកព្រះអម្ចាស់នាថ្ងៃបន្ទាប់ ជាការពិតមិនមែនដើម្បីអាហារផ្នែកព្រលឹងវិញ្ញាណតែជាអាហារផ្នែករូបកាយ ព្រះអម្ចាស់នៃយើងបានបដិសេធមិនទទួលពួកគេដោយឥតមានលក្ខខណ្ឌ។ ព្រោះនគរព្រះគ្រីស្ទមិនមែនជា « ការស៊ី ឬផឹកនោះទេ គឺស្រេចនឹងសេចក្តីសុចរិត សេចក្តីមេត្រី និងសេចក្តីអំណរ ដោយនូវព្រះវិញ្ញាណបរិសុទ្ធវិញទេតើ» (រ៉ូម ១៤:១៧)។

វគ្គបន្តបន្ទាប់ពីការប្រទានអាហារដល់មនុស្សទាំងប្រាំពាន់នាក់គឺជាការអធិប្បាយបង្រៀនរបស់ព្រះអម្ចាស់ដ៏វែងអំពីនំបុ័ងដែលអាចបន្តឲ្យមានជីវិតអស់កល្បជានិច្ច។ នំបុ័ងអស្ចារ្យដែលកើតឡើងពីនំបុ័ងប្រាំដុំនិងត្រីពីរកន្ទុយនៅមានគុណភាពត្រឹមតែពីរឬបីម៉ោងទេសម្រាប់ពួកអ្នកដែលសប្បាយរីករាយតែផ្នែកខាងក្រៅ តែបើអាចនៅមានគុណភាពហូតដល់បច្ចុប្បន្ននិងជារៀងរហូតតទៅគឺសម្រាប់អ្នកដែលសប្បាយរីករាយផ្នែកខាងក្នុងវិញ។ មិត្តអ្នកអាន តើនំបុ័ងអ្វីដែលលោកអ្នកកំពុងស្វែងរក?

**ការពិចារណា៖** ចូរស្វែងនំបុ័ងជីវិតជាមុន ទើបមានចិត្តស្កប់ស្កលនឹងនំបុ័ងចំអែតក្រពះ។
**ការអធិស្ឋាន៖** ឱសូមព្រះគ្រីស្ទជាទី១ នឹងគ្រប់យ៉ាងតាមលំដាប់ដោយរបស់វាចុះ។

ថ្ងៃទី ៦ សីហា
យ៉ូហាន ៦:១-១៤

*«...ឲ្យគ្រាន់តែទទួលដោយអរព្រះគុណប៉ុណ្ណោះ» (១ ធីម៉ូថេ ៤:៤)។*

## មេរៀនសម្រាប់កិច្ចសាមញ្ញពីកិច្ចការដ៏អស្ចារ្យ

តើអ្នកដឹងទេថាមានករណីពីការអស្ចារ្យនៃការប្រទានអាហារមួយទៀត គឺការប្រទានអាហារសំរាប់មនុស្សបួនពាន់នាក់ដោយនំប៉័ងប្រាំពីរដុំនិងត្រីពីរបីកន្ទុយដែរឬទេ (ម៉ាថាយ ១៥:៣២-៣៩ ម៉ាកុស ៨:១-១០)? នៅក្នុងករណី (អត្ថបទព្រះគម្ពីរ) នេះ ពួកបណ្ដាជនបានអត់អាហារបរិភោគ រយៈពេលបីថ្ងៃមកហើយ! តើរយៈពេលយូរប៉ុណ្ណាដែលមនុស្សទាំងប្រាំពាន់នាក់មិនបានបរិភោគ អាហារ? សូមអានកំណត់ត្រានៅក្នុងដំណឹងល្អទាំងបី (ម៉ាថាយ ម៉ាកុស និងលូកា)។ វិធីសាស្ត្រមួយនៃការសិក្សាព្រះគម្ពីរគឺត្រូវអាននូវកំណត់ត្រាទាំងអស់ដើម្បីបង្កើតនូវរូបផ្គុំគ្នាមួយ។

នៅក្នុងដំណឹងល្អតាមរយៈយ៉ូហាន លោកភីលីពគឺជាមនុស្សដ៏សំខាន់ម្នាក់ប្រៀបដូចជា «នាយទាហានផ្នែកភស្តុភារ» ប៉ុន្តែគាត់គ្មានដំណោះស្រាយដើម្បីផ្ដល់អាហារដល់ហ្វូងមនុស្សដ៏ធំដែលមានបុរស ៥,០០០ នាក់ដោយមិនរាប់ចំនួនស្ត្រីនិងកុមារ។ ឯលោកអន់ទ្រេដែលមានតួនាទីជាអ្នកនាំពេត្រុសជាប្អូនប្រុសខ្លួន ពេលនេះគឺឃើញថាគាត់បាននាំក្មេងប្រុសមកដែលក្មេងនោះមាននំប៉័ងប្រាំដុំនិងត្រីពីរកន្ទុយ។ ចូរយើងរៀនពីអន់ទ្រេដើម្បីធ្វើជាអ្នកនេសាទមនុស្សដ៏ល្អ។

នៅក្នុងការសម្ដែងការអស្ចារ្យ ដំណឹងល្អបានកត់ត្រាមកថាជាដំបូងព្រះគ្រីស្ទបានពោលពាក្យអរព្រះគុណ។ ការផ្ដល់នូវសេចក្ដីអត្ថាធិប្បាយត្រង់ចំណុចនេះ កាល់វីន លោកមានប្រសាសន៍ថា៖ «ព្រះគ្រីស្ទបានបង្រៀនយើងជាគំរូលើសជាងមួយដងថាយើងគួរតែចាប់ផ្ដើមបរិភោគអាហាររបស់យើងដោយការអធិស្ឋាន។ ដោយហេតុតែសេចក្ដីទាំងអស់ដែលព្រះបានតែងតាំងទុកសម្រាប់ការប្រើប្រាស់របស់យើង (ហើយទ្រង់)បង្គាប់ឲ្យយើងសរសើរទ្រង់ទុកដូចជានិមិត្តសញ្ញានៃសេចក្ដីសប្បុរសដ៏ធំធេងនឹងដោយសេចក្ដីស្រឡាញ់ក្នុងភាពជាបងប្អូនដល់យើង។ ការអរព្រះគុណដូចជាសាវ័កប៉ូលបង្គាប់យើងនៅក្នុង ១ ធីម៉ូថេ ៤:៤ គឺជាញែកជាបរិសុទ្ធ ដូច្នេះការប្រើប្រាស់គ្រឿងបរិភោគទាំងនេះនឹងប្រែជាបរិសុទ្ធដល់យើងគ្រប់រូប។ តែវានឹងអាស្រ័យលើអ្នកបរិភោគអាហារទាំងអស់ដែលឥតបានគិតដល់ព្រះ អ្នកទាំងនោះនឹងក្លាយជាអ្នកប្រមាថមើលងាយចំពោះអំណោយទានរបស់ទ្រង់។ ហើយសេចក្ដីបង្រៀននេះគួរបានត្រង់ត្រាប់ឲ្យបានខ្ជាប់ខ្ជួន ពីព្រោះយើងនៅឃើញមានមនុស្សជាច្រើននៃលោកីយនេះនៅតែបរិភោគដូចជាសត្វ។ តាមរយៈការមានព្រះទ័យចង់ប្រទាននំប៉័ង ដែលនឹងប្រទានដល់សាវ័កដើម្បីឲ្យកើនបរិមាណបានច្រើននៅក្នុងដៃរបស់យើង យើងបានរៀននូវមេរៀនពីការព្រះប្រទានពរកិច្ចការរបស់យើងនៅពេល យើងបម្រើគ្នាទៅវិញទៅមក»។

ការប្រមូលចំណិតនំប៉័ងដប់ពីរកន្ត្រកបង្រៀនយើងនូវមេរៀននៃការសន្សំសំចៃ។ ការខ្ជះខ្ជាយគឺជាអំពើបាប។ រាល់គ្រាប់បាយនៅក្នុងចានរបស់អ្នកគួរតែបរិភោគឲ្យអស់! ព្រះជាម្ចាស់គឺជាសេដ្ឋវិទូ (អ្នកសន្សំសំចៃ)។ ហើយការសន្សំសំចៃគឺជាមាតានៃភាពសំបូរមានបាន។

ព្រះពរដ៏ហូរហៀររបស់ព្រះនឹងមិនអនុញ្ញាតឲ្យយើងជាអ្នកសំបូរបែបទុកអាហារល្អៗដែលពុំទាន់បរិភោគចោលដូចឃើញនៅតាមពិធីជប់លៀងអាហារពេលល្ងាចនៃអាពាហ៍ពិពាហ៍ជនជាតិឡើយ។ ចូរអ្នកដែលចាប់អារម្មណ៍នូវការនេះដឹងថា ខ្លួននឹងត្រូវឆ្លើយតបនូវទ្រព្យសម្បត្តិដ៏ច្រើនលើសលប់ បើគេមិនបានអនុវត្តដោយប្រុងប្រយ័ត្នពីការប្រើប្រាស់វាឲ្យបានស្របតាមគោលបំណងល្អត្រឹមត្រូវ។

**ការពិចារណា៖** ការសន្សំសំចៃគឺជាមាតានៃភាពសំបូរមានបាន។

**ការអធិស្ឋាន៖** ព្រះអម្ចាស់អើយ កុំឲ្យខ្ញុំភ្លេចឡើយនូវរាល់ព្រះពរដែលទ្រង់បាននាំមកក្នុងជីវិតខ្ញុំ។

## «មានព្រះយេស៊ូវគង់ក្នុងទូក យើងអាចញញឹមពេលមានព្យុះ»

សម្រាប់កំណត់ត្រាពិស្ដារអំពីព្រះយេស៊ូវយាងលើទឹក សូមអានម៉ាថាយ ១៤:២២-៣៦ ម៉ាកុស ៦:៤៥-៥៦។ ក្រោយពីបានប្រទានអាហារដល់មនុស្សទាំងប្រាំពាន់នាក់ដោយការអស្ចារ្យ គឺជាសាវ័កយ៉ូហានដែលបានកត់ត្រាពីដំណើរហ្វូងមនុស្ស «គេគិតមកចាប់ទ្រង់ដោយកំលាំង ដើម្បីនឹងតាំងឡើងជាស្តេច» (យ៉ូហាន ៦:១៥)។ ដោយព្រះគ្រីស្ទបានយាងមកបង្កើតនគរខាងឯវិញ្ញាណហើយមិនមែនជានគរខាងផ្នែកសាច់ឈាមដូចជាបណ្តាមហាជនបានយល់ នេះពិតជាធ្វើឲ្យទ្រង់ខកព្រះទ័យយ៉ាងខ្លាំង។ ដើម្បីធ្វើឲ្យគោលបំណងរបស់ពួកអ្នកបះបោរខកខាន ព្រះអម្ចាស់នៃយើងបាន «បង្គាប់ជាបន្ទាន់» ឲ្យពួកសិស្សរបស់ទ្រង់ត្រឡប់ទៅផ្ទះតាមទូកខណៈពេលទ្រង់បំបែកហ្វូងមនុស្ស រួចយាងចាកចេញទៅតែអង្គទ្រង់ដើម្បីអធិស្ឋាន (ដូចជាទ្រង់ធ្លាប់ធ្វើជារៀងរាល់ពេលមានវិបត្តិ)។ យើងគួរតែរៀននូវអាថ៌កំបាំងនេះអំពីភាពនឹងធឹងជាម្ចាស់លើខ្លួនឯង។

ដោយសារតែទឹកបឹងមានទំហំធំរវាងទីកន្លែងប្រទាននំបុ័ងដោយការអស្ចារ្យនឹងត្រើយខាងលិច មិនជាយូរប៉ុន្មានក៏មានខ្យល់ព្យុះបក់រារាំងឲ្យទូកមានល្បឿនយឺត ពួកសិស្សបានចំណាយពេលពេញមួយយប់ព្យាយាមឆ្លងទៅត្រើយម្ខាងទៀត។ ព្រះយេស៊ូវទតឃើញពួកសិស្សពីចម្ងាយកំពុងខិតខំអុំនឹងចង្វាររបស់គេដោយព្រះនេតនៃភាពជាព្រះរបស់ទ្រង់ ព្រះអង្គក៏ធ្វើដំណើរដោយព្រះបាតនៃព្រះឆ្លងកាត់ទឹកទៅមើលប្រសិនទ្រង់អាចជួយដល់គេបាន។ (គឺលោកម៉ាថាយជាអ្នកផ្តល់ព័ត៌មានលម្អិតនូវកំណត់ត្រាអំពីសាវ័កពេត្រុសភ័យញ័រដើរលើទឹកលលកដូចជាព្រះអម្ចាស់)។ ដំបូងឡើយពួកគេភ័យខ្លាចព្រោះ ដូចជាលោកម៉ាកុសប្រាប់យើង ពួកគេបានគិតថាគេបានឃើញខ្មោច។ ក៏ប៉ុន្តែព្រះយេស៊ូវកំសាន្តចិត្តដល់ពួកគេ ដោយការរំឭកនូវព្រឹត្តិការណ៍ឆ្លងកាត់បឹងកាលពីគ្រាមុននឹងការបង្គាប់ឲ្យព្យុះស្ងប់ស្ងៀមដែលព្រះសង្គ្រោះបានធ្វើ។ ពួកគេក៏មានក្តីទំនុកចិត្ត ដូចនេះគេប្រាកដជាបានអុំទូកយ៉ាងលឿនទ្វេរដងឆ្ពោះទៅកាន់ដីគោកក្នុងរយៈដ៏ខ្លី។ ដូចជាសុភាសិតបុរាណពោលថា៖ «មានមិត្តរួមដំណើរល្អគឺអាចដើរលឿនដូចជាជិះរទេះសេះអញ្ចឹង»។ លោកបានយ៉ាន (*Bunyan*) មានប្រសាសន៍ថា៖ «នៅពេលព្រះគ្រីស្ទអវត្តមានពីរាស្ត្ររបស់ទ្រង់ ពួកគេនឹងបន្តដំណើរទៅយ៉ាងយឺតនឹងយ៉ាងលំបាក តែនៅពេលទ្រង់រួមដំណើរនឹងពួកគេ អូ! ពួកគេពិតជាអាចធ្វើដំណើរឆ្ពោះទៅមុខតាមដងផ្លូវយ៉ាងរលូន! ពួកគេនឹងឆ្ពោះទៅដល់ត្រើយទៅយ៉ាងលឿនបំផុត!»។

*«នៅក្នុងដួងចិត្តខ្ញុំមានព្រះយេស៊ូ ជីវិតខ្ញុំធូរផុតទុក្ខអំពល់*
*ទ្រង់ដកអស់ក្តីតប់ប្រមល់ ទ្រង់ដកអស់ទុក្ខព្រួយកង្វល់*
*ចិត្តខ្ញុំបានស្កប់ស្កល់ដោយផលព្រះវិញ្ញាណ នៅគ្រាវេទទុក្ខវេទនា*
*នៅគ្រាតែលតោលឯកា ទ្រង់លូកហត្ថាមកជួយខ្ញុំមិនដែលខាន។*
*ព្រះយេស៊ូគង់នៅទីណា ទីនោះមានក្តីសុខសាន្ត (ស្ងួន)»។* -- ទំនុកខ្មែរបរិសុទ្ធ ១១២

**ការពិចារណា៖** មានព្រះគង់ក្នុងទូក យើងអាចញញឹមពេលមានព្យុះ។
**ការអធិស្ឋាន៖** ព្រះអង្គសង្គ្រោះ.. សូមគង់ជិតបង្កើយ កាលព្រះអង្គកំពុង..តែប្រោសគេ សូមកុំចោលខ្ញុំឡើយ!

ថ្ងៃទី ៨ សីហា
យ៉ូហាន ៦:២២-២៩

*«ចូរកុំឲ្យខំប្រឹងបានតែអាហារ ដែលតែងតែពុករលួយនោះឡើយ ចូរខំឲ្យបានអាហារ ដែលនៅស្ថិតស្ថេរ ដរាបដល់ជីវិតអស់កល្បជានិច្ចវិញ...»។*

## តើនេះគឺជាការស្វែងរករបស់យើងដែរ?

ទោះបីជាព្រះយេស៊ូវបានបំបែកហ្វូងមនុស្សនឹងបានបញ្ជូនសិស្សទ្រង់ឲ្យត្រឡប់ទៅស្រុកកាពើណើមជាទីស្នាក់ការធំរបស់ទ្រង់វិញ ក៏មហាជនដែលទ្រង់បានចំអែតពួកគេដោយនំបុ័ងនៅបន្តព្យាយាមស្វែងរក «ស្តេច» របស់គេជានិច្ចដែរ។ ទូកជាច្រើនពីស្រុកទីបេរាស ដែលស្ថិតនៅនាច្រាំងខាងត្បូងក៏នាំឆ្ពោះមកគោលដៅនៃក្រុងផ្នែកព្រលឹងវិញ្ញាណដូចគ្នាដែរ ប៉ុន្តែអ្វីដែលមនុស្សទាំងនោះស្វែងរកគឺជាសម្ភារៈ។ នៅពេលព្រះវិហារមានលំនឹង ហើយផ្តល់ប្រាក់ខែល្អនិងតួនាទីដែលមានប្រាក់បន្ថែម ព្រះវិហារនឹងពុំចាំបាច់បារម្ភពីអ្នកដើរតាមឡើយ។ តើនោះគឺជាមូលហេតុដែលបងប្អូនខ្លះអញ្ជើញមកព្រះវិហារ? តើការស្វែងរកនំបុ័ងក៏ជាការស្វែងរករបស់យើងដែរ?

ព្រះយេស៊ូវបានដាស់រំឭកមនុស្សទាំងប្រាំពាន់នាក់នេះយ៉ាងច្បាស់។ ដូចជាទ្រង់មិនភ្លេចនូវគោលបំណងរបស់ទ្រង់នាពេលព្រះអង្គប្រោសជម្ងឺដល់ពួកមហាជន (ម៉ាកុស ១:៣៧-៣៩) ហេតុនេះទើបទ្រង់បានបដិសេធមិនប្រទានអាហារជាថ្មីម្តងទៀតដល់ពួកគេ។ ព្រះអង្គមានបន្ទូលឆ្លើយតបទៅគេថា៖ «ប្រាកដមែនខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា អ្នករាល់គ្នារកខ្ញុំ មិនមែនដោយព្រោះបានឃើញទីសំគាល់ទេ គឺដោយព្រោះតែបានបរិភោគនំបុ័ងឆ្អែតប៉ុណ្ណោះ»។ ដូច្នេះជំនួសការប្រទាននំបុ័ងដល់គេ ទ្រង់បានប្រទាននូវនំបុ័ងដែលមិនចេះផ្អូមខូច ជានំនៅរហូតជារៀងរហូត។ សម្រាប់នំបុ័ងនេះពួកគេត្រូវតែខំធ្វើការស្វែងរក។ ដោយរបៀបណា? នៅក្នុងខ ២៩ ព្រះយេស៊ូវបានសង្កត់ធ្ងន់ទៅលើសារៈសំខាន់នៃសេចក្តីជំនឿ។ ការជឿលើទ្រង់ មានន័យថាយើងទទួលយកទ្រង់ យើងទទួលបាននូវនំបុ័ងដ៏មិនចេះខូចរលួយតែជានំបុ័ងនៅរហូតដល់ជីវិតអស់កល្ប។ ជំនឿគឺជាសេចក្តីដ៏ចាំបាច់ដើសម្រាប់ទទួលលបាននូវគុណតម្លៃខាងផ្នែកព្រលឹងវិញ្ញាណ ហើយសេចក្តីសង្គ្រោះនៅក្នុងព្រះអម្ចាស់យេស៊ូវគ្រីស្ទក៏ដូច្នោះដែរ។ ជំនឿគឺជាការបម្រើកិច្ចការរបស់ព្រះ!

នាងម៉ាថានិងនាងម៉ារា ទាំងពីរនាក់បងប្អូនគឺជាសិស្សរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទដូចគ្នា។ ម៉ាថា នាងរវល់ខ្លាំងនឹងការចំអិននិងរៀបចំណីអាហារ ហើយដោយពុំចាំបាច់សង្ស័យ វាគឺជាកិច្ចការចាំបាច់ដើម្បីថ្វាយអាហារដ៏ឱជារសដល់ព្រះអម្ចាស់នៃយើង។ ចំណែកឯនាងម៉ារាកំពុងអង្គុយនៅទៀបព្រះបាទរបស់ព្រះយេស៊ូវស្តាប់ការបង្រៀនរបស់ទ្រង់។ ថ្វីដ្បិតព្រះយេស៊ូវមិនបានច្រានចោលនូវតម្លៃកិច្ចបម្រើរបស់ម៉ាថា ទ្រង់ក៏មិនអាចនឹងលាក់ទុកក្នុងការមានបន្ទូលប្រាប់ដល់នាង ពីម៉ារាជាប្អូនស្រីរបស់នាងដែលបានជ្រើសយកកិច្ចការល្អប្រសើរដែលគ្មានអ្នកណានឹងដកយកចេញពីនាងបានដែរ។ ការបំពេញការងារសម្រាប់ផាសុខភាពក្នុងជីវិតគឺជាការល្អត្រឹមត្រូវ តែវាជាការងារបណ្តោះអាសន្នប៉ុណ្ណោះ។ ការធ្វើកិច្ចការសម្រាប់សេចក្តីសង្គ្រោះនៃព្រលឹងវិញ្ញាណរបស់បុគ្គលម្នាក់គឺប្រសើរជាង ពីព្រោះគុណតម្លៃរបស់វាគឺស្ថិតស្ថេរជាដរាប។

សូមទន្ទេញ យ៉ូហាន ៦:២៧ «ចូរកុំឲ្យខំប្រឹងបានតែអាហារ ដែលតែងតែពុករលួយនោះឡើយ ចូរខំឲ្យបានអាហារ ដែលនៅស្ថិតស្ថេរ ដរាបដល់ជីវិតអស់កល្បជានិច្ចវិញ ជាអាហារដែលកូនមនុស្សនឹងឲ្យមកអ្នករាល់គ្នា ដ្បិតគឺកូនមនុស្សនេះហើយ ដែលព្រះវរបិតាដ៏ជាព្រះ ទ្រង់បានដៅចំណាំទុក»។

**ការពិចារណា៖** តើមានកើតឡើងចំពោះគ្រីស្ទបរិស័ទដូរបាយ?

**ការអធិស្ឋាន៖** «ឱព្រះអង្គអើយ ព្រលឹងទូលបង្គំដង្ហក់រកទ្រង់ ដូចជាក្តាន់ញីដង្ហក់រកជ្រោះទឹក» (ទំនុកដំកើង ៤២:១)។

*«ខ្ញុំជានំបុ័ងជីវិត អ្នកណាដែលមកឯខ្ញុំ នោះនឹងមិនឃ្លានទៀតឡើយ ហើយអ្នកណាដែលជឿដល់ខ្ញុំ ក៏មិនត្រូវស្រេកដែរ»។*

## តើជាទីសម្គាល់អ្វី?

បន្ទាប់ពីមនុស្សទាំង៥០០០នាក់បានឃើញនិងបរិភោគនំបុ័ងនៃការអស្ចារ្យរួច ពួកគេបានទាមទាររកទីសម្គាល់ ព្រោះតែព្រះយេស៊ូវហាក់ជាមនុស្សចម្លែកចំពោះគេ។ ទង្វើបែបនេះបង្ហាញយ៉ាងច្បាស់នូវភាពគ្មានជំនឿខាងក្នុងចិត្តរបស់ពួកគេ ហើយវាសមស្របនឹងការថ្កោលទោសនៃព្រះអម្ចាស់ចំពោះសាសន៍យូដាក្នុងម៉ាថាយ ១២:៣៩ «ដំណមនុស្សអាក្រក់ ហើយកំផិត គេចេះតែចង់ឃើញទីសំគាល់»។ ជាការពិត ពួកគេប្រមាថការអស្ចារ្យទាំងអស់ដែលគេបានឃើញពីមុន ដោយសារតែព្រះគ្រីស្ទមិនបានបំពេញតាមបំណងរបស់គេ។ លើសជាងនេះទៅទៀត ព្រះអង្គបានបង្វែរដំណើរយកចិត្តទុកដាក់របស់គេទៅផ្នែកព្រលឹងវិញ្ញាណ ជាសេចក្តីគេមិនចូលចិត្ត។

ពេលនេះពួកគេចាប់ផ្តើមដំកើងព្រះដែលបានប្រទាននំម៉ាណាឲ្យបុព្វបុរសរបស់គេបរិភោគនៅក្នុងទីរហោស្ថាន ពាក្យដំកើងនោះគឺគ្រាន់តែពាក្យបិទបាំងនូវគោលបំណងសម្ភារៈនិយមដែលព្រះអម្ចាស់បានថ្កោលទោសគេប៉ុណ្ណោះ។ ពួកគេថែមទាំងបានហៅនំម៉ាណាជានំបុ័ងមកពីស្ថានសួគ៌។ គេបានយល់ខុសជាថ្មីម្តងទៀត។ ថ្វីដ្បិតនំបុ័ងនេះធ្លាក់ចុះពីស្ថានសួគ៌ វាមិនមែនមកពីលោកម៉ូសេទេ តែវាមកពីព្រះវិញ។ នំម៉ាណាត្រូវបានប្រទានមកក្នុងអត្ថន័យដ៏ជ្រៅមួយ គឺដើម្បីណែនាំគេឲ្យចូលទៅឯព្រះគ្រីស្ទ ជាអង្គបុគ្គលយាងចុះមកពីស្ថានសួគ៌ ជានំបុ័ងដ៏ពិត យាងមកប្រទានជីវិតដល់លោកីយ។

ឥឡូវនេះព្រះយេស៊ូវដឹកនាំយើងចូលទៅក្នុងចំណុចដ៏កំពូលរបស់ទេវសាស្ត្រនៃការកើតជាថ្មី ដោយការផ្តល់ឲ្យយើងនូវចំណេះដឹងពីបញ្ហាដ៏អស់កល្បរបស់ព្រះជាម្ចាស់ គឺជាគោលលទ្ធិនៃការស្គាល់ជាមុន (*Predestination*) និងការជ្រើសតាំង (*Election*)។ ប្រាំពាន់នាក់បានបរិភោគនំបុ័ងពីការអស្ចារ្យ ក៏ប៉ុន្តែតើមានប៉ុន្មានអ្នកក្នុងពេលតែមួយបរិភោគខាងក្នុងចិត្តនូវ «នំបុ័ងពីស្ថានសួគ៌» នោះ (ខ ៣២)? បន្ទាប់ពីការអធិប្បាយដ៏វែងអំពីនំបុ័ងជីវិត ព្រះគម្ពីរបានកត់ត្រាថា «តាំងពីនោះមក មានសិស្សទ្រង់ជាច្រើនដកខ្លួនថយចេញ មិនតាមទ្រង់ទៀតទេ» (ខ ៦៦)។ ពិតជាឆ្លុះបញ្ចាំងឲ្យឃើញពីការវិលត្រឡប់រកជីវិតចាស់របស់ពួកអ្នកមកព្រះវិហារមែន។ នៅពេលតម្រូវឲ្យអ្នកស្តាប់លះបង់ការខិតខំស្វែងរកជីវិតបែបលោកីយរបស់គេនិងទទួលយកឈើឆ្កាង មនុស្សជាច្រើនត្រឡប់ទៅរកទម្លាប់ចាស់របស់គេ មានដូចជា ការលេងល្បែងស៊ីសង លេងបៀរតង (*mahjong*) ការចាក់សេះប្រណាំង ស៊ីផឹក ជក់បារី សាហាយស្មន់ មើលកុន ចូលបារ លេងកីឡាថ្ងៃអាទិត្យ ។ល។ និង ។ល។

មានតែពួកអ្នកជ្រើសតាំង ដែលព្រះបានជ្រើសទេទើបនឹងនៅជាប់ (ក្នុងជំនឿ)។ សូមអាន ខ ៣៧,៣៩, ៤៤, ៤៥។ ប៉ុន្តែបើអ្នកគឺជាអ្នកជ្រើសតាំង អ្នកនឹងតស៊ូនៅក្នុងជំនឿរហូតដល់ទីបញ្ចប់។ ព្រះគ្រីស្ទនឹងលើកអ្នកឡើងវិញនាថ្ងៃចុងក្រោយ (ខ ៣៩)។ ចំពោះអ្នកដែលជឿដោយស្មោះត្រង់គឺស្ថិតក្នុងចំណោមពួកអ្នកជ្រើសតាំងនិងបានសង្គ្រោះជារៀងរហូត! សូមទន្ទេញចងចាំ យ៉ូហាន ៦:៣៧។

**ការពិចារណា៖** តើទីសម្គាល់ចាំបាច់សម្រាប់ការមានជំនឿលើព្រះយេស៊ូវគ្រីស្ទ?
**ការអធិស្ឋាន៖** ឱអរព្រះគុណ ព្រះអម្ចាស់អើយ ខ្ញុំបានដឹងហើយថា ទ្រង់បានជ្រើសខ្ញុំឲ្យបានសង្គ្រោះ។

The Gospel of Life (□□□□□□□□□□□□□□□)-A5_ata.indd 47 2021-06-30 12:29:16 PM

*«ខ្ញុំជានំបុ័ងជីវិត» (យ៉ូហាន ៦:៤៨)។*

## ទីសម្គាល់នៃឈើឆ្កាង

ទីសម្គាល់នៃឈើឆ្កាងគឺជាសេចក្តីស្លាប់! នៅសម័យបុរាណ ឈើឆ្កាងគឺជាឧបករណ៍ប្រើសម្រាប់ឆ្កាងសម្លាប់អ្នកជាប់ទោសប្រហារជីវិត។ ព្រះយេស៊ូវត្រូវបានគេកាត់ទោសប្រហារជីវិតនៅលើឈើឆ្កាងដើម្បីសងសំណងទណ្ឌកម្មនៃអំពើបាបរបស់យើង។ បើគ្មានការសុគតរបស់ទ្រង់ យើងនឹងពុំអាចទទួលបានជីវិតមកវិញទេ ក៏ប៉ុន្តែតាមរយៈការសុគតរបស់ព្រះអង្គយើងមានជីវិតដ៏នៅអស់កល្បជានិច្ច។ ហើយយើងនឹងមិនអាចមានជីវិតដ៏នៅអស់កល្បជានិច្ចនេះបានដែរ ប្រសិនណាគ្មានការទុកចិត្តលើទ្រង់ គឺដោយការជឿទ្រង់ឲ្យអស់អំពីចិត្តរបស់យើង។

ការជឿតែបបូរមាត់ ឬតែក្នុងខួរក្បាល គឺវាមិនទាន់គ្រប់គ្រាន់នៅឡើយ។ នេះគឺជាករណីពិសេសនៃពួកអ្នកដែលធំពេញវ័យក្នុងក្រុមជំនុំ ជាអ្នករំជួលចិត្តដោយសារទំនៀមទម្លាប់គ្រីស្ទបរិស័ទដ៏យូរលង់ថ្វាយការយល់ស្របត្រឹមតែខាងគំនិត។ យើងត្រូវជឿឲ្យអស់ពីចិត្តរបស់យើង ពិតណាស់ គឺត្រូវជឿយ៉ាងជ្រាលជ្រៅទៅក្នុងពោះរបស់យើង(ជ្រួតជ្រាបក្នុងចិត្តជីវិតរបស់យើងទាំងស្រុង) ទៀតផង។ នោះគឺជាបទពិសោធន៍ជាមួយក្មេងប្រុសអាយុ១២ឆ្នាំម្នាក់ដែលជិតនឹងស្លាប់ដោយសារជម្ងឺបេះដូង។ ក្មេងម្នាក់នេះបានស្នើសុំទទួលបុណ្យជ្រមុជទឹកមុនការស្លាប់របស់គាត់។ ក្រោយពីបានប្រោះទឹកលើក្បាលរបស់គាត់រួច គាត់បានសួរថាបើគាត់ត្រូវផឹកទឹកពីក្នុងផ្តិលដាក់ទឹកសម្រាប់ពិធីជ្រមុជដែរ។ សំណើរនេះគឺសម្តែងឲ្យឃើញយ៉ាងច្បាស់នូវជម្រៅនៃសេចក្តីជំនឿដ៏រស់រវើករបស់គាត់។

នេះជាអ្វីដែលព្រះយេស៊ូវចង់ប្រាប់ពីអត្ថន័យនៅក្នុងផ្នែកទីពីរនៃសេចក្តីអធិប្បាយរបស់ទ្រង់ស្តីអំពីនំបុ័ងជីវិត។ នំបុ័ងនោះគឺជារូបកាយនិងលោហិតរបស់ទ្រង់។ លុះត្រាតែយើងបរិភោគសាច់របស់ទ្រង់និងផឹកព្រះលោហិតរបស់ទ្រង់ យើងនឹងគ្មានជីវិតឡើយ។ លុះត្រាតែយើងជឿ រហូតដល់យើងស្លាប់និងស៊ូក្នុងសេចក្តីទុក្ខលំបាក បើមិនដូច្នោះទេ យើងនឹងបន្តនៅខាងក្រៅព្រះគ្រីស្ទ។ ជំនឿបែបនេះគឺបានឃើញជាគំរូក្នុងការទទួលពិធីលៀងព្រះអម្ចាស់។ នៅពេលយើងទទួលពិធីលៀងព្រះអម្ចាស់ តើខាងព្រលឹងវិញ្ញាណរបស់យើងបានបរិភោគសាច់និងលោហិតរបស់ទ្រង់ដែរឬទេ? បើអត់ទេ យើងមិនមានជីវិតដ៏អស់កល្បនៅឡើយទេ។ យើងនៅជាមនុស្សមិនទាន់បានសង្គ្រោះ ជាគ្រីស្ទបរិស័ទតែនាមប៉ុណ្ណោះ។ ដូចជាសាសន៍យូដាដែលជជែកគ្នាក្នុងចំណោមពួកគេថា៖ «ធ្វើដូចម្តេចឲ្យអ្នកនេះអាចនឹងឲ្យសាច់ខ្លួនមកយើងបរិភោគបាន?» (ខ ៥២)។ ដូចជាសាសន៍យូដាដែលស្តាប់ឮព្រះយេស៊ូវបង្រៀនក្នុងសាលាប្រជុំនៅស្រុកកាពើណិមស៊កសម្តីថា៖ «ពាក្យនេះពិបាកស្តាប់ណាស់ តើអ្នកណាយល់បាន?» (ខ 60)។ ទោះជាយ៉ាងណា ការគ្មានជំនឿរបស់ពួកគេនិងការគ្មានជំនឿរបស់យើងមិនធ្វើឲ្យព្រះអម្ចាស់ភ្ញាក់ផ្អើលឡើយ។ «នេះដ្បិតព្រះយេស៊ូវទ្រង់ជ្រាបតាំងតែពីដើមមក អំពីអ្នកណាដែលមិនបានជឿ ហើយអំពីអ្នកណា ដែលនឹងបញ្ជូនទ្រង់» (ខ ៦៤)។

**ការពិចារណា៖** ទីសម្គាល់នៃឈើឆ្កាង គឺជាទីសម្គាល់នៃសេចក្តីស្រឡាញ់របស់ព្រះចំពោះមនុស្សបាត់បង់។
**ការអធិស្ឋាន៖** ព្រះជាម្ចាស់អើយ សូមឲ្យខ្ញុំឃើញការសង្គ្រោះអ្នកមានបាបក្នុងជីវិតខ្ញុំផង។

ថ្ងៃទី ១១ សីហា
យ៉ូហាន ៦:៦០-៧១

*«...យើងខ្ញុំក៏ជឿហើយដឹងថាទ្រង់ជាព្រះគ្រីស្ទ ជាព្រះរាជបុត្រានៃព្រះដ៏មានព្រះជន្មរស់ពិត»។*

**ការអធិប្បាយអំពីឈើឆ្កាងគឺជាព្រះចេស្តា** (២ កូរិន ២:១-៤)

ខណៈពេល «ពួកសិស្ស» ភាគច្រើនជាអ្នកស្រុកកាលីឡេបានចាកចេញពីព្រះគ្រីស្ទ ក៏នៅមានសិស្សស្មោះត្រង់ទាំងដប់ពីរនាក់ លើកលែងតែយូដាស-អ៊ីស្ការីយ៉ុត បន្តនៅជាប់នឹងទ្រង់ដែរ។ ចំណុចនេះ ព្រះយេស៊ូវមានបន្ទូលជាពាក្យប្រលយថា៖ «តើខ្ញុំមិនបានរើសអ្នករាល់គ្នាជាពួក១២នាក់ទេឬអី តែមានម្នាក់ក្នុងពួកអ្នករាល់គ្នាជាអារក្សវិញ?» (ខ ៧០, ៧១)។ ក៏នៅមានសិស្សស្មោះត្រង់ឯទៀតផងដែរ។ ជាកាពិតមែនហើយ គឺមានម៉ារាជាមាតាទ្រង់និងនាងម៉ារាម្នាក់ទៀត «ហើយស្ត្រីឯទៀតជាច្រើនដែរ ដែលយកទ្រព្យខ្លួនមកជួយទ្រង់» (លូកា ៨:១-៣)។

តើអ្នកទាំងនេះបានក្លាយជាជិតស្និទ្ធិនឹងព្រះអម្ចាស់ដោយរបៀបណា? នៅពេលព្រះយេស៊ូវសាកល្បងជំនឿរបស់គេ «អ្នករាល់គ្នាចង់ថយទៅដែរឬ?» ស៊ីម៉ូន-ពេត្រុស ជាសាវ័កបានឆ្លើយថា៖ «ព្រះអម្ចាស់ អើយ តើយើងខ្ញុំនឹងទៅឯអ្នកណាវិញ គឺទ្រង់ហើយដែលមាន**ព្រះបន្ទូលនៃជីវិត**ដ៏នៅអស់កល្បជានិច្ច។ យើងខ្ញុំក៏ជឿហើយដឹងថាទ្រង់ជាព្រះគ្រីស្ទ ជាព្រះរាជបុត្រានៃព្រះដ៏មានព្រះជន្មរស់ពិត» (ខ ៦៨, ៦៩)។ នេះគឺជាការយល់ដឹងដ៏ច្បាស់លាស់របស់អ្នកជ្រើសតាំង ជាអ្នកទទួលបាននូវសេចក្តីសង្គ្រោះតាមរយៈការអធិប្បាយរបស់ព្រះយេស៊ូវ។ នៅក្នុងខ ៦៣ ព្រះយេស៊ូវទ្រង់បានសង្កត់ធ្ងន់អំពីអំណាចនៃការអធិប្បាយពាក្យបន្ទូលថា៖ «ឯពាក្យដែលខ្ញុំនិយាយនឹងអ្នករាល់គ្នា នោះគឺត្រូវខាងវិញ្ញាណនឹងជីវិតវិញ» (ខ ៦៣)។ ក៏ប៉ុន្តែ តើវាគឺជា**ពាក្យអ្វី**? ជាពាក្យនៃការអធិប្បាយអំពីនំប៉័ងពីស្ថានសួគ៌ ជារូបសាច់ទ្រង់និងឈាមទ្រង់ដែលនៅពេលមនុស្សម្នាក់បរិភោគនឹងមិនត្រូវស្លាប់តទៅទៀតឡើយ។ នេះមានន័យថាគឺជាការអធិប្បាយពីឈើឆ្កាង ដូចជាសាវ័កប៉ុល បញ្ជាក់ប្រាប់ដល់អ្នកជឿស្រុកកូរិនដូច្នោះដែរ (១ កូរិនថូស ២:១-៤)។ «តែយើងខ្ញុំ ប្រកាសប្រាប់ ពីព្រះគ្រីស្ទ ដែលទ្រង់ត្រូវឆ្កាងវិញ ជាហេតុនាំឲ្យរវាតចិត្តដល់សាសន៍យូដា នឹងជាសេចក្តីល្ងង់ល្ងើដល់សាសន៍ក្រេក តែព្រះគ្រីស្ទ ទ្រង់ជាព្រះចេស្តា ហើយជាប្រាជ្ញារបស់ព្រះវិញ ដល់អស់អ្នកដែលទ្រង់ហៅ ទាំងសាសន៍យូដា ហើយនឹងសាសន៍ក្រេកផង» (ខ ២៣, ២៤)។

សូមឲ្យគ្រូគង្វាលនិងគ្រូថ្នាក់ថ្ងៃអាទិត្យទាំងឡាយចង់ចាំកុំងាករេចេញពីចំណុចស្នូលនៃឈើឆ្កាងក្នុងការអធិប្បាយនិងការបង្រៀនរបស់គេឡើយ! ក៏សូមឲ្យយើងច្រៀងឡើងវិញនូវ ទំនុកខ្លីៗដ៏មានប្រជាប្រិយភាពរបស់លោកគ្រូ ចន ស៊ុង ជាអំណាចនៃការលាងបាបដែលយើងទទួលបទពិសោធន៍នាពីទសវត្សសាមសិបរហូតដល់សព្វថ្ងៃនេះ៖

*ក្នុងឈើឆ្កាង ក្នុងឈើឆ្កាង*
*ជាក្តីរុងរឿងនៃខ្ញុំជាប*
*បាបធំខ្ញុំក៏បានលាងស្អាត*
*ដោយលោហិតព្រះយេស៊ូវ!*

**ការពិចារណា៖** ចូរប្រកាសពីព្រះយេស៊ូវដែលទ្រង់ត្រូវឆ្កាងវិញ។
**ការអធិស្ឋាន៖** ឱព្រះអម្ចាស់អើយគឺទ្រង់ហើយដែលមានព្រះបន្ទូលនៃជីវិតដ៏នៅអស់កល្បជានិច្ច!

# ជំពូកទី ៧

## ចំពោះអ្នកដែលទទួលវិញ្ញាណរបស់ទ្រង់ ព្រះយេស៊ូវនឹងហូរដូចជាទន្លេជីវិត

យើងបានសម្គាល់ដឹងនៅមេរៀនមុនរួចមកហើយថា ជាទម្លាប់រាល់ឆ្នាំរបស់ព្រះយេស៊ូវទ្រង់តែងតែនឹងយាងទៅចូលរួមពិធីបុណ្យរំលងនៅទីក្រុងយេរូសាឡឹម។ ក៏ប៉ុន្តែមិនមែនឆ្នាំនេះទេ! ចន្លោះពេលផ្គត់ផ្គង់អាហារដល់មនុស្សប្រាំពាន់នាក់និងពិធីបុណ្យបារាំ (*Feast of Tabernacle*) គឺមានរយៈពេលស្ងប់ស្ងៀមដាច់ឆ្ងាយពីគ្នានៅក្នុងដំណឹងល្អយ៉ូហាន ពីព្រោះព័ត៌មានលំអិតនៃអំឡុងពេលកន្លះឆ្នាំនេះបានត្រាតែនៅក្នុងបទសង្ខេបនៃដំណឹងល្អទាំងបី (*Synoptic Gospels*) តែប៉ុណ្ណោះ។ មូលហេតុដែលព្រះយេស៊ូវ «យាងតែនៅក្នុងស្រុកកាលីឡេ» និងមិនយាងក្នុងស្រុក «យូដា» គឺដោយសារសាសន៍យូដាប៉ុនប៉ងសម្លាប់ទ្រង់។ ដូចដែល «ពេលវេលារបស់» ទ្រង់ «មិនទាន់ដល់នៅឡើយ» (ខ ៦)។ ព្រះយេស៊ូវជ្រាបដឹងថា វាជាប្រយោជន៍ដើម្បីបង្រៀនអ្នកស្រុកកាលីឡេឲ្យអស់ពីលទ្ធភាព។ ការស្វែងរកគ្រោះថ្នាក់ដោយពុំចាំបាច់គឺមិនមែនជាប្រាជ្ញារបស់ព្រះឡើយ។ ហេតុនេះសម្រាប់ការស្នាក់នៅ ស្រុកកាលីឡេ ព្រះអម្ចាស់បានអញ្ជើញអ្នកស្រុក ជាពួកអ្នកទ្បកទ្បឺយរបស់ទ្រង់ឲ្យចូលមកព្រះអង្គ។

ប៉ុន្តែ ទោះជាយ៉ាងណា ព្រះអម្ចាស់នៃយើងឥតដែលងាកបែរចេញពីភារៈកិច្ចទ្រង់ម្តងណាឡើយ។ ព្រះអង្គបានយាងដំណើរចេញទៅក្រុងយេរូសាឡឹមនៅពេលបុណ្យបារាំខិតជិតមកដល់។ ដូចជាបរិយាយខាងលើ ពិធីបុណ្យបារាំជាពិធីមួយក្នុងពិធីបុណ្យសំខាន់ៗទាំងបីរបស់អ៊ីស្រាអែល។ វាគឺជាបុណ្យរំឭកពីការធ្វើដំណើរក្នុងទីរហោស្ថាននាសម័យអ៊ីស្រាអែលរស់នៅក្នុងជំរុំសំពត (លេវីវិន័យ ២៣:៣៣-៤៤)។ ថ្វីដ្បិតតែព្រះអម្ចាស់បានយាងមកដល់ពិធីបុណ្យបារាំនាពាក់កណ្តាលកម្មវិធី ក៏ការសម្រេចចិត្តរបស់ទ្រង់ដើម្បីប្រឈមនឹងបញ្ហាលំបាកនាពិធីបុណ្យរំលងដែលត្រូវប្រារព្ធធ្វើឡើងនាពេលប្រាំមួយខែក្រោយគឺជាគោលបំណងដ៏ចម្បងរបស់ទ្រង់ដែរ។ ហេតុនេះទើបទ្រង់យាងទៅយេរូសាឡឹម «ដោយសំងាត់វិញ» (ខ ១០)។

វាជាការមួយត្រូវចងចាំថា នៅគ្រានោះព្រះយេស៊ូវបានក្លាយជាមនុស្សល្បីល្បាញក្នុងស្រុកម្នាក់តាមរយៈការបង្រៀននិងការអស្ចារ្យជាច្រើន ហើយទ្រង់ក៏ជាត្រូវបានមនុស្សគ្រប់រូបលើកមកនិយាយជារៀងរាល់ថ្ងៃពីមាត់មួយទៅមាត់មួយទៀតផងដែរ។ ទ្រង់មិនចង់ប្រាសចាកចេញពីគោលបំណងដោយសារភាពដ៏រំជើបរំជួលរបស់មនុស្សឡើយ។

ទោះជាយ៉ាងណា ព្រះអង្គយាងចូលទៅក្នុងបេះដូងនៃរាជធានីដោយឥតភិតភ័យ។ មិនជាយូរប៉ុន្មាន សេចក្តីបង្រៀនរបស់ក៏បានប៉ះទង្គិចនឹងទំនៀមទម្លាប់របស់សាសន៍យូដា។ ដូចនេះទើបនាំឲ្យមានវិវាទថ្មីមួយទៀតជាមួយនឹងពួកអ្នកជំទាស់របស់ទ្រង់។ ក៏ប៉ុន្តែសេចក្តីអធិប្បាយពាក្យបន្ទូលគឺមិនជាការសន្ទនាទេ វាគឺជាឯកវាទ ជាពាក្យថ្លែងប្រកាសអំពី «ព្រះយេហូវ៉ាទ្រង់មានបន្ទូលដូច្នេះ» សម្រាប់អ្នកដែលមានឆន្ទៈស្តាប់វិញ។ យ៉ូហានជំពូក៧គឺត្រូវបានអ្នកជឿចងចាំដោយសារសេចក្តីថ្លែងការណ៍របស់ព្រះគ្រីស្ទក្នុងខទី៣៧និង៣៨ «នៅថ្ងៃក្រោយបង្អស់ ជាថ្ងៃបុណ្យយ៉ាងសំខាន់ នោះព្រះយេស៊ូវទ្រង់ឈរបន្លឺឧទានប្រកាសឡើងថា បើអ្នកណាស្រេក ចូរឲ្យអ្នកនោះមកឯខ្ញុំ ហើយផឹកចុះ។ អ្នកណាដែលជឿដល់ខ្ញុំ នោះនឹងមានទន្លេទឹករស់ហូរចេញពីពោះខ្លួនមក ដូចជាគម្ពីរសំដែងហើយ»។ សូមទន្ទេញខនេះ។

**ការពិចារណា៖** ការស្វែងរកគ្រោះថ្នាក់ដោយពុំចាំបាច់គឺមិនមែនជាប្រាជ្ញារបស់ព្រះឡើយ។
**ការអធិស្ឋាន៖** សូមអរព្រះគុណ ឱព្រះអង្គអើយ សម្រាប់ទឹកដ៏រស់ដែលទ្រងប្រទានដល់ខ្ញុំ។

*«...តែបើរងទុក្ខ ដោយព្រោះជាពួកគ្រីស្ទានវិញ នោះកុំឲ្យខ្មាសឲ្យសោះ ចូរសរសើរដំកើងដល់ព្រះ ដោយព្រោះនាមនោះវិញ»(១ ពេត្រុស ៤:១៦)។*

**«ឯពួកសត្រូវរបស់អ្នកណា នោះគឺជាពួកអ្នកនៅផ្ទះជាមួយនឹងខ្លួននោះឯង» (ម៉ាថាយ ១០:៣៦)**

នេះគឺជាសេចក្តីថ្លែងការណ៍បែបបរមតិដ៏ល្បីមួយរបស់ព្រះយេស៊ូវ។ ហើយដើម្បីជាការបន្ថែមទៅលើសេចក្តីនេះ ព្រះអម្ចាស់នៃយើងមានបន្ទូលជាថ្មីម្តងទៀតថា៖ «បងប្អូននឹងបញ្ជូនគ្នាឲ្យត្រូវស្លាប់ ឪពុកនឹងបញ្ជូនកូន ហើយកូននឹងលើកគ្នាទាស់នឹងឪពុកម្តាយ ព្រមទាំងសំឡាប់គាត់ផង»។ តើដោយសារមូលហេតុអ្វី? គឺ «ដោយព្រោះឈ្មោះខ្ញុំ»។ ឈើឆ្កាងនៃព្រះគ្រីស្ទក្លាយជាដាវ (ម៉ាថាយ ១០:៣៤) ពុះបំបែកទំនាក់ទំនងនៃក្តីស្រឡាញ់ដ៏ជិតស្និទ្ធរបស់មនុស្ស ពោលគឺនៅខាងក្នុងរង្វង់គ្រួសាររបស់បុគ្គលម្នាក់ៗ។ នៅក្នុងពួកជំនុំតែមួយដូច្នោះដែរ!

ព្រះអម្ចាស់មិនបានមានបន្ទូលអំពីបញ្ហាទាំងនេះចេញពីទ្រឹស្តីទេ តែចេញមកពីបទពិសោធន៍ទ្រង់ផ្ទាល់វិញ។ ព្រះអង្គត្រូវបានអ្នកស្រុករបស់ទ្រង់ គឺជាអ្នកស្រុកណាសារ៉ែតបដិសេធមិនរាប់អាន ចាប់តាំងពីពេលដំបូងដែលទ្រង់ចាប់ផ្តើមប្រកាសដំណឹងល្អមកម្ល៉េះ។ សូមចាំពីសេចក្តីដែលទ្រង់បានមានបន្ទូលពីដំបូង «គ្មានហោរាណាដែលគេរាប់អាននៅក្នុងស្រុករបស់ខ្លួននោះទេ» (លូកា ៥:២៤)។ ឥឡូវ ខណៈពេលទ្រង់យាងមកស្រុកណាសារ៉ែតម្តងទៀត ប្រាកដជាទ្រង់ត្រូវបានពួកប្អូនប្រុសស្រីរបស់ទ្រង់សើចចំអក់ដាក់ទ្រង់ជាមិនខាន «ដ្បិតពួកប្អូនទ្រង់មិនជឿដល់ទ្រង់ទេ» (យ៉ូហាន ៧:៥)។ មានសុភាសិតចិនមួយបានពោលថា «លទ្ធិខុសគ្នាបំបែកមិត្តសម្លាញ់» អត្ថន័យនៃសុភាសិតនេះគឺត្រូវនឹងករណីរបស់ទ្រង់។ ហោរាអេម៉ុសបានមានប្រសាសន៍ថា «បើមនុស្ស២នាក់មិនព្រមចិត្តគ្នា នោះតើនឹងដើរជា១គ្នាបានឬ?» (អេម៉ុស ៣:៣)។

ព្រះយេស៊ូវគ្រីស្ទគឺជាពន្លឺនៃលោកីយដូចជាយើងនឹងរៀនក្នុងជំពូកបន្ទាប់។ ដូចជាពន្លឺនិងងងឹតមិនលាយឡំគ្នាបាន នោះទ្រង់ក៏មិនអាចចុះចូលតាមពួកប្អូនទ្រង់ដែលនៅក្នុងទីងងឹតដូច្នោះដែរ។ មិត្តអ្នកអានអើយ តើអ្នកកំពុងជួបប្រទះនឹងស្ថានភាពស្រដៀងគ្នានៅក្នុងផ្ទះរបស់អ្នកផ្ទាល់ខ្លួន ដោយទទួលរងនូវការយល់ច្រឡំនិងការបៀតបៀនពីសំណាក់ឪពុកម្តាយរបស់អ្នក ស្វាមី ភរិយា បងឬប្អូនប្រុសស្រី ពូមីង? ព្រះអម្ចាស់នៃយើងទ្រង់បានឆ្លងកាត់នូវទុក្ខលំបាកទាំងនេះដោយយល់ដល់សេចក្តីពិតទ្រង់គង់នៅជិតបង្កើយនឹងអ្នកដើម្បីកំសាន្តចិត្តនិងផ្តល់ក្តីអំណររីករាយចិត្តដល់អ្នកជានិច្ច។ សូមឲ្យសេចក្តីបង្រៀនរបស់សាវ័កពេត្រុសបញ្ចប់វគ្គសិក្សាបែបសង្ខេបនេះយ៉ាងដូច្នេះ «ពួកស្ងួនភ្ងាអើយ កុំឲ្យមានប្លែកក្នុងចិត្ត ដោយភ្លើងដ៏ក្តៅក្រហាយ ដែលកំពុងតែល្បងអ្នករាល់គ្នា ទុកដូចជាកើតមានសេចក្តីចំឡែកនោះឡើយ។ ត្រូវអរសប្បាយវិញ ដោយព្រោះមានចំណែកក្នុងការរងទុក្ខរបស់ព្រះគ្រីស្ទ ដើម្បីឲ្យអ្នករាល់គ្នាបានត្រេកអររីករាយជាខ្លាំង ក្នុងកាលដែលសិរីល្អទ្រង់លេចមក។ បើសិនជាគេតិះដៀលអ្នករាល់គ្នា ដោយព្រោះព្រះគ្រីស្ទ នោះមានពរហើយ...។ តែបើរងទុក្ខ ដោយព្រោះជាពួកគ្រីស្ទានវិញ នោះកុំឲ្យខ្មាសឲ្យសោះ ចូរសរសើរដំកើងដល់ព្រះ ដោយព្រោះនាមនោះវិញ» (១ ពេត្រុស ៤:១២-១៤,១៦)។

**ការពិចារណា៖** «បើមនុស្ស២នាក់មិនព្រមចិត្តគ្នា នោះតើនឹងដើរជា១គ្នាបានឬ?» (អេម៉ុស ៣:៣)។

**ការអធិស្ឋាន៖** ឱព្រះអើយ សូមឲ្យខ្ញុំប្រឈមមុខនឹងការបៀតបៀនដោយព្រះគុណដ៏តែងតែជួយរបស់ទ្រង់ផង។

*«កំពុងដែលថ្ងៃនៅភ្លឺនៅឡើយ នោះត្រូវតែខ្ញុំធ្វើការរបស់ព្រះ ដែលចាត់ឲ្យខ្ញុំមក ដ្បិតយប់ដល់មក នោះគ្មានអ្នកណាអាចនឹងធ្វើការបានទេ»។*

## កាលវិភាគនៃជីវិត

ជីវិតរបស់ព្រះអម្ចាស់នៃយើងត្រូវបានរៀបចំយ៉ាងច្បាស់លាស់។ ព្រះអង្គមានព្រះជន្មរស់នាថ្ងៃនិមួយៗស្របនឹងកាលវិភាគរបស់ព្រះជាម្ចាស់។ នេះបានឆ្លុះបញ្ចាំងឲ្យឃើញក្នុងពាក្យបន្ទូលរបស់ទ្រង់ទៅកាន់ប្អូនៗរបស់ព្រះអង្គ «តែពេលវេលារបស់អញមិនទាន់ដល់នៅឡើយ...ព្រោះកំណត់អញមិនទាន់សំរេចនៅឡើយ» (ខ ៦, ៨)។ ហើយទ្រង់ជ្រាបដឹងពីម៉ោងនៃពេលកំណត់នោះទៀតផង (យ៉ូហាន ១២:២៧)។ វាគឺហាក់ដូចជាទ្រង់មាននាឡិកានៅព្រះហស្តម្ខាងរួចហើយផ្ទៀងមើលជាញឹកញាប់ដើម្បីឲ្យត្រូវនឹងម៉ោងនៃក្រដាសកម្មវិធីនៅព្រះហស្តម្ខាងទៀត។ ការមានស្មារតីភ្ញាក់រឭកបែបនេះដើម្បីបំពេញបេសកកម្មក្នុងជីវិតគឺមិនត្រឹមតែសម្ដែងនៅក្នុងករណីនេះទេ តែនាឱកាសជាច្រើនទៀតផងដែរ។ ឧទាហរណ៍ ចំពោះពួកសិស្សដែលយកអាហារមកថ្វាយទ្រង់ ព្រះអង្គបានមានបន្ទូលថា៖ «ឯអាហាររបស់ខ្ញុំ គឺត្រង់ដែលខ្ញុំធ្វើតាមព្រះហឫទ័យនៃព្រះដែលចាត់ឲ្យខ្ញុំមក ព្រមទាំងបង្ហើយការរបស់ទ្រង់នោះឯង» (យ៉ូហាន ៤:៣៤)។ នៅគ្រាប្រោសជម្ងឺបុរសខ្វាក់ពីកំណើតទ្រង់ប្រកាសថា៖ «កំពុងដែលថ្ងៃនៅភ្លឺនៅឡើយ នោះត្រូវតែខ្ញុំធ្វើការរបស់ព្រះដែលចាត់ឲ្យខ្ញុំមក ដ្បិតយប់ដល់មក នោះគ្មានអ្នកណាអាចនឹងធ្វើការបានទេ» (យ៉ូហាន ៩:៤)។

នេះហើយគឺជាអាថ៌កំបាំងនៃភាពជោគជ័យ។ ព្រះយេស៊ូវឥតបានខ្ជះខ្ជាយពេលវេលាដ៏ខ្លីនិងមានតម្លៃរបស់ទ្រង់នៅលើផែនដីមួយនាទីណាឡើយ។ នេះក៏ជាអាថ៌កំបាំងនៃការគ្រប់គ្រងពិភពលោករបស់សាវ័កប៉ុលសំរាប់ព្រះគ្រីស្ទផងដែរ។ លោកក៏បានរស់នៅជីវិតស្របនឹងកាលវិភាគរបស់ព្រះជាម្ចាស់ដែរ ដូច្នោះទើបក្នុងរយៈពេលដ៏ខ្លីត្រឹមតែ ៣០ឆ្នាំ គាត់អាចប្រកាសដំណឹងល្អទូទាំងអាណាចក្ររ៉ូម ពីទីក្រុងយេរូសាឡឹមរហូតដល់រាជធានីនៃចក្រភពរ៉ូម។ សូមស្ដាប់ពាក្យប្រឹក្សារបស់គាត់ដល់អ្នកជឿក្រុងអេភេសូរ «ដូច្នេះ ត្រូវប្រយ័តដោយមធ្យ័ត ដែលអ្នករាល់គ្នាដើរយ៉ាងណា កុំឲ្យដើរដូចជាមនុស្សឥតប្រាជ្ញាឡើយ ត្រូវតែដើរដោយមានប្រាជ្ញាវិញ។ ទាំងលៃយកឱកាសឲ្យទាន់ពេលផង ពីព្រោះសម័យនេះអាក្រក់ណាស់» (អេភេសូរ ៥:១៦,១៧)។ ចំពោះអ្នកជឿក្រុងកូឡុស លោកសាវ័កមានប្រសាសន៍ថា៖ «ចូរប្រព្រឹត្តនឹងពួកអ្នកក្រៅដោយប្រាជ្ញា ទាំងលៃយកឱកាសឲ្យទាន់ពេលផង» (កូល៉ុស ៤:៥)។

នៅពេលយើងបានសង្គ្រោះ ពេលវេលានៅលើផែនដីរបស់យើងក៏គួរតែបានសង្គ្រោះដែរ។ ឱព្រះអម្ចាស់អើយ សូមសង្គ្រោះខ្ញុំពីភាពខ្ជិលច្រអូស និងសង្គ្រោះខ្ញុំពីការចំណាយពេលមើលទូរទស្សន៍ទាំងថ្ងៃទាំងយប់ផង។ សូមសង្គ្រោះខ្ញុំឲ្យបានអានពាក្យបន្ទូលរបស់ព្រះអង្គជាប្រចាំថ្ងៃនិងឲ្យខិតខំស្វែងយល់ពាក្យបន្ទូលនោះឲ្យកាន់តែប្រសើរខ្លាំងឡើងផងដែរ។ សូមសង្គ្រោះខ្ញុំពី «ជម្ងឺខ្ជិលនាព្រឹកថ្ងៃអាទិត្យ» ដើម្បីនឹងឲ្យខ្ញុំថ្វាយបង្គំទ្រង់នាដំណាក់របស់ព្រះអង្គដែរ។ សូមបន្ថែមលើតារាងបញ្ជីនេះ នោះជីវិតអ្នកទាំងមូលនឹងបានផ្លាស់ប្ដូរទាំងស្រុង ខណៈពេលអ្នករស់នៅស្របនឹងកាលវិភាគរបស់ព្រះជាម្ចាស់សម្រាប់រាល់ជីវភាពគ្រីស្ទបរិស័ទដ៏ជោគជ័យ។

**ការពិចារណា៖** *«ចូរប្រព្រឹត្តនឹងពួកអ្នកក្រៅដោយប្រាជ្ញា ទាំងលៃយកឱកាសឲ្យទាន់ពេលផង»* (កូល៉ុស ៤:៥)។
**ការអធិស្ឋាន៖** «ឱព្រះអង្គ អើយ សូមនាំខ្ញុំមកជិត នៅទៀបជើងឈើឆ្កាងទ្រង់ផង សូមនាំជិតជាង ជិតជាង ឱព្រះអង្គដ៏ពិត ឲ្យបានជាប់ជាមួយព្រះអង្គ» (ចម្រៀងទំនុកដំកើង ១៨១)។

## ទេវសាស្ត្រជាវិទ្យាសាស្ត្រដ៏កំពូល

អ្នកអាចទទួលបានសញ្ញាបត្រថ្នាក់បណ្ឌិតផ្នែកការសិក្សាពីសត្វមូស ដោយអាចរាប់ចំនួនរោមជើងទន់ៗនៅលើខ្លួនវា ហើយអ្នកបានគេទទួលស្គាល់ថាអ្នកវិទ្យាសាស្ត្រ។ គឺជាបណ្ឌិតកាល់វិនដែលបានថ្លែងថាចំណេះដឹងពិតប្រាកដ (ជាចំណេះដឹងដ៏កំពូល) គឺជាចំណេះដឹងអំពីព្រះនិងអំពីមនុស្ស។

ជនជាតិយូដាដែលមានដូចជា ពួកអាចារ្យ ពួកអ្នកប្រាជ្ញខាងច្បាប់ ពួកផារីស៊ី គឺជាពួកអ្នកប្រាជ្ញ ដែលចេះដឹងគ្រប់ជ្រុងជ្រោយខាងក្រិត្យវិន័យរបស់សាសន៍យូដា តែជាចំណេះដឹងមិនល្អដែលមនុស្សបង្កើតប៉ុណ្ណោះ។ នៅពេលព្រះអម្ចាស់បង្រៀនគឺខុសគ្នាស្រឡះ! ព្រះអង្គដែលជាប្រភពនៃអស់ទាំងប្រាជ្ញានិងចំណេះដឹង (សុភាសិត ៨) ជាអង្គបុគ្គលមកពីស្ថានសួគ៌ យាងពីឱវាព្រះវរបិតា បង្រៀនទេវសាស្ត្រ! វិទ្យាសាស្ត្រដ៏កំពូល ជាចំណេះដឹងពិតនិងជាចំណេះដឹងដ៏ឧត្ដម! ហើយមិនទាន់ភ្លេចមនុស្ស ជាអ្នកមានព្រលឹងវិញ្ញាណថ្លៃជាងលោកីយ៍ទាំងមូល ដែលទ្រង់បានបង្រៀនជាច្រើនអំពីគេផងដែរ។ សេចក្ដីបង្រៀននេះបណ្ដាលឲ្យពួកអ្នកជំទាស់ទ្រង់កោតសរសើរភ្លាមៗ «ធ្វើដូចម្ដេចឲ្យអ្នកនេះចេះគម្ពីរដូច្នេះ ពីព្រោះគាត់មិនដែលរៀនសូត្រផង?» (ខ១៥)។ តើពួកគេមិនងឿយឆ្ងល់ផងនៅពេលព្រះយេស៊ូវព្រះជន្មដប់ពីរឆ្នាំគង់នៅកណ្ដាលពួកអាចារ្យ (ជាបណ្ឌិតច្បាប់) ក្នុងព្រះវិហារ?

សូមចង់ចាំថាទេវសាស្ត្រមិនអាចសិក្សាដូចជាវិទ្យាសាស្ត្រផ្សេងៗបានឡើយ។ មនុស្សឥតបានកើតជាថ្មីមិនអាចរៀនវាបានទេ «ប៉ុន្តែ មនុស្សខាងសាច់ឈាមគេមិនទទួលសេចក្ដីខាងឯព្រះវិញ្ញាណនៃព្រះទេ ពីព្រោះជាសេចក្ដីល្ងង់ល្ងើដល់គេ ក៏រកស្គាល់មិនបានដែរ ដ្បិតត្រង់ឯសេចក្ដីទាំងនោះ ត្រូវពិចារណាយល់ខាងវិញ្ញាណវិញ» (១ កូរិនថូស ២:១៤)។ «បើមិនបានកើតជាថ្មី នោះគ្មានអ្នកណាអាចនឹងឃើញនគរព្រះបានទេ» (យ៉ូហាន ៣:៣)។ នេះគឺជាន័យដែលទ្រង់បង្រៀននៅពេលទ្រង់មានបន្ទូលប្រាប់ដល់ពួកសាសន៍យូដាថាប្រភពចំណេះដឹងផ្នែកទេវសាស្ត្រដ៏កំពូលរបស់ទ្រង់ដែលដំកល់ទុកនៅនឹងព្រះវរបិតា គឺហួសដែនគំនិតដែលគេចាប់យកបាន លុះត្រាតែគេធ្វើតាមបំណងព្រះហឫទ័យរបស់ទ្រង់ និងចុះចូលតាមព្រះវិញ្ញាណនៃព្រះ។ «បើអ្នកណាចង់ធ្វើតាមព្រះហឫទ័យទ្រង់ នោះនឹងបានដឹងជាសេចក្ដីបង្រៀននេះមកពីព្រះ ឬជាខ្ញុំនិយាយដោយអាងខ្លួនខ្ញុំ» (យ៉ូហាន ៧:១៧)។ បើព្រះយេស៊ូវអធិប្បាយតែពីអង្គទ្រង់ ទ្រង់នឹងបង្រៀនពីលទ្ធិប្រាសចាកពីជំនឿ ហើយទ្រង់នឹងទទួលបាននូវសិរីល្អសម្រាប់អង្គទ្រង់ផងដែរ។ ប៉ុន្តែទ្រង់ធ្វើទីបន្ទាល់ផ្ទុយពីការនោះ។ ពួកសាសន៍យូដាដែលខ្វាក់ក្នុងសេចក្ដីអំណួតផ្ទាល់ខ្លួនឥតយល់ទេវសាស្ត្រ។ ដូចនេះពួកគេមើលមិនឃើញនៅក្នុងព្រះយេស៊ូវនូវអង្គបុគ្គលទីពីរនៃព្រះត្រីឯករហូតមកដល់សព្វថ្ងៃនេះ។ ពួកយើងក៏ដូច្នោះដែរ។ មានអ្នកដែលចូលរួមថ្វាយបង្គំនៅព្រះវិហារអស់មួយជីវិតរបស់ខ្លួននាបណ្ដាពួកជំនុំបង្កើតឡើងដោយអ្នកដឹកនាំសម័យទំនើប រួមទាំងចាស់ទុំនិងគ្រូគង្វាលបង្រៀនពាក្យបន្ទូលផងនោះ ពួកគេជាអ្នកបដិសេធនូវគោលលទ្ធិសំខាន់ៗរបស់គ្រីស្ទបរិស័ទ។ អ្នកទាំងនេះគឺជាពួកអាចារ្យនិងពួកផារីស៊ីសម័យទំនើប ជាអ្នកដឹកនាំខ្វាក់ដឹកនាំមនុស្សខ្វាក់។ អ្នកណាដើរតាមគេនឹងធ្លាក់ក្នុងរណ្ដៅជាមិនខាន (ម៉ាថាយ ១៥:១៤)។ កាល់វិនលោកមានប្រសាសន៍ថា មានតែអ្នកបន្ទាបខ្លួនទេទើបនឹងយល់ទេវសាស្ត្រ!

**ការពិចារណា៖** ការសិក្សាទេវសាស្ត្រគឺត្រូវ «បន្ទាបខ្លួន បន្ទាបខ្លួន បន្ទាបខ្លួន» (ចន កាល់វិន)

**ការអធិស្ឋាន៖** សូមព្រះអង្គរំដោះខ្ញុំចេញពីការបង្រៀនខុសឆ្គងរបស់ក្រុមផារីស៊ីសម័យទំនើបផង។

*«កុំឲ្យជំនុំជំរះតាមភាពដែលមើលឃើញតែខាងក្រៅឡើយ ត្រូវជំនុំជំរះតាម សេចក្ដីសុចរិតវិញ»*

## កិច្ចការរបស់ព្រះគឺសំខាន់ជាក្រិត្យវិន័យថ្ងៃឈប់សម្រាកមនុស្ស

មានកំណត់ត្រាពីជនជាតិយូដាជំទាស់នឹងព្រះអម្ចាស់នៃយើងនាឱកាសជាច្រើនអំពីការប្រតិបត្តិឈប់សម្រាក (ថ្ងៃសប្ប័ទ)។ រយៈពេលដប់ប្រាំបីខែបន្ទាប់ពីការប្រោសបុរសមានជម្ងឺ៣៨ឆ្នាំ នាស្រះទឹកបែសេដា ករណីប្រោសជម្ងឺនោះតែងតែជាបញ្ហារំខានចិត្តរបស់ពួកសាសន៍យូដាជាអ្នកចាំចាប់កំហុសជានិច្ចផងដែរ។

ព្រោះតែជ្រាបពីបញ្ហាក្នុងចិត្តរបស់គេ ទើបព្រះយេស៊ូវបើកឲ្យឃើញពីភាពពុតត្បុតរបស់ពួកគេ។ «លោកម៉ូសេតើមិនបានឲ្យក្រិត្យវិន័យមកអ្នករាល់គ្នាទេឬអី ប៉ុន្តែក្នុងពួកអ្នករាល់គ្នា គ្មានអ្នកណាមួយប្រព្រឹត្តតាមវិន័យនោះទេ?» សេចក្ដីអាថ៌កំបាំងត្រូវបានបើកចំហរឲ្យឃើញថាជាជនជាតិយូដាផ្ទាល់ទេទើបជាអ្នកបំពានក្រិត្យវិន័យថ្ងៃសប្ប័ទ។ ទង្វើនេះបានកើតឡើងនាសម័យលោកនេហេមាផងដែរ។ សូមអាន នេហេមា ១៣:១៥។

ពេលនេះព្រះយេស៊ូវបានចោទជាសំណួរដល់ពួកគេថា តើមិនមែនជាសាសន៍យូដាទម្លាប់ធ្វើពិធីកាត់ស្បែកនៅថ្ងៃសប្ប័ទទេឬអី? ព្រោះក្រិត្យវិន័យរបស់ម៉ូសេចែងថាទារកប្រុសត្រូវទទួលកាត់ស្បែកនៅថ្ងៃទីប្រាំបី។ ហើយនៅពេលមកថ្ងៃទីប្រាំបីនឹងត្រូវជាថ្ងៃសប្ប័ទ តើពួកគេនឹងធ្វើពិធីកាត់ស្បែកដែរឬទេ? ពួកគេប្រាកដជានឹងធ្វើ។ តើការកាត់ស្បែកមិនមែនទាក់ទងនឹងការប្រកបការងារ? ប៉ុន្តែនៅត្រង់ចំណុចនេះគ្មាន ការបំពានក្រិត្យវិន័យរបស់ម៉ូសេឡើយ។ «ច្បាប់កំពូល ត្រួតលើច្បាប់បឋម»។ កិច្ចការដែលព្រះជាម្ចាស់បង្គាប់ជាកិច្ចការសម្រាលនូវក្ដីឈឺចាប់របស់មនុស្សនិងសម្រាប់បំពេញនូវតម្រូវការជាបន្ទាន់ប្រាកដជានឹងអនុគ្រោះពីសេចក្ដីតម្រូវការដ៏តឹងរ៉ឹងជាមិនខាន។ ដូច្នេះ តើហេតុអ្វីបានជាពួកគេប៉ុនប៉ងសម្លាប់ព្រះអម្ចាស់នៃយើង? តើដោយសារការធ្វើកិច្ចការមេត្តាករុណានាថ្ងៃឈប់សម្រាក?

«កុំឲ្យជំនុំជំរះតាមភាពដែលមើលឃើញតែខាងក្រៅឡើយ» មានន័យថាតាមតែអក្សរនិង «ត្រូវជំនុំជំរះតាមសេចក្ដីសុចរិតវិញ» (ខ ២៤) មានន័យថាតាមរយៈវិញ្ញាណផងដែរ។ មានកាតព្វកិច្ចស្របច្បាប់ តែក៏មានសីលធម៌ស្របច្បាប់ផងដែរ។

ពិតជាគោលការណ៍នៃសមធម៌ដ៏អស្ចារ្យដែលព្រះអម្ចាស់នៃយើងប្រកាសសម្រាប់ការដឹកនាំរបស់យើងអំពីរបៀបរក្សាថ្ងៃនៃព្រះអម្ចាស់ជាបរិសុទ្ធសម្រាប់សម័យបច្ចុប្បន្នមែន!។ ហើយវាអាចនឹងមានភាពជ្រុលនិយមចំពោះខ្លួនយើងគឺការដាក់បញ្ហាឲ្យបងប្អូនជាអ្នកជឿរបស់យើងនូវសេចក្ដីដែលត្រូវធ្វើនិងមិនអាចធ្វើលើបញ្ហាសើរៗខាងក្រៅផងដែរ។ យើងត្រូវថ្លឹងថ្លែងរាល់ស្ថានការនិងមិនត្រូវវិនិច្ឆ័យ តាមតែអក្សរឡើយ ក៏ប៉ុន្តែត្រូវតាមវិញ្ញាណផងដែរ។ គោលការណ៍ដ៏ប្រសើរដើម្បីចងចាំគឺក្រិត្យវិន័យកំពូលនៃមនុស្សធម៌គឺត្រួតលើក្រិត្យវិន័យទាបនៃពិធីបុណ្យ។ ថ្ងៃសប្ប័ទបង្កើតឡើងសម្រាប់មនុស្ស ហើយមិនមែនមនុស្សសម្រាប់ថ្ងៃឈប់សម្រាកឡើយ។

**ការពិចារណា៖** «ចូរឲ្យនឹកចាំពីថ្ងៃឈប់សំរាក ដើម្បីញែកថ្ងៃនោះចេញជាបរិសុទ្ធ» (និក្ខមនំ ២០:៨)។
**ការអធិស្ឋាន៖** ឱព្រះជាម្ចាស់អើយ សូមឲ្យខ្ញុំយកថ្ងៃឈប់សម្រាកដើម្បីថ្វាយបង្គំទ្រង់ដោយអំណរ និងប្រកាសដំណឹងល្អដល់អ្នកដែលបាត់បង់ផង។

**«មិនដែលមានអ្នកណានិយាយដូចអ្នកនោះទេ»**

ទីបន្ទាល់ពីមន្ត្រីដែលសម្តេចសង្ឃនិងផារិស៊ីបានបញ្ជូនឲ្យទៅចាប់ព្រះអម្ចាស់ពិតជាល្អមែន! គឺដូចជាយើងធ្លាប់បានសម្គាល់ឃើញរួចហើយថា ព្រះអង្គមិនបានបង្រៀនដូចជាពួកអ្នកប្រាជ្ញជនជាតិយូដា ដែលមានគំនិតពីវិធីសាស្ត្របង្រៀនដ៏ធុនទ្រាន់តែមួយឡើយ ទ្រង់បានបង្រៀនពេញដោយព្រះចេស្តានិងអំណាច។ នៅពេលទ្រង់មានបន្ទូល ទ្រង់បានដាស់អង្រួន់ចិត្តគំនិត ទោះបីបែបជាការជំទាស់ ឬជាការចុះចូលក្តី។ ព្រះអង្គបង្រៀនពីសេចក្តីពិតដែលទ្រង់បានមានបន្ទូលថានឹងប្រោសឲ្យគេបានរួច។

គ្មានហោរា ឬទស្សនៈវិទូណាម្នាក់បង្រៀនដូចជាព្រះយេស៊ូវគ្រីស្ទឡើយ។ ផ្ទុយទៅវិញ ហោរាបានបង្រៀនស្របតាមបទទំនាយរបស់ព្រះវិញ្ញាណដែលទ្រង់ផ្តល់មកឲ្យគាត់ គឺគ្មានសេចក្តីអ្វីឲ្យលើសពីសេចក្តីនោះទេ។ ផ្ទុយទៅវិញ ទស្សនៈវិទូបង្រៀនតែពីសេចក្តីដែលគេស្រាវជ្រាវរកឃើញបន្ទាប់ពីឆ្លងកាត់ការជញ្ជឹងគិតរយៈពេលដ៏យូរប៉ុណ្ណោះ។ ព្រះគ្រីស្ទមានបន្ទូលដូចជាព្រះបន្ទូលនៃព្រះ។ ព្រះអង្គគឺជាព្រះជាម្ចាស់ដែលកំពុងមានបន្ទូលជំនួសព្រះវរបិតា។ ទ្រង់ប្រកាសប្រាប់ជាច្រើនដងថាទ្រង់មិនបានយាងមក(ផែនដី) ដោយចិត្តឯងទេ តែព្រះវរបិតាបានបញ្ជូនឲ្យទ្រង់មកវិញ។ នៅពេលទទួលការគំរាមកំហែងពីពួកសត្រូវរបស់ទ្រង់ ព្រះអង្គបានមានបន្ទូលបែបជាប្រស្នាអំពីដំណើរយាងត្រឡប់ទៅព្រះអង្គដែលបានបញ្ជូនទ្រង់មក។ ចំណុចនេះ បញ្ជាក់ពីអំណាចនិងព្រះចេស្តានៃសេចក្តីបង្រៀនរបស់ទ្រង់។

ព្រះគ្រីស្ទមិនត្រឹមតែប្រកាសប្រាប់ពីចំណេះដឹងពីនគរស្ថានសួគ៌ទេ ក៏ប៉ុន្តែទ្រង់ក៏ប្រទានសេចក្តីប្រោសលោះដល់មនុស្សបាត់បង់នូវទឹករស់ដើម្បីបំបាត់ភាពស្រេកឃ្លានដល់អ្នកដែលអាចស្តុកទឹកអណ្តូងពីខាងក្នុងចិត្តអ្នកជឿជាទន្លេទឹករស់ផងដែរ។ ទ្រង់ប្រទានជីវិតដល់ពិភពលោកដែលកំពុងស្លាប់ ផ្តោតលើល័ក្ខខណ្ឌមួយគឺជាការចុះចូលនឹងព្រះរាជបុត្រាទ្រង់។ ព្រះអង្គព្យាករណ៍ទុកជាមុននូវរួចស្រេចហើយពីដំណើរយាងមកនៃព្រះវិញ្ញាណបរិសុទ្ធនាថ្ងៃបុណ្យទី៥០ ដែលក្រោយមកទ្រង់នឹងផ្តល់ជាកម្លាំងដល់ពួកជំនុំ។ ទស្សនៈវិទូប៉ែកលោកខាងលិច ឬប៉ែកខាងកើតពុំដែលធ្លាប់បានផ្តល់ជីវិតដល់លោកីយដែលកំពុងស្លាប់នោះឡើយ។

ចំណែកឯជនជាតិយូដាដែលបានព្យាយាមកសាងនូវសេចក្តីសុចរិតផ្ទាល់ខ្លួនក្នុងការរក្សាក្រិត្យវិន័យជាអសារឥតការ ក៏គេមិនអាចធ្វើអ្វីបានដែរ។ ប៉ុន្តែព្រះគ្រីស្ទបានយាងមកដើម្បីធ្វើកិច្ចការដែលលោកម៉ូសេមិនអាចសម្រេចធ្វើបាន។ ឱសូមឲ្យជនជាតិយូដាសព្វថ្ងៃនេះបានចូលមកទទួលព្រះយេស៊ូវគ្រីស្ទធ្វើព្រះមែស៊ីរបស់ផងគេចុះ! ក្នុងធ្វើទីបន្ទាល់របស់យើង សូមកុំឲ្យយើងខ្ញុំភ្លេចថាដំណឹងល្អត្រូវបានប្រទានមក ជាបឋមតាមពិត សំរាប់សាសន៍យូដា។ សូមប្រាប់មិត្តភក្តិជាជនជាតិយូដាអំពីព្រះយេស៊ូវ។

**ការពិចារណា៖** ព្រះយេស៊ូវទ្រង់សង្គ្រោះ។
**ការអធិស្ឋាន៖** ឱសូមប្រទានអំណាចដល់អ្នកបម្រើទ្រង់ឲ្យបានប្រកាសពាក្យបន្ទូលដោយប្រសិទ្ធិភាពផង។

ថ្ងៃទី ១៨ សីហា
យ៉ូហាន ៧:៤០-៥៣



## «អ្នករាល់គ្នានឹងស្គាល់សេចក្តីពិត ហើយសេចក្តីពិតនោះនឹងប្រោសឲ្យ អ្នករាល់គ្នាបានរួច» (យ៉ូហាន ៨:៣២)

ព្រះយេស៊ូវជាសេចក្តីពិត។ ចំណេះដឹងយើងអំពីទ្រង់នឹងកំណត់នូវសុភមង្គលរបស់យើង។ ប្រភេទមនុស្សដែលមានទំនាក់ទំនងជាមួយនឹងព្រះអម្ចាស់អាចឃើញនៅក្នុងមហាជនដែលបានប្រមូលផ្តុំគ្នាក្នុងទីក្រុងយេរូសាឡឹមនាពិធីបុណ្យបារាំ។

(១). ពួកអ្នកជឿជ្រុលនិយម គណៈផារីស៊ីនិងសង្គ្រាជ អាចារ្យ និងអ្នកប្រាជ្ញច្បាប់ ជាសមាជិកអង្គជំនុំជំរះទាំងចិតសិបនាក់ ជាអ្នកមានចិត្តរឹងមានះក្នុងសេចក្តីសំអប់របស់គេដោយបានស្បថថានឹងសម្លាប់ព្រះយេស៊ូវ។ តើអ្នកប្រឆាំងនឹងព្រះគ្រីស្ទដោយក្តីសំអប់ដែរ?

(២). ពួកអ្នកចេះបទគម្ពីរដែលអាចផ្តល់នូវចម្លើយយ៉ាងត្រឹមត្រូវស្របតាមបទទំនាយ។ ពួកគេអាចចង្អុលប្រាប់ពីព្រះគ្រីស្ទថាជាពូជហ្លួងដាវីឌនិងមកពីភូមិបេថ្លេហិមជាក្រុងនៃស្តេចដាវីឌ តែពួកគេមិនខ្វាយខ្វល់នឹងស្វែងរកពីទីកន្លែងដែលព្រះយេស៊ូវជាអ្នកស្រុកណាសារ៉ែតយាងមកពិតប្រាកដឡើយ។ ដូចជាអតីតសាស្ត្រាចារ្យប្រវត្តិសាស្ត្រនៅសាកលវិទ្យាល័យជាតិសឹង្ហបូរី ដែលបានសរសេរខុសថាព្រះគ្រីស្ទប្រសូត្រនៅស្រុកណាសារ៉ែត (អ្នកជំនួយការព្រះវិហារជីវិត *«Life Church»* បានឃើញពីកំហុសនោះក៏បានសរសេរលិខិតមួយច្បាប់ដោយសន្តានចិត្តល្អជម្រាបគាត់ពីកំហុសនោះ ហើយគាត់បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ) សាសន៍យូដាទាំងនេះបានសន្និដ្ឋានដោយគ្មានការពិចារណាថាព្រះយេស៊ូវជាអ្នកស្រុកកាលីឡេ (ពីកំណើត) ដូច្នោះដែរ។ ចំណេះដឹងត្រឹមតែទ្រឹស្តីដោយគ្មានការបញ្ជាក់ច្បាស់លាស់អាចក្លាយជាចំណេះដឹងបែបអញ្ញមតិ (មតិខុសឆ្គង)។ តើអ្នកស្គាល់ព្រះគ្រីស្ទត្រឹមតែទ្រឹស្តី?

(៣). ពួកអ្នកចាប់អារម្មណ៍ត្រឹមតែមួយរយៈខ្លី ប្រៀបដូចជាដីមានបន្លាដែលគ្រាប់ពូជបានធ្លាក់លើរួចដុះឡើងចាក់ឫសតែសើរៗដី។ អ្នកទាំងនេះគឺជាសាសន៍យូដាដែលបាប់អារម្មណ៍នឹងចំណេះដឹងរបស់ព្រះយេស៊ូវ ជាពួកមន្ត្រីដែលត្រូវបានគេបញ្ជូនទៅចាប់ព្រះយេស៊ូវតែត្រូវបានត្រឡប់ទៅវិញដោយសារអំណោយទានដ៏ប៉ិនប្រសព្វរបស់ទ្រង់។ តើអ្នកគឺជាមនុស្សបែបនេះ?

(៤). ពួកអ្នកកើតជាថ្មីដូចជាលោកនីកូដេម (ខ ៥០) ជាអ្នកបានជឿតាមរយៈការអស្ចារ្យដែលព្រះយេស៊ូវបានធ្វើថាទ្រង់បានយាងមកពីព្រះជាម្ចាស់។ សាសន៍យូដាមានជំនឿស្មោះត្រង់មកពីស្រុកផ្សេងៗទៀតដែលបានមកចូលរួមពិធីបុណ្យ (ខ ៣១) ក៏ដូចជាលោកនីកូដេមដែរ គឺជាអ្នកបានដឹងពីសេចក្តីពិត ថាព្រះយេស៊ូវគឺពិតជាព្រះរាជបុត្រានៃព្រះជាព្រះសង្គ្រោះនៃពិភពលោក។ អ្នកទាំងនេះជាអ្នកជឿសាសន៍យូដាដែលបាននិយាយថា «លោកនេះ ពិតប្រាកដជាហោរានោះហើយ» មានន័យថា ជាហោរាដែលលោកម៉ូសេបានព្យាករណ៍ទុកជាមុននៅក្នុងចោទិយកថា ២៨:១៥, ១៨។ បើអ្នកពិតជាជឿ នោះសេចក្តីពិតនឹងប្រោសឲ្យអ្នកបានរួច គឺរួចចេញពីចំណងទាសភាពអំពើបាបនៃអវិជ្ជាដ៏ចេតនា។ អ្នកណាដែលស្គាល់ព្រះគ្រីស្ទនឹងដើរក្នុងពន្លឺ។ អ្នកមិនជឿគឺជាប់ក្នុងសេចក្តីងងឹតវិញ។

*តាំងពីព្រះគ្រីស្ទប្រោសឲ្យរួចចាក នោះលោកីយនេះដូចស្ថានសួគ៌ហើយ*
*កំពុងរងទុក្ខ ឬព្រួយលំបាក បើស្គាល់ព្រះអង្គនោះមិនភ័យឡើយ។* (ចម្រៀងទំនុកដំកើង ១៧១)។

**ការពិចារណា៖** តើអ្វីទៅជាសេចក្តីពិត?

**ការអធិស្ឋាន៖** ព្រះអម្ចាស់អើយ សូមបណ្តាលឲ្យខ្ញុំស្គាល់សេចក្តីពិតរបស់ទ្រង់ផង។

*«ដ្បិតទ្រង់នឹងអុជប្រទីបរបស់ទូលបង្គំ ព្រះយេហូវ៉ាដ៏ជាព្រះនៃទូលបង្គំ ទ្រង់ធ្វើឲ្យសេចក្តីងងឹតនៃទូលបង្គំភ្លឺឡើង» (ទំនុកដំកើង ១៨:២៨)។*

# ជំពូកទី ៨

## ព្រះយេស៊ូវគ្រីស្ទចាំងពន្លឺនៃជីវិតដល់បុរសនិងស្ត្រីនៅក្នុងសេចក្តីស្រើបស្រាលខ្មៅងងឹត

មកដល់ពេលនេះពិធីបុណ្យរបាំបានបញ្ចប់ទៅដោយបរិបូណ៌ (ជំពូក ៧:៣៧) តែព្រះអម្ចាស់នៃយើងទ្រង់មិនបានត្រឡប់ទៅស្រុកកាលីឡេវិញទេ។ ព្រះអង្គបន្តស្នាក់នៅក្នុងក្រុងយេរូសាឡឹមព្រោះទ្រង់បានបញ្ចប់កិច្ចការរបស់ទ្រង់នៅឯនាជនបទ។ អាស្រ័យទៅតាមកាលវិភាគរបស់ព្រះជាម្ចាស់ ទ្រង់ត្រូវតែធ្វើបន្ទាល់នៅក្នុងរាជធានីជាតិ។ ខណៈពេលមហាជនចូលរួមពិធីបុណ្យធ្វើដំណើរជាបន្តបន្ទាប់ទៅបណ្តាផ្ទះសំណាក់នៅក្នុងក្រុង «គេក៏ត្រឡប់ទៅផ្ទះវិញរៀងខ្លួន» តែព្រះយេស៊ូវទ្រង់យាងទៅឯភ្នំដើមអូលីវវិញ (យ៉ូហាន ៧:៥២, ៥៣)។ ព្រះអង្គដែលបានមានបន្ទូល «កូនមនុស្សគ្មានកន្លែងណានឹងកើយក្បាលទេ» (លូកា ៩:៥៨) បានតាំងត្រសាលនៅលើភ្នំខាងក្រោមដើមអូលីវនាយប់នោះ។

នៅពេលព្រះយេស៊ូវត្រឡប់មកព្រះវិហារនាព្រឹកព្រលឹមវិញ ពួកអាចារ្យនិងផារិស៊ីបាននាំស្ត្រីម្នាក់ដែលពួកគេចាប់បានកំពុងប្រព្រឹត្តអំពើកំផិត។ ពួកគេចង់បានយោបលពីទ្រង់ថាគួរធ្វើយ៉ាងណាចំពោះស្ត្រីរូបនេះ គួរតែចោលសម្លាប់នាងនឹងដុំថ្មដូចក្រិត្យវិន័យរបស់ម៉ូសេ ឬក៏យ៉ាងណា។ នេះគឺជាអន្ទាក់។ ជាធម្មតាព្រះអម្ចាស់នៃយើងប្តូរស្ថានភាពទៅជាមានប្រៀបលើសត្រូវរបស់ទ្រង់។ ដោយឥតមានពាក្យជំទាស់តវ៉ាពួកអ្នកចោទប្រកាន់ទាំងប៉ុន្មានក៏បានចែកផ្លូវគ្នារៀងៗខ្លួន។ មេធាវីលើអស់ទាំងមេធាវីនិងជាចៅក្រមលើអស់ទាំងចៅក្រម ជាចៅហ្វាយដ៏ជាព្រះបានរារាំងរាល់ល្បិចកលនិងឧបាយកលរបស់មនុស្ស។

ហេតុតែគ្មានឆន្ទៈទទួលស្គាល់នូវភាពបរាជ័យ សាសន៍យូដាបានផ្តុំគ្នាជាក្រុមឡើងវិញដើម្បីបង្កជម្លោះបន្ថែមទៀត។ ពួកគេបង្កជម្លោះឡើងវិញទាស់នឹងចំណេះដឹងរបស់ទ្រង់ព្រោះតែនៅក្រោមក្រិត្យវិន័យម៉ូសេបើមានសាក្សីត្រឹមតែពីរនាក់គឺនឹងត្រូវកោះហៅមកផ្តល់ចម្លើយ។ ព្រះយេស៊ូវបានឆ្លើយថាទ្រង់មានសាក្សីដទៃទៀត គឺជាព្រះវរបិតារបស់ទ្រង់។ ទោះបីជាព្រះអង្គនៅតែម្នាក់ឯង ទីបន្ទាល់ទ្រង់គឺជាការពិត ព្រោះទ្រង់បានបង្រៀនដ៏ស៊ីជម្រៅសម្រាប់ឲ្យគេធ្វើការវិនិច្ឆ័យ។ ការប្រឈមមុខកើតឡើងនៅក្នុងរតនាគារព្រះវិហារដែលគេស្គាល់ថាជាទីធ្លាស្ត្រី។ ព្រះយេស៊ូវទ្រង់គឺជាកំពូលគ្រូអធិប្បាយសង្គ្រាមប៉ាកា។

វាគឺជាការប្រឈមមុខគ្នាដ៏ជូចត់មួយ ហើយវាគឺជាការដ៏អស្ចារ្យមួយដែលពួកចៅហ្វាយសាសន៍ខឹងសម្បារអនុញ្ញាតឲ្យទ្រង់ចាកចេញ។ នៅក្នុងការដឹកនាំ (បុព្វទេព) នៃព្រះជាម្ចាស់ ពួកគេត្រូវបានបង្អាក់ដោយសារអ្នកគាំទ្រដ៏មានប្រជាប្រិយភាពថ្វាយដល់ព្រះអម្ចាស់ «តែគ្មានអ្នកណាចាប់ទ្រង់ទេ ព្រោះកំណត់របស់ទ្រង់មិនទាន់ដល់នៅឡើយ» (ខ២០)។ បុព្វហេតុ (ខាងក្រោយ) នៃការរារាំងដ៏ខ្លាំងក្លានេះតាមពិតគឺជាព្រះជាម្ចាស់ផ្ទាល់។

ខ ២១-៣០ គឺជាផ្នែកថ្មី។ នៅចំណុចនេះព្រះយេស៊ូវបង្ហើបប្រាប់ពីការជាប់ឆ្កាងរបស់ទ្រង់ (ខ ២៨) និងការសុគតនាដែលជិតនិងកើតឡើង ហើយនិងពីដំណើរយាងទៅឯព្រះវរបិតារបស់ទ្រង់វិញ (ខ ២១-២៤)។ ជាថ្មីម្តងទៀតទ្រង់ត្រូវបានគេបដិសេធន៍ដោយឥតញញើត។

ខ ៣១-៥៩ សម្តែងប្រាប់ពីការប្រឈមមុខចុងក្រោយគឺបើអាស្រ័យតាមជំពូកនេះ។ វាគឺជាជម្លោះវែកញែកដ៏វែងអន្លាយមួយដែលបញ្ចប់ដោយសាសន៍យូដាជាអ្នកមិនជឿបានព្យាយាមចោលព្រះយេស៊ូវនឹងដុំថ្ម តែទ្រង់ចាកចេញពីទីកណ្តាលនៃព្រះវិហារដោយសុវត្ថិភាព។

ប្រធានបទចម្បងគឺសេរីភាព។ ពួកសាសន៍យូដាមានអំណួតពីខ្លួនគេព្រោះជាកូនចៅលោកអ័ប្រាហាំហេតុនេះទើបនៅចំពោះព្រះគេបានគិតថាគេជាប្រជាជាតិមានសេរីភាព។ នេះគឺជាការបើកសម្តែងពីទឹកចិត្តស្នេហាជាតិដែលនាំឲ្យគេក្លាយជាទាសករយ៉ាងច្បាស់ក្រោមអំណាចបរទេសគឺពីប្រទេសអេស៊ីព្ទរហូតដល់ចក្រភពរ៉ូម។ ព្រះយេស៊ូវព្យាយាមបង្ហាញនូវសេរីភាពពីបាបដែលទ្រង់កំពុងបង្រៀន។ ព្រះអង្គចង្អុលប្រាប់ថាពួកគេជាកូនរបស់អារក្ស (ខ ៤៤) និងកំពុងជាប់ក្នុងចំណងទាសករនៃអំពើបាប។ មធ្យោបាយតែមួយគត់ដើម្បីរួចផុតបីចំណងទាសករនៃអំពើបាបនិងសេចក្តីស្លាប់ឆ្ពោះទៅរកសេរីភាពនិងជីវិតគឺតាមរយៈព្រះបុត្រា។ ពាក្យនេះបានបង្កជាជម្លោះជាលើកទីពីរនឹងសាសន៍យូដាអំពីលោកអ័ប្រាហាំដែលព្រះយេស៊ូវសម្តែងប្រាប់ពីវត្តមានរបស់ទ្រង់មុនលោកមានកំណើត។ ជាថ្មីម្តងទៀត ការបង្រៀននេះបង្កជាជម្លោះព្រោះគេចាត់ទុកព្រះអម្ចាស់មានព្រះជន្មត្រឹមក្រោម៥០ឆ្នាំ។ តើធ្វើដូចម្តេចនឹងលោកអ័ប្រាហាំឃើញទ្រង់បើគាត់បានស្លាប់ជាច្រើនឆ្នាំមកហើយ? សាសន៍យូដាពិតជាយល់ខុសពីព្រះបន្ទូលនៃជីវិតមែន! ចុះចំណែកអ្នកវិញ?

**ការពិចារណា៖** បើខ្ញុំនៅក្នុងទីងងឹតនៃអំពើបាប ខ្ញុំនឹងមិនយល់ពីទីមានពន្លឺឡើយ។
**ការអធិស្ឋាន៖** ឱព្រះវរបិតាអើយ សូមទ្រង់បំភ្លឺជីវិតខ្ញុំដោយពន្លឺនៃសេចក្តីពិតរបស់ទ្រង់ផង។

*«ក្នុងពួកអ្នកកាល់គ្នា បើមានអ្នកណាមានប្រាជ្ញានិងយោបល ត្រូវឲ្យអ្នកនោះសម្តែងចេញជាកិរិយាល្អ ដោយសារការដែលខ្លួនប្រព្រឹត្ត ដោយសុភាពនៃប្រាជ្ញាចុះ»* (១ ពេត្រុស ៣:១៣)។

## ចៅក្រមដ៏ខ្ពស់អស់ទាំងចៅក្រមនិងជាកំពូលមេធាវី

អ្នកអានព្រះគម្ពីរភាសាអង់គ្លេសកែសម្រួលបែបស្តង់ដារ (*Revised Standard Version*) នឹងឃើញអត្ថបទដ៏បរិសុទ្ធនៃព្រះគម្ពីរនៅក្នុងជំពូកនេះបោះពុម្ពជាអក្សរតូចៗ និងនៅក្នុងព្រះគម្ពីរអង់គ្លេសថ្មី (*New English Bible*) យកជំពូកនេះទៅដាក់នៅខាងក្រោយព្រះគម្ពីរទុកដូចជាការបន្ថែម។ មូលផលនៃការដាក់អត្ថបទនេះដូច្នេះព្រោះតែអ្នកបកប្រែសម័យទំនើបសម្រាប់កំណែព្រះគម្ពីរខាងលើអះអាងថាផ្នែកនេះមិនមាននៅក្នុងសំណៅនៃច្បាប់ដើមពីបុរាណ ដូចនេះវាមិនមែនជាផ្នែកនៃដំណឹងល្អរបស់សាវ័កយ៉ូហាន។ យើងជឿកំណត់ត្រាអំពីព្រះយេស៊ូវនិងស្ត្រីដែលគេចាប់បាននាពេលកំពុងប្រព្រឹត្តអំពើផិតក្បត់នេះថាពិតជាពាក្យបន្ទូលរបស់ព្រះ។ អត្ថន័យយោងរបស់លោកស្កូហ្វីលស៍ (*Scofield*) ត្រង់ចំណុចនេះគាំទ្រទស្សនៈរបស់យើង។ បណ្ឌិត ហូម៉ឺរ អេ ខិន (*Homer A. Kent*) ជាសាស្ត្រាសាកលវិទ្យាល័យទេវសាស្ត្រក្រេស(*Grace Theological Seminary*) បានស្រង់ពាក្យរបស់លោកលេអុន ម៉ូរីស (*Leon Morris*) ដូច្នេះថា៖ «ក៏ប៉ុន្តែបើយើងមិនអាចមានអារម្មណ៍ថាផ្នែកនេះគឺជាដំណឹងល្អរបស់សាវ័កយ៉ូហានទេ យើងអាចនឹងមានអារម្មណ៍ថាដំណើររឿងនោះគឺជាការពិតដោយផ្អែកលើចរឹកលក្ខណៈរបស់ព្រះយេស៊ូវ។ នៅក្នុងប្រវត្តិសាស្ត្រនៃពួកជំនុំបានគ្រាំទ្រថាទោះបីជាបុគ្គលណាសរសេរផ្នែកនេះក៏ដោយកំណត់ត្រានេះគឺជាការពិត។ វាគឺជាការពិត។ ព្រះវិញ្ញាណបរិសុទ្ធនឹងបញ្ជាក់ប្រាប់នៅក្នុងចិត្តរបស់អ្នកបន្ទាប់ពីបានអានវារួចថាតើវាជាផ្នែកនៃពាក្យបន្ទូលរបស់ព្រះឬយ៉ាងណា។

ឥឡូវនេះចូរយើងរៀនមេរៀនដ៏ល្អមួយអំពីប្រាជ្ញាដ៏អស្ចារ្យពីចៅក្រមដ៏កំពូល។ ទ្រង់នេះហើយគឺជាអង្គដ៏ធំជាងស្តេចសាឡូម៉ូន។ ព្រះអង្គនេះហើយដែលឆ្លាតជាងហោរាដានីយ៉ែល។ សូមពិនិត្យមើលពាក្យពេចន៍មកពីព្រះឱស្ឋមេធាវីកំពូលបង្វែរអន្ទាក់ដែលសាសន៍យូដាបានគប់ដាក់ទ្រង់ឲ្យត្រឡប់ទៅកាន់ពួកគេវិញ។ ពួកអ្នកចោទប្រកាន់បានក្លាយប្រែទៅជាប់ចោទវិញម្តង។ ពួកគេបានក្លាយជាមានទោស ដោយបញ្ញាចិត្តរបស់គេបានចាក់ចុចក្នុងចិត្តរបស់គេ។ ពេជ្ឈឃាតបានប្រែជាត្រូវបានគេសំឡាប់វិញ។

ពួកអ្នកសួរដេញដោលព្យាយាមស្មានពាក្យដែលព្រះយេស៊ូវបានសរសេរ។ អ្នកខ្លះថែមទាំងបានអះអាងថាខ្លួនមានចំណេះដឹងអំពីការបើកសម្តែងពីព្រះវិញ្ញាណបរិសុទ្ធ។ នេះគឺជាការដើកសួរមិនបរិសុទ្ធ។ នេះគឺជាមោទនភាពនៃការបញ្ឆោតខ្លួនឯង។ ចូរយើងរៀនពីបណ្ឌិតកាល់វីនដែលពោលថាកន្លែងណាព្រះគម្ពីរនៅស្ងៀមយើងគួរគប្បីដោយសេចក្តីគោរពនៅស្ងៀមដែរ នោះទើបជាវិទ្យាសាស្ត្រនៃសិល្បៈកាត់ស្រាយពាក្យបន្ទូលដ៏ល្អ។

លោក យូធីមីអាស ហ្សីហ្គាបិណឹស (*Euthymius Zigabenus*) ជាសង្ឃនៃក្រុងខន់ស្តែនទីណូប៉ូល បាននិពន្ធសៀវភៅនាសតវត្សទី១២ មានកំណត់សំគាល់ដ៏ល្អមួយអំពីស្ថានភាពដូចខាងលើថា៖ «ព្រះយេស៊ូវឱនចុះនិងដោយសេចក្តីក្រោធរបស់ទ្រង់សរសេរនៅលើដី នៅពេលជារឿយៗពួកសាសន៍យូដាមិនដឹងថានឹងត្រូវដោះស្រាយយ៉ាងណាជាពួកអ្នកគ្មានឆន្ទៈផ្តល់ចម្លើយសម្រាប់សំណួរគ្មានតម្លៃនាស្ថានភាពមិនល្អ»។ តើយើងអាចហៅទង្វើរបស់ទ្រង់នេះដូចជាពាក្យរបស់អ្នកអប់រំសម័យទំនើបជា «ភាសាកាយវិការ» ដែរឬទេ?

**ការពិចារណា៖** សូមទន្លេញចងចាំ ១ ពេត្រុស ៣:១៣។
**ការអធិស្ឋាន៖** ពេលត្រូវនិយាយ និងពេលត្រូវនៅស្ងៀមស្ងាត់។

ថ្ងៃទី ២១ សីហា
យ៉ូហាន ៨:១២-២០

*«ខ្ញុំជាពន្លឺលោកីយ៍ អ្នកណាដែលតាមខ្ញុំ នោះមិនដែលដើរក្នុងសេចក្ដីងងឹតទៀតឡើយ គឺនឹងមានពន្លឺនៃជីវិតវិញ»។*

## ពន្លឺនៃជីវិតនៅក្នុងសង្គមងងឹត

នេះគឺជាទស្សនីយភាពមួយទៀតអំពីទំនាស់នៃព្រះយេស៊ូវនឹងគណៈផារីស៊ី។ នៅក្នុងកម្រងអត្ថាធិប្បាយដំណឹងល្អទាំងបួនដែលមានបីភាគរួមគ្នា បណ្ឌិតដេវីឌ ស្មីត (*Dr. David Smith*) បានធ្វើសេចក្ដីអត្ថាធិប្បាយថា៖ «ពេលនេះគឺជាចុងរដូវស្លឹកឈើជ្រុះ ប្រហែលនៅក្នុងអំឡុងខែតុលា ជារដូវកាលដែលមានរយៈពេលថ្ងៃខ្លី ហើយខណៈពេលទ្រង់បង្រៀនក្បែរឃ្លាំង (រតនាគារ) (សូមអានដំណឹងល្អម៉ាកុស ១២:៤១ និង លូកា ២១:១) ស្បែរាត្រីបានឈានមកដល់គេក៏បានដុតចង្កៀងបំភ្លឺនៅក្នុងបរិវេណព្រះវិហារ។ ជាទម្លាប់របស់ទ្រង់ ព្រះអង្គតែងតែផ្លាស់ប្ដូរទស្សនីយភាពទៅជាការបង្រៀនបែបប្រៀបប្រដូច៖ «ខ្ញុំជាពន្លឺលោកីយ៍» យើងអាចបន្ថែមកំណត់សំគាល់នេះជាមួយលោកស្លូហ្វីល ថាការប្រព្រឹត្តបែបអសីលធម៌ដ៏ខ្មៅងងឹតទាំងឡាយរបស់សាសន៍យូដាក៏អាចប្រើជាផ្ទាំងឆាកសម្រាប់សម្ដែងរាជសាររបស់ទ្រង់បានដែរ។

ជាពិសេស ការតាំងខ្លួនជា**ពន្លឺ**លោកីយនៃព្រះយេស៊ូវនាំឲ្យគណៈផារីស៊ីអាក់អន់ចិត្ត។ ព្រោះវាជានាមសម្រាប់ព្រះមែស៊ី។ នៅក្នុងន័យនេះ បណ្ដាគ្រូទាំងឡាយក៏ជា «ពន្លឺ» តូចៗដែរ។ តើគ្រូដ៏វ័យក្មេងនេះជាអ្នកណាហ៊ានទទួលយកនាមនេះ? ពួកគេបដិសេធទ្រង់ដោយសារការខ្វះនូវលក្ខណៈសម្បត្តិផ្នែកចំណេះដឹងរបស់ទ្រង់។ តើអ្នកណាជាអ្នកបញ្ជាក់ពីលក្ខណៈសម្បត្តិរបស់ទ្រង់?

ចម្លើយតបរបស់ព្រះអម្ចាស់គឺមានពីរផ្នែក៖ (១) ព្រះអង្គគឺជាសាក្សីពិតពីអង្គទ្រង់ផ្ទាល់។ ពាក្យទាំងឡាយណាដែលទ្រង់បានមានបន្ទូលពីអង្គទ្រង់គឺស្ថិតក្នុងលទ្ធភាពមួយដែលសាសន៍យូដាមិនអាចយល់បាន។ ហេតុនេះពួកគេមិនអាចបញ្ជាក់ថាទ្រង់ខុសឆ្គងបានឡើយ។ (២) ព្រះអង្គមានសាក្សីទីពីរ ស្របតាមក្រិត្យវិន័យរបស់ម៉ូសេ (ចោទិយកថា ១៩:១៥) គឺព្រះវរបិតាជាព្រះដែលចាត់ឲ្យទ្រង់មក។ ទោះជាយ៉ាងណា ព្រះវរបិតាដែលព្រះអម្ចាស់នៃយើងបានមានបន្ទូលគឺជាប្រស្នាមួយដល់ពួកគេ។ ព្រោះវិធីនៃការស្គាល់ព្រះវរបិតាគឺតាមរយៈព្រះរាជបុត្រា តែបើគេមិនស្គាល់ព្រះបុត្រាធ្វើយ៉ាងឲ្យពួកគេស្គាល់ព្រះវរបិតាបាន? ជាថ្មីម្ដងទៀត សាសន៍យូដាគឺត្រូវបានចាត់ទុកដូចជាមហាជនដែលអវិជ្ជា។ ដូច្នេះហើយទើបពួកគេក្ដៅក្រហាយមានចិត្តចង់ធ្វើសម្លាប់ទ្រង់។

លុះត្រាតែជឿដ៏ស្មោះត្រង់និងទទួលស្គាល់ព្រះយេស៊ូវគ្រីស្ទជាព្រះរាជបុត្រានៃព្រះ ទើបអ្នកនឹងមិនបដិសេធទ្រង់ថាជា**ពន្លឺ**លោកីយ។ បើពុំនោះសោតទេ អ្នកនឹងចាត់ទុកទ្រង់ស្ថិតនៅលំដាប់ជាមួយនឹងព្រះពុទ្ធ ដែលពេលខ្លះហៅថាជា «**ពន្លឺនៃអាស៊ី**»។ ដូចនេះ ព្រះយេស៊ូវត្រូវបានពួកអ្នកបង្រៀនខុសឆ្គងនៃជនជាតិអាស៊ីអាគ្នេយ៍មួយក្រុមចាត់ទុកថាជាពន្លឺមួយក្នុងចំណោមពន្លឺឯទៀត គឺ «សមាគមសាសនាទាំងប្រាំ (*Five Religion Society*)»។ ក្រុមខុសឆ្គងមួយទៀតចាត់ទុកព្រះគ្រីស្ទថាជាអាទិទេពមួយក្នុងបណ្ដាអាទិទេពឯទៀត គឺក្រុមសមាគមស្វាស្ទីកាក្រហម (*Red Swastika Society*)។ ហើយយើងក៏អាចបន្ថែមឈ្មោះក្រុមជាច្រើនទៀតទៅក្នុងតារាងនេះដែរ ដោយចាប់ផ្ដើមពីពួកសាសន៍យូដាដែលមិនជឿទាំងនេះ។

**ការពិចារណា៖** បើព្រះយេស៊ូវជាពន្លឺនៃលោកីយ៍ (ខ ១២) នោះអ្នកគិតយ៉ាងណាអំពីពន្លឺឯទៀត?
**ការអធិស្ឋាន៖** ឱព្រះអម្ចាស់អើយ សូមកុំឲ្យខ្ញុំភ្លេចឡើយថាខ្ញុំជាពន្លឺតូចៗដែលត្រូវបំភ្លឺថ្វាយទ្រង់ដែរ។

*«កំពុងដែលទ្រង់មានព្រះបន្ទូលសេចក្តីទាំងនេះ នោះមានមនុស្សជាច្រើនបានជឿដល់ទ្រង់»។*

## ការបដិសេធន៍ផ្លូវទៅនគរឋានសួគ៌

ជាថ្មីម្តងទៀតព្រះយេស៊ូវបានប្រកាសអំពីប្រភពដើមពីស្ថានសួគ៌និងដំណើរវិលត្រឡប់ទៅស្ថានសួគ៌ដ៏ឆាប់ៗរបស់ទ្រង់។ ជាថ្មីនេះ ព្រះអង្គក៏សម្តែងប្រាប់ពីដំណើរយាងមកផែនដីរបស់ទ្រង់ពីព្រះវរបិតានានគរស្ថានសួគ៌និងដំណើរវិលត្រឡប់ដ៏ឆាប់ៗទៅកាន់ព្រះវរបិតាផងដែរ។

ចំណេះដឹងនេះគឺជ្រាលជ្រៅណាស់សម្រាប់មនុស្សធម្មតា ព្រោះពួកគេគិតថាទ្រង់នឹងធ្វើអត្តឃាត (ខ ២២) បើមិនដូច្នោះទេ គេសន្និដ្ឋានថាមានតែទ្រង់ជាមនុស្សសតិមិនល្អនិងជាមនុស្សឆ្កួត ដែលនឹងត្រូវធ្លាក់ទៅនរក (ជនជាតិយូដាជឿថាអ្នកធ្វើអត្តឃាតនឹងវិនាសក្នុងអំពើបាបរបស់ខ្លួន)។

ជាការជំទាស់នឹងពាក្យមិនគួរសមរបស់ពួកគេ ព្រះអម្ចាស់នៃយើងបានមានបន្ទូលប្រាប់យ៉ាងច្បាស់លាស់ថាពួកគេនឹងស្លាប់ក្នុងអំពើបាបរបស់គេ ប្រសិនបើគេបន្តរឹងរូសក្នុងជំហរបដិសេធន៍អង្គបុគ្គលដែលប្រាប់គេពីសេចក្តីពិតចាប់តាំងពីពេលដំបូងរៀងមក (ខ ២៥)។ ពីព្រោះតែការបដិសេធព្រះបុត្រា ហេតុនេះទើបពួកគេមិនអាចទទួលយកទីបន្ទាល់របស់ព្រះអម្ចាស់នៃយើងអំពីព្រះវរបិតា។

នៅក្នុងខទី២៨ ព្រះយេស៊ូវបានព្យាករណ៍ទុកជាមុនពីដំណើរដែលទ្រង់នឹងត្រូវសុគត។ «កាលណាអ្នករាល់គ្នាបានលើកកូនមនុស្សឡើង» មានន័យថាជា «ពេលអ្នករាល់គ្នាឆ្កាងកូនមនុស្ស»។ តាមរយៈសេចក្តីស្លាប់របស់ទ្រង់ដែលពួកគេនឹងដឹងពីភាពជាព្រះរាជបុត្រានៃព្រះរបស់ទ្រង់ អំពីពេលកំណត់និងការទទួលស្គាល់ពីព្រះជាម្ចាស់របស់ទ្រង់។ ហេតុអ្វី? ព្រោះការសុគតរបស់ទ្រង់នឹងមិនមែនជាសេចក្តីស្លាប់ធម្មតាដូចការស្លាប់ដែលអ្នកនិងខ្ញុំនឹងត្រូវស្លាប់ឡើយ។ វាគឺជាសេចក្តីស្លាប់មួយដែលតាមរយៈសេចក្តីស្លាប់នេះទ្រង់នឹងប្រោសឲ្យមានជីវិតឡើងវិញដល់ពួកអ្នកជឿដោយព្រោះតែការរស់ពីស្លាប់របស់ទ្រង់។ ការរស់ពីស្លាប់ឡើងវិញរបស់ទ្រង់នឹងនាំឆ្ពោះទៅរកការយាងត្រឡប់ទៅស្ថានសួគ៌និងការលើកដំកើងរបស់ទ្រង់ ហើយនិងការបញ្ជូនអង្គព្រះវិញ្ញាណបរិសុទ្ធនាបុណ្យថ្ងៃទី៥០ដើម្បីបន្តពន្ធ័កិច្ចក្នុងពិភពលោក។

វាគឺជាសេចក្តីអំណររីករាយមួយដោយឃើញថាទោះជាការបដិសេធនៃសាសន៍យូដាថាព្រះយេស៊ូវជាពន្លឺនៃលោកីយ៍ ក៏នៅមានមនុស្ស «ជាច្រើននាក់» ផ្សេងទៀតជឿលើទ្រង់ដែរ (ខ ២៩)។ នេះពិតជាកត្តាលើកទឹកចិត្តមួយដល់យើងដែលប្រកាសប្រាប់ពីព្រះយេស៊ូវថាទោះជាសេចក្តីអធិប្បាយរបស់យើងទទួលរងនូវការបដិសេធរបស់មនុស្សមួយចំនួន ក៏នៅមានអ្នកឯទៀតជឿលើដំណឹងល្អដែរ។ អាម៉ែន!

**ការពិចារណា៖** តើខ្ញុំស្ថិតនៅក្នុងចំណោម *«មនុស្សជាច្រើនបានជឿដល់ទ្រង់»* (ខ ៣០)?
**ការអធិស្ឋាន៖** ព្រះវរបិតាអើយ សូមឲ្យខ្ញុំជាភាជនៈដែលទ្រង់ប្រើសម្រាប់ប្រកាសដំណឹងល្អទ្រង់ផង។

*«អ្នករាល់គ្នានឹងស្គាល់សេចក្តីពិតហើយសេចក្តីពិតនោះនឹងប្រោសឲ្យអ្នករាល់គ្នាបានរួច» (ខ ៣០)។*

## កូននៃសេរីភាព

នៅផ្នែកមួយនៃអត្ថបទខគម្ពីរមុនបញ្ចប់ដោយពាក្យដ៏រីករាយ «កំពុងដែលទ្រង់មានបន្ទូលសេចក្តីទាំងនេះ នោះមានមនុស្សជាច្រើនបានជឿដល់ទ្រង់» (ខ ៣០)។ ពួកអ្នកជឿទាំងនេះ គឺជាទារកទើបនឹងបានកំណើតថ្មី ហើយត្រូវការ «ទឹកដោះសុទ្ធខាងឯព្រលឹងវិញ្ញាណ» ដើម្បីឲ្យគេបានចំរើនធំឡើង (១ ពេត្រុស ២:២)។ ដូច្នេះព្រះអម្ចាស់នៃយើងបន្តបង្រៀនដល់អ្នកជឿជនជាតិយូដាទាំងនេះដើម្បីឲ្យគេពិសោធនូវភាពដ៏ពេញលេញក្នុងសេចក្តីសង្គ្រោះ។ ព្រះអង្គមានបន្ទូលថា៖ «អ្នករាល់គ្នានឹងស្គាល់សេចក្តីពិត ហើយសេចក្តីពិតនោះនឹងប្រោសឲ្យអ្នករាល់គ្នាបានរួច» (ខ ៣០)។

សាសន៍យូដា ទោះបីគេបានក្លាយជាបាវបំរើដោយសារជនជាតិបរទេសដូចជាសាសន៍អេស៊ីព្ទ សាសន៍អាសើ សាសន៍បាប៊ីឡូន សាសន៍ពើស៊ី សាសន៍ក្រេកនិងបច្ចុប្បន្នសាសន៍រ៉ូម៉ាំងក្នុងប្រវត្តិសាស្ត្រដ៏យូរលង់របស់ពួកគេ ក៏ពួកគេនៅតែជាសាសន៍មួយដ៏មានអំណួតដដែល។ គេអួតខ្លួនថាជាពូជរបស់លោកអ័ប្រាហាំ ជារាស្ត្រជ្រើសតាំងរបស់ព្រះជាម្ចាស់។ ហេតុនេះទើបគេឆ្លើយថា៖ «យើងរាល់គ្នាជាពូជលោកអ័ប្រាហាំ ក៏មិនដែលធ្វើជាបាវបំរើរបស់អ្នកណាឡើយ» (ខ ៣៣)។ ពាក្យនេះគឺពិតជាមកពីគំនិតរបស់គេផ្ទាល់ខ្លួនពិតមែន!

រាជសាររបស់ព្រះអម្ចាស់នៃយើងអំពីសេរីភាពគឺជាសេរីភាពដ៏មានន័យជ្រៅ។ វាមិនមែនជារាជសារទាក់ទងនឹងនយោបាយនិងបែបសេរីៗខាងក្រៅនោះឡើយ។ វាទាក់ទងជាមួយនឹងផ្នែកព្រលឹងវិញ្ញាណនិងជាផ្នែកពីខាងក្នុង (នៃមនុស្សម្នាក់ៗ) វិញ។ ជនជាតិយូដាជាកូនរបស់លោកអ័ប្រាហាំ តែគេជាបាវបំរើនៃអំពើបាបនៅឡើយ។ ហេតុនេះពួកគេមិនមែនជាកូនមានសេរីភាពជាពួកអ្នកដែលត្រឹមតែអាចប្រកាសយកសាច់សាលោហិតរបស់អ័ប្រាហាំនោះឡើយ។ គេជាកូននៃសេរីភាពលុះត្រាគេមានសេរីភាពពីបាបដោយសារព្រះយេស៊ូវគ្រីស្ទដែលជាផ្លូវ ជាសេចក្តីពិត និងជាជីវិត។ ពួកគេជាកូននៃសេរីភាពព្រោះបានរំដោះចេញពីចំណងទាសករនៃអំពើបាប។

វានឹងគ្មានអត្ថប្រយោជន៍អ្វីចំពោះសាសន៍យូដាដែលតាំងខ្លួនជាកូនរបស់អ័ប្រាហាំត្រឹមតែខាងផ្នែកសាច់ឈាមនោះឡើយ។ ពួកគេគួរតែជាកូនរបស់លោកអ័ប្រាហាំខាងផ្នែកព្រលឹងវិញ្ញាណ តាមរយៈការមានជំនឿលើព្រះអម្ចាស់យេស៊ូវគ្រីស្ទ ដូចអ័ប្រាហាំជា «ឪពុកដល់អស់អ្នកដែលជឿ» (រ៉ូម ៤:១១) ទើបជាការប្រសើរ។ ដូច្នេះនៅពេលសាសន៍យូដានាំគ្នាអួតអាងខ្លួនជាកូនលោកអ័ប្រាហាំនោះពាក្យបញ្ជាក់អះអាងថាគេជាកូនមានសេរីភាព (មិនមែនបាវបំរើ) ព្រះអម្ចាស់នៃយើងបង្ហាញកំហុសនេះដើម្បីឲ្យគេភ្ញាក់ខ្លួន។ មូលហេតុគឺព្រោះតែគេមិនបានប្រព្រឹត្តឲ្យសាកសមជាកូនរបស់អ័ប្រាហាំ។ គេបានព្យាយាមប៉ុនប៉ងសម្លាប់ព្រះយេស៊ូវ ជាអង្គបុគ្គលដែលប្រាប់ពួកគេពីសេចក្តីពិតនៃព្រះដែលអាចរំដោះគេឲ្យមានសេរីភាពពីបាប។ ពួកគេបានប្រព្រឹត្តផ្ទុយខុសនឹងលោកអ័ប្រាហាំជាអ្នកបានទទួលព្រះយេហូវ៉ា ជាព្រះគ្រីស្ទនៃនាសម័យសញ្ញាចាស់ ដោយក្តីអំណររីករាយនាសម័យលោកនៅរស់មានជីវិត (ខ៥៦)។

កូននៃសេរីភាពគឺជាកូនបានជឿលើព្រះយេស៊ូវជាព្រះសង្គ្រោះនៃព្រះដោយបានទទួលនូវការអត់ទោសបាប និងត្រូវបានប្រទានអំណាចឲ្យរស់នៅជីវិតរួចពីចំណងទាសភាពនៃអំពើបាប។

**ការពិចារណា៖** ខ្ញុំក៏ជាកូនរបស់លោកអ័ប្រាហាំដែរ តែជាកូនខាងឯសេចក្តីជំនឿ (រ៉ូម ៤:១១)។
**ការអធិស្ឋាន៖** ឱសូមឲ្យខ្ញុំអួតតែពីព្រះយេស៊ូវគ្រីស្ទដែលបានបង្កើតខ្ញុំជាថ្មីបានហើយ។

ថ្ងៃទី ២៤ សីហា
សុភាសិត ៥
យ៉ូហាន ៨:៤១-៥០

*ដោយព្រោះតែខ្ញុំនិយាយសេចក្ដីពិត បានជាអ្នករាល់គ្នាមិនជឿខ្ញុំ!»*

## កូនរបស់អារក្សសាតាំង

សាសន៍យូដាមិនត្រឹមតែអួតខ្លួនថាជាកូនរបស់លោកអ័ប្រាហាំទេ តែជាកូនរបស់ព្រះដែរ (ខ ៤១)។ តើពួកគេមិនមែនជារាស្ត្រជ្រើសតាំង? អត្តចរឹកបែបនេះមិនត្រឹមតែបង្ហាញនាពេលប្រឈមមុខនឹងព្រះសង្គ្រោះនៃយើងទេ ក៏ប៉ុន្តែនៅក្នុងអត្តចរឹកក្រអឺតក្រទមរបស់ពួកគេចំពោះយ៉ូហាន-បាទីស្ទផងដែរ។ អត្តចរឹកនេះហើយទើបបណ្ដាលឲ្យមានការស្ដីបន្ទោសពីយ៉ូហាន-បាទីស្ទ «ហើយកុំឲ្យគិតក្នុងចិត្តថា មានលោកអ័ប្រាហាំជាឪពុកខ្លួននោះឡើយ» (ម៉ាថាយ ៣:៩)។ នាគ្រាដើមដំបូងនៃការអធិប្បាយរបស់គាត់ លោកយ៉ូហាន-បាទីស្ទបានហៅគេថាជា «ពូជពស់វែក» (ម៉ាថាយ ៣:៧)។

«ហើយអ្នកណាដែលមានឫកខ្ពស់ នឹងចិត្តឆ្មើងឆ្មៃ នោះទូលបង្គំនឹងទ្រាំមិនបានឡើយ» (ទំនុកដំកើង ១០១:៥)។ ព្រះយេស៊ូវផ្ដល់ឱកាសដល់មនុស្ស មិនដូច្នេះទេ ទ្រង់មិនផ្ដល់ឱកាសលើកទីពីរដល់មនុស្សអំណួតឡើយ។ ដូច្នេះព្រះអង្គបានមានបន្ទូលប្រាប់សាសន៍យូដាដែលតាំងខ្លួនជាមនុស្សសុចរិតទាំងនេះផ្ទាល់ថា «អ្នករាល់គ្នាមានអារក្សសាតាំងជាឪពុក ហើយអ្នករាល់គ្នាចូលចិត្តធ្វើតាមតណ្ហា ដែលគាប់ចិត្តដល់ឪពុករបស់អ្នក វាជាអ្នកសំឡាប់គេតាំងពីដើមមក វាមិនបាននៅជាប់ក្នុងសេចក្ដីពិត ព្រោះគ្មានសេចក្ដីពិតនៅក្នុងវាទេ កាលណាវាពោលពាក្យភូតភរ នោះដុះចេញអំពីចិត្តវាមក ដ្បិតវាជាអ្នកកំភូត ហើយជាឪពុកនៃសេចក្ដីនោះឯង។ ដោយព្រោះតែខ្ញុំនិយាយសេចក្ដីពិត បានជាអ្នករាល់គ្នាមិនជឿខ្ញុំ!» (ខ ៤៤-៤៥)។ ពិតជាអាក្រក់មែន! នៅពេលមនុស្សម្នាក់បដិសេធព្រះគ្រីស្ទបន្ទាប់ពីបានឮសេចក្ដីពិត គឺដូចសេចក្ដីងងឹតរលាយពីពន្លឺភ្លឺ គាត់នឹងក្លាយជាកូនរបស់អារក្សសាតាំង។ ពេលមនុស្សម្នាក់បដិសេធពាក្យបន្ទូលរបស់ព្រះយេស៊ូវ គាត់នឹងចុះចូលខាងសាតាំង។ គាត់នឹងធ្វើកិច្ចការទាំងឡាយណាដែលអារក្សចង់ធ្វើ ដូចជាការកាប់សម្លាប់ ការនិយាយកុហកភូតភរ ពោលគឺធ្វើការគ្រប់យ៉ាងទាស់នឹងសេចក្ដីពិត។

ហេតុនេះតែបដិសេធសេចក្ដីពិតដែលនាំឲ្យគេមានសេរីភាព ពួកសាសន៍យូដាបែរជាប្រព្រឹត្តពីការនិយាយភូតកុហក់រហូតដល់ការមូលបង្កាច់។ ពួកគេបានប្រមាថព្រះយេស៊ូវថាជាសាសន៍សាម៉ារី។ គេដេរប្រមាថទ្រង់ថាជាអារក្សខាំផ្អេញយ៉ាងសាហាវដូចជាសត្វព្រានជួបនឹងរំពា។ ព្រះអម្ចាស់នៃយើងឥតសម្របតាមការប្រមាថនេះឡើយ។ ទ្រង់ទូលអំនាវដល់ព្រះជាម្ចាស់ (ខ ៥០)។ កូនរបស់ព្រះតយុទ្ធដ៏ល្អប្រសើរសម្រាប់សេចក្ដីពិតទាស់នឹងកូនអារក្សសាតាំង។ នេះដាស់រំឭកយើងជាថ្មីម្ដងទៀតអំពីតម្រូវការអធិប្បាយបែបសង្គ្រាមប៉ាកានាពេលបច្ចុប្បន្ន។ ការផ្ដល់បទបង្ហាញដំណឹងល្អបែបវិជ្ជមានក្នុងវិធីសាស្ត្រប្រសើរគឺមិនមែនជាបទបង្ហាញដោយវិញ្ញាណនៃសេចក្ដីពិតទេ ហើយក៏មិនមែនតាម**គំរូ**របស់ព្រះរាជបុត្រានៃព្រះដែរ។ វិធីសាស្ត្របែបនេះតាមពិតគឺជាការសម្របសម្រួល (ឬចរចារ) ជាមួយនឹងអារក្សសាតាំងវិញ។

**ការពិចារណា៖** ការត្រឡប់ទៅជីវិតចាស់គឺបណ្ដាលមកពីការបដិសេធសេចក្ដីពិតនៃព្រះបន្ទូល។
**ការអធិស្ឋាន៖** ព្រះវរបិតាអើយ សូមទ្រង់ជួយកុំឲ្យខ្ញុំធ្វើតាមចិត្តរបស់ខ្ញុំឡើយ តែឲ្យតាមពាក្យបន្ទូលទ្រង់វិញ។

ថ្ងៃទី ២៥ សីហា
យ៉ូហាន ៨:៥១-៥៩

*«...មុនដែលលោកអ័ប្រាហាំកើតមក នោះមានខ្ញុំហើយ»។*

## ធំជាងលោកអ័ប្រាហាំ

ដោយសារតែព្រះអម្ចាស់នៃយើងធ្វើឲ្យការអួតអាងនៃសាសន៍យូដាពីភាពជាកូនអ័ប្រាហាំរបស់គេបរាជ័យ ហើយហៅគេថាជាកូនអារក្សសាតាំងផងនោះ ទើបពួកគេបានផ្លាស់ប្តូរយុទ្ធសាស្ត្ររបស់គេទៅភាពឧត្តុងឧត្តមនៃលោកអ័ប្រាហាំវិញម្តង។ នេះគឺគ្រាន់តែជាការដំកើងខ្លួនគេម្តងទៀតតាមវិធីផ្សេងប៉ុណ្ណោះ។

នៅពេលព្រះអម្ចាស់នៃយើងប្រទានជីវិតដ៏មិនចេះស្លាប់ដល់អ្នកស្តាប់តាមពាក្យបន្ទូលរបស់ទ្រង់ (ខ៥១) ពួកសាសន៍យូដាបានស៊កសម្តីថាព្រះអង្គគឺកំពុងតែតាំងខ្លួនធំជាងលោកអ័ប្រាហាំ។ តើទ្រង់ធំជាងលោកអ័ប្រាហាំដែលបានស្លាប់រហូតមកដល់ពេលនេះនិងធំជាងបណ្តាពួកហោរាដែលឥឡូវនេះបានស្លាប់រួចហើយដែរឬ? ព្រះយេស៊ូវបានមានបន្ទូលតបថាភាពមហិមាអស្ចារ្យរបស់ទ្រង់ឥតទទួលបានមកពីទ្រង់ផ្ទាល់ទេ តែមកពីព្រះដ៏ជាព្រះវរបិតាជាអង្គបុគ្គលដែលគេមិនទទួលស្គាល់ជាព្រះវរបិតារបស់គេវិញ។ កិត្តិយសនេះបានប្រទានមកព្រះអង្គដោយសារទ្រង់ស្តាប់បង្គាប់ព្រះវរបិតាយ៉ាងស្មោះត្រង់ (ខ ៥៥)។ ពិតមែនហើយ ទ្រង់គឺជាព្រះរាជបុត្រានៃព្រះ ជាព្រះយេហូវ៉ានៃសម័យសញ្ញាចាស់។ ព្រះយេស៊ូវមានបន្ទូលសំដៅពីការលេចឡើងជាមនុស្សរបស់ព្រះចំពោះលោកអ័ប្រាហាំដែលនៅគ្រានោះទ្រង់គឺជាអង្គបុគ្គលដែលនិម្មិតឡើងដល់បុព្វបុរសរបស់គេ។ នេះទើបជាសេចក្តីដែលទ្រង់ចង់មានបន្ទូលនៅពេលព្រះអង្គមានបន្ទូលថា «លោកអ័ប្រាហាំ ជាឰយុកោអ្នករាល់គ្នា លោកបានត្រេកអរដោយឃើញគ្រាខ្ញុំ លោកក៏បានឃើញមែន ហើយមានសេចក្តីរីករាយ» (ខ៥៦)។ តើអ្នកអាចរាប់ចំនួននៃការលេចឡើងនៃព្រះជាម្ចាស់ដល់លោកអ័ប្រាហាំចាប់តាំងពីពេលត្រាស់ហៅរបស់គាត់ក្នុងក្រុងអ៊ើរនៃស្រុកខាល់ដេដល់ពេលការថ្វាយអ៊ីសាក់ជាដង្វាយយញ្ញបូជារបស់គាត់បានទេ?

ដោយការគ្មានចំណេះដឹងថាព្រះយេស៊ូវជាព្រះរាជបុត្រាតែ១របស់ព្រះវរបិតា «ជាព្រះដ៏ជាព្រះ» (គោលជំនឿណៃស៊ិន *«Nicene Creed»*) ឥឡូវនេះបានត្រឡប់ជាសាច់ឈាមតាមរយៈនាងក្រមុំព្រហ្មចារីម៉ារី ពួកគេបានសើចចំអកដាក់ទ្រង់ព្រោះតែទ្រង់មិនទាន់មានព្រះជន្ម៥០ឆ្នាំ។ មានអ្នកខ្លះគិតថាព្រះយេស៊ូវមើលទៅហាក់ដូចជាមានវ័យចាស់ជាងព្រះជន្មរបស់ទ្រង់ តែយើងគិតថាអាយុ៥០ឆ្នាំដែលបានលើកឡើងមកពីភាក្យាព្រោះវាជាឆ្នាំចូលនិវត្តន៍របស់ពួកលេវីវិញ (ជនគណនា ៨:២៥)។ នេះគឺចង់មានន័យថា នៅក្នុងក្រសែភ្នែករបស់ពួកគេ ព្រះយេស៊ូវគឺគ្រាន់តែមនុស្សទើបតែធំពេញវ័យម្នាក់ប៉ុណ្ណោះ។ ហើយទ្រង់បានអះអាងថាបានឃើញលោកអ័ប្រាហាំ ពិតជាចម្លែកពេកហើយ!

នៅពេលព្រះយេស៊ូវប្រកាសពីភាពអស់កល្បរបស់ទ្រង់ជាអង្គបុគ្គលគង់ជាមួយព្រះជាម្ចាស់ ដោយការប្រើពាក្យខ្ញុំជា (*I AM*) ផ្អែកលើបច្ចុប្បន្នកាលមិនបរិបូរនៃវេយ្យាករណ៍ភាសាហេព្រើរជាកាលគ្មានដែនកំណត់ ពួកសាសន៍យូដារឹតតែគិតថាវាជាការប្រមាថថែមទៀត។ ដូច្នោះហើយទើបពួកគេស្ទុះទៅចោលទ្រង់ ក៏ប៉ុន្តែព្រះគ្រីស្ទបានរំដោះអង្គទ្រង់ចេញដើម្បីបញ្ជាក់ដល់គេនូវសកម្មភាពនៃភាពជាព្រះរបស់ទ្រង់។

**ការពិចារណា៖** ព្រះយេស៊ូវជាព្រះ១០០%និងជាមនុស្ស១០០%។
**ការអធិស្ឋាន៖** យើងខ្ញុំជឿហើយថាព្រះយេស៊ូវគ្រីស្ទជាព្រះរាជបុត្រាតែ១ ជាព្រះតាំងពីអស់កល្បរៀងមក។

*«មិនមែនដោយព្រោះអ្នកនេះ ឬឪពុកម្ដាយគាត់បានធ្វើបាបទេ
គឺដើម្បីឲ្យការរបស់ព្រះបានសំដែងមក ក្នុងខ្លួនគាត់វិញ»។*

## ជំពូកទី ៩

### ចំពោះអ្នកខ្វាក់នៃផ្នែកអវៈយវៈនិងព្រលឹងវិញ្ញាណព្រះយេស៊ូវគ្រីស្ទគឺជាគំហើញនៃជីវិត

នៅពេលព្រះអម្ចាស់នៃយើងយាងមកក្រុងយេរូសាឡឹមនាអំឡុងពិធីបុណ្យបារាំ នៅវេលានោះគឺជិតដល់ថ្ងៃដាច់ខែកញ្ញា។ នៅក្នុងជំពូកនេះយើងឃើញថាព្រះអង្គកំពុងនៅទីក្រុងយេរូសាឡឹមនៅឡើយ តែពេលនេះជារដូវរងារនិងជាពិធីបុណ្យឆ្លងព្រះវិហារ ដែលត្រូវបានគេហៅថាបុណ្យនៃពន្លឺដែរនោះគឺកំពុងខិតជិតមកដល់ផងដែរ។ ពិធីបុណ្យនេះរំឭកពីការលាងសម្អាតនិងការឆ្លងព្រះវិហារផ្ដួចផ្ដើមឡើងដោយលោកយូដាស ម៉ាកាប៊ែរ (*Judas Maccabeus*) បន្ទាប់ព្រះវិហារត្រូវបានធ្វើឲ្យទៅជាមិនស្អាត ដោយស្នាដៃស្ដេចអាន់ធីយ៉ូកឹស អិហ្វីហ្វានីស (*Anitiochus Ephiphanes*) នាឆ្នាំ ១៦៥មុន គ.ស។ បច្ចុប្បន្នជនជាតិអ៊ីស្រាអែលរក្សាពិធីបុណ្យនេះជាបុណ្យហានូកា (*Hanukkah or Chanuka*)។

ស្ថិតនៅក្នុងឱកាសនេះ សាវ័កយ៉ូហានបានរៀបរាប់ប្រាប់យើងពីការប្រោសបុរសខ្វាក់ពីកំណើតម្នាក់នាថ្ងៃឈប់សម្រាក (ថ្ងៃសប្ប័ទ)។ ការប្រោសជំងឺនេះបង្កឲ្យមានជម្លោះដ៏ល្វីងជូរចត់មួយទៀតនឹងសាសន៍យូដា ជាជម្លោះដ៏ជូរចត់ហេតុបង្ខំឲ្យទ្រង់បង្ខំចិត្តចាកចេញពីក្រុង (យ៉ូហាន ១០:៣៩)។ តើយើងឃើញជម្លោះពាក្យសំដីបែបនេះនាបណ្ដាពួកជំនុំក្នុងពិភពលោកនាបច្ចុប្បន្នដែរទេ? តើវីរៈបុរស ក្លាហានដើម្បីសេចក្ដីពិតនៅឯណា?

ការប្រោសបុរសខ្វាក់ពីកំណើតទាក់ទិននឹងសំណួរបែបទេវសាស្រ្តដ៏ជ្រៅមួយ។ វាគឺគោលជំនឿសាសន៍យូដាទទួលយកជាយូរមកហើយដែលជឿថាសេចក្ដីវេទនាខាងផ្នែករូបកាយជាទូទៅគឺជាទណ្ឌកម្មមកពីបាបរបស់បុគ្គលម្នាក់បានប្រព្រឹត្ត (សូមអាន លូកា ១៣:១-៥)។ ចុះចំណែកអ្នកខ្វាក់ពីកំណើត? នេះក៏ចាត់ទុកជាទណ្ឌកម្មដែរ តែក្នុងករណីនេះអំពើបាបមានប្រភពជ្រាលជ្រៅជាង។ មានទ្រឹស្ដីពីរដែលបានសន្មត់ថា (១) សេចក្ដីវេទនាគឺការដំណរពូជ (សូមអាន និក្ខមនំ ២០:៥)។ (២) សេចក្ដីវេទនាបណ្ដាលមកពីអំពើបាបរបស់បុគ្គលផ្ទាល់ខ្លួន សូម្បីតែនៅក្នុងករណីទារកនៅក្នុងផ្ទៃម្ដាយផងដែរ។ ពួកសាសន៍យូដាចូលចិត្តយកលោកុប្បត្តិ ២៥:២២ ជាឧយោងដែលបានកត់ត្រាថា «ឯកូនក្នុងផ្ទៃនាងវាប្រធាក់គ្នា»។

លើសជាងនេះទៅទៀត មានជំនឿប៉ែកអាស៊ីខាងកើតដែលជឿលើការចាប់ជាតិ (ភាពរស់នៃវិញ្ញាណ) ដែលត្រូវបានធ្វើឲ្យមានប្រជាប្រិយភាពដោយសារលោកភីថាហ្គោរ៉ាស (៥៨២-៥០០ មុន គ.ស) និងផ្លាតូ (៤២៧-៣៤៧ មុន គ.ស)។ ជំនឿលើការចាប់ជាតិដូចនេះបានបញ្ជៀតចូលក្នុងគំនិតរបស់ពួកសាសន៍យូដា (ប្រាជ្ញាសាឡូម៉ូន ៨:១៩, ២០ ជាសៀវភៅអាប៉ូគ្រីហ្វា និងជាទស្សនៈវិជ្ជារបស់លោកហ្វីឡូ)។ បើតាមទ្រឹស្ដីនេះនៅក្នុងជាតិនិមួយៗដែលខ្លួនកើតមនុស្សនឹងច្រូតនូវសេចក្ដីដែលខ្លួនបានសាបព្រោះកាលពីជាតិមុន (ដារឹឌ ស្មឹត)។ ជាធម្មតាអ្នកកាន់ព្រះពុទ្ធសាសនាជឿថាបើអ្នកជាមនុស្សអាក្រក់នៅជាតិនេះ នោះអ្នកនឹងកើតជាសត្វជ្រូកនៅជាតិក្រោយ។

ដោយពួកសាវ័កមានផ្នត់គំនិតរបស់សាសន៍យូដានេះហើយទើបបានជាគេសួរព្រះយេស៊ូវថា៖ «លោកគ្រូ តើអ្នកណាបានធ្វើបាប មនុស្សនេះ ឬឪពុកម្ដាយរបស់គាត់ បានជាគាត់កើតមកខ្វាក់ដូច្នេះ?»។ ជាការបំភ្លឺដល់ការកត់សម្គាល់ដ៏ងងឹតងងល់របស់សាសន៍យូដា (ព្រះអង្គដ៏ជា) ពន្លឺនៃលោកីយ៍ផ្ដល់ចម្លើយដ៏ច្បាស់លាស់ដល់ពួកសិស្សទ្រង់ថា៖ «មិនមែនដោយព្រោះអ្នកនេះ ឬឪពុកម្ដាយគាត់បានធ្វើបាបទេ គឺដើម្បីឲ្យការរបស់ព្រះបានសំដែងមក ក្នុងខ្លួនគាត់វិញ» (៩:៣)។ ពិតជាការកំសាន្តចិត្តដល់យើងមែន ព្រោះថារាល់ជម្ងឺពាធាដែលយើងឆ្លងកាត់មិនមែនសុទ្ធតែមកពីអំពើបាបរបស់យើង ឬក៏មកពីឪពុកម្ដាយយើងឡើយ។ មានអត្រាករណីជម្ងឺខ្លះ គឺជាមកពីអង្គព្រះជាម្ចាស់! ព្រះទ្រង់

ប្រើប្រាស់ជម្ងឺពេលខ្លះដើម្បីសម្តែងឲ្យឃើញនូវអំណាចរបស់ទ្រង់ដើម្បីឲ្យអស់អ្នកដែលពិសោធនូវការប្រោសព្យាបាលរបស់ទ្រង់អាចធ្វើបន្ទាល់ពីសេចក្តីពិត គឺដើម្បីបញ្ចាំងពីពន្លឺដែលបានលេចមកក្នុងលោកីយប្រយោជន៍ឲ្យអ្នកខ្វាក់ខាងផ្នែកព្រលឹងវិញ្ញាណអាចទទួលនូវពន្លឺសម្រាប់ភ្នែកខាងក្នុងចិត្តគំនិតរបស់គេ។ ចូរយើងសិក្សាប្រសិនបើអ្នកដឹកនាំខ្វាក់ដឹកនាំមនុស្សខ្វាក់អាចចូលមកពន្លឺ?

**ពិចារណា៖** គោលជំនឿដ៏ចម្បងនៃគ្រីស្ទបរិស័ទគឺការជឿលើការរស់ពីស្លាប់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ។
**ការអធិស្ឋាន៖** ឱព្រះអម្ចាស់អើយ សូមកុំឲ្យខ្ញុំរង់ចាំរហូតដល់ទ្រង់ផ្ទាញ់ផ្ទាល់ទើបចុះចូលនឹងទ្រង់ឡើយ។

*«ចូរឲ្យអ្នកផ្សាយព្រះបន្ទូលចុះ ហើយទទូចដំរុញផង ទោះត្រូវពេល ឬខុសក្តី...» (២ ធីម៉ូថេ ៤:២)។*

## ពន្លឺនៃលោកីយតយុទ្ធនឹងសេចក្តីងងឹតខាងព្រលឹងវិញ្ញាណ

នេះគឺជាបុរសខ្វាក់ពីកំណើត។ ប៊ីហ្សប ចេ ស៊ី រ៉ែល (*Bishop J.C. Ryle*) បានអធិប្បាយថា៖ «រាល់បន្ទុកខាងផ្នែកសារពាង្គកាយទាំងអស់ដែលអាចដាក់លើមនុស្ស ក្រៅពីការដកហូតជីវិតចេញ ប្រហែលជាគ្មានបន្ទុកណាធ្ងន់ធ្ងរជាងការបាត់ បង់គំឃើញនោះឡើយ។ ការបាត់បង់គំហើញកាត់ផ្តាច់យើងចេញពីសេចក្តីរីករាយដ៏សំខាន់ៗទាំងឡាយនៅក្នុងជីវិត។ វាហ៊ុំបិទឲ្យនៅក្នុងរង្វង់នៃពិភពដ៏តូចចង្អៀតមួយរបស់យើង។ វាបណ្តាលឲ្យយើងគ្មានទីពឹងពំនាក់ដ៏សែនវេទនា ហើយឲ្យពឹងផ្អែកតែលើអ្នកដទៃ។ តាមពិត មានតែពេលមនុស្សម្នាក់បាត់បង់នូវគំហើញរបស់ខ្លួនទេ ទើបគាត់នឹងអាចដឹងពីគុណតម្លៃរបស់វា»។

ការពិការភ្នែកក៏ដូចជាជម្ងឺឯទៀតដែរគឺវាជាផលផ្លែនៃអំពើបាប។ បន្ទាប់ពីការធ្លាក់ចុះក្នុងអំពើបាបរបស់លោកអ័ដាម យើងមិនត្រឹមទទួលមរតកនិស្ស័យបាបរបស់គាត់ ដែលហៅថាជាប្រភពនៃអំពើបាបប៉ុណ្ណោះទេ តែយើងក៏ទទួលរងនូវគុណវិបត្តិដ៏វេទនានៃការធ្លាក់ចុះនោះនោះផងដែរ។ បណ្តាសារនៃជម្ងឺពិការភ្នែកគឺជាសេចក្តីងងឹតគ្របបាំងជីវិតខាងផ្នែករូបកាយនៃបុគ្គលម្នាក់រហូតដល់ស្លាប់។ ប៉ុន្តែសេចក្តីដ៏ងងឹតបំផុតដែលកើតឡើងក្នុងព្រលឹងវិញ្ញាណរបស់យើង គឺជាសេចក្តីងងឹតដែលបិទបាំងយើងចេញពីផ្លូវនាំឆ្ពោះទៅឯនគរស្ថានសួគ៌ ទើបជាសេចក្តីបង្កើននូវការភ័យខ្លាចធ្លាក់ទៅស្ថាននរករបស់យើង។

ព្រះយេស៊ូវគ្រីស្ទជាពន្លឺនៃលោកីយដែលអាចបណ្តេញចេញនូវសេចក្តីងងឹតផ្នែកព្រលឹងវិញ្ញាណនេះ។ ការផ្តល់នូវគំហើញខាងផ្នែកវិញ្ញាណដល់មនុស្សជាតិជាមនុស្សអ្នកបាត់បង់ក្នុងបាបគឺជាបេសកកម្មរបស់ព្រះអម្ចាស់នៃយើង ទោះបីជាទ្រង់ប្រោសភ្នែកខាងសារពាង្គកាយរបស់មនុស្សខ្វាក់នៅពេលណាទ្រង់នឹងសព្វព្រះហឫទ័យក៏ដោយ។ ដើម្បីសម្រេចនូវបេសកកម្មនេះទ្រង់ត្រូវតែចំណាយពេលវេលាឲ្យមានក្តីទំនុកចិត្ត។ ព្រះអង្គមិនអាចខ្ជះខ្ជាយមួយនាទីណាទេ គឺដូចជាអ្នកដំណើរខំរួតរះមុនព្រះអាទិត្យលិចដូច្នោះដែរ «កំពុងដែលថ្ងៃនៅភ្លឺនៅឡើយ នោះត្រូវតែខ្ញុំធ្វើការរបស់ព្រះ ដែលចាត់ឲ្យខ្ញុំមក ដ្បិតយប់ដល់មក នោះគ្មានអ្នកណាអាចនឹងធ្វើការបានទេ» (យ៉ូហាន ៩:៤)។ ព្រះយេស៊ូវមានពេលដ៏ខ្លីត្រឹមតែបីឆ្នាំសម្រាប់បំពេញបេសកកម្មប៉ុណ្ណោះ។ ដូចនេះទើបយើងឃើញថាទ្រង់តែងតែមានភាពមមាញឹកជានិច្ច។

បណ្ឌិត ចន ស៊ុង អាចសម្រាចពន្ធ័កិច្ចក្នុងរយៈពេល១៥ឆ្នាំដែលអ្នកដទៃអាចនឹងចំណាយពេល៥០ឆ្នាំ។ គាត់ជ្រាបដឹងពីព្រះអម្ចាស់ថាអាយុរបស់គាត់មានដែនកំណត់ ប្រហែលជាតាមរយៈការសិក្សាពីជីវិតរបស់ស្តេចហេសេគា។ ហេតុនេះទើបគាត់ប្រញាប់ប្រញាល់។ ជារៀងរាល់ពេលនៃយុទ្ធនាការប្រកាសដំណឹងល្អគាត់នឹងអធិប្បាយពាក្យបន្ទូលចំនួនបីដងក្នុងមួយថ្ងៃ ដែលការអធិប្បាយនិមួយៗមានរយៈពេលពីរម៉ោង។

លោក វីលាម ប៊ឺនស៍ (*William Burns*) ជាបេសកកជនត្រួសត្រាយរបស់បេសកកម្មដំណឹងល្អនៃនិកាយប្រ៊េសប៊ីធើរានអង់គ្លេសទៅប្រទេសចិនអាចអធិប្បាយដំណឹងល្អពីទីក្រុងហុងកុងក្នុងភាគខាងត្បូងទៅញូវឆុង (*Newchuang*) នៅក្នុងភាគខាងជើងតំបន់ម៉ានជូរានៃឧបទ្វីបប្រទេសចិនព្រោះតែគាត់ប្រញាប់។ ចរិកលក្ខណៈមួយអំពីជីវិតរបស់គាត់គឺនៅពេលណាគាត់មានអារម្មណ៍រំខានដោយសារកិច្ចការមិនសំខាន់គឺគាត់នឹងដកខ្លួនចេញពីមិត្តភក្តិរបស់គាត់៖ «ខ្ញុំត្រូវតែរត់»។

**ពន្លឺ**នៃលោកីយបានយាងមកជនជាតិយូដានិងបានរះបំភ្លឺយ៉ាងចែងចាំងនាពេលដ៏ខ្លីប៉ុណ្ណោះ ហើយក៏យាងចេញពីគំហើញរបស់គេទៅ។ ចំពោះអ្នកបដិសេធពន្លឺនោះគឺជាប់មានទោសនឹងសេចក្តីងងឹតខាងផ្នែកព្រលឹងវិញ្ញាណជារៀងរហូត។

**ការពិចារណា៖** ចូរយើងធ្វើជាបេសកជននៅគ្រួសារនិងទីក្រុងរបស់យើង។

**ការអធិស្ឋាន៖** ព្រះវរបិតាអើយ សូមប្រទានប្រាជ្ញាឲ្យយើងខ្ញុំប្រើប្រាស់ពេលវេលាដោយឆ្លាតវៃថ្វាយដល់ទ្រង់។

ថ្ងៃទី ២៨ សីហា
យ៉ូហាន ៩:៦

*«...ពីព្រោះទ្រង់បានលាក់សេចក្ដីទាំងនេះនឹងពួកអ្នកប្រាជ្ញ ហើយនិងពួកឈ្លាសវៃ តែបានសំដែងឲ្យពួកកូនក្មេងយល់វិញ...» (លូកា ១០:២១)។*

## «តើនេះស្របនឹងស្តង់ដារអនាម័យសម័យទំនើប?»

សាស្ត្រាចារ្យផ្នែកទេវសាស្ត្រសម័យទំនើបបានសួរសិស្សរបស់គាត់សំណួរបែប «អ្នកគាំទ្រគំនិតសម័យនិយម» ទាក់ទិននឹងការព្យាបាលដែលព្រះយេស៊ូវបានធ្វើយកដីឥដ្ឋលាយជាមួយទឹកមាត់ទៅបិទភ្នែកបុរសពិការភ្នែកថា៖ «តើនេះស្របនឹងស្តង់ដារអនាម័យសម័យទំនើបដែរទេ?» សំណួរហាក់ដូចជា «អ្នកគាំទ្រគំនិតសម័យនិយម» គឺមិនដូចជាបង្កនូវគ្រោះថ្នាក់ណាស់ណាឡើយ។

ការនិយាយបែបបន្ទះបង្អាប់ពីកិច្ចការរបស់ព្រះអម្ចាស់គឺពិសពុលដូចជាពស់ចាស់ចិកដែរ។ នៅពេលថ្នាក់រៀននេះវាយប្រហារចំពោះព្រះអម្ចាស់នៃយើងគឺទាក់ទិនទៅនឹងវេជ្ជបណ្ឌិតគ្រីស្ទបរិស័ទម្នាក់ ដែលបានឆ្លើយតបវិញដោយញាក់ភ្នែករបស់គាត់ថា៖ «បើពិនិត្យមើលពីផ្នែកវេជ្ជសាស្ត្រ ទឹកមាត់របស់យើងផ្ទុកនូវអង់ស៊ីម (វិភេទនរស) ដែលជាសារជាតិសម្លាប់ពពួកមេរោគ»។ ដូច្នេះបណ្ឌិតផ្នែកទេវសាស្ត្រគួរតែបានសិក្សាបន្តិចបន្តួចពីឱសថសាស្ត្រមុនពេលពិភាក្សាអំពីប្រធានបទខាងក្រៅពីចំណេះដឹងជំនាញរបស់ខ្លួន។ វេជ្ជបណ្ឌិត ដេវីឌ ស្មីត មានប្រសាសន៍ថា៖ «ទឹកមាត់ត្រូវបានគ្រូពេទ្យបុរាណទទួលស្គាល់ គឺទាំងជនជាតិយូដានិងជនជាតិដទៃផងដែរ ថាវាផ្តល់សារប្រយោជន៍ដល់ផ្នែកឱសថសាស្ត្រជាពិសេសក្នុងករណីចក្ខុរោគ (ជម្ងឺភ្នែក)»។

តើអ្នកដឹងពីឱកាសនៃការព្យាបាលជំងឺពីរករណីដទៃទៀតដែលព្រះយេស៊ូវប្រើ «វេជ្ជបញ្ជារ» ដដែលដូចគ្នានេះដែរឬទេ? ករណីទីមួយមានមួយនៅក្នុងកំណត់ត្រានៃដំណឹងល្អ ម៉ាកុស ៧:៣៣-៣៥ ជាការប្រោសជម្ងឺដែលព្រះយេស៊ូវស្តោះទឹកមាត់ហើយប៉ះអណ្តាតរបស់បុរសថ្លង់ហើយគ។ ករណីមួយទៀត គឺក៏នៅក្នុងម៉ាកុស ៨:២៣-២៥ ជាករណីទ្រង់បានស្តោះទឹកមាត់ដាក់ភ្នែករបស់បុរសពិការភ្នែក។ បើទឹកមាត់គឺមិនត្រឹមត្រូវតាមបែបអនាម័យ ទាំងបុរាណឬសម័យទំនើប តើហេតុអ្វីបានជាព្រះអម្ចាស់នៃយើងប្រើវាម្តងហើយម្តងទៀត? យើងមិនអាចសួរព្រះអម្ចាស់នៃយើងថាការប្រើទឹកមាត់ត្រឹមត្រូវស្របនឹងស្តង់ដារអនាម័យសម័យទំនើបឡើយ។ យើងគ្រាន់តែអាចយល់ស្របតាម «វេជ្ជសាស្ត្រ» ដែលទ្រង់ប្រើប៉ុណ្ណោះ គឺដូចជាមនុស្សជិតស្លាប់ត្រូវការការវះកាត់ដែលប្រគល់ខ្លួនគាត់ទៅក្នុងដៃគ្រូពេទ្យវះកាត់ដូច្នោះដែរ។

តើហេតុអ្វីបានជាព្រះយេស៊ូវប្រើទឹកមាត់និងដីឥដ្ឋ ហើយហេតុអ្វីបានទ្រង់បញ្ជូនបុរសពិការភ្នែកទៅលាងសម្អាតនៅក្នុងស្រះស៊ីឡោម? ចូរយើងអនុញ្ញាតឲ្យប៊ីហ្សប រ៉ៃល៍ (*Bishop Ryle*) ឆ្លើយសំណួរជំនួសយើងវិញ៖ «ការផ្តល់នូវការណែនាំត្រង់ចំណុចនេះដល់បុរសពិការភ្នែកនឹងរំឭកដល់សាសន៍យូដាអំពីការណែនាំរបស់ហោរាអេលីសេចំពោះមេទ័ពណាម៉ាន «សូមឲ្យលោកទៅមុជទឹកក្នុងទន្លេយ័រដាន់...» (២ ពង្សាវតារក្សត្រ ៥:១០)។ ... ការដាក់បង្គាប់គឺជាការសាកល្បងអំពីសេចក្តីជំនឿ ហើយព្រោះតែស្តាប់បង្គាប់បុរសពិការភ្នែកបានរកឃើញនូវអ្វីដែលគាត់ទន្ទឹងចង់បាន។ វាគឺជាគោលការណ៍ដ៏អស្ចារ្យមួយដែលមានទូទាំងព្រះគម្ពីរ «ចូរជឿហើយធ្វើតាមនោះនឹងបានល្អប្រសើរជាមិនខាន»។

យើងអាចនិយាយសង្កត់បន្ថែមទៀតថាការស្តាប់បង្គាប់ត្រូវតែផុសចេញមកពីការចុះចូលនឹងព្រះអម្ចាស់ដ៏លើអស់ទាំងព្រះអម្ចាស់ ទោះបីជាទឹកមាត់របស់ទ្រង់លាយនឹងដីឥដ្ឋធ្វើឲ្យអ្នកទទួលអាម៉ាសក៏ដោយ។ មានពាក្យនិយាយថាអ្នកគោរពព្រហ្មញ្ញសាសនាដែលថ្វាយបង្គំសត្វគោគឺ (ជឿជាក់) លើទេវធីតា ជាសត្វជើង បួនរបស់គេយ៉ាងខ្លាំងរហូតដល់មានអ្នកខ្លះផឹកទឹកដោះគោលាយជាមួយនឹងលាមករបស់សត្វគោ មួយស្លាបព្រាបដើម្បីបង្ហាញនូវភក្តីភាពរបស់ពួកគេទៀតផង។ ចុះចំណែកយើងនឹងព្រះអម្ចាស់របស់យើងវិញ?

**ការពិចារណា៖** «ចូរជឿហើយធ្វើតាមនោះនឹងបានល្អប្រសើរជាមិនខាន»។

**ការអធិស្ឋាន៖** ព្រះជាម្ចាស់អើយ សូមឲ្យខ្ញុំគ្រាន់តែជឿតាម គ្រាន់តែជឿតាម គឺជឿតាមព្រះយេស៊ូវ!

ថ្ងៃទី ២៩ សីហា
យ៉ូហាន ៩:៧

*«...ដ្បិតអ្នកណាដែលចូលទៅឯព្រះ នោះត្រូវតែជឿថាមានព្រះមែន ហើយថា ទ្រង់ប្រទានរង្វាន់ដល់អស់អ្នកដែលស្វែងរកទ្រង់» (ហេព្រើរ ១១:៦)។*

## ស្រះទឹកស៊ីឡោម

ស្រះស៊ីឡោមត្រូវបានគេស្គាល់ថាបច្ចុប្បន្នជាស្រះដែលមានទីតាំងនៅភាគខាងត្បូងនៃក្រុងយេរូសាឡឹម។ ទឹកស្រះនេះហូរមកពីអូរហ្គីហូន (*Spring of Gihon*) តាមផ្លូវទឹកក្រោមដីស្ថាបនាដោយស្តេចហេសេគា (២ ពង្សាវតារក្សត្រ ២០:២០ របាក្សត្រ ៣២:៣០)។ មានមតិមួយយល់ថានៅពេលព្រះយេស៊ូវប្រកាសពីអង្គទ្រង់ថាជាទឹកដ៏រស់នាឱកាសបញ្ចប់ពិធីបុណ្យបារាំ (៧:៣៧,៣៨) ទ្រង់ បានប្រើរូបពន្យល់ពីទឹកស្រះស៊ីឡោម ដែលត្រូវបានគេប្រើប្រាស់នាពិធីបុណ្យនេះជានិម្មិតរូបឲ្យព្រះពរទាំងឡាយរបស់ព្រះជាម្ចាស់។

សារៈសំខាន់អំពីការលាងសម្អាតនាស្រះទឹកស៊ីឡោមអាចឃើញនូវបំណកស្រាយប្រកបដោយពិស្តារក្នុងកម្រងអត្ថាធិប្បាយរបស់លោក ម៉ាធជូ ហិនរី។ លោកហិនរីបានអត្ថាធិប្បាយថា «ទឹកស្រះស៊ីឡោមមានទីសម្គាល់ពីបុរាណបញ្ជាក់ពីរាជបល្ល័ង្កនិងរាជវាំងនៃនគររបស់ស្តេចដាវីឌ ដែលជាការចង្អុលប្រាប់ពីព្រះមែស៊ី (អេសាយ ៨:៦) ហើយចំណែកឯសាសន៍យូដាដែលបដិសេធទឹកស្រះស៊ីឡោម ជាគោលលទ្ធិនិងក្រិត្យវិន័យរបស់ព្រះគ្រីស្ទ ពួកគេរីករាយក្នុងទំនៀមទម្លាប់របស់ពួកចាស់ទុំ។ គ្រូផ្សាយដំណឹងល្អបានសម្គាល់អំពីសារៈសំខាន់នៃឈ្មោះទឹកន្លែង។ ព្រះគ្រីស្ទគឺជារឿយៗត្រូវបានគេស្គាល់ថាជាអ្នកដែលព្រះចាត់ឲ្យមក ជាអ្នកនាំសារនៃសេចក្តីតាំងសញ្ញា (ម៉ាឡាគី ៣:១) ដូច្នេះនៅពេលព្រះគ្រីស្ទបង្គាប់ឲ្យគាត់ទៅស្រះស៊ីឡោម ទ្រង់បង្គាប់ឲ្យបុរសនោះទៅរកអង្គទ្រង់ផ្ទាល់ ដោយសារតែព្រះគ្រីស្ទគឺសព្វគ្រប់ទាំងអស់ដល់ការប្រោសព្រលឹង។ ព្រះគ្រីស្ទ ក្នុងនាមជាព្យាការីនិងជាសម្តេចសង្ឃ ទ្រង់នាំយើងទៅកាន់អង្គទ្រង់ផ្ទាល់។ ចូរទៅលាងសម្អាតនៅក្នុងកន្លែងទឹកផុស ជាកន្លែងទឹកផុសនៃជីវិត មិនមែនជាស្រះឡើយ។

ការប្រោសជម្ងឺត្រូវបានជោគជ័យ ដោយបុរសពិការភ្នែករូបនេះអាចមើលឃើញ។ ត្រង់នេះគឺជា (១) ព្រះចេស្តានៃព្រះគ្រីស្ទ។ តើកិច្ចការអ្វីដែលទ្រង់មិនអាចធ្វើបាន ទ្រង់មិនត្រឹមតែអាចធ្វើការនេះបានទេ តែធ្វើបានទាន់ហេតុការណ៍ទៀតផង? ប្រាកដណាស់ នេះគឺជាព្រះអង្គដែលត្រូវយាងមក។ (២) វាគឺជាសគុណនៃសេចក្តីជំនឿនិងការស្តាប់បង្គាប់ភ្លាមៗ។ បុរសនេះអនុញ្ញាតឲ្យព្រះគ្រីស្ទធ្វើការដែលទ្រង់សព្វព្រះហឫទ័យ និងអ្វីដែលទ្រង់បង្គាប់ឲ្យគាត់ធ្វើ ហើយគាត់ក៏បានជាសះស្បើយ។ ពួកអ្នកដែលនឹងទទួលនូវការប្រោសពីព្រះគ្រីស្ទត្រូវតែគ្រប់គ្រងដោយព្រះអង្គ។ បុរសនោះបានត្រឡប់មកពីស្រះស៊ីឡោមវិញឆ្ងល់ហើយឆ្ងល់ទៀត។ គាត់មើលឃើញ។ នេះតំណាងឲ្យប្រយោជន៍នៃព្រលឹងដ៏សេចក្តីសប្បុរសមានបទពិសោធន៍ក្នុងការចូលរួមបណ្តាពិធីដែលតែងតាំងស្របទៅតាមការកំណត់របស់ព្រះគ្រីស្ទដូច្នោះដែរ។ ពួកគេបានទៅឯស្រះស៊ីឡោមដោយទន់ខ្សោយ ហើយត្រឡប់មកវិញដោយកំឡាំងខ្លាំងក្លា ចេញទៅទាំងសង្ស័យត្រឡប់មកវិញដោយពេញចិត្ត ចេញទៅទាំងទុក្ខព្រួយ ត្រឡប់មកវិញដោយអំណរ ចេញទៅទាំងភិតភ័យ ត្រឡប់មកវិញដោយជ័យជំនះ ចេញទៅទាំងងងឹតងងល់ត្រឡប់មកវិញដោយភ្នែកភ្លឺ គឺមកទាំងច្រៀងទៀតផង (អេសាយ ៥២:៨)»។

ស្រះទឹកស៊ីឡោមគឺជាស្រះ ពិតមែនហើយជាកន្លែងទឹកផុសជាអង្គដែលព្រះជាម្ចាស់បញ្ជូនមក។ តើអ្នកបានលាងនៅក្នុងស្រះនេះប្រយោជន៍កុំឲ្យអ្នកសម្លឹងមើលតែសម្ភារៈបណ្តោះអាសន្ននាលោកីយនេះ តែសម្លឹងមើលសេចក្តីដ៏ស្ថិតស្ថេរនានគរស្ថានសួគ៌ហើយឬនៅ?

**ការពិចារណា៖** ព្រះយេស៊ូវជាទឹកដ៏រស់។

**ការអធិស្ឋាន៖** *ឱ អរព្រះគុណ ព្រះអម្ចាស់អើយ ខ្ញុំបានស្អាតហើយ អើ បានស្អាតបាត*។

*«ដ្បិតយើងខ្ញុំពុំអាចនឹងធ្វើអ្វីទាស់ នឹងសេចក្តីពិតបានទេ ធ្វើបានតែអ្វីដែលសំរាប់សេចក្តីពិតវិញ»*

## ជំនឿក្រោមការសួរចម្លើយរបស់ប៉ូលីសសម្ងាត់នៃព្រះវិហារ

បើយើងអានចំពាក់កណ្តាលនៃដំណើររឿង យើងអាចបណ្តុំនូវព្រឹត្តិការណ៍ដែលបានកើតឡើងនា ពេលបុរសពិការភ្នែកទទួលរងនូវកំដៅព្រះអាទិត្យ ដើរឆ្ពោះទៅរកស្រះទឹកជាមិនខាន។ ហ្វូងមនុស្សដើរតាមដើម្បីពិនិត្យមើលប្រសិនបើភ្នែករបស់គាត់ពិតជានឹងបើកមើលឃើញប្រាកដមែន។ នៅពេលគាត់លាងជំរះ ហើយជំរះទៀត រំពេចភ្លាមនោះ ស្រាប់តែគាត់ស្រែកឡើងថា៖ «ហ្អេ! ខ្ញុំអាចមើលឃើញហើយ! ខ្ញុំអាចមើលឃើញហើយ!»។ មនុស្សមួយហ្វូងធំបានចោមរោមគាត់នាពេលគាត់ប្រញាប់រួសរាន់ទៅផ្ទះដើម្បីប្រាប់ញាតិសន្តានរបស់គាត់។

ព្រះយេស៊ូវជាអ្នកដែលធ្លាប់មានទំនាស់ច្រើនដងជាមួយនឹងគណៈផារីស៊ីជាតំណាងអង្គាធរព្រះវិហារជនជាតិយូដា ពេលនេះទ្រង់គឺកំពុងស្ថិតក្រោម «ការហាមឃាត់»។ នេះបណ្តាលឲ្យមានការភ័យខ្លាចមិនត្រឹមតែចំពោះអ្នកមានចិត្តអាណិតមេត្តាប៉ុណ្ណោះទេ តែចំពោះឪពុកម្តាយរបស់បុរសពិការភ្នែកនោះដែរ។ ហេតុនេះទើបពួកគេមិនហ៊ានអរសប្បាយក្នុងការប្រោសជម្ងឺកូនប្រុសរបស់គេ។ នៅពេលគណៈផារីស៊ីកោះហៅមកសួរ ពួកគេរុញរាឆ្លើយដោយកំសាកថា៖ «...យើងខ្ញុំ មិនដឹងទេ ក៏មិនដឹងជាអ្នកណាបានធ្វើឲ្យវាភ្លឺផងដែរ វាពេញអាយុហើយ សូមសួរវាចុះ វានឹងជំរាបពីដំណើរខ្លួនវា» (ខ ២១)។ អ្នកដទៃទៀតក៏អញ្ចឹង ស្ថិតក្រោមការសួរចម្លើយរបស់ប៉ូលីសសម្ងាត់នៃព្រះវិហារ ខណៈពេលពួកគេសម្តែងនូវការសង្ស័យផ្ទាល់ខ្លួនគេ (ខ ៨, ៩)។ ពួកអ្នកមានការទទួលខុសត្រូវចំពោះជនជាតិយូដាថែមទាំងបាននាំគាត់ទៅឲ្យគណៈផារីស៊ី សួរចម្លើយទៀតផង (ខ ១៣)។ ពិតជាការស្រងាកចិត្តដ៏អាក្រក់មែន! ត្រង់ចំណុចនេះ បណ្ឌិតដេវីឌ ស្មីត មានប្រសាសន៍ថា៖ «ជំនួសដោយការអរសប្បាយនឹងភព្វសំណាងរបស់អ្នកជិតខាងរបស់ខ្លួន ពួកអ្នកទាំងនោះ ដើម្បីកុំឲ្យខ្លួនគេជាប់មានការសង្ស័យ គេបានអូសគាត់ (បុរសពិការភ្នែក) ទៅឯពួកគណៈផារីស៊ីជាអ្នកដឹកនាំសាលាប្រជុំដែលបានប្រកាសបម្រាប។ ជាការពិតវាគឺជាករណីធ្ងន់ធ្ងរមួយ ព្រោះវាគឺជាថ្ងៃឈប់សម្រាក ហើយការអស្ចារ្យបានរំលងច្បាប់នៃថ្ងៃឈប់សម្រាកគ្រូបង្រៀនសាសនាយូដា ហើយក៏បានប៉ះពាល់ដល់អ្នកមានយសស័ក្តិខ្ពង់ខ្ពស់។ ពីព្រោះមានអ្នកខ្លះ ឃើញត្រឹមតែការអស្ចារ្យមិនស្របច្បាប់ ឯអ្នកដទៃទៀតមានអារម្មណ៍អស្ចារ្យអំពីការប្រោសជម្ងឺនោះនិងទទួលស្គាល់វាថាជាភស្តុតាងពីបេសកកម្មរបស់ព្រះនៃព្រះអម្ចាស់របស់យើង ហើយដោយមានសេចក្តីសង្ឃឹមថានឹងទទួលបាននូវព័ត៌មានឲ្យកាន់តែច្បាស់អំពីករណី (នេះ) ពួកគេក៏សាកសួរបុរសវ័យក្មេងដ៏ឈ្លាសវៃនិងប្រកបដោយបញ្ញាប៉ិនប្រសប់ ខុសពីបុរសខ្វិនវ័យចំណាស់មកពីស្រុកបេតសៃដារូបនោះ ហើយដោយការគាំទ្រចំពោះឧបការី របស់គាត់យ៉ាងអស់ពីចិត្ត គាត់បានឆ្លើយថា «លោកជាហោរា» (ខ ១៧)»។

«សេចក្តីពិត» បើតាមលោកហ្សូរូបាបេល «ស្ថិតស្ថេរ និងជានិច្ចកាលខ្លាំងក្លា វាមានជីវិតហើយជោគជ័យនិរន្តរ៍» (១ អែស្ត្រាស (*I Esd.*) ៤:៣៨)។ អ្នកបរិសុទ្ធ ប៉ុល មានប្រសាសន៍ថា «ដ្បិតយើងខ្ញុំពុំអាចនឹងធ្វើអ្វីទាស់ នឹងសេចក្តីពិតបានទេ ធ្វើបានតែអ្វីដែលសំរាប់សេចក្តីពិតវិញ» (២ កូរិនថូស ១៣:៨)។

**ការពិចារណា៖** ខ្ញុំមិនខ្មាស់ក្នុងការធ្វើទីបន្ទាល់ពីដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទឡើយ (រ៉ូម ១:១៦)។
**ការអធិស្ឋាន៖** ព្រះអម្ចាស់សូមប្រទានសេចក្តីក្លាហានដូចជាហោរាដានីយ៉ែលដល់ខ្ញុំផង។

*«បើលោកជាមនុស្សមានបាប នោះខ្ញុំមិនដឹងទេ ខ្ញុំដឹងតែប៉ុណ្ណោះថា ពីដើមខ្វាក់ តែឥឡូវនេះខ្ញុំមើលឃើញ»។*

## ជំនឿក្រោមការវិនិច្ឆ័យ

សូមអនុញ្ញាតឲ្យបណ្ឌិត ដេវីឌ ស្មីត ផ្តល់ពាក្យអត្ថាធិប្បាយដ៏ក្បោះក្បាយពីដំណើររឿងទាំងមូលៈ «គ្មានបញ្ហាអ្វីចំពោះករណីប្រោសជម្ងឺនេះទេ តែវាគ្រាន់ជាការលើកយកមកពិនិត្យវិនិច្ឆ័យប៉ុណ្ណោះ...។

ជាដំបូងមានសំណួរសួរនាំប្រសិនការប្រោសជម្ងឺនោះគឺជាករណីពិតប្រាកដនិងមិនមែនជាការក្លែងបន្លំ ហើយដើម្បីបញ្ជាក់ពីការនេះពួកគេបានកោះហៅឪពុកម្តាយរបស់បុរសពិការភ្នែកមកសួរ ដោយការនាំគាត់ចេញទៅខាងក្រៅសាលជំនុំជំរះរួចហើយសួរឪពុកម្តាយគាត់ចំនួនបីសំណួរៈ (១) តើបុរសពិការភ្នែកពិតជាកូនរបស់ពួកគេ? (២) តើគាត់ពិតជាខ្វាក់ពីកំណើត ហើយបើគាត់ខ្វាក់ពីកំណើតមែន (៣) តើពេលនេះគាត់អាចមើលឃើញដោយវិធីណា? ពីរសំណួរដំបូងពួកគេបានឆ្លើយជាវិជ្ជមានដោយឥតស្ទាក់ស្ទើរ ក៏ប៉ុន្តែសំណួរទីបីគឺគ្រោះថ្នាក់ផ្អែកលើការគម្រាមកំហែងនៃការបណ្តេញចេញពីសាលាប្រជុំ ហេតុនេះទើបពួកដោះខ្លួនមិនព្រមឆ្លើយ។ «សូមសួរវាចុះ» ពួកគេបានឆ្លើយ (ស្របនឹងស្ថានភាពជាក់ស្តែង) «វាពេញអាយុហើយ» ក្នុងន័យត្រង់ «វាគ្រប់អាយុ» មានន័យថាគាត់ពេញវ័យគ្រប់គ្រាន់ អាចនិយាយដោយខ្លួនគាត់បាន មិនមែនដូចជាឃ្លាដែលផ្តល់មតិដល់យើងថា គាត់មានអាយុម្ភៃមួយឆ្នាំទេ តែអាស្រ័យទៅតាមការប្រើប្រាស់ពាក្យពេចន៍របស់ជនជាតិយូដាវិញ (សូមមើល លូកា ២:៤២) គឺគាត់មានអាយុច្រើនជាងដប់ពីរឆ្នាំ។ ដោយសារភាពរួញរានេះ ទើបពួកដឹកនាំសាសន៍យូដាកោះហៅយុវជននោះមកម្តងទៀត ហើយដាក់អន្ទាក់ចាំចាប់កំហុសគាត់។ ពួកគេបាននិយាយថា «ចូរសរសើរដំកើងដល់ព្រះវិញ» ពុំមែនមានន័យដូចជាបានផ្តល់មតិ «ចូរផ្តល់សរសើរដំកើងពីការអស្ចារ្យថ្វាយដល់ព្រះ» តែ «ផ្តល់សិរីរុងរឿងដល់ព្រះតាមរយៈការនិយាយសេចក្តីពិតវិញ» (មើល យ៉ូស្វេ ៧:១៩)៖ កូនអើយ ចូរសរសើរដល់ព្រះយេហូវ៉ា ទោះបីជាសំដែងឲ្យឃើញពីក្តីអាម៉ាស់របស់ឯងក៏ដោយ...ជាថ្មីម្តងទៀតអញបង្គាប់ឯងឲ្យពិនិត្យមើលពីសុវត្ថិភាពព្រលឹងរបស់ឯងដោយការផ្តល់សិរីរុងរឿងដល់ព្រះហើយនិយាយការពិតវិញ»។

ភាពពុតត្បុតរបស់គេគឺដោយគេបានប្រមូលផ្តុំព័ត៌មានពិតពីឪពុកម្តាយរបស់យុវជនម្នាក់នោះ ប្រយោជន៍ដើម្បីកុំឲ្យគាត់បន្តធ្វើជាអ្នកការក្លែងបន្លំតទៅទៀត «ចូរសរសើរដំកើងដល់ព្រះវិញ ឯមនុស្សនោះ យើងដឹងថាជាអ្នកមានបាបទេ»។ «បើលោកជាមនុស្សមានបាប» គាត់បានឆ្លើយយ៉ាងម៉ឺងម៉ាត់ «នោះខ្ញុំមិនដឹងទេ ខ្ញុំដឹងតែប៉ុណ្ណោះថា ពីដើមខ្វាក់ តែឥឡូវនេះខ្ញុំមើលឃើញ»។ គាត់ក៏ឈ្នះគេដាច់ ដូចនេះទើបពួកគេបានត្រឡប់មកសំណួរដើមរបស់គេវិញពីដំណើរការប្រោសជម្ងឺប្រព្រឹត្តយ៉ាងណា សង្ឃឹមថាគាត់នឹងក្បត់ពាក្យដើមឆ្លើយចម្លើយមិនស្របគ្នា។ ប៉ុន្តែគាត់ឆ្លើយប្រាប់គេដោយពាក្យបញ្ឈឺចិត្តវិញ។ «ខ្ញុំបានជំរាបហើយ តែលោកមិនស្តាប់ ហេតុអ្វីបានជាចង់ស្តាប់ម្តងទៀត តើលោកចង់ធ្វើជាសិស្សរបស់លោកនោះដែរឬអី?»។

ពួកគេបានប្រព្រឹត្តកំហុសដ៏អកុសលនៃការផ្ទុះជាកំហឹងឡើង។ «គឺឯងជាសិស្សអ្នកនោះហើយ» គេជេរៀលត្មះគាត់ «ឯយើង ជាសិស្សរបស់លោកម៉ូសេវិញ... តែអ្នកនោះ យើងមិនដឹងជាមកពីណាទេ»។ យុវជនរូបនោះមានអំណោយទានខាងកំប្លុកកំប្លែង និងអាចរក្សាកំហឹងបាន ដោយការផ្អែកតាមគោលជំនឿរបស់អ្នកដឹកនាំសាសាយូដាគាត់ក៏បង្រៀនគេវិញប្រកបពាក្យសំដីព្រហើនថា៖ «នេះចំឡែកណាស់មែន ចាប់តាំងពីអស់កល្បរៀងមក មិនដែលឮនិយាយពីអ្នកណាដែលធ្វើឲ្យភ្នែកមនុស្សខ្វាក់ពីកំណើតបានភ្លឺទេ បើលោកនោះមិនមែនមកពីព្រះទេ នោះលោកពុំអាចនឹងធ្វើអ្វីបានឡើយ តែលោករាល់គ្នា ជាគ្រូបង្រៀនសាសន៍អ៊ីស្រាអែលបែរជា «មិនដឹងថាលោកនោះមកពីណា!» ពាក្យនេះបានបញ្ចប់សេចក្តី។

«ឯងបង្រៀនយើងឬ?» ពួកគេស្រែកតបទៅគាត់វិញ រួច «គេបណ្តេញគាត់ទៅ» គឺមិនមែនគ្រាន់ឲ្យចេញក្រៅមាត់ទ្វារទេ តែចេញពីការប្រកបគ្នារបស់ពួកគេ គឺជាការបណ្តេញចេញពីសាលាប្រជុំសាសនាយូដ)។

ហេតុការណ៍បែបនោះនឹងកើតមានឡើង ជាពេលពួកអ្នកធ្វើបន្ទាល់សម្រាប់ព្រះគ្រីស្ទនឹងត្រូវសាកល្បងជំនឿប្រហាក់ប្រហែលគ្នានឹងករណីនេះដែរ។ តើយើងអាចនឹងទ្រាំទ្រនឹងការសាកល្បងដែរឬទេ?

**ការពិចារណា៖** ចូរប្រយ័ត្ននឹងបាបទាស់នឹងព្រះវិញ្ញាណបរិសុទ្ធ។
**ការអធិស្ឋាន៖** ឱព្រះអម្ចាស់អើយ សូមឲ្យខ្ញុំមានចិត្តក្លាហានថ្លែងពីការល្អទ្រង់នៅក្នុងជីវភាពរាល់ថ្ងៃផង។

## ព្រះគ្រីស្ទនិងការបន្តពង្រឹងសេចក្តីជំនឿ

ថ្វីដ្បិតតែអ្នកជឿត្រូវបានបង្ខំឲ្យចាកចេញពីពួកជំនុំរបស់ខ្លួន ដូចជាក្នុងករណីបុរសពិការភ្នែករូបនេះ ក៏គាត់មិនមែនគ្មានទីស្នាក់អាស្រ័យនោះដែរ។ ការពិត គាត់គួរតែចាកចេញពីប្រព័ន្ធដឹកនាំពួកជំនុំអាក្រក់បែបនេះ ដូចបានបង្គាប់ក្នុង ២ កូរិនថូស ៦:១៤-១៨ (ចំណុចនេះគឺជាគោលលទ្ធិនៃការញែកជំនុំដោយព្រោះសេចក្តីពិតនិងភាពបរិសុទ្ធ)។ ហើយនៅពេលអ្នកជឿចេញមកក្រៅ នោះនឹងមានព្រះវរបិតាចាំទទួលគាត់ជាមិនខាន។

នៅក្នុងករណីនេះ ព្រះអម្ចាស់នៃយើងដែលបានយាងមកជួបគាត់បន្ទាប់ពីការទទួលរងនូវការកាត់កាល់ទ្រង់គឺជាព្រះវរបិតា។ នោះជាការបន្តពង្រឹងសេចក្តីជំនឿដោយគ្រួគង្វាលដ៏អស្ចារ្យ។ តើអ្វីជាគោលការណ៍ដ៏សំខាន់បំផុតក្នុងការបន្តពង្រឹងសេចក្តីជំនឿ? គោលការណ៍ដ៏សំខាន់បំផុតគឺដើម្បីជួយឲ្យអ្នកជឿថ្មោងថ្មីបានរឹងមាំក្នុងសេចក្តីជំនឿ។ ពេលនេះព្រះអម្ចាស់នៃយើងបើកបង្ហាញអង្គទ្រង់ផ្ទាល់ដល់អ្នកជឿថ្មីថាទ្រង់គឺជាព្រះរាជបុត្រារបស់ព្រះ។ ជាមួយនឹងការបន្តពង្រឹងសេចក្តីជំនឿនៃគោលលទ្ធិអង្គទ្រង់ផ្ទាល់ នោះគឺរួមទាំងគោលលទ្ធិនៃព្រះត្រៃឯកនិងបណ្តាសេចក្តីបង្រៀនផ្សេងៗទៀតនៅក្នុងគោលជំនឿនៃពួកសាវ័ក (*Apostles Creed*) ផងដែរ។ នៅពេលយើងស្គាល់ព្រះគ្រីស្ទកាន់តែខ្លាំង យើងនឹងក៏កាន់តែចុះចូលនឹងអំណាចដ៏ទន់ភ្លន់របស់ទ្រង់ថែមទៀតផងដែរ។ «គាត់ទូលថា ខ្ញុំជឿហើយ ព្រះអម្ចាស់អើយ រួចគាត់ក៏ក្រាបថ្វាយបង្គំទ្រង់» (ខ ៣៨)។

សូមអនុញ្ញាតឲ្យបណ្ឌិតដេវីឌ ស្មីត សន្និដ្ឋានពីការសង្កេតរបស់យើងនៅជំពូកនេះ៖ «មហាជនបានប្រជុំគ្នា រួមទាំងគណៈផារីស៊ីមួយចំនួនដែលជាអ្នកបានប្រកាសក្តីស៊ីពីការកាត់ទោសបណ្តេញចេញ (ពីសាលាប្រជុំ) និងអ្នកកំពុងតាមដានមើលអ្នកមានកំហុសដោយចិត្តច្រណែនឈ្នានីស។ ស្ថិតក្នុងវេលានេះព្រះអម្ចាស់នៃយើងបានទតឃើញឱកាសដើម្បីសង្កត់បន្ថែមពីមេរៀននៃការដោះស្រាយជាមួយបុរសពិការភ្នែក។ ដូចជាយើងបានដឹងរួចហើយពីរឿងប្រៀបប្រដូចដែលបានថ្លែងប្រាប់ គឺវាជារូបភាពមួយសំដៅលើមនុស្សខ្វាក់ពីក្រុងយេរូសាឡឹមក្នុងគោលបំណងដើម្បីបើកភ្នែករបស់ពួកសាសន៍យូដាឲ្យចូលមកឯពន្លឺនៃលោកីយ»។ ព្រះអង្គបានមានបន្ទូលថា៖ «ខ្ញុំបានមកក្នុងលោកីយនេះ ដើម្បីនឹងជំនុំជំរះ ឲ្យពួកអ្នកដែលមើលមិនឃើញបានភ្លឺឡើង ហើយឲ្យពួកអ្នកដែលមើលឃើញ បានទៅជាខ្វាក់វិញ»។ តាមរយៈឥរិយាបទរបស់ពួកគេចំពោះទ្រង់ មនុស្សយើងបានផ្តល់នូវក្តីវិនិច្ឆ័យទោសដល់ខ្លួនឯង (ប្រៀបធៀប ជំពូក iii:១៩)។ ពាក្យនេះក៏បានធ្វើឲ្យប៉ះពាល់ដល់សេចក្តីអំណួតរបស់ពួកផារីស៊ីផងដែរ។ «តើយើងខ្ញុំខ្វាក់ដែរឬអី?» ពួកគេបានប្រើពាក្យយើងខ្ញុំជាគ្រូបង្រៀនរបស់អ៊ីស្រាអែល? ព្រះអង្គក៏បានមានបន្ទូលជាប្រយោគដ៏មុះមុតថា «បើសិនជាអ្នករាល់គ្នាខ្វាក់មែន នោះអ្នករាល់គ្នាឥតមានបាបទេ តែឥឡូវនេះ អ្នករាល់គ្នាអាងថាភ្លឺ បានជាជាប់មានបាបនៅឡើយ»។ ជាការពិតណាស់ចំពោះពួកគេ ដោយសារតែគេមិនយកចិត្តទុកដាក់ដូចជាបណ្តាពួកហ្វូងមនុស្សទេ ពីព្រោះគេបានធ្វើជាលេសដោះសារ។ ពួកគេមានចំណេះដឹងប្រសើរជាងមនុស្សធម្មតា ហើយចំណេះនោះគឺជាការថ្កោលទោសរបស់គេ»។

**ការពិចារណា៖** *«ព្រះគុណអស្ចារ្យ..ជាសព្ទពិរោះ.. ដែលបានប្រោសមនុស្សដូចខ្ញុំ ពីដើមបាត់បង់ តែទ្រង់សង្គ្រោះ.. ក៏ខ្វាក់ តែទ្រង់អប់រំ»*។ (ចម្រៀងទំនុកដំកើង ៩៧)

**ការអធិស្ឋាន៖** សូមព្រះអង្គប្រទានការបន្ទាបខ្លួនស្របតាមសេចក្តីពិតនៃពាក្យបន្ទូលរបស់ទ្រង់។

## ជំពូកទី១០

### ចំពោះចៀមរបស់ទ្រង់ដែលស្តាប់តាមពាក្យបន្ទូលព្រះអង្គ ព្រះយេស៊ូវគ្រីស្ទគឺជាទ្វារនៃជីវិត

ជំពូកដ៏ល្បីអំពីពាក្យប្រៀបប្រដូចពីអ្នកគង្វាលល្អនេះគួរតែសិក្សាជាមួយនឹងជំពូកទី៩ដែលជាប្រវត្តិនៃផ្ទៃរឿងរបស់វាទាំងមូល។ ពាក្យប្រៀបប្រដូចនេះគឺត្រូវបានលើកយកមកបង្រៀនទុកជាការស្តីបន្ទោសដល់អ្នកមិនជឿជនជាតិយូដានិងអ្នកជឿលក្ខណៈជាអាជីព ហើយម្យ៉ាងវិញទៀតវាក៏ទុកជាការធានាដល់ពួកអ្នកជឿផងដែរ ពោលគឺចំពោះមនុស្សគ្រប់រូបនិងគ្រប់ជំនាន់ដែលនឹងទុកចិត្តលើទ្រង់ ទាំងនៅជិតនិងនៅឆ្ងាយ។

ការអះអាងបញ្ជាក់នៃព្រះយេស៊ូវពីនិស្ស័យរបស់ទ្រង់តាមរយៈការមានបន្ទូលទៅព្រះវរបិតាដែលកំពុងសហការធ្វើការជាមួយទ្រង់ ព្រះអង្គបានក្លាយជាចំណុចវិវាទនៃការផ្ទុះកំហឹងម្តងទៀត។ ពួកជនជាតិយូដាបានឡោមព័ទ្ធជុំវិញទ្រង់ត្រង់បាំងសាចហ្លួងសាឡូម៉ូនក្នុងបរិវេណហាមឃាត់របស់ព្រះវិហារ។ (ដូចជាបានបរិយាយនៅក្នុងជំពូកមុនរួចមកហើយថា ព្រះអម្ចាស់នៃយើងពេលនេះកំពុងចូលរួមពិធីបុណ្យស្អាងព្រះវិហារ ឬបុណ្យហានូកា ដែលជាបុណ្យនៃពន្លឺ ប្រហែលជាប្រារព្ធធ្វើឡើងដូចជានារដូវបុណ្យណូអែល)។ គេចង់ឲ្យទ្រង់ប្រកាសជាចុងក្រោយបើទ្រង់ពិតជាព្រះមែស៊ីដែលគេបានរង់ចាំប្រាកដមែន (ព្រះមែស៊ីក្នុងអត្ថន័យភាសាហេព្រើរគឺអ្នកទទួលចាក់ប្រេងតាំង ជាភាសាក្រិកគឺគ្រីស្តុសនិងក្រែស្ទ (*Christ*) ជាភាសាអង់គ្លេស (ឯចំណែកជាភាសាខ្មែរគឺព្រះគ្រីស្ទ)។ ព្រះយេស៊ូវបានឆ្លើយដោយពាក្យបញ្ឈឺដ៏សមហេតុផលដូចទ្រង់ដាក់ក្នុងចម្លើយរបស់បុរសពិការភ្នែកផ្តល់ទៅគណៈផារីស៊ីសកាលពីគ្រាមុនដែរ (៩:២៧) «ខ្ញុំបានប្រាប់អ្នករាល់គ្នាហើយ តែអ្នករាល់គ្នាមិនជឿ» (ខ២៥)។ បន្ទាប់មក ប្រើភស្តុតាងនៃក្រិត្យវិន័យម្តងទៀតមកបញ្ជាក់នូវការអះអាងរបស់ទ្រង់ ព្រះអង្គបានដកស្រង់បន្ទាល់នៃការអស្ចារ្យរបស់ទ្រង់ដោយនូវក្នុងព្រះនាមនៃព្រះវរបិតាជាភស្តុតាងដ៏មិនអាចបដិសេធបានពីភាពជាព្រះមែស៊ីរបស់ទ្រង់។ ព្រះអង្គក៏បានបើកសម្តែងដល់ពួកគេនូវអាថ៌កំបាំងនៃការមិនជឿរបស់គេផងដែរ បើទោះបីជាមានមួយរយភស្តុតាងមកបញ្ជាក់ ហើយអាថ៌កំបាំងនោះគឺស្ថិតនៅក្នុងការពិតមួយគឺថាពួកគេមិនមែនជាចៀមរបស់ទ្រង់។ ពួកគេមិនមែននៅក្នុងរង្វង់ពួកអ្នកបានសង្គ្រោះដែលព្រះវរបិតាបានជ្រើសតាំងប្រគល់ឲ្យព្រះបុត្រារបស់ទ្រង់ឡើយ (សូមមើល យ៉ូហាន ៦:៣៧)។ ក៏ប៉ុន្តែចំពោះពួកអ្នកបានសង្គ្រោះ នោះនឹងស្តាប់ពាក្យបន្ទូលរបស់ព្រះអង្គ ហើយគេនឹងបានសង្គ្រោះជារៀងរហូត (ខ ២៧, ២៨)។ ក្នុងការធានាទ្វេរដងដល់ចៀមរបស់ទ្រង់អំពីជីវិតដ៏អស់កល្បដែលទ្រង់បានប្រទានដល់គេ ព្រះអម្ចាស់នៃយើងបានអះអាងជាថ្មីម្តងទៀតពីភាពស្មើគ្នារបស់ទ្រង់ជាមួយនឹងព្រះវរបិតា (ខ ៣០)។ ការអះអាងនេះបណ្តាលឲ្យមានការគម្រាមចង់គប់នឹងដុំថ្មម្តងទៀត ព្រោះពួកសាសន៍យូដាអាចអត់ធ្មត់នឹងពាក្យអះអាងពីការអស្ចារ្យ តែមិនអាចអត់ធ្មត់នឹងពាក្យអះអាងពីភាពស្មើគ្នានឹងព្រះជាម្ចាស់។ ចំណុចនេះព្រះអម្ចាស់នៃយើងបានជជែកបកស្រាយវិញផ្អែកលើទំនុកដំកើង ៨២:៦។ ពិតជាអស្ចារ្យមែនដែលពាក្យបន្ទូលដ៏បរិសុទ្ធរបស់ព្រះផ្តល់ចម្លើយជាស្រេចដល់យើងដើម្បីឆ្លើយដល់ពួកអ្នកវាយប្រហារចំពោះសេចក្តីពិត។

នៅពេលសាតាំងល្បួងព្រះយេស៊ូវចំនួនបីដងក្នុងអំឡុងសែសិបថ្ងៃនៅក្នុងទីរហោស្ថាន តើទ្រង់មិនទទួលជ័យជំនះលើសត្រូវរបស់ទ្រង់តាមរយៈការដកស្រង់ពាក្យបន្ទូលពីកណ្ឌចោទិយកថាចំនួនបីដង? (សូមចងចាំ ១ ពេត្រុស ៣:១៥)។

**ការពិចារណា៖** តើខ្ញុំជាកូនចៀមក្នុងទីគង្វាលរបស់ទ្រង់?

**ការអធិស្ឋាន៖** ឱព្រះអង្គអើយ សូមឲ្យឃ្វាលខ្ញុំ កុំឲ្យខ្ញុំនៅឆ្ងាយពីទីគង្វាលរបស់ទ្រង់ឡើយ។

*«ចៀមខ្ញុំទាំងប៉ុន្មានវាស្ដាប់ខ្ញុំ ហើយមកតាម ខ្ញុំក៏ស្គាល់វាដែរ» (យ៉ូហាន ១០:២៧)។*

## តើអ្វីនៅក្នុងរឿងប្រៀបប្រដូច

បើតាមវចនានុក្រម ឆាំប៊ើស៍ (*Chambers Dictionary*) រឿងប្រៀបប្រដូចគឺជារឿងបែបប្រៀបធៀប ជារឿងព្រេង ឬជាដំណើរនៃព្រឹត្តិការណ៍អ្វីមួយដែលបានកើតឡើង លើកមកទិទានដើម្បីពន្យល់ពីការបង្រៀនដ៏ជាក់លាក់មួយ ឬដើម្បីធ្វើឲ្យកាតព្វកិច្ច អ្វីមួយច្បាស់លាស់។ (ពាក្យប្រៀបប្រដូច« *«Parable»* មកពីពាក្យភាសាក្រិកពីរបន្សំចូលគ្នាគឺ ផារ៉ា *«para* ក្បែរ» នឹងពាក្យ បាលិអ៊ីន *«to throw* គប់ ឬគ្រវែង»)។

លោកស្កុបហ្វីលដ៍ បានស្រង់បញ្ជីរឿងប្រៀបប្រដូចចំនួន៤០ពីសង្ខេបដំណឹងល្អ (ម៉ាថាយ ម៉ាកុស និង លូកា) តែគាត់មិនបានបញ្ចូលរឿងប្រៀបប្រដូចមួយនេះដែលមាននៅក្នុងដំណឹងល្អយ៉ូហានឡើយ។ រឿងប្រៀបប្រដូចរបស់ដំណឹងល្អយ៉ូហានគឺបែប «រូបបាទិដ្ឋាន» (ការធ្វើឲ្យទៅជាមានរូប)។ តើអ្នកអាចបង្ហាញប្រាប់ពីតួអង្គនិងវត្ថុដែលមាននៅក្នុងរឿងប្រៀបប្រដូចនេះទេ? តើមានប៉ុន្មានក្រុម?

(១). ព្រះអង្គសង្គ្រោះនៃយើងគឺជាអ្នកគង្វាលល្អ ទ្វារ វាលស្មៅ។

(២). អ្នកគង្វាលរង ជាគ្រូគង្វាល គឺជាឆ្មាំទ្វារ ហ្វូងចៀមនៃពួកជំនុំ ចៀមគឺជាអ្នកបានសង្គ្រោះ គឺជាអ្នកជឿ។ ចៀមឯទៀតគឺជាសាសន៍ដទៃរស់នៅទីឆ្ងាយដែលត្រូវប្រកាសប្រាប់ឲ្យឮពីដំណឹងល្អហើយនាំមកក្នុងពួកជំនុំ។

(៣). គ្រូបង្រៀនក្លែងក្លាយគឺជាពួកចោរលួចនិងចោរប្លន់ មនុស្សដទៃ គឺជាឆ្កែព្រៃ។

(៤). អ្នកដែលជាអាជីពគឺជាអ្នកស៊ីឈ្នួល។ នៅសម័យលោកប៊ីហ្សប រ៉ៃល គាត់បានថ្លែងថា៖ «បច្ចុប្បន្នមានគ្រូគង្វាលទទួលចាក់ប្រេងតាំងរាប់ពាន់នាក់ដែលមិនដឹងអ្វីទាល់តែសោះអំពីព្រះគ្រីស្ទ គឺស្គាល់តែនាមរបស់ព្រះអង្គប៉ុណ្ណោះ»។

តើអត្តចរិកពិសេសនៃក្រុមទាំងបួនខាងលើមានអ្វីខ្លះ?

(១). ព្រះសង្គ្រោះអញ្ជើញយើងឲ្យចូលក្នុងទីគង្វាលនិងតាមរយៈទ្រង់ផ្ទាល់ (ជាទ្វារ)។ ទ្រង់ហៅឈ្មោះយើងនិងដឹកនាំយើងទៅទីវាលស្មៅ គឺឲ្យមានជីវិតដ៏ពេញបរិបូរ។ ព្រះអង្គប្រទានជីវិតទ្រង់ដើម្បីសង្គ្រោះចៀមរបស់ទ្រង់។ ទ្រង់មានព្រះទ័យទុកដាក់ចំពោះចៀមឯទៀតដើម្បីនឹងនាំគេមកក្នុងពួកជំនុំដែរ។

(២). គ្រូគង្វាលណាដែលបើកទ្វារបម្រើពួកជំនុំមូលដ្ឋានដ៏ស្មោះត្រង់ហើយរងចាំអ្នកគង្វាលដ៏ធំ។ គាត់បើកទ្វារប្រយោជន៍ឲ្យចៀមអាចចេញចូលបាន។ គ្រូគង្វាលម្នាក់ៗគួរតែជាអ្នកនាំព្រលឹងវិញ្ញាណថ្វាយដល់ព្រះ។

(៣). គ្រូបង្រៀនក្លែងក្លាយដណ្ដើមកិត្តិយសពីព្រះអម្ចាស់ ឬលួចចូលមកក្នុងពួកជំនុំដោយការឡើងតាមរបងឬគាស់ទ្វារចូល ក្នុងគោលបំណងដើម្បីនឹងបំផ្លាញហ្វូងចៀមប៉ុណ្ណោះ (យូដាស ៤)។ ពួកគេគឺជាឆ្កែព្រៃ (កិច្ចការ ២០:២៩)។

(៤). ពួកអ្នកអាជីព ជាអ្នកស៊ីឈ្នួល នៅពេលណាគេឃើញពួកជំនុំទទួលការវាយប្រហារដោយគ្រូបង្រៀនក្លែងក្លាយគេនឹងមិនយកចិត្តទុកដាក់ចំពោះព្រលឹងវិញ្ញាណរបស់សមាជិកឡើយ។ ពួកគេនឹងរត់ចោលពេលណាជួបនឹងការលំបាក។

សមាជិកពួកជំនុំរបស់ព្រះយេស៊ូវគ្រីស្ទពិតប្រាកដមាន*ព្រះដ៏បរិសុទ្ធចាក់លាបឲ្យ* ដូច្នេះពួកគេអាចសម្គាល់ដឹងពីមនុស្សម្នាក់ៗនៅក្នុងព្រះវិហារ ទោះបីជាមនុស្សល្អឬអាក្រក់ក្ដី។ សូមទន្ទេញចងចាំ ១ យ៉ូហាន ២:២០ និងសូមអាន ខ ២៧។ នេះគឺជាអត្ថន័យនៃសេចក្ដីបង្រៀន «ចៀមខ្ញុំទាំងប៉ុន្មានវាស្ដាប់ខ្ញុំ» និង «វាមិនព្រមតាមមនុស្សដទៃទេ» (ខ ៥)។ គ្រីស្ទបរិស័ទម្នាក់ៗមានកាតព្វកិច្ចមួយគឺដើម្បីរក្សាពួកគ្រូបង្រៀនខុសឆ្គងពីវេទិការអធិប្បាយពាក្យបន្ទូល។

**ការពិចារណា៖** តើព្រះយេស៊ូវអ្នកគង្វាលខ្ញុំ?

**ការអធិស្ឋាន៖** ឱព្រះអម្ចាស់អើយ សូមអរព្រះគុណទ្រង់ហើយដែលប្រទានព្រះយេស៊ូវធ្វើជាអ្នកគង្វាលដ៏ល្អដល់ខ្ញុំ។

ថ្ងៃទី ៤ កញ្ញា
យ៉ូហាន ១០:២៨-២៩

*«ខ្ញុំឲ្យជីវិតអស់កល្បជានិច្ចដល់វា វាមិនត្រូវវិនាសនៅអស់កល្បរៀងទៅ ក៏គ្មានអ្នកណាឆក់យកវាពីដៃខ្ញុំបានទេ»។*

## តើជីវិតអស់កល្បគឺជាអ្វី?

បើតាមវចនានុក្រមឆាំបឺរ ពាក្យ «*eternal*» ជាភាសាខ្មែរគឺ «*អស់កល្ប*» មានន័យថា «គ្មានការចាប់ផ្តើម ឬគ្មានទីបញ្ចប់នៃការមានជីវិតរស់នៅ» ជារៀងរហូត និងស្ថិតស្ថេរជានិច្ច។ ជីវិតអស់កល្បដែលព្រះអម្ចាស់នៃយើងប្រទានដល់អ្នកស្តាប់តាមពាក្យរបស់ទ្រង់ (ខ២៧) ពោលគឺចំពោះអ្នកដែលជឿលើទ្រង់ហើយប្រតិបត្តិតាមព្រះអង្គ គឺជាជីវិតដែលគ្មានទីបញ្ចប់និងស្ថិតស្ថេរជានិច្ច។ ទោះជាយ៉ាងណា គ្រូបង្រៀនគ្រីស្ទបរិស័ទខ្លះបង្រៀនថាយើងអាចបាត់បង់នូវជីវិតអស់កល្បនាពេលយើងធ្វើបាបម្តងទៀត។

ជាការពិត អំពើបាបគឺជាទង្វើដ៏អាក្រក់។ នៅពេលលោកអ័ដាមនិងនាងអេវ៉ាមិនស្តាប់បង្គាប់ទ្រង់ បាបបានដឹកនាំយើងឆ្ពោះទៅរកសេចក្តីស្លាប់ដ៏វេទនានិងការធ្លាក់ក្នុងស្ថាននរក។ តើគ្រីស្ទបរិស័ទណាម្នាក់អាចបាត់បង់សេចក្តីសង្គ្រោះរបស់ខ្លួននៅពេលខ្លួនធ្លាក់ទៅក្នុងបាបម្តងទៀតដែរឬទេ? ព្រះគម្ពីរហេព្រើរ ១០:២៦ បានហាមនឹងការធ្វើបាបដោយចេតនាដែលហាក់ដូចជាទាក់ទងនឹងខទី២៩ ចែងពីការ «ជាន់ឈ្លីព្រះរាជបុត្រានៃព្រះ ទាំងរាប់ព្រះលោហិតនៃសេចក្តីសញ្ញាដែលបានញែកគេចេញជាបរិសុទ្ធ ទុកដូចជារបស់ប្រើធម្មតា ហើយត្មះតិះដៀលដល់ព្រះវិញ្ញាណដ៏មានព្រះគុណផងនោះ»។ តើគ្រីស្ទបរិស័ទដែលបានកើតជាថ្មីពិតប្រាកដប្រមាថព្រះសង្គ្រោះរបស់គាត់ដូចបានចែងនៅក្នុងហេព្រើរ ១០:២៦? ប្រសិនដូច្នោះមែន គាត់នឹងស្ថិតនៅក្នុងសភាពដ៏គ្រោះថ្នាក់បំផុតមួយ។ តែយើងមិនគិតថាគាត់នឹងធ្វើដូច្នោះឡើយ។ គ្រីស្ទបរិស័ទដែលបានកើតជាថ្មីពិតប្រាកដនឹងស្រឡាញ់ព្រះអម្ចាស់របស់ខ្លួន ហើយនៅពេលគាត់ធ្វើបាប គាត់មាន «ព្រះដ៏ជាជំនួយ១អង្គហើយ ដែលទ្រង់គង់នៅចំពោះព្រះវរបិតា គឺជាព្រះយេស៊ូវគ្រីស្ទ ជាព្រះដ៏សុចរិត ដែលទ្រង់ជាដង្វាយធួននឹងបាបយើងរាល់គ្នា... » (១ យ៉ូហាន ២:១,២)។ «បើយើងលន់តួបាបវិញ នោះទ្រង់មានព្រះហឫទ័យស្មោះត្រង់ ហើយសុចរិត ប្រយោជន៍នឹងអត់ទោសបាបឲ្យយើង ហើយនឹងសំអាតយើង ពីគ្រប់អំពីទុច្ចរិតទាំងអស់ផង» (១ យ៉ូហាន ១:៩)។ យើងមិនគិតថាគ្រីស្ទបរិស័ទម្នាក់នឹងបាត់បង់សេចក្តីសង្គ្រោះរបស់ខ្លួននោះឡើយ ពីព្រោះជីវិតដែលបានប្រទានដល់គាត់គឺអស់កល្បនិងស្ថិតស្ថេរជានិច្ច។

ដូច្នេះជីវិតអស់កល្បគឺជាជីវិតដ៏នៅស្ថិតស្ថេរ ហើយជីវិតដ៏នៅស្ថិតស្ថេរគឺជាជីវិតបន្តរស់នៅជារៀងរហូតនឹងមិនដែលបាត់បង់សូម្បីតែក្នុងអំឡុងពេលខ្លីណាមួយ។ ហេតុនេះ បើតាមបែបទេវសាស្ត្រគ្រីស្ទបរិស័ទមាន «ការធានាដ៏អស់កល្ប»។ នេះហើយគឺជាសេចក្តីដែលព្រះយេស៊ូវចង់បង្រៀនពេលទ្រង់មានបន្ទូលថា៖ «ខ្ញុំឲ្យជីវិតអស់កល្បជានិច្ចដល់វា វាមិនត្រូវវិនាសនៅអស់កល្បរៀងទៅ ក៏គ្មានអ្នកណាឆក់យកវាពីដៃខ្ញុំបានទេ» (យ៉ូហាន ១០:២៨)។ ដើម្បីធានាទ្វេរដងដល់យើងពីអំណាចនៃសេចក្តីសន្យារបស់ទ្រង់ថាយើងនឹងមិនដែលបាត់បង់សេចក្តីសង្គ្រោះ ព្រះអង្គបានបន្ថែមទៀតថា «ព្រះវរបិតានៃខ្ញុំ ដែលប្រទានវាមកខ្ញុំ ទ្រង់ធំលើសជាងទាំងអស់ គ្មានអ្នកណាអាចនឹងឆក់យកវាចេញពីព្រះហស្តរបស់ព្រះវរបិតាខ្ញុំបានឡើយ» (ខ ២៨, ២៩)។

ចូរយើងបញ្ចប់ដោយការដកស្រង់របស់លោកចន កាលវិនពី យ៉ូណាស ២:១០ «ឯសេចក្តីសង្គ្រោះ នោះកើតមកតែពីព្រះយេហូវ៉ាទេ»។ សូមសរសើរដំកើតព្រះអម្ចាស់ យើងបានសង្គ្រោះមិនមែនព្រោះតែយើងជាមនុស្សល្អគ្រប់លក្ខណ៍នោះទេ តែពីព្រោះទ្រង់ល្អដល់យើងវិញ។ «នោះទ្រង់បានជួយសង្គ្រោះយើង មិនមែនដោយការដែលយើងបានប្រព្រឹត្តដោយសុចរិតទេ គឺដោយសេចក្តីមេត្តាករុណារបស់ទ្រង់វិញ...» (ទីតុស ៣:៥)។ សូមទន្ទេញចងចាំខនេះ។

**ការពិចារណា៖** «ឯសេចក្តីសង្គ្រោះ នោះកើតមកតែពីព្រះយេហូវ៉ាទេ» (យ៉ូណាស ២:១០)។

**ការអធិស្ឋាន៖** ឱសូមអរព្រះគុណទ្រង់ហើយ សម្រាប់សេចក្តីមេត្តាករុណារបស់ទ្រង់ដល់យើងខ្ញុំ។

*«...ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា ខ្ញុំជាទ្វារចៀម»។*

## ការអះអាងដ៏ពិសេសនៃអ្នកគង្វាលល្អ

តើមានអ្នកណាម្នាក់នៅក្នុងពិភពលោកនេះ ទោះបីជាហោរាណម្នាក់ ឬទស្សនវិទូណាម្នាក់ធ្លាប់បានអះអាងចំពោះអ្នកដូចជាព្រះអង្គសង្គ្រោះនៃយើងដែរឬទេ? ទោះបីជា លោក ផ្លាតូ (*Plato*) បានផ្តល់មតិថាទស្សនវិទូម្នាក់ៗគួរតែជាស្តេច ហើយលោកកុងជឺ (*Confucius*) បានពិភាក្សាអំពីមនុស្សដ៏ជាស្តេច ក៏នៅតែគ្មានអ្នកណាម្នាក់ក្នុងចំណោមពិភពអ្នកទស្សនវិទ្យាទាំងឡាយរបស់ពួកគេបានអះអាងដូចព្រះអម្ចាស់នៃយើងដែរ។

នៅក្នុងជំពូកនេះព្រះអម្ចាស់នៃយើងបានប្រកាសអង្គទ្រង់ថាជាអ្នកគង្វាលល្អ ជាទ្វារ និងជាវាលស្មៅ។ ឥឡូវនេះសូមសំគាល់អ្នកគង្វាលនៃទំនុកដំកើង២៣ ដែលយើងគ្រប់រូបស្គាល់ជាក់ច្បាស់ថាគឺគ្មានអង្គណាក្រៅពីព្រះយេហូវ៉ានៃយើងឡើយ។ សូមកត់សម្គាល់អក្សរធំក្នុងភាសាអង់គ្លេស L-O-R-D។ នេះគឺជាការបកប្រែនៃព្រះគម្ពីរ ឃីង ជេមស៍ (*King James Version*) ដែលអ្នកបកប្រែប្រើវាដើម្បីបង្ហាញពីព្រះនាមនៃព្រះជាម្ចាស់គឺព្រះយេហូវ៉ា។ អ្នកគង្វាលល្អគឺជាព្រះយេស៊ូវ ដែលទ្រង់អះអាងថាជាព្រះយេហូវ៉ា ជាព្រះនៃសាសន៍អ៊ីស្រាអែលនាសម័យសញ្ញាចាស់។ ជាទ្វារមានអត្ថន័យសំដៅលើការចូលពួកជំនុំ ជាមធ្យោបាយចូលទៅឯព្រះជាម្ចាស់។ ដូចនេះ បើតាមទំនុកដំកើង៨៤ សេចក្តីអំណររីករាយនៃអ្នកជឿម្នាក់គឺការក្លាយជា «ឆ្មាំទ្វារនៅក្នុងដំណាក់របស់ព្រះនៃទូលបង្គំ»។ វាលស្មៅពិពណ៌នាអំពីការផ្គត់ផ្គង់ដ៏ល្អដល់ចៀមដែលជាពាក្យរំឭកពីទំនុកដំកើង១០០ ជាទីកន្លែងរាស្ត្ររបស់ព្រះហៅថា «ជាហ្វូងចៀមនៅទីគង្វាលរបស់ទ្រង់» (ខ ៣)។ ផ្ទុយពីការអះអាងនូវភាពជាព្រះនិងភាពជាព្រះសង្គ្រោះនេះ គឺបើអាស្រ័យទៅតាមបរិបទនៃជំពូកនេះ ពួកសាសន៍យូដា គណៈផារីស៊ី ពួកអាចារ្យ និងពួកអ្នកប្រាជ្ញខាងច្បាប់ ជាអ្នកដឹកនាំខ្វាក់ដឹកនាំមនុស្សខ្វាក់ ពួកគេគឺជាពួកចោរលួចនិងចោរប្លន់ មនុស្សជទៃនិងឆ្កែព្រៃ ហើយអ្នកបំរើជាអាជីពក្នុងពន្ធកិច្ចព្រះវិហារត្រូវបានហៅថាជាអ្នកស៊ីឈ្នួល។ ចំណុចនេះគឺជាអំណះអំណាងសម្រាប់បញ្ជាក់ពីនិស្ស័យជាព្រះរបស់ព្រះអម្ចាស់នៃយើង។ ការអះអាងរបស់ទ្រង់គឺសំដៅទៅលើអំណាចទាំងអស់ ហើយនិងលក្ខណៈសម្បត្តិដ៏ជាព្រះរបស់ទ្រង់ផងដែរ។ ប្រសិនបើការអះអាងទាំងនេះមិនពិត ព្រះអង្គប្រាកដជានឹងក្លាយជាមនុស្សក្លែងបន្លំនិងជាមនុស្សអួតអាងដ៏ធំជាមិនខាន។

ព្រះអង្គអះអាងថាទ្រង់ជាប្រភពដើមនៃជីវិត។ ទ្រង់ព្យាករណ៍ទុកជាមុនអំពីការសុគតនិងការរស់ពីស្លាប់ឡើងវិញរបស់ទ្រង់។ វាគឺជាការអះអាងបែបជាព្រះនេះហើយដែលបណ្តាលឲ្យមានសន្ទុះនៃការប្រឆាំងពីសំណាក់ពួកអ្នកមិនជឿសាសន៍យូដារហូតដល់ផ្ទុះឡើងនូវការចាប់ខ្លួនព្រះអង្គ ការជំនុំជំរះទោស និងការឆ្កាងទ្រង់។ ក៏ប៉ុន្តែទីបន្ទាល់ដ៏ឥតភិតភ័យរបស់ទ្រង់អំពីអង្គទ្រង់ផ្ទាល់បង្កើតបានជាអំណះអំណាងដ៏ល្អត្រឹមត្រូវ។ នៅខណៈពេលអ្នកខ្លះហៅទ្រង់ថាជាអារក្សនិងជាមនុស្សឆ្កួត ក៏នៅមានអ្នកខ្លះទៀបន្តស៊ូនៅជាមួយទ្រង់ដែរ (ខ ១៩-២០)។ តើអ្នកនៅភាគីខាងណាដែរ?

**ការពិចារណា៖** តើអ្នកណានៅខាងព្រះអម្ចាស់?

**ការអធិស្ឋាន៖** ព្រះអម្ចាស់អើយ ខ្ញុំដឹងហើយទោះបីមានតែម្នាក់នៅក្នុងទ្រង់ក៏ជាចំនួនច្រើនដែរ។

*«ពីព្រោះបើមិនជឿថា ខ្ញុំនេះជាព្រះ នោះអ្នករាល់គ្នានឹងស្លាប់ក្នុង អំពើបាបរបស់ខ្លួនជាពិតមែន» (៨:២៤)។*

## ការអះអាងស្មើនឹងព្រះវរបិតាមួយផ្សេងទៀត

បន្ទាប់ពីការប្រឈមមុខនឹងសាសន៍យូដាពីការប្រោសបុរសស្វិតដៃជើង៣៨ឆ្នាំ ការអះអាងពីការសហការគ្នានៃព្រះយេស៊ូវនឹងព្រះវរបិតាក្នុងពន្ធកិច្ចរបស់ទ្រង់បាននាំមកនូវការមិនសប្បាយចិត្តចំពោះសាសន៍យូដា។ ពីព្រោះគេយល់ថាបើការអះអាងនោះជាការពិត ដូច្នោះព្រះយេស៊ូវបានយកព្រះធ្វើជាព្រះបិតារបស់ទ្រង់ ដោយ «តាំងខ្លួនឡើងជាព្រះ»។ ការអះអាងនេះមិនត្រឹមសំដៅលើភាពស្មើគ្នានូវអំណាចនោះទេ តែពីស្មើភាពគ្នានៃនិស្ស័យជាព្រះផងដែរ។

អត្ថបទព្រះគម្ពីរបែបនេះហើយដែលអ្នកនិពន្ធគោលជំនឿគ្រីស្ទបរិស័ទសំណួរនិងចម្លើយខ្នាតខ្លីវេស្ទមីនស្ទឺរ បានបង្កើតសេចក្ដីបង្រៀនរបស់គេផ្ដែកលើភាពជាព្រះនៃព្រះគ្រីស្ទនឹងព្រះវរបិតាហើយនឹងព្រះវិញ្ញាណបរិសុទ្ធ។

សំណួរទី១១នៃគោលជំនឿគ្រីស្ទបរិស័ទខ្នាតវែងសួរថា៖ តើដូចម្ដេចដែលហាក់ដូចជាព្រះបុត្រានិងព្រះវិញ្ញាណបរិសុទ្ធគឺស្មើនឹងព្រះដ៏ជាព្រះវរបិតា?

ចម្លើយ៖ ព្រះគម្ពីរសម្ដែងថាព្រះបុត្រានិងព្រះវិញ្ញាណបរិសុទ្ធគឺជាព្រះស្មើនឹងព្រះវរបិតា ដោយការសន្មត់ឲ្យនាមនៃអង្គបុគ្គលទាំងនេះនូវ **បុគ្គលិកលក្ខណៈ កិច្ចការ** និងការថ្វាយបង្គំ ដូចជាការថ្វាយដ៏ត្រឹមត្រូវសម្រាប់ព្រះជាម្ចាស់ដែរ។

«ខ្ញុំហើយនឹងព្រះវរបិតា គឺតែ១ព្រះអង្គទេ» សំដៅទៅលើ**បុគ្គលិកលក្ខណៈ**នៃព្រះគ្រីស្ទនិងនិស្ស័យជាព្រះតែមួយរួមគ្នានឹងព្រះវរបិតា។ ពាក្យនេះគឺតាំងទ្រង់ឡើងស្មើព្រះ ហើយជាហេតុនាំឲ្យមានបំណងចោលទ្រង់នឹងដុំថ្មពីសំណាក់សាសន៍យូដាដែលខឹងទ្រង់។ ការអះអាងនេះបានធ្វើឲ្យសាសន៍យូដាចោទប្រកាន់ព្រះអម្ចាស់នៃយើងពីបទប្រមាថ។ ជាថ្មីម្ដងទៀតពួកគេបានស៊កពាក្យសម្ដីពីក្នុងចិត្តដ៏គ្មានជំនឿរបស់គេថា៖ «យើងចោលអ្នកនឹងថ្ម មិនមែនដោយព្រោះការល្អណាទេ គឺដោយព្រោះពាក្យប្រមាថដល់ព្រះ ហើយពីព្រោះអ្នកដែលជាមនុស្ស បានតាំងខ្លួនឡើងជាព្រះវិញប៉ុណ្ណោះ» (ខ៣៣)។

បច្ចុប្បន្នមានអ្នកចេះដឹងជាច្រើននាក់ដែលទទួលព្រះយេស៊ូវគ្រីស្ទត្រឹមជាហោរា នោះរួមទាំងអ្នកកាន់សាសនាអ៊ីស្លាមផងដែរ។ ប៉ុន្តែពួកគេបដិសេធទ្រង់ជាបុត្រានៃព្រះស្មើនឹងព្រះដ៏ជាព្រះវរបិតា។ តែសូមនឹកចាំពាក្យដាស់តឿនពីដំបូងរបស់ព្រះអម្ចាស់នៃយើងម្ដងទៀត «ពីព្រោះបើមិនជឿថា ខ្ញុំនេះជាព្រះ នោះអ្នករាល់គ្នានឹងស្លាប់ក្នុងអំពើបាបរបស់ខ្លួនជាពិតមែន» (៨:២៤) តើអ្នកលុតជង្គង់ក្រាបថ្វាយ បង្គំព្រះយេស៊ូវគ្រីស្ទជាបុត្រានៃព្រះ ជាព្រះដ៏ពិតដែរឬទេ?

**ការពិចារណា**៖ មិនមែនឃើញទើបជឿទេ តែជឿវិញទើបឃើញជាក្រោយ។
**ការអធិស្ឋាន**៖ ព្រះវរបិតាអើយ សូមអរព្រះគុណទ្រង់ហើយដែលប្រទានជំនឿដល់ខ្ញុំ (អេភេសូរ ២:៨)។

ថ្ងៃទី ៧ កញ្ញា
យ៉ូហាន ១០:៣១-៣៨

*«...ដើម្បីឲ្យអ្នករាល់គ្នាបានដឹង ហើយជឿថាព្រះវរបិតា ទ្រង់គង់នៅក្នុងខ្ញុំ ហើយខ្ញុំក្នុងទ្រង់ដែរ»។*

## ព្រះយេស៊ូវគ្រីស្ទ មហាតក្កវិទូ

សាសន៍យូដាបានរើសដុំថ្មដើម្បីចោលព្រះយេស៊ូវព្រោះគេខឹងទ្រង់ជាមនុស្សតាំងខ្លួនឡើងជាព្រះ។ ព្រះយេស៊ូវបានឈរនៅនឹងកន្លែង ដោយឥតភ័យខ្លាច ដើម្បីការពារបុព្វហេតុរបស់ទ្រង់។ ព្រះអង្គបានសួរគេមួយសំណួរពីព្រះគម្ពីរសញ្ញាចាស់ ជាបទគម្ពីររបស់ជនជាតិយូដា។ ដោយដកស្រង់ពីទំនុកដំកើង ៨២:៦ ទ្រង់បានសួរគេថា៖ «តើគ្មានសេចក្តីចែងទុកមកក្នុងក្រិត្យវិន័យរបស់អ្នករាល់គ្នាថា អញបាននិយាយថា ឯងរាល់គ្នាជាព្រះ ទេឬអី?»។ ដូច្នេះ បើទ្រង់បានហៅអ្នកទាំងនោះជាព្រះ («អេឡូហ៊ីម *Elohim*» នៅក្នុងភាសាហេព្រើរ គឺជាពាក្យប្រើដូចគ្នាសំរាប់**ព្រះជាម្ចាស់** «*GOD*») ដែលព្រះបន្ទូលរបស់ព្រះអង្គបានឮទៅដល់គេ ហើយបើលើកចោលបទគម្ពីរណាមិនបាន នោះតើអ្នករាល់គ្នានិយាយមកខ្ញុំនេះ ដែល ព្រះវរបិតាញែកជាបរិសុទ្ធហើយចាត់មកក្នុងលោកីយថា ខ្ញុំពោលពាក្យប្រមាថដល់ព្រះ ដោយព្រោះតែ ខ្ញុំនិយាយ ខ្ញុំជាព្រះរាជបុត្រានៃព្រះដូច្នេះឬអី? បើសិនជាខ្ញុំមិនធ្វើការរបស់ព្រះវរបិតាខ្ញុំទេ នោះកុំឲ្យជឿ ដល់ខ្ញុំឡើយ។ ប៉ុន្តែបើខ្ញុំធ្វើការរបស់ទ្រង់វិញ នោះទោះបើអ្នករាល់គ្នាមិនជឿខ្ញុំ គង់តែត្រូវជឿដល់ការទាំងនោះដែរ ដើម្បីឲ្យអ្នករាល់គ្នាបានដឹង ហើយជឿថាព្រះវរបិតាទ្រង់គង់នៅក្នុងខ្ញុំ ហើយខ្ញុំក្នុងទ្រង់ដែរ»។

ពាក្យដែលព្រះយេស៊ូវដកស្រង់ចេញពីព្រះគម្ពីររបស់សាសន៍យូដាផ្ទាល់បានធ្វើឲ្យគេរកគន្លឹះឆ្លើយមិនបាន។ អ្វីដែលទ្រង់ជំទាស់នឹងពួកគេគឺដូចនេះ «តើគ្មានសេចក្តីចែងទុកមកក្នុងក្រិត្យវិន័យរបស់អ្នករាល់គ្នាថា អ្នកដែលមានព្រះបន្ទូល (ពួកចៅក្រមនៃអ៊ីស្រាអែល) គឺជាព្រះ ទេឬអី?» បើអ្នកទាំងនេះដែលជាដឹកនាំអ៊ីស្រាអែលត្រូវបានហៅថាជាព្រះ នោះតើអ្នករាល់គ្នានិយាយមកខ្ញុំនេះ ដែលព្រះវរបិតាញែកជាបរិសុទ្ធហើយចាត់មកក្នុងលោកីយថា ខ្ញុំពោលពាក្យប្រមាថដល់ទ្រង់? បើសិនជាខ្ញុំមិនធ្វើការរបស់ព្រះវរបិតាខ្ញុំទេ នោះកុំឲ្យជឿដល់ខ្ញុំឡើយ។ ប៉ុន្តែ បើខ្ញុំធ្វើការរបស់ទ្រង់វិញ នោះទោះបើអ្នករាល់គ្នាមិនជឿខ្ញុំ គង់តែត្រូវជឿដល់ការអស្ចារ្យទាំងនោះដែរ ដើម្បីឲ្យអ្នករាល់គ្នាបានដឹង ហើយជឿថាព្រះវរបិតាទ្រង់គង់នៅក្នុងខ្ញុំ ហើយខ្ញុំក្នុងទ្រង់ដែរ»។ ប្រសិនបើចៅក្រមជាមនុស្សត្រូវបានហៅថាជាព្រះពីសម័យបុរាណក្នុងប្រទេសអ៊ីស្រាអែល ព្រះយេស៊ូវជាអង្គដែលព្រះជាម្ចាស់ចាត់មកពីស្ថានសួគ៌ដើម្បីធ្វើជាព្រះសង្គ្រោះរបស់មនុស្សជាតិគឺសាកសមមួយពាន់ដងហៅថាជាព្រះរាជបុត្រានៃព្រះ។ តើតក្កវិជ្ជាបែបនេះអាចបដិសេធបានដែរឬទេ?

សាក្ខីភាពនៃការដែលសាសន៍យូដាគ្មានចម្លើយហើយប្រើប្រាស់អំណាចបង្ខិតបង្ខំមកជំនួសវិញគឺបញ្ជាក់យ៉ាងច្បាស់ពីការពិតដែលទ្រង់បកស្រាយដោយខ្លួនឯង។ ព្រះយេស៊ូវគ្រីស្ទ គឺពិតជាមហាតក្កវិទូ (អ្នកប្រាជ្ញផ្នែកហេតុវិជ្ជា)!

**ការពិចារណា៖** «*សេចក្តីកោតខ្លាចដល់ព្រះយេហូវ៉ា នោះជាដើមចមនៃតម្រិះ...*» (សុភាសិត ១:៧)។
**ការអធិស្ឋាន៖** ព្រះអម្ចាស់ សូមប្រទានតម្រិះដល់ខ្ញុំ សម្រាប់បកស្រាយដំណឹងល្អដល់មនុស្សបាត់បង់ផង។

*«កាលណាគេធ្វើទុក្ខ បៀតបៀនអ្នករាល់គ្នា ក្នុងក្រុងនេះ នោះត្រូវរត់ទៅឯក្រុង១ទៀតវិញ» (ម៉ាថាយ ១០:២៣)។*

**តើរត់គឺជាភាពកំសាក?**

យើងឃើញនៅក្នុងខគម្ពីរសល់ក្នុងជំពូកនេះព្រះអម្ចាស់នៃយើងក្លាយជាអ្នករត់គេចខ្លួនជាថ្មីម្តងទៀត។ តើរត់គឺជាភាពកំសាក? តើវាគឺជាការកំសាកករណីសាវ័កប៉ុលភៀសខ្លួនចេញពីក្រុងដាម៉ាសក្នុងកញ្ច្រែ «សំរូតចុះតាមកំផែងក្រុង»? វាមិនមែនជាភាពកំសាកក្នុងការរត់ចេញមុនពេលកំណត់របស់បុគ្គលម្នាក់ទៀតមកដល់ឡើយ។ ព្រះអម្ចាស់នៃយើង «បានចាត់ទុកសេចក្តីស្លាប់ជាការទៅផ្ទះ» (បើប្រើសុភាសិតចិន) នៅពេលទ្រង់ជ្រាបពីវេលាកំណត់របស់ទ្រង់ដែលត្រូវសុគតឈានជិតមកដល់។ ឯចំណែកសាវ័កប៉ុលវិញក៏ដូច្នោះដែរនៅគ្រាចុងក្រោយមកគាត់ត្រូវបានគេបញ្ជូនទៅទីក្រុងរ៉ូម។ មុនវេលាកំណត់របស់បុគ្គលម្នាក់ជាមួយនឹងព្រះជាម្ចាស់ នោះនឹងមានបញ្ជាពីព្រះអម្ចាស់នៃយើងដូចបានសម្តែងប្រាប់ដល់ពួកអ្នកទាំងដប់ពីរ៖ «កាលណាគេធ្វើទុក្ខ បៀតបៀនអ្នករាល់គ្នា ក្នុងក្រុងនេះ នោះត្រូវរត់ទៅឯក្រុង១ទៀតវិញ» (ម៉ាថាយ ១០:២៣)។

ចំពោះទីកន្លែងនៃការភៀសខ្លួនរបស់ទ្រង់ យើងមានព័ត៌មានបន្ថែមនៅដំណឹងល្អ ម៉ាថាយ ៣:១, ១៣។ នៅក្នុងម៉ាថាយ ១៩:១ យើងមានឃ្លាបន្លឺដ៏ច្បាស់លាស់មួយ «ទៅឯព្រំស្រុកយូដា នៅខាងនាយទន្លេយ័រដាន់» ឬ«ត្រើយខាងនាយទន្លេយ័រដាន់ក្នុងស្រុកយូដា» (ព្រះគម្ពីរខ្មែរសម្រាយ«*KHSV*»)»។ លោក អិលីខត (*Ellicott*) យល់ថាទីតាំងនេះ គឺស្ថិតនៅខាងជើងសមុទ្រកាលីឡេនាភាគខាងកើតនៃទន្លេយ័រដាន់។ ទីតាំងនេះគឺជាតំបន់ហ្គូឡាន់ ហៃស៍ (*Golan Hights*) ដែលប្រទេសអ៊ីស្រាអែលដណ្តើមគ្រប់គ្រងពីប្រទេសស៊ីរី នាសង្គ្រាមប្រាំមួយថ្ងៃ ក្នុងឆ្នាំ ១៩៦៧។

តើព្រះអង្គគង់នៅទីនោះរយៈពេលយូរប៉ុណ្ណា? ចាប់ពីពិធីបុណ្យថ្វាយព្រះវិហាររហូតដល់ពិធី បុណ្យរំលងគឺមានរយៈពេលបួនខែ (ខែធ្នូដល់ខែមេសា)។ នៅក្នុងចន្លោះពេលប៉ុន្មានខែនោះ គឺជាការវិលត្រឡប់ទៅខាងក្រៅរាជធានីគឺទៅឯភូមិបេថានី ដើម្បីប្រោសឡាសារពីស្លាប់និងជាពេលគង់នៅក្នុងទីក្រុងមួយឈ្មោះថាអេប្រាអិម «ក្បែរទីរហោស្ថានវិញ» (យ៉ូហាន ១១:៥៤)។

ពួកអ្នកជឿដែលបានកើតជាថ្មីដ៏ស្មោះត្រង់កាលពីគ្រាដំបូងនៃព័ន្ធកិច្ចរបស់ទ្រង់បាននាំគ្នាទៅតាមព្រះអង្គនៅទីនោះ។ នេះពិតជាខុសគ្នាស្រឡះនឹងពួកសាសន៍យូដាមានចិត្តរឹងមានៈបះបោរក្នុងទីក្រុងយេរូសាឡឹមតែម្តង។ ការនេះបានលើកទឹកចិត្តព្រះអម្ចាស់នៃយើងឲ្យបានទតឃើញដំណឹងល្អពង្រឹងក្នុងជីវិតរបស់គេថ្វីត្បិតតែមានអ្នកបៀតបៀន និងតាមរយៈពួកអ្នកជឿទាំងនេះអ្នកដទៃទៀតក៏បាននាំមកក្នុងនគរព្រះ។ មនុស្សជាច្រើននៅពេលប្រៀបធៀបយ៉ូហាន-បាទីស្ទជាមួយនឹងព្រះគ្រីស្ទ សន្និដ្ឋានថាព្រះគ្រីស្ទប្រសើរជាងព្រោះការអស្ចារ្យរបស់ទ្រង់គឺគួរឲ្យស្ញប់ស្ញែងបំផុត ចំណែកយ៉ូហាន-បាទីស្ទ គាត់មិនបានធ្វើការអស្ចារ្យអ្វីសោះឡើយ។ ទោះជាយ៉ាងណា ពួកគេបានសន្និដ្ឋានថាយ៉ូហានមិនបានសម្តែងការអស្ចារ្យដោយយល់ព្រះយេស៊ូវដើម្បីឲ្យទ្រង់នឹងត្រូវបានដំកើងកាន់តែខ្ពង់ខ្ពស់ឡើង (លោក កាល់វិន)។

ការគង់នៅឯនាយទន្លេយ័រដាន់របស់ព្រះគ្រីស្ទគឺត្រូវបានព្រះប្រើប្រាស់សម្រាប់បង្កើតផលផ្លែកាន់តែច្រើនឡើងថែមទៀត។ វាមិនមែនជាភាពកំសាកក្នុងការរត់គេចចេញពីកាលៈទេសៈនោះនៃជីវិតរបស់ទ្រង់ឡើយ។

**ការពិចារណា៖** «គឺព្រះយេហូវ៉ាដែលតម្រង់ផ្លូវអស់ទាំងជំហាននៃមនុស្សល្អ ហើយទ្រង់ សព្វព្រះហឫទ័យនឹងផ្លូវដែលគេដើរ» (ទំនុកដំកើង ៣៧:២៣)។

**ការអធិស្ឋាន៖** ព្រះអង្គអើយ សូមឲ្យគ្រប់កាលៈទេសៈខ្ញុំចេះស្តាប់តាមការដឹកនាំរបស់ទ្រង់ផង។

*«បើព្រះគ្រីស្ទមិនបានរស់ឡើងវិញ នោះដំណឹងដែលយើងខ្ញុំផ្សាយនេះ ជាការឥតប្រយោជន៍ទេ..»(១ កូរិនថូស ១៥:១៤)។*

## ជំពូកទី១១

## ព្រះយេស៊ូវគ្រីស្ទគឺជាសេចក្តីរស់ឡើងវិញនិងជាជីវិត ចំពោះអ្នកជឿដែលបានស្លាប់និងនៅមានជីវិត

ទោះបីនេះគឺជាពេលដំបូងដែលឡាសារ នាងម៉ារានិងម៉ាថាត្រូវបានលើកមកប្រាប់នៅក្នុងដំណឹងល្អយ៉ូហាន យើងបានស្គាល់បងប្អូនស្រីទាំងពីរនាក់នេះរួចមកហើយតាមរយៈកំណត់ត្រានៃដំណឹងល្អលូកា (១០:៣៨-៤២)។ ជាមួយនឹងឈ្មោះឡាសារលេចឡើងនៅជំពូកនេះថាជាអ្នកព្រះយេស៊ូវស្រឡាញ់ យើងអាចមានរូបភាពដ៏គ្រប់ជ្រុងជ្រោយពេញមួយអំពីអ្នកស្រុកបេថានីទាំងបីនាក់បងប្អូននោះ។

ចម្ងាយប្រហែលជាងបីគីឡូម៉ែតពីទីក្រុងយេរូសាឡឹមតាមជម្រាលភ្នំអូលីវ (*Mt. Olives*)តាមដងផ្លូវទីក្រុងយេរីខូ គឺជាភូមិបេថានី។ នៅភូមិនោះមានបងប្អូនស្រីពីរនាក់និងប្អូនប្រុសម្នាក់រស់នៅជុំគ្នា បើតាមការស្មានជាគ្រួសារអ្នកមានជីវភាពធូរធារម្នាក់។ នេះគឺជាគ្រួសារដែលបានទទួលព្រះយេស៊ូវគ្រីស្ទ មិនត្រឹមតែមក ខាងក្នុងផ្ទះរបស់គេ ប៉ុណ្ណោះទេ ក៏ប៉ុន្តែក៏មកខាងចិត្តរបស់ពួកគេផងដែរ។ ព្រះអម្ចាស់និងសាវ័ក ទ្រង់ពិតជាបានទទួលនូវការលើកទឹកចិត្តយ៉ាងខ្លាំងពីបដិសណ្ឋារកិច្ចដោយក្តីស្រឡាញ់និងការទទួលនូវការស្វាគមន៍ប្រកបដោយភាពកក់ក្តៅនៅពេលណាពួកគេបានឆ្លងកាត់ភូមិនោះឈប់សម្រាកដើម្បីបន្តដំណើរទៅទីក្រុងយេរូសាឡឹម។

ស្រាប់តែពេលនេះជាអំឡុងពេលព្រះអម្ចាស់នៃយើងបានយាងពីក្រុងយេរូសាឡឹមទៅឯត្រើយទន្លេយ័រដាន់ ឡាសារបានធ្លាក់ខ្លួនឈឺ។ ជម្ងឺនេះគឺមានសភាពធ្ងន់ធ្ងរ ហេតុនេះគេបានឲ្យអ្នកនាំសារទៅយាងព្រះយេស៊ូវមក។ នៅពេលព្រះអម្ចាស់នៃយើងបានទទួលដំណឹងរួចហើយ ទ្រង់ជ្រាប់ថាជំងឺនោះគឺជាផែនការមួយទៀតរបស់ព្រះវរបិតាដើម្បីឲ្យព្រះនាមរបស់ព្រះជាម្ចាស់នឹងបានលើកដំកើងយ៉ាងអស្ចារ្យនៅភូមិនោះ។ ព្រះអង្គជ្រាបដឹងថាជម្ងឺនេះនឹងនាំមកនូវសេចក្តីស្លាប់តែដោយទ្រង់គឺជាម្ចាស់នៃជីវិតទ្រង់នឹងប្រោសឡាសារពីស្លាប់ឡើងវិញ។ នេះគឺជាការសម្តែងការអស្ចារ្យចុងក្រោយនៃព័ន្ធកិច្ចជាព្រះមែស៊ីរបស់ព្រះអង្គ ដែលទ្រង់មិនបានយាងមកដើម្បីសម្រេចគោលបំណងរបបនយោបាយរបស់ជនរួមជាតិរបស់ទ្រង់ទេ ក៏ប៉ុន្តែដើម្បីសង្គ្រោះមនុស្សជាតិទាំងអស់ពីអំពើបាបនិងសេចក្តីស្លាប់វិញ។ មុនសម្តែងនូវការនេះព្រះអម្ចាស់នៃយើងបានប្រោសកូនស្រីរបស់លោកយ៉ៃរុស (លូកា ៨:៤៩) និងកូនប្រុសរបស់ស្ត្រីមេម៉ាយពីស្រុកណាអ៊ីន (លូកា ៧:១១)។ ឥឡូវនេះទ្រង់នឹងត្រូវធ្វើកិច្ចការនោះម្តងទៀត គឺជាការអស្ចារ្យបីបញ្ជាក់ពីភាពជាព្រះបុត្រានៃទ្រង់។ ព្រះអង្គមានចេតនាពន្យាពេលយាងមកដើម្បីឲ្យឡាសារ ដែលមកដល់ពេលនេះជាសាកសពស្អុញបន្ទាប់ពីស្លាប់ចំនួនបួនថ្ងៃ គឺប្រយោជន៍ផ្តល់នូវទីបន្ទាល់ពីអំណាចរបស់ទ្រង់កាន់តែខ្លាំងក្លាឡើងថែមទៀត។

ពួកសាវ័កដែលនៅជាមួយទ្រង់ឯនាយទន្លេយ័រដាន់ បានដឹងពីគ្រោះថ្នាក់នៃការវិលត្រឡប់ទៅទីក្រុងបានព្យាយាមឃាត់ព្រះអម្ចាស់នៃយើងយាងទៅទីនោះ។ សាវ័កថូម៉ាស នៅគ្រានោះ ហាក់ដូចជាបានអត់ធ្មត់នឹងគ្រោះភ័យរបស់ពួកគេ។ ទោះជាយ៉ាង ព្រះយេស៊ូវបានលើកទឹកចិត្តគេ ថានឹងគ្មានអ្វីបង្កជាគ្រោះថ្នាក់ដលគេទេដរាបណាពេលវេលាកំណត់របស់គេមិនទាន់មកដល់។

ការប្រោសឡាសារគឺជាកិច្ចការចុងក្រោយនៃការអស្ចារ្យរបស់ព្រះយេស៊ូវដែលមិនអាចឲ្យសាសន៍យូដាទប់កំហឹងតទៅទៀតបាន។ ពេលនេះពួកគេត្រៀមចិត្តជាស្រេចនឹងចាប់ទ្រង់។ គេត្រូវតែសម្លាប់ព្រះគ្រីស្ទ។ ការបដិសេធន៍សេចក្តីពិតបែបនេះគឺមិនមែនជាការភ្ញាក់ផ្អើលនោះទេនៅពេលយើងឮពាក្យលោកអ័ប្រាហាំនិយាយទៅអ្នកមាននៅក្នុង

ឋាននរក «បើគេមិនព្រមស្តាប់លោកម៉ូសេ នឹងពួកហោរាទេ នោះទោះ បើមានអ្នកណារស់ពីស្លាប់ឡើងវិញក៏ដោយ គង់តែគេមិនព្រមជឿដែរ» (លូកា ១៦:៣១)។

ប៉ុន្តែចំពោះអ្នកជឿដែលបានស្លាប់និងអ្នកនៅរស់ ព្រះយេស៊ូវគឺជាសេចក្តីរស់ឡើងវិញនិងជាជីវិត។

**ការពិចារណា៖** *«តែយើងដឹងថា គ្រប់ការទាំងអស់ផ្សំគ្នា សម្រាប់សេចក្តីល្អដល់ពួកអ្នកដែលស្រឡាញ់ព្រះ គឺដល់ពួកអ្នកដែលទ្រង់ហៅមកតាមព្រះតម្រិះទ្រង់»* (រ៉ូម ៨:២៨)។
**ការអធិស្ឋាន៖** ឱព្រះវរបិតាអើយ សូមអរព្រះគុណទ្រង់ដែលព្រះយេស៊ូវជាសេចក្តីរស់ឡើងវិញ។

## ឱភូមិបេថានី ជាលំនៅដ្ឋានដ៏ពីកាយរបស់ខ្ញុំអើយ!

ផ្ទះភូមិបេថានីជាទីអាស្រ័យរបស់ព្រះអម្ចាស់នៃយើងស្ថិតនៅពាក់កណ្តាលផ្លូវទៅទីក្រុងយេរូសាឡឹមស្រាប់តែមានបញ្ហាភ្លាមៗកើតឡើង។ ឡាសារបានឈឺហើយនឹងត្រូវស្លាប់។ អ្នកដែលជាម្ចាស់ផ្ទះប្រុសនិងម្ចាស់ផ្ទះស្រីរបស់ព្រះអម្ចាស់នៃយើងពេលនេះមានទំនុកចិត្តក្នុងការស្វែងរកជំនួយនាគ្រាមានអាសន្ន។ «បងប្អូនស្រី២នាក់នោះ ក៏ចាត់គេឲ្យទៅឯព្រះយេស៊ូវ ទូលថា ព្រះអម្ចាស់អើយ មើល អ្នកដែលទ្រង់ស្រឡាញ់នោះគាត់ឈឺ» (ខ៣)។

មានសុភាសិតចិនមួយបានពោលថា៖ «បើអ្នកគ្មានភ្ញៀវនៅស្រុកកំណើត អ្នកក៏គ្មានម្ចាស់ផ្ទះណាទទួលអ្នកនៅស្រុកក្រៅដែរ»។ សាវ័កបានលើកទឹកចិត្តគ្រីស្ទបរិស័ទជនជាតិហេព្រើរឲ្យមានបដិសណ្ឋារកិច្ច។ «កុំឲ្យភ្លេចសេចក្តីចៅរ៉ៅឡើយ ដ្បិតមនុស្សខ្លះបានទទួលទាំងទេវតា ឲ្យសំណាក់នៅឥតដឹងផង ដោយសេចក្តីនោះឯង» (ហេព្រើរ ១៣:២)។ ចុះសំខាន់ប៉ុណ្ណាសម្រាប់គ្រីស្ទបរិស័ទទទួលរាក់ទាក់ព្រះអម្ចាស់ ជាមហាទេវតា! ពិតជាកិត្តិយសនិងជាព្រះពរដ៏ធំដែលហូរពីការទទួលស្វាគមន៍រាក់ទាក់នោះមែន។ បើអ្នកបានរស់នៅដោយភាពជិតស្និទ្ធជាមួយព្រះអម្ចាស់យេស៊ូវគ្រីស្ទ បើអ្នកបានបម្រើការងារសម្រាប់បុព្វហេតុរបស់ទ្រង់ បើអ្នកបានបម្រើពួកជំនុំរបស់ទ្រង់យ៉ាងស្មោះត្រង់និងត្រឹមត្រូវ ការអធិស្ឋានរបស់អ្នកទូលសូមឲ្យទ្រង់ជួយនាគ្រាមានអាសន្ននឹងឮដល់ទ្រង់ជាមិនខាន។ នាងម៉ាថាម្នាក់នេះបានព្យាយាមបំពេញកិច្ចការជាស្ត្រីរបស់នាងដោយការចំអិនអាហារឆ្ងាញ់ៗថ្វាយដល់ព្រះអម្ចាស់។ នៅក្នុងករណីបែបនេះ បងប្អូនស្ត្រីនៃពួកជំនុំរបស់យើងដែលជាអ្នកចាត់ចែងការងារផ្ទះបាយគឺបានទទួលព្រះពរបើពួកគាត់បម្រើព្រះអង្គដោយក្តីស្រឡាញ់ និងមិនមែនដោយព្រោះតែមូលហេតុផ្សេង។ នៅក្នុងន័យនេះផងដែរ ស្ត្រីនៃពួកជំនុំរបស់យើងដែលមកចូលរួមសិក្សាព្រះគម្ពីរ គឺដូចជានាងម៉ារាដែលកំពុងអង្គុយនៅទៀបព្រះបាតរបស់ព្រះយេស៊ូវ ពួកគាត់បានជ្រើសយកចំណែកដ៏ល្អដែលគ្មានអ្នកណាយកពីពួកគាត់បាន (លូកា ១០:៣៨-៤២)។

ឱភូមិបេថានី ជាលំនៅដ្ឋានដ៏ពីកាយខ្ញុំអើយ! ទីនោះហើយព្រះអម្ចាស់ខ្ញុំស្នាក់អាស្រ័យ។
ទោះបើខ្ញុំនេះជាមនុស្សគ្មានតំលៃ តែព្រះអង្គថ្លៃបានអត់បាបដោយព្រះគុណ។
ពិតជាព្រះពរដ៏ច្រើនក្រៃអង្គុយនៅជិតទៀបព្រះបាត តើចំណែកនេះអ្នកណាអាចឆក់ពីខ្ញុំបាន?
ឱភូមិបេថានី ជាលំនៅដ្ឋានដ៏ពីកាយរបស់ខ្ញុំអើយ! កន្លែងនេះហើយដែលព្រះប្រកបគ្នានឹងមនុស្ស
បន្ទុកបាបខ្ញុំធ្ងន់ទ្រង់ស៊ូរងជួស ទឹកភ្នែកហូរដូចទន្លេនិងទុក្ខសោកគ្មានទៀតឡើយ។
ព្រោះព្រះយេស៊ូវជាលំនៅដ្ឋានដ៏ពីកាយរបស់ខ្ញុំ រៀងរាល់ថ្ងៃខ្ញុំត្រូវជួបទ្រង់។
ក្តីស្រឡាញ់របស់ទ្រង់គង់វង្សស្ថិតស្ថេរ ទ្រង់នាំមកជីវិតដ៏គ្មានក្តីភិតភ័យ។
ក្តីស្រឡាញ់របស់ទ្រង់គង់វង្សស្ថិតស្ថេរ ខ្ញុំនឹងទៅជាមួយទ្រង់រៀងរាបដរាប។

*បកប្រែពីសៀវភៅចំរៀងសរសើរដំកើង ហ៊ិវិនលី ភីផលស៏ ខរីសៃ* ( Heavenly People’s Choruses )

**ការពិចារណា៖** «*កុំឲ្យភ្លេចសេចក្តីចៅរ៉ៅឡើយ...*» (ហេព្រើរ ១៣:២)។
**ការអធិស្ឋាន៖** ឱសូមឲ្យខ្ញុំរៀនពីកិច្ចបម្រើគ្នាទៅវិញទៅមកក្នុងរូបកាយរបស់ទ្រង់ដោយក្តីស្រឡាញ់ផង។

*«...សូមឲ្យព្រះហឫទ័យទ្រង់បានសម្រេចនៅផែនដី ដូចនៅស្ថានសួគ៌ដែរ» (ម៉ាថាយ ៦:៩)។*

## ការអធិស្ឋានគ្មានចម្លើយ?

តើហេតុអ្វីបានជាព្រះយេស៊ូវមិនរួសរាន់ទៅកន្លែងមានបញ្ហា? តើលោកឡាសារមិនមែនកំពុងតែជិតស្លាប់ទេឬអី? ព្រះអង្គមិនចាំបាច់រួសរាន់ទៅកន្លែងនោះឡើយ។ ទ្រង់ក៏អាចគ្រាន់តែមានបន្ទូលមួយពាក្យដូចកាលទ្រង់បានធ្វើពីគ្រាមុនក្នុងការប្រោសកូនប្រុសនាម៉ឺនម្នាក់នៅស្រុកកាពើណិមដែរ (យ៉ូហាន ៤:៤៦-៥៤)។ គ្រាន់តែមានបន្ទូលបែបនោះក៏ទ្រង់ឥតបានមានបន្ទូល។ ព្រះអង្គបានជ្រើសយកការពន្យាពេលនៃយាងមករបស់ទ្រង់។ «នោះទ្រង់ក៏គង់នៅកន្លែងដដែល ២ថ្ងៃទៀត» (ខ ៦)។

ព្រះអង្គធ្វើបែបនេះមិនមែនព្រោះទ្រង់ខ្លាចដូចជាពួកសាវ័កដែលរីករាយចិត្តក្នុងការពន្យាពេលនោះឡើយ។ ពួកសិស្សបានសម្ដែងនូវការយកចិត្តនៅពេលទីបំផុតព្រះអម្ចាស់មានបន្ទូលថា៖ «ចូរយើងត្រឡប់ទៅឯស្រុកយូដាវិញ» (ខ ៧)។ គេបានជំទាស់ថា៖ «លោកគ្រូ ពួកសាសន៍យូដាទើបនឹងរកចោលលោកនឹងដុំថ្មពីមុននោះ ដូច្នេះ លោកគិតទៅឯណោះទៀតឬ?» (ខ ៨)។

ចម្លើយរបស់ព្រះយេស៊ូវគឺជាចម្លើយមួយអំពីក្ដីទំនុកចិត្តនិងការធានា។ ព្រះយេស៊ូវជឿលើការកំណត់ពេលវេលានៃព្រះជាម្ចាស់។ ព្រះអង្គឥតភ័យញញើតនឹងប្រឈមមុខនឹងគ្រោះថ្នាក់ដោយផ្ទាល់ឡើយ។ បើវេលារបស់ទ្រង់មិនទាន់មកដល់ ទ្រង់នឹងមានសុវត្ថិភាព។ ដូចនេះព្រះយេស៊ូវបានពន្យាពេលទៅទីកន្លែង (មានបញ្ហា) មិនមែនព្រោះតែគ្រោះថ្នាក់រងចាំទ្រង់ឡើយ។

ការពន្យាពេលរបស់ព្រះយេស៊ូវ ដែលហាក់ដូចជានាំមកនូវការអធិស្ឋានដែលគ្មានចម្លើយ គឺដើម្បីឲ្យសិរីល្អនៃព្រះជាម្ចាស់ «គឺសំរាប់ជាកិត្តិសព្ទដល់ព្រះវិញ» (ខ ៤)។ ការពន្យាពេលរបស់ព្រះយេស៊ូវជាការផ្ដល់នូវពេកលសម្រាកបន្តិចបន្តួចដល់ពួកសិស្សដែលភ័យខ្លាច បង្ហាញពីគំនិតនិងចេតនានៃចិត្តរបស់យើង។ បើពិនិត្យមើលសាវ័កថូម៉ាសគាត់ហាក់ដូចជាមានអត្តចរិកអត់ធ្មត់។ គាត់បាននិយាយទៅកាន់សិស្សឯទៀតជាមិត្តសំឡាញ់ថា៖ «ចូរយើងរាល់គ្នាទៅដែរ ដើម្បីនឹងប្ដូរស្លាប់ជាមួយនឹងលោក» (ខ ១៦)។

ការពន្យាពេលរបស់ព្រះយេស៊ូវ ពិតជាមិនមែនជាការអធិស្ឋានដែលគ្មានចម្លើយនោះទេ។ វាក៏មិនត្រឹមសម្រាប់កិត្តិសព្ទរបស់ព្រះប៉ុណ្ណោះដែរ គឺវាសម្រាប់ប្រយោជន៍របស់មនុស្សគ្រប់រូបដែលទ្រង់ស្រឡាញ់ផងដែរ។ សេចក្ដីសន្និដ្ឋាននៅវគ្គនេះគឺត្រូវបានសង្ខេបនៅក្នុងខទី១៥ «ខ្ញុំក៏អរណាស់ ដោយយល់ដល់អ្នករាល់គ្នា ព្រោះខ្ញុំមិនបានទៅឯណោះដើម្បីឲ្យអ្នករាល់គ្នាបានជឿ...»។ ពាក្យថា «អ្នករាល់គ្នា» រួមទាំង «ពួកសាសន៍យូដាដែលមកតាមនាងម៉ារាបានឃើញការដែលព្រះយេស៊ូវធ្វើ» នៃខ៤៥ ដូចជាមិត្តសំឡាញ់នៃភូមិបេថានីជាលំនៅដ្ឋានដ៏រីករាយផងដែរ។

នៅពេលអ្វីៗមិនបានមកដូចបំណង សូមកុំកើតទុក្ខសៅហ្មង! សូមអង្គុយដូចជានាងម៉ារា។ សូមកុំម៉ីម្នាដូចជានាងម៉ាថា។ តើអ្នកអាចច្រៀងបទចម្រៀងនេះបានដែរឬទេ?

*ខ្ញុំច្រៀងកាលឃើញផ្លូវដាក់ច្បាស់ កាលងងឹត..នោះ អធិស្ឋាន...*
*បើមានអ្វីនាំឲ្យភ័យណាស់ នោះទុកចិត្តព្រះអង្គក៏បាន*
*កំពុង..ពេលវេលា..កន្លង.. នៅថ្ងៃ ខែ ទៅមុខ ជាយូរ*
*មិនថាកើតអ្វីតាមផ្លូវផង មានតែទុកចិត្តព្រះយេស៊ូវ។ (ចម្រៀងទំនុកដំកើង ៨៣ ខ ៣)*

**ការពិចារណា៖** *ចូរអធិស្ឋានឥតឈប់ឈរ!*

**ការអធិស្ឋាន៖** ព្រះអម្ចាស់អើយ សូមប្រទានជំនឿដល់ការអធិស្ឋានរបស់យើងខ្ញុំផង។

ថ្ងៃទី ១២ កញ្ញា
យ៉ូហាន ១១:១៧-៣៧

*«ព្រះពរព្រះអម្ចាស់ ខ្ញុំម្ចាស់ជឿហើយ ទ្រង់ជាព្រះគ្រីស្ទ គឺជាព្រះរាជបុត្រានៃព្រះ ដែលត្រូវយាងមកក្នុងលោកីយមែន»*

## «ជំនឿគ្មានបទពិសោធន៍ ជំនឿមានបទពិសោធន៍ ជំនឿដែលមិនត្រូវការបទពិសោធន៍»

ជំហានទាំងបីដំណាក់ការនៃការរីកចម្រើនសេចក្តីជំនឿ ដូចបណ្ឌិត ជា យូ មីង (*Dr. Chia Yu-Ming*) ជាអ្នកទេវសាស្ត្រដ៏ល្បីល្បាញរបស់ប្រទេសចិនបានបញ្ជាក់យ៉ាងច្បាស់ គឺអាចនឹងឃើញនៅក្នុងការស្វែងរករបស់នាងម៉ាថា។ នាងម៉ាថាដើរតាមព្រះអម្ចាស់នៃយើងនិងបានឃើញកិច្ចការអស្ចារ្យជាច្រើនរបស់ទ្រង់។ បើនាងមិនបានឃើញនូវការអស្ចារ្យទាំងឡាយដូចជាអ្នកឯទៀតបានឃើញក៏នាងនៅតែជឿលើកិច្ចការទាំងនោះដែរ។ ជឿនោះនឹងបានឃើញ!

ប្រាកដណាស់ មកដល់ពេលនេះនាងបានដឹងថាព្រះយេស៊ូវបានប្រោសបុរសជម្ងឺស្វិតដៃជើង៣៨ឆ្នាំ ពីការទ្រង់បានប្រោសភ្នែកយុវជនពិការពីកំណើតដោយបង្គាប់ឲ្យគាត់ទៅលាងសម្អាតនៅឯស្រះទឹកស៊ីឡោម។ ហើយនាងក៏អាចដឹងពីកូនស្រីលោកយ៉ៃរុសនិងកូនប្រុសរបស់ស្ត្រីមេម៉ាយជាអ្នកស្រុកណាអ៊ីនដែរ។ ក៏ប៉ុន្តែឥឡូវនេះប្រុសបង្កើតរបស់នាងបានស្លាប់ចំនួនបួនថ្ងៃមកហើយ។ តើព្រះយេស៊ូវអាចប្រោសឲ្យគាត់រស់ឡើងវិញបានដែរឬទេ?

ក្នុងករណីប្អូនប្រុសនាង ជំនឿរបស់នាងលើសមត្ថភាពនៃព្រះអម្ចាស់ប្រោសឲ្យគាត់រស់ឡើងវិញគឺជាជំនឿដែលបណ្ឌិត ជា យូ មីង ហៅថាជំនឿគ្មានបទពិសោធន៍។ នេះគឺបានឆ្លុះបញ្ចាំងឲ្យឃើញនៅក្នុងខ២៤ «ខ្ញុំដឹងថា នៅថ្ងៃចុងបំផុត កាលណាមនុស្សត្រូវរស់ពីស្លាប់ឡើងវិញ នោះប្អូនខ្ញុំម្ចាស់នឹងរស់ឡើងដែ»។ នៅពេលព្រះយេស៊ូវ បង្គាប់ឲ្យយកថ្មចេញ ជំនឿគ្មានបទពិសោធន៍របស់នាងម៉ាថាបានបន្លឺឡើងម្តងទៀតថា៖ «ព្រះអម្ចាស់អើយ ខ្មោច នេះ ធុំក្លិនហើយ ព្រោះស្លាប់កន្លងមកបាន៤ថ្ងៃ» (ខ ៣៧)។ ជំនឿគ្មានបទពិសោធន៍ស្ទាក់ស្ទើរនឹងសេចក្តីពិតនេះ។ នាងម៉ាថាមិនធ្លាប់ដែលឃើញមនុស្សស្លាប់បួនថ្ងៃត្រូវបានប្រោសឲ្យរស់ឡើងវិញឡើយ។

នៅពេលព្រះយេស៊ូវបានបន្លឺព្រះឱស្ឋឡើងដើម្បីប្រោសឡាសារ ការបន្លឺព្រះឱស្ឋនោះក៏បានប្រោសជំនឿលិចលង់របស់នាងម៉ាថាដែរ។ ឥឡូវនេះនាងបានឃើញផ្ទាល់ភ្នែក នាងក៏ជឿដូចជាអ្នកដទៃទៀតដែរ (ខ ៤៥)។ ជំនឿលើព្រះចេស្តារបស់ព្រះអម្ចាស់ប្រោសពួកអ្នកស្លាប់នាថ្ងៃចុងក្រោយត្រូវបានបញ្ជាក់ជាទ្វេរដង។ ជំនឿមានបទពិសោធន៍!

នៅក្នុងជំពូកបន្ទាប់សម្តែងប្រាប់ពីទីកន្លែងឡាសារដែលត្រូវបានប្រោសឲ្យរស់ពីស្លាប់កំពុងអង្គុយនៅតុជាមួយព្រះអម្ចាស់និងព្រះសង្គ្រោះរបស់គាត់ ហើយនាងម៉ាថាដែលរវល់នឹងការបម្រើ មកដល់ពេលនេះគាត់មានទំនុកចិត្តទាំងស្រុង បើប្រៀបធៀបនឹងចិត្តដ៏រន្ធត់ញាប់ញ័ររបស់នាងមុនព្រឹត្តិការណ៍ប្រោសឡាសារពីស្លាប់។ ពេលនេះនាងអាចនិយាយដោយទំនុកចិត្តមិនដូចជាពីគ្រាមុនទេឡើយ «ព្រះពរព្រះអម្ចាស់ ខ្ញុំម្ចាស់ជឿហើយ ទ្រង់ជាព្រះគ្រីស្ទ គឺជាព្រះរាជបុត្រានៃព្រះ ដែលត្រូវយាងមកក្នុងលោកីយមែន» (ខ ២៧)។ ជំនឿដែលមិនត្រូវការបទពិសោធន៍!

អ្វីដែលយើងត្រូវការគឺជាជំនឿមានបទពិសោធន៍ដែលនឹងរីកចម្រើនទៅរកជំនឿដែលមិនត្រូវការបទពិសោធន៍។ សូមអានព្រះគម្ពីរជារៀងរាល់ថ្ងៃ។ ព្រះគម្ពីរជាជំនឿមានបទពិសោធន៍ដែលនឹងពង្រឹងយើងដើម្បីឲ្យសេចក្តីជំនឿ នឹងឈប់ត្រូវការបទពិសោធន៍។

**ការពិចារណា៖** «ឯអ្នកណាដែលរស់នៅ ហើយជឿដល់ខ្ញុំ នោះមិនត្រូវស្លាប់ឡើយ..» (យ៉ូហាន ១១:២៦)។
**ការអធិស្ឋាន៖** ឱព្រះអង្គអើយ សូមទ្រង់ចងចាំខ្ញុំនាថ្ងៃដែលទ្រង់យាងមកផង (១ ថែស្សាឡូនីច ៤:១៣-១៨)។

## ការសន្សំសំចៃនៃការអស្ចារ្យ

តើអ្នកចាំនូវអ្វីដែលបានកើតឡើងបន្ទាប់ពីការប្រទានអាហារដល់មនុស្សទាំងប្រាំពាន់នាក់ដែរទេ? ព្រះយេស៊ូវបានបង្គាប់ដល់ពួកសិស្សថា៖ «ចូរប្រមូលចំណិតដែលសល់នៅ ដើម្បីកុំឲ្យបាត់អ្វីឡើយ» (យ៉ូហាន ៦:១២)។ នេះគឺជាគោលការណ៍ដ៏មានសារៈសំខាន់អំពីការអស្ចារ្យ ពោលគឺជាការសន្សំសំចៃនៃការអស្ចារ្យ។

សូមចងចាំផងដែរនូវពាក្យដកស្រង់របស់លោកគ្រូ ចន ស៊ុងអំពីសុភាសិតនៃគ្រីស្ទបរិស័ទក្រុងប៉េកាំងដែលពោលថា៖ «នៅពេលអ្នកឈឺស្រាល ចូរទៅជួបគ្រូពេទ្យ នៅពេលអ្នកឈឺធ្ងន់ពន់ពេក អ្នកត្រូវទៅជួបព្រះយេស៊ូវ»។ នេះក៏សម្តែងប្រាប់ពីគោលការណ៍ដ៏មានសារៈសំខាន់ពីការសន្សំសំចៃនៃការអស្ចារ្យដែរ។

នោះមានន័យថា កិច្ចការដែលយើងអាចធ្វើ នោះយើងត្រូវតែធ្វើ។ កិច្ចការដែលយើងមិនអាចធ្វើ ព្រះយេស៊ូវទ្រង់នឹងធ្វើ។ ចូរកត់សម្គាល់ពីករណីប្រោសឡាសារ ព្រះយេស៊ូវបានបន្លឺហៅយ៉ាងឮដើម្បីសម្តែងការអស្ចារ្យ។ តែព្រះអង្គមិនបានមានបន្ទូលប្រាប់ឲ្យថ្មរមៀលចេញដោយខ្លួនឯងទេ ទ្រង់ក៏មិនបានបង្គាប់ឲ្យក្រណាត់រុំសាកសពនិងកន្សែងគ្របមុខរបូតដោយការបន្លឺសម្លេងម្តងទៀតដែរ។ ទ្រង់បង្គាប់ឲ្យមនុស្សដែលត្រូវធ្វើការនោះធ្វើវិញ។

បច្ចុប្បន្ន ព្រះជាម្ចាស់បានប្រទានដល់យើងនូវឱសថនិងការវះកាត់ដ៏ទាន់សម័យ។ សេវាកម្មសុខភាពមានសន្ទុះជឿនលឿនដ៏ខ្លាំងក្លា ដូចនេះជម្ងឺរបេងនិងជម្ងឺរលាកផ្លូវដង្ហើមអាចនឹងទទួលការព្យាបាលឲ្យជាសះស្បើយបាន ហើយភ្នែកអាចបើកឲ្យមើលឃើញដោយកាំបិតរបស់គ្រូពេទ្យវះកាត់ផងដែរ។ ការមិនស្វែងរកការព្យាបាលពីគ្រូពេទ្យឯកទេសនៅក្នុងវិជ្ជាជីវៈរបស់គេ តែបែរជាពឹងផ្អែកលើគ្រូប្រោសជម្ងឺដោយជំនឿគឺជាការប្រើប្រាស់សេដ្ឋកិច្ចរបស់ព្រះដោយមិនត្រឹមត្រូវ។ ការមិនញុំាថ្នាំអាស្ពីរីនពីរគ្រាប់ហើយអរគុណដល់ព្រះសម្រាប់ថ្នាំនោះដូចជាអ្នកអរគុណមុនពេលបរិភោគអាហារ តែបែរជាស្វែងរកគ្រូប្រោសជម្ងឺដោយជំនឿឲ្យព្យាបាលរោគឈឺក្បាលរបស់អ្នកគឺជាទង្វើបរិសុទ្ធល្ងីល្ងើ។

នៅក្នុងប្រទេសអាមេរិកមានគ្រូផ្សព្វផ្សាយដំណឹងល្អជាច្រើននាក់ដែលព្យាយាមចាប់សត្វពស់ពិតប្រាកដហើយផឹកពិសរបស់វាដើម្បីអួតពីជំនឿរបស់ពួកគេ។ មានគ្រូផ្សាយដំណឹងល្អម្នាក់ថែមទាំងបានព្យាយាមប្រោសសាកសពម្តាយបង្កើតខ្លួនទៀតផង ព្រោះគាត់បានអះអាងថាព្រះយេស៊ូវបានបង្គាប់ពួកសិស្សរបស់ទ្រង់ឲ្យប្រោសមនុស្សស្លាប់។ គ្រូផ្សាយដំណឹងល្អរូបនេះបានអធិស្ឋាននិងបង្ហូរញើសយ៉ាងអស់ពីកំឡាំងកាយចិត្តរបស់គាត់ដើម្បីប្រោសម្តាយខ្លួនពីស្លាប់ឡើងវិញ តែគ្មានលទ្ធផលសោះឡើយ។ នេះគឺជាទង្វើបរិសុទ្ធដ៏ល្ងីល្ងើបូកនឹងភាពក្លាហានជ្រុលហួស។

ខណៈពេលយើងអរគុណដល់ព្រះជាម្ចាស់សម្រាប់ឱសថនិងសេវាកម្មវះកាត់ដ៏ទំនើប យើងក៏មិនគួរធ្វេសប្រហែសនូវការអធិស្ឋានដ៏យកចិត្តទុកដាក់ដែរ។ យើងក៏ជឿលើការព្យាបាលដោយជំនឿដែរ តែជាប្រភេទប្រោសជម្ងឺក្នុងភាពជាដៃគូរវាងព្រះនិងមនុស្ស។ បេសកជនគ្រួសត្រាយដែលកំពុងបម្រើការនៅជួរមុខនៃបណ្តាភូមិនានាមិនត្រឹមតែអធិស្ឋានសម្រាប់អ្នកជម្ងឺទេតែក៏បានប្រើថ្នាំពេទ្យនិងសាពុំាងចាក់ថ្នាំ ហើយនិងរថយន្តឡង់រ៉ូវើរបស់គាត់ដឹកអ្នកឈឺទៅកាន់មន្ទីរពេទ្យដែរ។ នេះគឺជាការសម្តែងនូវការសន្សំសំចៃនៃការអស្ចារ្យ ដោយការអនុញ្ញាតឲ្យព្រះជាម្ចាស់ធ្វើកិច្ចការដែលយើងធ្វើមិនបាន និងធ្វើកិច្ចការណាដែលយើងអាចធ្វើបាន។

**ការពិចារណា៖** គ្មានការអ្វីដែលព្រះទ្រង់ធ្វើមិនបានឡើយ!

**ការអធិស្ឋាន៖** ព្រះអម្ចាស់អើយ សូមប្រទានឪកាសឲ្យខ្ញុំបម្រើក្នុងកិច្ចការអស្ចារ្យដែលទ្រង់ធ្វើផង។

ថ្ងៃទី ១៤ កញ្ញា
យ៉ូហាន ១១:៣១-៣៦ *«ព្រះយេស៊ូវក៏ទ្រង់ព្រះកន្សែង»។*

## ទឹកភ្នែកនៃក្តីស្រឡាញ់របស់គ្រីស្ទបរិស័ទ

សាសន៍យូដាជាច្រើននាក់បានមកជួយរំលែកទុក្ខនាងម៉ាថានិងម៉ារានៅពេលប្អូនប្រុសរបស់ពួកនាងស្លាប់។ ទស្សនីយ៍ភាពនោះហាក់ដូចជាគំនូរមួយផ្ទាំងពីភាពស្ងប់ស្ងាត់រហូតដល់ពេលព្រះយេស៊ូវយាងមកដល់។ បន្ទាប់មកទឹកភ្នែកដែលមិនទប់ទុកជាយូរក៏ផ្ទុះចេញដូចជាចរន្តទឹកពីភ្នែករបស់នាងម៉ារានាពេលនាងឃើញទ្រង់។ នេះនាំឲ្យមានការយំសោកក្នុងបណ្តាពួកសាសន៍យូដា ហើយក៏ជាហេតុធ្វើឲ្យព្រះអម្ចាស់ ព្រះកន្សែង (យំ) ដែរ។ ទឹកភ្នែកនៃការអាណិតអាសូរ។ ទឹកភ្នែកនៃសេចក្តីស្រឡាញ់។

គ្មានអំណាចនៅលើផែនដីណាមួយដែលធំជាអំណាចនៃក្តីស្រឡាញ់ឡើយ។ សេចក្តីស្រឡាញ់អាចរំលាយចិត្តដ៏រឹងដូចដែកថែបដែលគ្រាប់រំសេវមិនអាចបបែកបាន។

ក្នុងការប្រោសឡាសារពីស្លាប់យើងមិនត្រឹមតែអាចរៀននូវមេរៀនបែបសេចក្តីជំនឿនោះឡើយ។ ឥឡូវនេះយើងក៏រៀននូវមេរៀនបែបក្តីស្រឡាញ់ គឺជាសេចក្តីស្រឡាញ់នៃគ្រីស្ទបរិស័ទផងដែរ។ សេចក្តីស្រឡាញ់របស់បងស្រីចំពោះប្អូនប្រុសគឺជាសេចក្តីស្រឡាញ់ចំពោះគ្នាទៅវិញទៅមកក្នុងភាពជាបងប្អូន។ សេចក្តីស្រឡាញ់របស់បងស្រីក្នុងព្រះគ្រីស្ទសម្រាប់ប្អូនប្រុសក្នុងព្រះគ្រីស្ទគឺជាសេចក្តីដ៏ពិសេសអស្ចារ្យ។ នៅពេលបីនាក់ប្អូនជាអ្នកភូមិបេថានីជឿលើព្រះអម្ចាស់ យើងឃើញមានសកម្មភាពនៃសេចក្តីស្រឡាញ់ពីរផ្នែកនៅក្នុងនោះ។

យើងក៏ឃើញពីការដែលនាងម៉ារាស្រឡាញ់ព្រះអម្ចាស់នាងនិងពីការដែលព្រះយេស៊ូវស្រឡាញ់នាង ជាកូនចៀមក្នុងបណ្តាកូនចៀមជាច្រើនដែលលោះដោយព្រះលោហិតរបស់ទ្រង់ដែរ។ ចូរសម្គាល់នូវពាក្យដែលនាងម៉ាថាបាននិយាយទៅកាន់នាងម៉ារាខណៈពេលនាងមកដល់ផ្ទះក្រោយពីបានជួបព្រះយេស៊ូវនៅតាមផ្លូវ។ «លោកគ្រូអញ្ជើញមកដល់ហើយ **លោកហៅរកឯង**» (ខ ២៨)។ សេចក្តី ស្រឡាញ់ដូចគ្នានៃអ្នកគង្វាលចំពោះចៀមវង្វេងរបស់ទ្រង់គឺឃើញនៅក្នុងកំណត់ត្រានៃដំណឹងល្អម៉ាកុសត្រង់ចំណុចដែលទេវតាបាននិយាយទៅកាន់ស្ត្រីថា៖ «ចូរអ្នករាល់គ្នាទៅប្រាប់ពួកសិស្សទ្រង់ **ព្រមទាំងពេត្រុសផង**...» (ម៉ាកុស ១៦:៧)។

នេះគឺជាមេរៀនពីរបៀបជួយកំសាន្តចិត្តអ្នកកាន់ទុក្ខ។ មិនមែនតាមរយៈពាក្យសម្តីទេ តែតាមរយៈទឹកភ្នែកវិញ។ ទឹកភ្នែកនៃក្តីស្រឡាញ់របស់គ្រីស្ទបរិស័ទ។ ដូចនេះ យើងមានពាក្យណែនាំពីសាវ័កប៉ុលថា «ចូរអរសប្បាយ ជាមួយនឹងអ្នកណាដែលអរសប្បាយ ហើយយំ ជាមួយនឹងអ្នកណាដែលយំផង។ ចូរឲ្យមានគំនិតព្រមព្រៀងគ្នាទៅវិញទៅមក...» (រ៉ូម ១២:១៥-១៦)។

*មានពរហើយចំណង.. ដែលចងចិត្ត ជាប់ដោយស្រឡាញ់នៃពួកគ្រីស្ទាន*
*ជាការប្រកប..គ្នានៃចិត្តដែលព្រះទ្រង់សណ្ឋិត នោះដូចជានៅស្ថានសួគ៌វិមាន..។*
*យើងខ្ញុំទទួល.. រងទុក្ខផងគ្នា ក៏ទ្រាំទ្របន្ទុក..នៃគ្នាផង*
*ទាំងមានទឹកភ្នែកហូរញើកញយក្នុងកាលវេទនា ដោយចិត្តអាណិតអាសូរស្មោះត្រង់។ (ចម្រៀងទំនុកដំកើង ៣១)។*

**ការពិចារណា៖** ទឹកភ្នែកគឺសម្រាប់ឲ្យចេះអាណិតអ្នកដទៃដូចជាព្រះជាម្ចាស់អាណិតអាសូរដល់យើង។
**ការអធិស្ឋាន៖** សូមឲ្យយើងនឹកចាំអ្នកដែលទុក្ខវេទនាក្នុងការអធិស្ឋានប្រចាំថ្ងៃរបស់ខ្ញុំផង។

ថ្ងៃទី ១៥ កញ្ញា
យ៉ូហាន ១១:៤៧-៥៧

*«បើមានមនុស្សម្នាក់ស្លាប់ជំនួសបណ្ដាជន នោះមានប្រយោជន៍ដល់អ្នករាល់គ្នាជាង...»។*

## ព្រះរាជបុត្រានៃព្រះត្រូវតែសុគតជំនួសបទឧក្រិដ្ឋរបស់គេ!

ការអស្ចារ្យដ៏មហាអស្ចារ្យនេះដាស់ឲ្យភ្ញាក់ពីអំណាចឆ្កួតលីលានៃពួកអ្នកដឹកនាំសាសន៍យូដាឲ្យមានការប្រជុំក្រុមប្រឹក្សាភ្លាមៗ។ សម្ដេចសង្ឃនិងពួកគណៈផារីស៊ីបានពិគ្រោះគ្នាថា៖ «តើយើងត្រូវធ្វើដូម្ដេច ព្រោះមនុស្សនេះធ្វើទីសំគាល់ច្រើនណាស់? បើទុកឲ្យធ្វើតែយ៉ាងដូច្នេះទៅ នោះមុខជាមនុស្សទាំងអស់នឹងជឿតាមវាហើយ រួចសាសន៍រ៉ូមនឹងមកចាប់យកទាំងស្រុក នឹងជាតិយើងផង» (ខ ៤៨)។

លោកកាល់វិនធ្វើអត្ថាធិប្បាយថា៖ «អាវផាយ (ដែលមើលពីដំបូងហាក់ដូចជាល្អ) បិទបាំងឆន្ទៈអាក្រក់ដែលក្លែងបន្លំធ្វើសម្រាប់ប្រយោជន៍សារធារណៈ។ ការព្រួយបារម្ភនិងការភ័យខ្លាចដ៏ធំរបស់គេគឺអំណាចផ្ដាច់ការនឹងត្រូវបំផ្លាញ ប៉ុន្តែគេពុតជាព្រួយបារម្ភពីព្រះវិហារនិងការថ្វាយបង្គំព្រះជាម្ចាស់ ហើយនិងពីកិត្តិស័ព្ទជាតិនិងស្ថានភាពរបស់ប្រជាជន»។

ក្រោយមកកៃផាជាសម្ដេចសង្ឃនៅឆ្នាំនោះ លោកបានមានប្រសាសន៍ថា៖ «អ្នករាល់គ្នាមិនដឹងអ្វីសោះ ក៏មិនគិតពិចារណាឃើញថា បើមានមនុស្សម្នាក់ស្លាប់ជំនួសបណ្ដាជន នោះមានប្រយោជន៍ ដល់អ្នករាល់គ្នាជាង ដើម្បីកុំឲ្យជាតិយើងនេះត្រូវវិនាសទាំងអស់ឡើយ» (ខ ៤៩-៥០)។ ដំណោះស្រាយសម្រាប់បញ្ហាឈ្លានពានរបស់សាសន៍រ៉ូមគ្រប់គ្រងលើពួកអជ្ញាធររបស់គេគឺត្រូវតែមានមនុស្សដែលគ្មានទោសម្នាក់យកមកដាក់ទោសប្រហារជីវិត។

នៅពេលយ៉ូហានមានប្រសាសន៍ថាលោកកៃផាមិននិយាយសេចក្ដីទាំងនោះដោយខ្លួនឯងគាត់ សាវ័កចង់មានន័យស៊ីជម្រៅជាងអំពីការឃុបឃិតរបស់កៃផាសទៅទៀត ពីព្រោះព្រះជាម្ចាស់មានចេតនាធ្វើបន្ទាល់តាមរយៈពាក្យរបស់គាត់ពីសេចក្ដីដ៏ជ្រាលជ្រៅជាងពាក្យដែលចេញមកពីក្នុងចិត្ត។ ក្នុងតួនាទីជាសម្ដេចសង្ឃ លោកកៃផាបានព្យាករណ៍ដោយអចេតនាថាព្រះយេស៊ូវនឹងត្រូវសុគតជាដង្វាយជំនួសប្រជាជាតិ និងលើសជាងនោះទៅទៀត ជំនួសពួកកូនៗរបស់ព្រះដែលនឹងត្រូវប្រមូលផ្ដុំមកពីបណ្ដាប្រជាជាតិដទៃទៀតផងដែរ។

ជាថ្មីម្ដងទៀត មុនពេលកំណត់របស់ព្រះយេស៊ូវមកដល់ ព្រះអង្គបានយាងចេញឆ្ងាយពីការប្រឈមមុខជាមួយពួកសាសន៍យូដា។ ទ្រង់បានយាងចេញទៅដោយស្ងាត់ៗទៅក្រុងមួយដែលគេហៅថាភូមិ អេប្រាអិមស្ថិតក្នុងស្រុកយូដាក្បែរក្រុងសាម៉ារី។ នេះមិនមែនធ្វើឲ្យពួកសាសន៍បន្ថយការតាំងចិត្តសម្លាប់ទ្រង់ឡើយ។ ពីព្រោះនៅពេលព្រះយេស៊ូវយាងទៅឈប់សម្រាក កិត្តិនាមរបស់ទ្រង់បានឮខ្ចរខ្ចាយ ដល់បរទេសរហូតក្លាយទៅជាប្រធានបទពិភាក្សារបស់មហាជនដែលកំពុងធ្វើដំណើរទៅទីក្រុងយេរូសាឡឹមចូលរួមពិធីបុណ្យរំលងចុងក្រោយនៃជីវិតរបស់ទ្រង់។

**ការពិចារណា៖** ព្រះយេស៊ូវគ្រីស្ទជាដង្វាយធួននឹងបាបរបស់មនុស្សជាតិទាំងអស់។
**ការអធិស្ឋាន៖** ព្រះយេស៊ូវអើយ សូមអរព្រះគុណទ្រង់ហើយដែលទ្រង់ជាដង្វាយធួននឹងបាបរបស់យើងខ្ញុំ។

*«...ហើយត្រូវគេធ្វើគុតផង តែក្រោយ៣ថ្ងៃមក ទ្រង់នឹងមានព្រះជន្មរស់ឡើងវិញ» (ម៉ាថាយ ១៦:២១)។*

## ជំពូកទី ១២

### តាមរយៈការសុគតរបស់ទ្រង់មនុស្សជាច្រើននឹងអាចរស់ ដោយសារព្រះយេស៊ូវគ្រីស្ទជាគ្រាប់ពូជនៃជីវិត

នៅក្នុងជំពូកនេះ សាវ័កយ៉ូហាននាំយើងទៅក្នុងសប្តាហ៍បរិសុទ្ធ។ ពេលកំណត់បានមកដល់នៅគ្រាដែលព្រះអម្ចាស់ត្រូវយាងទៅទីក្រុងយេរូសាឡឹមវិញ និងនៅទីនោះ «ហើយត្រូវរងទុក្ខជាច្រើន នៅដៃនៃពួកចាស់ទុំ ពួកសង្គ្រាជ នឹងពួកអាចារ្យ ហើយត្រូវគេធ្វើគុតផង តែក្រោយ៣ថ្ងៃមក ទ្រង់នឹងមានព្រះជន្មរស់ឡើងវិញ» (ម៉ាថាយ ១៦:២១)។

ព្រឹត្តិការណ៍ដ៏រំជួលចិត្តមួយក្នុងបណ្តាព្រឹត្តិការណ៍ជាច្រើនទៀតមុនពេលការសុគតរបស់ទ្រង់គឺការអប់ប្រេងលើរូបកាយទ្រង់ដោយម៉ារាជាអ្នកភូមិបេថានី (ម៉ាថាយ ២៦:៦-១២ ម៉ាកុស ១៥:៣-៩)។ សៀវភៅ*សមោយោគដំណឹងល្អ* និពន្ធដោយលោករីរ៉ា (*Ryrie*) បានដាក់ថ្ងៃអប់ប្រេងត្រូវនឹងថ្ងៃសប្ប័ទ (ថ្ងៃឈប់សម្រាក) មុនសប្តាហ៍បរិសុទ្ធបន្តិច។ ការអានប្រៀបធៀបរវាងដំណឹងល្អម៉ាថាយនិងម៉ាកុសបង្ហាញថាព្រឹត្តិការណ៍នោះបានកើតឡើងនៅក្នុងផ្ទះរបស់ស៊ីម៉ូនជាមនុស្សឃ្លង់ ជាអ្នកជិតខាង។

នៅពេលព្រឹត្តិការណ៍នេះត្រូវបានដំណាលប្រាប់ទៅអ្នកស្រុកឆ្ងាយថាព្រះអម្ចាស់នៃយើងបានយាងមកដល់ភូមិបេថានី ពួកសាសន៍យូដាមួយក្រុមធំបានផ្តុំគ្នា។ អ្នកខ្លះមកដោយព្រោះទទូចចង់ឃើញមិនត្រឹមតែព្រះយេស៊ូវទេ តែលោកឡាសារជាមនុស្សដើរចេញពីរូងផ្នូរថ្មបន្ទាប់ពីស្លាប់៤ថ្ងៃផងដែរ។ អ្នកខ្លះទៀតដើម្បីតាមដានពីដំណើរចេញចូលរបស់ទ្រង់ ប្រយោជន៍ឲ្យគេនឹងអាចសម្លាប់ព្រះយេស៊ូវនិងលោកឡាសារផងដែរ។ នេះកើតមានឡើងនៅក្នុងរាល់បណ្តាជំនុំ! មានអ្នកថ្វាយបង្គំដ៏ស្មោះត្រង់ដូចជាបងប្អូនទាំងបីនាក់និងលោកស៊ីម៉ូនជាអ្នកភូមិបេថានី។ មានអ្នកទទូចចង់ដឹង។ មានអ្នកស្វែងរកចាប់កំហុសនិងអ្នកឃុបឃិតក្បត់ចូលមកដូចជាអ្នកស៊ើបការណ៍។ ខាងក្រោមនេះគឺជាចំណាប់អារម្មណ៍របស់បណ្ឌិត ចន ស៊ុង។

នៅថ្ងៃបន្ទាប់ គឺជាថ្ងៃអាទិត្យមុនការសុគតរបស់ទ្រង់ ព្រះអង្គបានគង់លើសត្វលាជំទង់យាងចូលក្រុងយេរូសាឡឹមលក្ខណៈបែបជាពិធីបុណ្យ។ ដំណើរយាងចូលក្រុងយេរូសាឡឹមនេះ បច្ចុប្បន្នត្រូវបានគេដឹងថាជាដំណើរយាងចូលដោយជ័យជំនះ (*Triumphant Entry*)។ សូមអានដំណឹងល្អ ម៉ាថាយ ២១:១-១៧, ម៉ាកុស ១១:១-១១, លូកា ១៨:២៩-៤៤ សម្រាប់បណ្តុំផ្ទាំងទស្សនីយភាពទាំងមូល។ សាវ័កយ៉ូហានកត់ត្រាពីពួកអ្នកក្នុងបណ្តាមហាជនដែលបានស្វាគមន៍ទ្រង់ជាស្តេចនៃទីក្រុងយេរូសាឡឹមថាជាអ្នកបានឃើញព្រះអង្គប្រោសឡាសារឲ្យរស់ឡើងវិញ។

មិនជាយូរប៉ុន្មាននាអំឡុងពេលសប្តាហ៍បរិសុទ្ធ នាពេលនោះគឺសាវ័កយ៉ូហានដែលប្រាប់យើងពីបទសម្ភាសន៍មួយដោយសាសន៍ក្រេកតាមរយៈភីលីពជាអ្នកភូមិបេតសៃដា នៃស្រុកកាលីឡេ។ ជនជាតិក្រេកទាំងនេះគឺកើតពីគ្រួសារនៃសាសន៍ដទៃដែលបានទទួលយកជំនឿសាសនាយូដា មានអ្នកខ្លះក្នុងចំណោមពួកគេបានតាំងលំនៅដ្ឋានក្នុងស្រុកកាលីឡេ ហើយគេប្រហែលជាអាចនឹងស្គាល់ភីលីពផងដែរ។ (ភីលីពគឺជាឈ្មោះជនជាតិក្រេក ទោះបីជាគាត់ជាជនជាតិយូដា)។ សំណើរសុំចង់ជួបព្រះយេស៊ូវសម្តែងឲ្យឃើញនូវការគាំទ្ររបស់គេ ដែលជាការលើកទឹកចិត្តមួយដល់ព្រះអម្ចាស់នៃយើងនាពេលមានវិបត្តិនេះ។

នៅពេលព្រះយេស៊ូវមានបន្ទូលទៅសាវ័ករបស់ទ្រង់និងសាសន៍ក្រេកទាំងនេះ ព្រះអង្គមានមោទនភាពដោយសារផលផ្លែដែលទ្រង់ហាក់បីដូចជាគ្រាប់ស្រូវពីស្ថានសួគ៌ ជាគ្រាប់ពូជជីវិតបានធ្លាក់ចុះទៅដីដើម្បីសុគតប្រយោជន៍បង្កើតផលផ្លែឡើង។ ប៉ុន្តែខណៈពេលទ្រង់បានអធិប្បាយព្រះអង្គក៏បានទទួលនូវបទពិសោធន៍នៃសួនគេតសេម៉ានីជា

មុនដែរ ដូចនេះទើបទ្រង់បានបន្លឺឡើងថា៖ «ឥឡូវនេះ ខ្ញុំមានចិត្តតប់ប្រមល់» (ខ ២៧)។ ក្នុងពំនោលដ៏ស្រងោតស្រងាត់របស់ទ្រង់មានការដ៏អស្ចារ្យមួយបានកើតឡើង។ មានឮសម្លេងពីលើមេឃ លាន់ឮឡើងយ៉ាងខ្លាំងបណ្ដាលឲ្យអ្នកខ្លះនិយាយថាជាផ្គរលាន់។ សម្លេងនោះមិនមែនឮដោយព្រោះព្រះអម្ចាស់នៃយើងដូចជាបណ្ដាមនុស្សដែលឈរនៅទីនោះអះអាងឡើយ។ អ្នកដែលស្ដាប់ឮសម្លេងនោះគឺបានសង្គ្រោះ តែចំពោះអ្នកដែលធ្វើជាមានត្រចៀកថ្លង់គឺជាប់ការជំនុំជំរះវិញ។ ឯអ្នកដូចជាសាសន៍ក្រេកដែលបានចូលមកជួបព្រះយេស៊ូវដើម្បីស្ដាប់ពីសេចក្ដីពិត ព្រះបានទទួលពួកគេ តែចំណែកឯអ្នកឈរមើលដោយគ្មានចិត្តជឿ ព្រះបានបដិសេធមិនទទួលយកពួកគេឡើយ។

**ការពិចារណា៖** «ប្រាកដមែន ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា បើគ្រាប់ស្រូវដែលធ្លាក់ចុះទៅដីមិនងាប់ទេ នោះក៏នៅតែ១ដដែល តែបើងាប់វិញ នោះក៏បង្កើតផលជាច្រើនឡើង» (យ៉ូហាន ១២២៤)

**ការអធិស្ឋាន៖** ព្រះវរបិតាអើយ ខ្ញុំដឹងថាខ្ញុំនឹងរស់ឡើងវិញដូចព្រះរាជបុត្រាទ្រង់បានរស់ពីស្លាប់ឡើងវិញដែរ។

ថ្ងៃទី ១៧ កញ្ញា
យ៉ូហាន ១២:១-១១

*«...កន្លែងណាដែលគេនឹងប្រកាសប្រាប់ដំណឹងល្អនេះ នៅគ្រប់ក្នុងលោកីយទាំងមូល នោះគេនឹងដំណាលពីការដែលនាងបានធ្វើនេះដែរ ទុកសំរាប់ជាកេរ្តិ៍នាង»។*

## ទឹកអប់ដ៏ក្រអូបរបស់នាងម៉ារី

ដូចជាយើងបានដឹងពីមុនរួចហើយថាភូមិបេថានីគឺជាទីស្នាក់អាស្រ័យរបស់ព្រះអម្ចាស់នៃយើងនាកំណាត់ផ្លូវពីផ្នែកខាងលើនៃផ្ទៃប្រទេសឆ្ពោះទៅទីក្រុងយេរូសាឡឹម។ ហើយដោយព្រោះនេះគឺជាព្រះរាជដំណើរចុងក្រោយរបស់ព្រះគ្រីស្ទទៅភូមិបេថានី លោកស៊ីម៉ូនជាមនុស្សកើតឃ្លង់ដែលព្រះយេស៊ូវបានប្រោសកាលពីមុនបានបើកផ្ទះរបស់គាត់ទទួលព្រះអង្គនិង ពួកសិស្សទ្រង់។ បើតាមបណ្ឌិតចន ស៊ុង នោះគឺដើម្បីផ្តល់អាហារ ពោលគឺមិនត្រឹមសម្រាប់ព្រះអម្ចាស់ទេ តែក៏សម្រាប់បុរសទាំងដប់ពីរនាក់ដែលហត់ហេវផងដែរ។ ហេតុនេះទើបមានការរាប់ឈ្មោះរបស់នាងម៉ាថានៅក្នុងផ្ទះបាយរបស់ស៊ីម៉ូន។ ឯលោកឡាសារ ដើម្បីសម្តែងនូវការអរព្រះគុណដល់ព្រះអម្ចាស់សម្រាប់ការប្រោសពីស្លាប់ គាត់បានមកជាមួយទ្រង់ដែរ។

ខណៈពេលពួកសិស្សបរិភោគអាហាររបស់គេ ស្រាប់តែការដ៏ភ្ញាក់ផ្អើលមួយបានកើតឡើង តែព្រះអម្ចាស់នៃយើង សញ្ជឹងគិតយ៉ាងស្ងៀមស្ងាត់។ គ្មាននរណាម្នាក់ដឹងពីព្រះហឫទ័យរបស់ទ្រង់ទេ លើកលែងតែនាងម៉ារា។ ក្រៅពីនាងម៉ារា ក៏ គ្មានអ្នកណាម្នាក់ដឹងពីអំម្រែកដ៏ធ្ងន់ដែលព្រះអម្ចាស់នៃយើងកំពុងរែកដែរ។ មានតែម៉ារាទេដែលបានយល់ពីអារម្មណ៍ខាងក្នុងព្រះហឫទ័យរបស់ព្រះអម្ចាស់នៃយើង ពីព្រោះនាងបានស្រឡាញ់ទ្រង់ជាខ្លាំង។ ហើយសេចក្តីស្រឡាញ់ជាទូទៅគឺបាន សម្តែងមកតាមរយៈការបរិច្ចាករបស់នាង។ ស្រឡាញ់កាន់តែខ្លាំងនឹងផ្តល់ឲ្យកាន់តែច្រើន។ ស្រឡាញ់តិច ក៏ផ្តល់ឲ្យតិចដែរ (សូមមើល លូកា ៧:១៤-៤៣)។ នាងម៉ារាស្រឡាញ់ព្រះយេស៊ូវព្រោះនាងបានទទួលនូវបទពិសោធន៍នៃការអត់ទោសបាប ដែលគ្មានអ្នកណាម្នាក់ធ្លាប់ទទួលបានដូចជានាង។

ប្រេងទេព្វិរុសុទ្ធតម្លៃ ៦០ រៀល ឬដិណារី (*denarii*) គឺស្មើនឹងចំនួនប្រាក់ខែពេញមួយឆ្នាំ។ លោកម៉ាកុសប្រាប់ថានាងម៉ារាបានបំបែកដបថ្មកែវប្រេងទេព្វិរូមុនពេលនាងចាក់ប្រេងអប់ទ្រង់។ (ដបថ្មកែវប្រេងទេពិរូគឺមានពណ៌សថ្លាស្រអាប់ បន្តិច)។ រំពេចភ្លាមនោះស្រាប់តែឮពាក្យស្តីបន្ទោសដ៏ធ្ងន់ធ្ងរចេញពីមាត់របស់យូដាស-អ៊ីស្ការីយ៉ុត។ គាត់កម្រនឹងនិយាយពាក្យពិរោះទៅកាន់អ្នកណាម្នាក់ណាស់សូម្បីតែចំពោះព្រះអម្ចាស់នៃយើងផងដែរ។ នោះហើយក៏ជារូបភាពមួយពីសមាជិកក្នុងពួកជំនុំដែលនិយាយអាក្រក់ពីអ្នកដទៃ តែតាមពិតទង្វើបែបនោះបង្ហាញពីសេចក្តីអាក្រក់របស់ខ្លួនគាត់ប៉ុណ្ណោះ។ គ្មានសេចក្តីស្រឡាញ់អ្វីនៅក្នុងពាក្យដែលយូដាសនិយាយទេ ទោះបីជាគាត់សម្តែងជាយកចិត្តទុកដាក់ចំពោះអ្នកក្រីក្រក៏ដោយ ពីព្រោះយ៉ូហានប្រាប់យើងថាយូដាសគឺជាចោរ។ ការយកមូលនិធិសាធារណៈប្រើប្រាស់សម្រាប់ផ្ទាល់ខ្លួនវាគឺបទល្មើសដ៏ធ្ងន់ ធ្ងរមួយ! បើប្រើពាក្យច្បាប់ គឺជាបទល្មើសបំពានលើសេចក្តីទំនុកចិត្ត។

ប៉ុន្តែព្រះយេស៊ូវបានទទួលដង្វាយក្តីស្រឡាញ់របស់នាងម៉ារា។ ព្រះយេស៊ូវបានសរសើរ តែស្តីបន្ទោសយូដាសដោយការប្រទានសម្តីគាត់ចោល «ឯអ្នករាល់គ្នា តែងតែមានពួកអ្នកក្រនៅជាមួយជាដរាប តែខ្ញុំមិននៅជាមួយជាដរាបទេ» (ខ ៨)។ ព្រះយេស៊ូវផ្តល់តម្លៃលើអំណោយទាំងឡាយរបស់យើង។

នេះគឺជាវគ្គមួយទៀតពីពីបទចម្រៀងភូមិបេថានីដែលបានបកប្រែពីទីក្រុងហុងកុងនៃសៀវភៅ *ចម្រៀងខ្លីៗនៃរាស្ត្រស្ថាន សួគ៌* (*Heavenly People's Choruses*) របស់លោកគ្រូ គង្វាល ចន អ៊ី ស៊ូ (*Rev. John E Su*)៖ ព្រះអម្ចាស់នៃយើងនឹងមានបន្ទូលមកយើងរាល់គ្នានៅពេលយើងច្រៀងបណ្តើរ ហើយគិតពីនាងម៉ារាបណ្តើរជាមិនខានឡើយ! «ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា កន្លែងណាដែលគេនឹងប្រកាសប្រាប់ដំណឹងល្អនេះ នៅគ្រប់ក្នុងលោកីយទាំងមូល នោះគេនឹងដំណាលពីការដែលនាងបានធ្វើនេះដែរ ទុកសំរាប់ជាកេរ្តិ៍នាង» (ម៉ាថាយ ២៦:១៣)។

*ឱភូមិបេថានី ជាលំនៅដ្ឋានដ៏រីករាយរបស់ខ្ញុំ ក្បែរភ្នំអូលីវ*
*កន្លែងនេះហើយព្រះគុណបានពីអេម៉ាញូអែលជាព្រះ*
*បេថានីនេះហើយចិត្តមួយបានរួម*
*ព្រលឹងយើងអណ្តែតឡើងខ្ពស់ដល់វេហារ។*
*ខ្ញុំអប់ទ្រង់ដោយគ្រឿងក្រអូបថ្លៃ*
*ទុកដូចជាក្តីស្រឡាញ់នៃខ្ញុំ។*
*ឱបេថានី ជាទីអាស្រ័យដ៏ថ្លៃខ្ញុំអើយ*
*កន្លែងនេះហើយបានពរឥតស្រាកពីសួគ៌ាលៃ។*

**ការពិចារណា៖** តើអ្នកក្រីក្រឬព្រះយេស៊ូវនៅជាមួយខ្ញុំជាដរាប?
**ការអធិស្ឋាន៖** ឱសូមឲ្យខ្ញុំថ្វាយអ្វីៗដែលល្អបណ្តាច់គេដល់ទ្រង់ផង។

ថ្ងៃទី ១៨ កញ្ញា
យ៉ូហាន ១២:១២-១៩

*«ថ្ងៃនេះជាថ្ងៃដែលព្រះយេហូវ៉ាបានកំណត់ទុក នៅថ្ងៃនេះ យើងរាល់គ្នានឹងរីករាយសប្បាយឡើង» (ទំនុកដំកើង ១១៨:២៤)។*

## សារៈសំខាន់នៃថ្ងៃអាទិត្យមុនព្រះយេស៊ូវសុគត់

ខណៈពេលសាសន៍យូដាបានរៀបចំគម្រោងការសម្លាប់ព្រះយេស៊ូវ នាព្រឹកព្រលឹមថ្ងៃអាទិត្យភ្លឺស្រាងបានមកដល់! «ក្នុង១ថ្ងៃមាន១២ម៉ោងទេតើ? បើអ្នកណាដើរនៅពេលថ្ងៃ នោះមិនជំពប់ជើងទេ ព្រោះឃើញពន្លឺលោកីយនេះ» (យ៉ូហាន ១១:៩)។ «ថ្ងៃនេះជាថ្ងៃដែលព្រះយេហូវ៉ាបានកំណត់ទុក នៅថ្ងៃនេះ យើងរាល់គ្នានឹងរីករាយសប្បាយឡើង» (ទំនុកដំកើង ១១៨:២៤)។

សារៈសំខាន់ពីការព្រះយេស៊ូវជិះកូនលាជំទង់ចូលទីក្រុងយេរូសាឡឹម ពួកសាវ័កឥតបានយល់រហូតដល់បន្ទាប់ពីទ្រង់បានមានព្រះជន្មរស់ឡើងវិញ ដែលពេលនោះហើយទើបគេបាននឹកចាំបទគម្ពីរដែលបានព្យាករណ៍អំពីភាពជាស្ដេចដ៏សុភាពរបស់ព្រះអង្គ (សាការី ៩:៩)។

ពួកមហាជន លើកដៃគ្រវីឡើងជាបន្តបន្ទាប់គ្នា ដោយគេបានប្រជុំគ្នាដើម្បីទទួលស្ដេចរបស់ពួកគេ ឯស្លឹកដូងបានគ្រវីឡើងជាមួយពាក្យហូសាណា ហូសាណាដល់បុត្រារបស់ស្ដេចដាវីឌ! ហូសាណានៅស្ថានដ៏ខ្ពស់បំផុត! ហូសាណាគឺជាសមាសពាក្យ (ពាក្យបន្សំ) មួយទៀតរបស់ភាសាហេព្រើរដែលមានន័យត្រង់ថា៖ «ខ្ញុំសូមអង្វរដល់អ្នកសូមរក្សាសុវត្ថិភាព»។ បច្ចុប្បន្នពាក្យនេះត្រូវបានពួកជំនុំយកមកប្រើក្នុងបណ្ដាភាសាផ្សេងៗ។ វាគឺជាពាក្យបន្លឺសម្រាប់សរសើរដំកើងព្រះជាម្ចាស់និងជាពាក្យអធិស្ឋានសម្រាប់ការប្រទានពរ។

នៅពេលសប្ដាហ៍បរិសុទ្ធរំកិលជិតមកដល់នាឆ្នាំនិមួយៗ យើងបានឃើញថាវាគឺជាព្រះពរពិសេសមួយក្នុងការប្រារព្ធពិធីនោះ ដោយការចាប់ផ្ដើមពីថ្ងៃអាទិត្យមុនព្រះយេស៊ូវសុគត (*Palm Sunday*)។ ព្រះវិហារខ្លះតុបតែងលំអរនាឱកាសពិធីនោះដោយធាងដូង ឬក៏ថែមទាំងធ្វើជាក្បួនដង្ហែជុំវិញបរិវេណព្រះវិហារមុនពេលចូលបដិសណ្ឋានពិសិដ្ឋ (ទីបរិសុទ្ធ) ដើម្បីថ្វាយបង្គំទៀតផង។ ការប្រារព្ធពិធីបុណ្យថ្ងៃអាទិត្យមុនព្រះយេស៊ូវសុគតដាក់យើងមកក្រោមអំណាចព្រះគ្រីស្ទដ៏ជាស្ដេចនិងថ្វាយកិត្តិយសដល់ទ្រង់ដោយពាក្យសរសើរដំកើង។ ការប្រារព្ធពិធីបុណ្យថ្ងៃអាទិត្យមុនព្រះយេស៊ូវសុគតនេះគឺដើម្បីរៀបចំចិត្តរបស់ពួកអ្នកជឿស្មោះត្រង់សម្រាប់ថ្ងៃសុក្រល្អ (*Good Friday*) ជាថ្ងៃរំលឹកការសុគតរបស់ព្រះយេស៊ូវ និងថ្ងៃអាទិត្យរំលឹកពីថ្ងៃព្រះយេស៊ូវរស់ឡើងវិញ (*Easter Sunday*)។ សូមយើងកុំភ្លេចឲ្យសោះថា ព្រះគ្រីស្ទគឺមិនត្រឹមជាព្រះសង្គ្រោះទេ តែជាព្រះអម្ចាស់និងជាស្ដេចផងដែរ! ហើយព្រះអង្គនឹងយាងមកផែនដីវិញឆាប់ៗធ្វើជាស្ដេច មិនត្រឹមតែគ្រងលើពួកជំនុំទេ តែក៏គ្រងលើរាល់បណ្ដាប្រទេសជាតិសាសន៍និងគ្រប់ភាសាផងដែរ។

ការច្រៀងបទហូសាណាគឺលើកដំកើងព្រះគ្រីស្ទជាស្ដេចនៃសាសន៍អ៊ីស្រាអែល។ គណៈផារីស៊ីដែលធ្លាប់ច្រណែននឹងអំណាចថ្នាក់កំពូលរបស់គេបានអាក់អន់ចិត្តកាន់តែខ្លាំងជាងមុន។ ដំណឹងល្អ ម៉ាថាយ ២១:១៥ ចែងប្រាប់ថាពួកគេ «មានចិត្តគ្នាន់ក្នាញ់ណាស់»។ ពួកគេបានតាំងចិត្តកែប្រែពាក្យហូសាណាជា «ឆ្កាងវាទៅ»។ ទោះបីជាយ៉ាងណា មុនពេលកំណត់មកដល់ ព្រះអម្ចាស់នៃយើងត្រូវបានព្រះវរបិតាការពារទ្រង់ប្រកបដោយសុវត្ថិភាព។ ពួកមហាជនដែលបានឃើញព្រះគ្រីស្ទប្រោសឡាសារពីស្លាប់ ហើយមកដល់ពេលនេះជាអ្នកមកដោយកម្លាំងបានក្លាយជាជញ្ជាំងព័ទ្ធការពារជុំវិញទ្រង់។ «ដូច្នេះ ពួកផារីស៊ីនិយាគ្នាគេថា មើល ពួកយើងមិនឈ្នះទេ ឃើញឬទេ លោកីយទាំងស្រុងទៅតាមអ្នកនោះហើយ» (ខ ១៩)។ តើអ្នកឈរនៅកន្លែងណាក្នុងចំណោមពួកមហាជន?

**ការពិចារណា៖** បើគ្មានឈើឆ្កាងនាភ្នំកាល់វ៉ារីក៏គ្មានការអត់ទោសបាបដល់មនុស្សជាតិទាំងមូលដែរ។

**ការអធិស្ឋាន៖** ឱសូមឲ្យរាល់ថ្ងៃ ជាពិសេសនៅអាទិត្យខ្ញុំនឹកចាំពីថ្ងៃព្រះយេស៊ូវគ្រីស្ទរស់ឡើងវិញផង។

ថ្ងៃទី ១៩ កញ្ញា

យ៉ូហាន ១២:២០-២២ *«ខ្ញុំមានសេចក្តីជំពាក់ទាំងសាសន៍ក្រេក នឹងសាសន៍ដទៃ ទាំងអ្នកប្រាជ្ញ នឹងអ្នកខ្លៅផង» (រ៉ូម ១:១៤)។*

## សាសន៍យូដាបដិសេធ សាសន៍ក្រេកទទួល

គឺជាសាវ័កយ៉ូហានជាអ្នកអនុញ្ញាតឲ្យយើងចូលរួមក្នុងបទសម្ភាសន៍របស់សាសន៍ក្រេកជាមួយនឹងព្រះអម្ចាស់នាអំឡុងពេលនៃសប្តាហ៍បរិសុទ្ធ។ អ្នកទាំងនេះគឺជាអ្នកជឿស្មោះត្រង់សាសន៍ដទៃពីបណ្តាប្រទេសផ្សេងៗដែលបានមកចូលរួមពិធីបុណ្យរំលងក្នុងទីក្រុងយេរូសាឡឹម។ (បើតាមសំបុត្រ រ៉ូម ១:១៦ ពាក្យថាសាសន៍ក្រេកគឺត្រូវបានសំដៅជាទូទៅលើសាសន៍ដទៃ)។

ក្រៅពីការសន្និដ្ឋានថាពួកគេអាចជាអ្នកមកពីស្រុកកាលីឡេ យើងមានគំរូដ៏ល្អៗជាច្រើនទៀតអំពីជំនឿដ៏ស្មោះត្រង់របស់គេផងដែរ។ សូមអានកំណត់ត្រាពីដំណើររឿងមេទ័ពស្រុកកាពើណិម (ម៉ាថាយ ៨:៥-១៣)។ ដោយព្រោះជំនឿដ៏អស្ចារ្យនិងការថ្វាយបង្គំព្រះអម្ចាស់យេស៊ូវ គាត់បានធ្វើជាអ្នកត្រួសត្រាយផ្លូវសម្រាប់មនុស្សជាច្រើនដែលនឹងមកពីលោកខាងកើតនិងខាងលិច ជាអ្នកដែលនឹងអង្គុយជាមួយលោកអ័ប្រាហាំ លោកអ៊ីសាក់ និងលោកយ៉ាកុបនានគរស្ថានសួគ៌។ លូកាប្រាប់យើងបន្ថែមទៀតថាមេទ័ពម្នាក់នេះបានកសាងសាលាប្រជុំមួយសម្រាប់សាសន៍យូដា (លូកា ៧:៥)។ ជនជាតិក្រេកជាសាសន៍ដទៃទាំងនេះមានចំនួនដ៏ច្រើននៅក្នុងសៀវភៅកិច្ចការនៃពួកសាវ័កដែលត្រូវបានហៅថាជា «អ្នកកោតខ្លាចដល់ព្រះ» ឬ «អ្នកថ្វាយបង្គំព្រះ» ជាបងប្អូនស្មោះត្រង់ដែលបានបែរចេញពីរូបព្រះ មកក្នុងជំនឿសាសន៍យូដា ជាការជឿលើព្រះដ៏ពិត ឲ្យបានគោរពប្រតិបត្តិដល់ព្រះដ៏មានព្រះជន្មរស់នៅ (១ ថែស្សាឡូនីច ១:៩)។ ទោះបីសាសន៍ «ក្រេក» មិនចូលរួមក្នុងពិធីបុណ្យក៏ពួកគេបានចូលរួមក្នុង ការថ្វាយបង្គំក្នុងសាលាប្រជុំនិងព្រះវិហារដែរ។ លោកកូនេលាសជាម្នាក់ក្នុងចំណោមពួកគេដែលគាត់ជាមេទ័ពជនជាតិរ៉ូម៉ាំងត្រួតលើទាហានជនជាតិអ៊ីតាលី។

ក្រៅពីសាសន៍ «ក្រេក» ទាំងនេះ យើងក៏អាចនឹកចាំពីបុរសកំរៀវជនជាតិអេធីយ៉ូពីម្នាក់ទៀត (កិច្ចការ ៨:២៧) ជាអ្នកមកក្រុងយេរូសាឡឹមដើម្បីចូលរួមពិធីបុណ្យផងដែរ (កិច្ចការ ៨:២៧)។

ដូច្នេះទើបពេលសាសន៍ក្រេកទាំងនោះស្នើសុំជួបព្រះយេស៊ូវ គឺពួកគេកំពុងតែស្វែងរកសេចក្តីពិត។ ខណៈពេលសាសន៍យូដាបដិសេធព្រះអង្គ តែនៅជំពូកនេះប្រាប់ថាសាសន៍ក្រេកបានទទួលទ្រង់។ អ្នកទាំងនេះជាចៀមឯទៀតដែលត្រូវនាំមកក្នុងក្រោល (យ៉ូហាន ១០: ១៦)។ ហើយនៅពេលសាសន៍ក្រេក សាសន៍រ៉ូម៉ាំងនិងសាសន៍អេធីយ៉ូពីទទួលជឿព្រះគ្រីស្ទពួកគេនឹងច្រៀងថា៖

នៅក្នុងព្រះគ្រីស្ទ គ្មានទេទិសកើតឬទិសលិច ក្នុងទ្រង់ក៏គ្មានដែរទិសត្បូងឬទិសជើង<br>
មានតែការប្រកបគ្នាដោយក្តីស្រឡាញ់ ដ៏ធំពាសពេញផ្ទៃភពសាកល។

សាសន៍ក្រេកតំណាងឲ្យជនជាតិបរទេសដែលមានវប្បធម៌និងការអប់រំ។ ព័ន្ធកិច្ចរបស់ យើងមិនត្រូវភ្លេចអ្នកមានកម្រិតវប្បធ៌មខ្ពង់ខ្ពស់ឡើយ (រ៉ូម ១:១៤)។

អ្នកខ្លៅគឺជាអ្នកនិយាយភាសាគ្មានវប្បធ៌ម គឺជាសហភាតរៈ (ដៃគូ) របស់ពួកគេដែលសាវ័កប៉ូលជំពាក់ដំណឹងល្អ។ ដូចនេះបេសកកម្មដំណឹងល្អដល់បណ្តាកោះនានានិងដែនដីនៃទ្វីបទាំងឡាយគឺចាំបាច់បំផុត។ ពួកគេក៏បានស្រែកបន្លឺឡើងថា៖ «លោកម្ចាស់ យើងខ្ញុំចង់ឃើញព្រះយេស៊ូវ»។ តើលោកអ្នកនាំពួកគេមកឯព្រះគ្រីស្ទដូចជាភីលីពដែរឬទេ?

**ការពិចារណា៖** តើខ្ញុំឥតជំពាក់ដំណឹងល្អនឹងអ្នកណាម្នាក់សោះ?

**ការអធិស្ឋាន៖** សូមព្រះអង្គបើកទ្វារដំណឹងល្អដើម្បីឲ្យខ្ញុំធ្វើបន្ទាល់ថ្វាយទ្រង់ផង។

## ការលើកដំកើងតាមរយៈការសុគតជាប់ឆ្កាង

ក្នុងការឆ្លើយតបនឹងសំណួររបស់សាសន៍ក្រិក ព្រះយេស៊ូវមានបន្ទូលអំពីការលើកដំកើងនៃព្រះបុត្រា តើពាក្យនេះមានន័យដូចម្តេច? បណ្ឌិត កាល់វិនមានប្រសាសន៍ថាការលើកដំកើងនេះ «សំដៅទៅលើការប្រកាសដំណឹងល្អដែលហាក់ដូចជាទ្រង់មានបន្ទូលថាមិនយូរប៉ុន្មាន ចំណេះដឹងអំពីអង្គទ្រង់នឹងផ្សព្វផ្សាយទៅពាសពេញតំបន់នៃពិភពលោក។ លោក អិលីកុត (*Ellicot*) មាន ប្រសាសន៍ថា៖ «នេះនឹងបានសម្រេចក្នុងព្រះរាជនិវត្តន៍ឡើងទៅឋានសួគ៌របស់ទ្រង់ តែព្រឹត្តិការណ៍ទាក់ទងភ្លាមៗគឺការទ្រង់ចាត់ទុកការពង្រីកពន្ធកិច្ចនៃភាពជាព្រះមេស៊ីរបស់ទ្រង់និងការប្រជាជាតិនានាលើពិភពលោកទទួលស្គាល់សេចក្តីពិតរបស់ទ្រង់ជាផ្នែកនៃការលើកដំកើងព្រះរាជបុត្រា»។

ក៏ប៉ុន្តែវិធីឆ្ពោះទៅរក «ការលើកដំកើង» នេះគឺមានតែមួយ គឺតាមរយៈឈើឆ្កាងតែមួយគត់។ ព្រះយេស៊ូវប្រកាសសារជាថ្មីម្តងទៀតពីការសុគតរបស់ទ្រង់ថា គ្រាប់ស្រូវពីឋានសួគ៌នឹងធ្លាក់ចុះទៅដីរបស់មនុស្សជាតិហើយនិងងាប់។ ព្រះអង្គមានសុទិដ្ឋិនិយមអំពីការសុគតរបស់ទ្រង់ព្រោះលទ្ធផលពីការសុគតនេះនឹងមានការរស់ពីស្លាប់ឡើងវិញ ហើយនឹងនាំព្រលឹងវិញ្ញាណជាច្រើនអនេកមកជាមួយ ទុកជាផលផ្លែពីការសុគតរបស់ទ្រង់។ នៅក្នុងខ២៥ ព្រះអង្គបានលើកទឹកចិត្តសារជាថ្មីដល់ពួកសិស្សដែលភ័យខ្លាចឲ្យបន្តដើរតាមទ្រង់រហូតដល់ទីបំផុត។ ពួកអ្នកដែលនឹងរងរងទុក្ខជាមួយទ្រង់ក៏នឹងសោយរាជ្យជាមួយទ្រង់ដែរ (ខ ២៦)។ នេះគឺជាប្រធានបទដ៏សំខាន់ដែលព្រះអង្គមានបន្ទូលជាច្រើនដងចាប់តាំងពីក្រុងសេសារា-ភីលីព (ម៉ាថាយ ១៦:២១) ដើម្បីផ្តល់កម្លាំងចិត្តដល់ពួកសិស្ស។

តែព្រះយេស៊ូវដែលជាព្រះនិងមនុស្ស ជាព្រះដ៏គ្រប់លក្ខណ៍និងជាមនុស្សដ៏គ្រប់លក្ខណ៍ ព្រះអង្គគ្មានបាបសោះឡើយ។ ក្នុងភាពជាមនុស្សទ្រង់ក៏មានសេចក្តីកំសោយខាងផ្នែករូបកាយផងដែរ។ «ឯវិញ្ញាណ ក៏ប្រុងជាស្រេចមែន តែសាច់ឈាមខ្សោយទេ» (ម៉ាថាយ ២៦:៤១)។ រំពេចភ្លាមនោះ ពពកខ្មៅពីសួនគែតសេម៉ានីមានសណ្ឋានដូចជាស្រមោលបានសន្ធប់គ្របលើទ្រង់ «ឥឡូវនេះ ខ្ញុំមានចិត្តតប់ប្រមល់ តើត្រូវឲ្យខ្ញុំទូលដូចម្តេច? ឱព្រះវរបិតាអើយ សូមជួយសង្គ្រោះទូលបង្គំឲ្យរួចពីពេលនេះផង ប៉ុន្តែគឺដោយហេតុនេះឯង បានជាទូលបង្គំមកដល់ពេលនេះ» (ខ ២៧)។ អូ! នេះពិតជាអាថ៌កំបាំងនៃសេចក្តីកោតខ្លាចដល់ព្រះនិងអាថ៌កំបាំងនៃមនុស្សជាតិផ្សះផ្សាមកតែមួយក្នុងព្រះគ្រីស្ទមែន។ អាថ៌កំបាំងពីភាពតានតឹងនៃមនុស្សក្នុងសេចក្តីកោតខ្លាចដល់ព្រះនិងអាថ៌កំបាំងពីភាពតានតឹងនៃព្រះក្នុងមនុស្សជាតិ។

តើអ្នកណាអាចចូលទៅក្នុងអាថ៌កំបាំងនៃថ្ងៃនោះមុនការសុគតជាប់ឆ្កាងបាន? ចូរឲ្យយើងនិយាយជាមួយសាវ័កប៉ូល «ដើម្បីឲ្យខ្ញុំបានស្គាល់ទ្រង់ នឹងព្រះចេស្តានៃដំណើរដែលទ្រង់រស់ឡើងវិញ ហើយនឹងសេចក្តីប្រកបក្នុងការរងទុក្ខរបស់ទ្រង់ ព្រមទាំងត្រឡប់ទៅដូចជាទ្រង់ក្នុងសេចក្តីស្លាប់ផង» (ភីលីព ៣:១០)។ សូមទន្ទេញខនេះ។

**ការពិចារណា៖** «ចូរបន្ទាបខ្លួននៅចំពោះព្រះអម្ចាស់ នោះទ្រង់នឹងដំកើងអ្នករាល់គ្នាឡើង (យ៉ាកុប ៤:១០)។
**ការអធិស្ឋាន៖** «ហើយឲ្យគ្រប់ទាំងអណ្តាតបានថ្លែងប្រាប់ថា ព្រះយេស៊ូវគ្រីស្ទទ្រង់ជាព្រះអម្ចាស់ សម្រាប់ជាសិរីល្អដល់ព្រះដ៏ជាព្រះវរបិតា»(ភីលីព ២:១១)។

*«...ដ្បិតគ្រង់ឯសេចក្ដីទាំងនោះ ត្រូវពិចារណាយល់ខាងវិញ្ញាណវិញ»។*

## ការបញ្ជាក់ជាចុងក្រោយរបស់ព្រះវរបិតា

ព្រះវរបិតាបានមានបន្ទូលពីស្ថានសួគ៌នាពិធីបុណ្យជ្រមុជរបស់ព្រះយេស៊ូវដើម្បីបញ្ជាក់ប្រាប់ដល់លោកីយ៍ថានេះគឺជាព្រះរាជបុត្រាស្ងួនភ្ងារបស់ទ្រង់ (ម៉ាថាយ ៣:១៧)។ ព្រះដ៏ជាព្រះវរបិតាបានមានបន្ទូលពីស្ថានសួគ៌ជាថ្មីម្ដងទៀតនាពេលរូបកាយប្រែទៅក្នុងសិរីរុងរឿងរបស់ព្រះបុត្រាដើម្បីពង្រឹងជំនឿរបស់សិស្សទាំងបីនាក់ (ម៉ាថាយ ១៧:៥)។ ពេលនេះ ព្រះវរបិតា បានមានបន្ទូលជាលើកទីបីនិងជាចុងក្រោយដើម្បីប្រាប់មនុស្សទូទាំងពិភពលោកនិងសិស្សទ្រង់នូវកិច្ចការដែលនឹងត្រូវធ្វើដោយព្រះរាជបុត្រា។ នៅពេលសម្លេងបាត់ទៅ ព្រះអម្ចាស់នៃយើងបានប្រកាសថា «សំឡេងនេះមិនមែនឮដោយព្រោះខ្ញុំទេ គឺដោយយល់ដល់អ្នករាល់គ្នាវិញ» (ខ ៣០)។

តើពួកមហាជនមានប្រតិកម្មបែបណាចំពោះសម្លេងពីស្ថានសួគ៌? ចំពោះមនុស្សភាគច្រើននៅក្នុងពួកមហាជនសម្លេងនោះគឺជាការឮខ្ទរដូចផ្គរលាន់ប៉ុណ្ណោះ។ ផ្អែកលើលទ្ធផលនៃការសន្និដ្ឋានរបស់យើងលើអត្ថបទយ៉ូហាន ៣:៣ គឺថា «បើមនុស្សម្នាក់មិនបានកើតជាថ្មី គាត់មិនអាចឮសំឡេងពីនគរស្ថានសួគ៌ឡើយ»។ ដូចសាវ័កប៉ុលមានប្រសាសន៍ថា «ប៉ុន្តែមនុស្សខាងសាច់ឈាម គេមិនទទួលសេចក្តីខាងឯវិញ្ញាណនៃព្រះទេ ពីព្រោះជាសេចក្តីល្ងង់ល្ងើដល់គេ ក៏រកស្គាល់មិនបានដែរ ដ្បិតគ្រង់ឯសេចក្តីទាំងនោះ ត្រូវពិចារណាយល់ខាងវិញ្ញាណវិញ» (១ កូរិនថូស ២:១៤)។ ការបង្រៀនរបស់គ្រូអធិប្បាយប្រកាសពីរាជសាររបស់ព្រះជាម្ចាស់ដល់ក្រុមជំនុំពីថ្ងៃអាទិត្យមួយទៅថ្ងៃអាទិត្យមួយអាចនឹងប៉ះទៅចំមនុស្សមានត្រចៀកថ្លង់ជាច្រើននាក់។ តើអ្នកនៅក្នុងចំណោមអ្នកមានត្រចៀកថ្លង់ដែរ?

មានអ្នកខ្លះពីពួកមហាជនបាននិយាយថា៖ «មានទេវតាទូលនឹងទ្រង់» (ខ ២៩)។ សម្លេងមកពីព្រះវរបិតាដោយយល់ដល់ពួកគេ តែគេគិតថាជាសម្លេងទៅកាន់ព្រះយេស៊ូវតាមរយៈអំណាចទេវតា។ ពួកអ្នកឮសម្លេងប្រភេទទីពីរដែលបានយល់ពីតម្រូវការក្នុងជីវិតអ្នកដទៃតែមិនយល់ពីតម្រូវការផ្ទាល់ខ្លួនគឺមិនមែនជាមនុស្សថ្លង់ទេ តែជាមនុស្សខ្វាក់។ តើនៅពេលអ្នកមកព្រះវិហារអ្នកមកព្រោះតែមានកម្មវិធីចម្រៀងពិសេសនិងតន្ត្រីពិរោះៗ (ព្រះវិហារសព្វថ្ងៃប្រើកម្មវិធីកំសាន្តដើម្បីទាក់ទាញមហាជន) ឬព្រោះតែអ្នកចង់ស្តាប់ពីសេចក្តីដែលព្រះជាម្ចាស់មានបន្ទូលកាន់រូបអ្នក?

នៅពេលព្រះវរបិតាឆ្លើយថា «អញបានដំកើងហើយ ក៏នឹងដំកើងឡើងទៀតដែរ» ដល់ការអធិស្ឋានរបស់ព្រះរាជបុត្រាដែលបានទូលថា «ឱព្រះវរបិតាអើយ សូមដំកើងព្រះនាមទ្រង់ឡើង»។ ទ្រង់ចង់មានន័យថា «ខ្ញុំនឹងធ្វើឲ្យគ្រប់លក្ខណៈនូវអ្វីដែលខ្ញុំបានចាប់ផ្តើម» (កាល់វីន)។ វាគឺជាកាតព្វកិច្ចរបស់យើងដើម្បីធ្វើឲ្យសិរីរុងរឿងរបស់ព្រះជាម្ចាស់បានដំកើងខ្ពស់ជាងជីវិតរបស់យើង ប្រសិនជាចាំបាច់រហូតដល់អស់ជីវិត។ នេះគឺជាការចុះចូលនៃព្រះបុត្រាដល់ព្រះវរបិតាដែលទ្រង់បានមានបន្ទូលបញ្ជាក់វាសាឡើងវិញនាពេលទ្រង់មានបន្ទូលពីការ «លើកឡើង» ពោលគឺជាការជាប់ឆ្កាងលើឈើឆ្កាងដើម្បីសង្គ្រោះពួកគេដែលជឿ។ ការបញ្ជាក់ពីព្រះរាជបុត្រាជាចុងក្រោយរបស់ព្រះវរបិតាឃើញការចុះចូលមកវិញរបស់ព្រះបុត្រាចំពោះព្រះវរបិតា។ ការសុគតជាដង្វាយធួននឹងបាបនៅលើឈើឆ្កាងគឺជាតម្រូវការទុកជាមុនដើម្បីសិរីរុងដែលនឹងមកដល់។ ហើយទ្រង់អញ្ជើញពួកមហាជនម្តងទៀតឲ្យជឿលើទ្រង់ដោយការដើរក្នុងពន្លឺនៃសេចក្តីបង្រៀនរបស់ទ្រង់។ ចុះអ្នកវិញ!

*មកឯពន្លឺ ដែលភ្លឺសំរាប់អ្នក*
*ពន្លឺភ្លឺច្បាស់ចាំងជះលើរូបខ្ញុំ*
*ពីដើមខ្ញុំខ្វាក់ តែឥលូវខ្ញុំភ្លឺ*
*ពន្លឺលោកីយ៍គឺព្រះយេស៊ូវ។* (ចម្រៀងទំនុកដំកើង៖ *The Light of the World is Jesus*)

**ការពិចារណា៖** បើគ្មានព្រះវិញ្ញាណគង់ក្នុងចិត្តទេ អ្នកនឹងចាត់ទុកព្រះគម្ពីរបរិសុទ្ធដូចជាសៀវភៅធម្មតា។
**ការអធិស្ឋាន៖** ព្រះវរបិតាអើយ សូមបើកសម្តែងសេចក្តីអាថ៌កំបាំងក្នុងពាក្យបន្ទូលទ្រង់ដល់ខ្ញុំផង។

ថ្ងៃទី ២២ កញ្ញា
សាស្ត្រា ៣
យ៉ូហាន ១២:៣៧-៥០

*«ពីព្រោះបើមិនជឿថា ខ្ញុំនេះជាព្រះ នោះអ្នករាល់គ្នានឹងស្លាប់ក្នុងអំពើបាបរបស់ខ្លួនពិតមែន» (យ៉ូហាន ៨:២៤)*

## ការថ្កោលទោសជាចុងក្រោយនៃព្រះវរបិតា

នៅពេលព្រះបានមានបន្ទូលហើយមានបន្ទូលម្តងទៀត ហើយទ្រង់បានមានបន្ទូលជាថ្មីម្តងទៀត រួចហើយមនុស្សម្នាក់បដិសេធព្រះអង្គ អ្នកនោះគាត់នឹងជាប់មានទោសជារៀងរហូត។ ជាមួយនឹងស្នូរសម្លេងជំនួយជាច្រើន ដែលជាសម្លេងពីស្ថានសួគ៌ព្រមទាំងការអស្ចារ្យដែលព្រះបុត្រាបានសម្តែងធ្វើនៅលើផែនដី ពិតជាគួរឲ្យស្តាយណាស់ លទ្ធផលពីទស្សនិកជនគឺមានចំនួនតិចតួចបំផុត។ ហេតុនេះទើបយ៉ូហានជាគ្រូផ្សាយដំណឹងល្អធ្វើសេចក្តីអត្ថាធិប្បាយថា «ប៉ុន្តែទោះបើទ្រង់បានធ្វើទីសំគាល់ នៅមុខគេជាច្រើនទាំងម្ល៉េះក៏ដោយ គង់តែគេមិនបានជឿដល់ទ្រង់ដែរ» (ខ ៣៧)។

នៅពេលសេចក្តីមេត្តាករុណានិងព្រះគុណរបស់ព្រះត្រូវបានបដិសេធជ្រាំដែល នោះការបណ្តាលឲ្យចិត្តមនុស្សប្រែជារឹងមានៈខាងក្រិត្យវិន័យនឹងកកើតឡើង។ ពាក្យដ៏ល្បីល្បាញរបស់ហោរាអេសាយត្រូវបានដកស្រង់មកបញ្ជាក់លើចំណុចនេះ «ទ្រង់បានធ្វើឲ្យភ្នែកគេខ្វាក់ ហើយឲ្យចិត្តគេរឹង ក្រែងភ្នែកគេមើលឃើញ ចិត្តគេយល់ ហើយគេប្រែគំនិត ដើម្បីឲ្យអញបានប្រោសឲ្យជា» (ខ ៤០)។ ឧទាហរណ៍ដ៏ល្អពីការបដិសេធបែបនេះយើងអាចនឹកចាំពីករណីស្តេចផារ៉ោន។ ថ្វីដ្បិតតែមានការអនុគ្រោះរបស់ព្រះយេហូវ៉ាផ្តល់ឲ្យទ្រង់បន្ទាប់ពីវាល់គ្រោះកាចនិមួយៗក៏ស្តេចផារ៉ោននៅតែបំពានពាក្យសន្យាម្តងហើយម្តងទៀតដោយមិនព្រមអនុញ្ញាតឲ្យអ៊ីស្រាអែលចាកចេញដែរ។ ព្រះគុណរបស់ព្រះបណ្តាលឲ្យចិត្តរឹងប្រៀបដូចជាទឹកស្រោចលើស៊ីម៉ង់ធ្វើឲ្យវាកាន់តែរឹងបន្ថែមទៀត! ជនជាតិយូដាដែលមានអភ័យឯកសិទ្ធិឃើញនិងស្តាប់ការបង្រៀនដ៏ច្រើនពីព្រះរាជបុត្រាតែ១របស់ព្រះជាម្ចាស់ គេបានក្លាយជាមនុស្សមានចិត្តរឹងទាស់នឹងព្រះគុណព្រះ។ នេះគឺជាការពិតសម្រាប់បច្ចុប្បន្នដែរ។ បណ្តាប្រទេសជាគ្រីស្ទានច្រើនជាងគេបំផុតសព្វថ្ងៃ ដូចជាប្រទេសលោកខាងលិច អាចរាប់ទុកថាជាប្រទេសគ្រីស្ទាន។ បើតាមការពិត ប្រទេសទាំងនោះមានអត្រាគ្រីស្ទបរិស័ទតិចបំផុត បើប្រៀបនឹងប្រទេសពុំសូវអភិវឌ្ឍន៍ដែលទើបតែចាប់ផ្តើមបើកទ្វារឲ្យផ្សព្វផ្សាយដំណឹងល្អ។ តើនោះគឺជាស្ថានភាពជាក់ស្តែងនៃចិត្តគំនិតរបស់អ្នកដែរ ជាពិសេសដែលអ្នកជាគ្រីស្ទបរិស័ទជំនាន់ទីបីនិងទីបួន? «អ្នកមុននឹងត្រឡប់ជាក្រោយ»។

ប៉ុន្តែតែងតែនៅមានអ្នកជឿមួយចំនួន សូម្បីតែក្នុងចំណោមពួកអ្នកដ៏មានចិត្តរឹងមានៈ។ វាគឺជាការគួរឲ្យពេញចិត្តដើម្បីកត់សម្គាល់ថាចំណោមពួកគេ ក្រៅពីលោកនីកូដេម (យ៉ូហាន ៧:៥០) គឺមានអ្នកដឹកនាំជាច្រើននាក់ទៀតបានជឿទ្រង់ដោយសម្ងាត់ផងដែរ (យ៉ូហាន ១២:៤២)។ មិត្តអ្នកអានជនជាតិថ្មីប តើលោកអ្នកគឺជាអ្នកជឿដោយសម្ងាត់ដែរឬ?

ពាក្យព្រមានមុនពេលព្រះគ្រីស្ទបញ្ចប់ដំណាក់កាលនៃព័ន្ធកិច្ចសាធារណៈរបស់ទ្រង់នេះគឺ «អ្នកណាដែលជៀសបង់ចោលខ្ញុំ ហើយមិនទទួលពាក្យខ្ញុំ អ្នកនោះមានចៅក្រមដែលកាត់ទោសខ្លួនហើយ គឺជាពាក្យដែលខ្ញុំបាននិយាយនោះឯងពាក្យនោះនឹងកាត់ទោសដល់គេ នៅថ្ងៃចុងបំផុត» (ខ ៤៨)។ នេះឆ្លុះបញ្ចាំងឲ្យឃើញពីពាក្យព្រមានដាស់តឿនរបស់ទ្រង់កាលពីមុន «ពីព្រោះបើមិនជឿថា ខ្ញុំនេះជាព្រះ នោះអ្នករាល់គ្នានឹងស្លាប់ក្នុងអំពើបាបរបស់ខ្លួនពិតមែន» (យ៉ូហាន ៨:២៤)។

*មានបន្ទាត់គូសបដិសេធព្រះអម្ចាស់នៃយើង*
*ជាគំនូសហៅនាមឈ្មោះព្រះវិញ្ញាណបាត់*
*ហើយអ្នកកាន់រួសឈ្លក់នឹងក្តីសប្បាយសាច់ឈាមហួស*
*តើអ្នកនឹងស្តាលក្រោយទេ ស្តាយដែរឬទេ?*

**ការពិចារណា៖** «អ្នកមុននឹងត្រឡប់ជាក្រោយ»
**ការអធិស្ឋាន៖** ឱសូមដាស់តឿនយើងខ្ញុំផង ( ចម្រៀងទំនុកដំកើង ៩១ )

# ជំពូកទី ១៣

## ចំពោះសិស្សបានស្អាត ព្រះយេស៊ូវគ្រីស្ទនៅតែអ្នកសម្អាតជីវិតរបស់គេជានិច្ច

វាគឺជាការចាំបាច់ដើម្បីកត់សម្គាល់ពីព្រឹត្តិការណ៍នៃសប្តាហ៍បរិសុទ្ធ ជាថ្ងៃចុងក្រោយនៃជីវិតនាលើផែនដីរបស់ព្រះអម្ចាស់នៃយើងដែលមានកំណត់ត្រាដ៏ធំក្នុងសៀវភៅនិមួយៗនៃដំណឹងល្អទាំងបួន។ លោកយ៉ូហានចំណាយជាងពាក់កណ្តាល់នៃសៀវភៅរបស់គាត់ជាពិសេសសម្រាប់សកម្មភាពនិងសេចក្តីបង្រៀនរបស់ព្រះយេស៊ូវដែលមិនឃើញមាននៅក្នុងដំណឹងល្អដទៃទៀត។ ដំណឹងល្អយ៉ូហានជំពូកទី៣ ជាករណីដូចបានលើកឡើងខាងលើនេះ។ ដូច្នេះទើបដំណឹងល្អជាសង្ខេប (ម៉ាថាយ ម៉ាកុស និង លូកា) ប្រាប់យើងតិចឬច្រើនពីព្រឹត្តិការណ៍នៃការតែងតាំងពិធីលៀងព្រះអម្ចាស់ដូចគ្នានេះ ហើយអ្នកបន្ថែមកំណត់ត្រានោះគឺជាលោកយ៉ូហានដែលផ្តល់ព័ត៌មានដ៏លំអិតអំពីព្រះយេស៊ូវលាងជើងឲ្យពួកសិស្ស។

ប្រសិនបើរាល់ការលាងសម្អាតជើងគឺជាសុជីវធម៌ចាំបាច់ត្រូវធ្វើនាឱកាសដូចជាការរក្សាពិធីបុណ្យរំលងក្នុងបន្ទប់លើផ្ទះម្តាយរបស់លោកម៉ាកុស ពួកសាវ័កគួរជាអ្នកត្រូវលាងសម្អាតជើងគ្រូរបស់ខ្លួន។ ផ្ទុយទៅវិញ ពួកគេគឺហាក់បីដូចជាក្មេងរបិលរប៉ូចមួយក្រុមដែលកំពុងប្រជែងគ្នាធ្វើជាអ្នកលេខ១ (ម៉ាថាយ ២២:២៤-២៧)។ ការដែលធ្វើឲ្យកាន់តែអាក្រក់ថែមទៀតនោះគឺនៅតុអាហាររបស់ព្រះអម្ចាស់មានគោលបំណងដ៏ខ្មៅកខ្វក់របស់យូដាស-អ៊ីស្ការីយ៉ុត ជាជនក្បត់បានរៀបចំគម្រោងការឡើង។ ទុកជាការបង្ហើបឲ្យដឹង «ឯអ្នករាល់គ្នាក៏បានស្អាតហើយ តែមិនមែនទាំងអស់គ្នាទេ»។ នេះព្រោះទ្រង់ជ្រាបពីអ្នកនឹងក្បត់ព្រះអង្គ។ ដូច្នេះទើបទ្រង់បានមានបន្ទូលថា «អ្នករាល់គ្នាមិនមែនស្អាតគ្រប់គ្នាទេ»។ ការលាងសម្អាតជើងឲ្យពួកគេ ព្រះយេស៊ូវបង្រៀនមេរៀនដ៏ចាំចាច់ពីការបន្ទាបខ្លួននិងភាពស្មោះត្រង់ដល់គេ។ «មនុស្សអួតខ្លួន» បុព្វជិតអ៊ូហ្គាស្ទីនបានមានប្រសាសន៍ថា «នឹងវិនាសអន្តរាយលុះត្រាតែព្រះដ៏បន្ទាបខ្លួនរកគាត់ឃើញ»។ ដូចនេះចូរយើងរៀនមេរៀននេះដែរ ហើយលាងសម្អាតជើងឲ្យគ្នាទុកជាការលើកដំកើងនិងការអត់ទោសគ្នាទៅវិញទៅមក នៅក្នុងកិច្ចបម្រើស្មោះត្រង់ចំពោះព្រះអម្ចាស់។

ក្រុមគ្រីស្ទានខ្លះអនុវត្តការលាងសម្អាតជើងនៅក្នុងន័យត្រង់ដូចគណៈនិកាយសិរិនដេ អែតវិនទីស្ទ (*the Seventh Day Adventists*) ជាដើម។ សម្តេចប៉ាបនឹងលាងសម្អាតជើងសមាជិកព្រះវិហារចំនួនដប់ពីរនាក់ក្នុងអំឡុងសប្តាហ៍បរិសុទ្ធ។ ពិធីបុណ្យពិសិដ្ឋដែលគេប្រារព្ធធ្វើនេះព្រោះគេបានយកពាក្យបន្ទូលរបស់ព្រះយេស៊ូវនៅក្នុងន័យត្រង់។ យើងមិនអនុវត្តការលាងសម្អាតជើងទេព្រោះយើងទទួលយកខ្លឹមសារនៃមេរៀនដាក់ទុកក្នុងចិត្តជាជាង។ នៅក្នុងកិច្ចបម្រើដ៏បរិសុទ្ធថ្វាយដល់ព្រះអម្ចាស់ យើងក៏មិនហ៊ានប្រព្រឹត្តតាមផ្លូវនៃឈើឆ្កាង ដោយឥតបានលាងសម្អាតជើងយើងជាមុនដែរ។ សូមកុំឲ្យយើងដូចជា «មនុស្សល្ងង់ស្ទុះទៅក្នុងកន្លែងដែលពួកទេវតាមិនហ៊ានទៅ» នោះឡើយ។ ជីវិតបរិសុទ្ធនិងកិច្ចបម្រើដ៏ស្មោះត្រង់ទាំងពីរនេះគឺកំពុងតែខ្វះខាតនៅក្នុងបណ្តាពួកជំនុំនាបច្ចុប្បន្ននេះ។ តើអ្នកនឹងឈរនឹងខ្នាតរង្វាស់របស់ព្រះដែលព្រះអម្ចាស់នៃយើងបង្កើតឡើងនាពេលទ្រង់ឱនចុះលាងសម្អាតជើងរបស់អ្នកដែរឬទេ?

**ការពិចារណា៖**«មនុស្សអួតខ្លួននឹងវិនាសអន្តរាយ លុះត្រាតែព្រះដ៏បន្ទាបខ្លួនរកគាត់ឃើញ» (អ៊ូហ្គាស្ទីន)។
**ការអធិស្ឋាន៖** ព្រះអង្គអើយ សូមឲ្យការបន្ទាបខ្លួននៃព្រះយេស៊ូវជាគំរូដល់យើង។

*«ដូច្នេះដែលទ្រង់បានស្រឡាញ់ដល់ពួកទ្រង់នៅក្នុងលោកីយនេះ នោះទ្រង់ក៏ចេះតែស្រឡាញ់គេ ដរាបដល់ចុងបំផុត»។*

## សេចក្តីស្រឡាញ់អ្វីហ្នឹង!

មានសុភាសិតចិនមួយពោលថា៖ «មុនពេលមនុស្សម្នាក់ស្លាប់ ពាក្យរបស់គាត់គឺជាសម្តីមាស»។ អត្តចរឹករបស់គាត់ចំពោះមិត្តភក្តិគឺស្រាប់តែប្រែទៅជាល្អ។ ចំណែកព្រះហឫទ័យនៃព្រះអម្ចាស់យើងវិញគឺនឹងល្អជាងជាងនោះទៅទៀត។ ទ្រង់ជាអង្គបុគ្គដែលបានបញ្ជូនពីព្រះមកបំពេញបេសកកម្មមួយដើម្បីសង្គ្រោះលោកីយបាត់បង់។ ជាអង្គដែលត្រូវបានបញ្ជូនមកដើម្បីសុគតជំនួសសេចក្តីស្លាប់របស់យើង មួយដងជាសម្រេចប្រយោជន៍ឲ្យយើងបានរំដោះចេញពីសេចក្តីស្លាប់ហើយមានជីវិតជារៀងរហូត!

ដើម្បីផ្សព្វផ្សាយដំណឹងល្អអំពីព្រះគុណប្រោសលោះរបស់ទ្រង់ដល់មនុស្សជាតិដែលកំពុងស្លាប់ ព្រះអង្គបានជ្រើសរើសសិស្សដប់ពីរនាក់ ហើយបានបង្ហាត់បង្រៀនពួកគេរយៈពេលបីឆ្នាំកន្លះ។ ទ្រង់បានសោយអាហារនិងផ្ទុំព្រមទាំងយាងជាមួយនឹងពួកគេខណៈពេលទ្រង់ប្រកាសនិងបង្រៀនពាក្យបន្ទូលទូទាំងទឹកដីស្រុកយូដា។ ជាភាពមិត្តសម្លាញ់អ្វីហ្នំ ជាចំណងសប្បុរសជាបងប្អូនអ្វីដែលចងភ្ជាប់រវាងព្រះអម្ចាស់និងពួកសិស្សបានបង្កើននិងបានជ្រាលជ្រៅនាពេលជាច្រើនឆ្នាំនោះ។ សេចក្តីស្រឡាញ់ជាបងប្អូនដ៏មិនអាចពិពណ៌នានោះ «ហួសជាងសេចក្តីស្រឡាញ់របស់ស្ត្រីភេទ» មានតែស្តេចដាវីឌទេដែលអាចសម្តែងពីជម្រៅដ៏មិនអាចប៉ាន់ស្មានបាននាមរណៈភាពរបស់យ៉ូណាថាន់ (២ សាំយូអែល ១:២៦)។ សេចក្តីស្រឡាញ់នេះត្រូវបានយ៉ូហានជាសិស្សសំណព្វសរសេរឡើងវិញទាក់ទងនឹងព្រះអម្ចាស់គាត់នាពេលចុងក្រោយនៃជីវិតលើផែនដីរបស់ទ្រង់ថា «ដូច្នេះដែលទ្រង់បានស្រឡាញ់ដល់ពួកទ្រង់នៅក្នុងលោកីយនេះ នោះទ្រង់ក៏ចេះតែស្រឡាញ់គេ ដរាបដល់ចុងបំផុត» (យ៉ូហាន ១៣:១)។ បណ្ឌិតដេវីដ ស្មីត ព្យាយាមពិពណ៌នាពីសេចក្តីស្រឡាញ់នេះយ៉ាងដូច្នេះថា៖ «ដោយបានស្រឡាញ់ពួកគេដល់ទីបំផុត ដូចជាទ្រង់បានស្រឡាញ់ពីមុន។ វាគឺជាការចាកចេញដ៏ទន់ភ្លន់ ហើយព្រះទ័យរបស់ទ្រង់គឺពោរពេញរហូតដល់ហូរ ហៀរចេញនៅពេលពួកគេបានប្រជុំគ្នានាយប់នោះសម្រាប់ពេលជាចុងក្រោយនៅក្នុងបន្ទប់លើផ្ទះ។ ពីដំបូងឡើយភាពទន់ភ្លន់របស់ទ្រង់គឺត្រូវបានល្បងលយ៉ាងធ្ងន់ក្រៃ។ លោកលូកាបានប្រាប់យើង (២២:២៤-៣០) ពីជម្លោះដែលបានកើតមានឡើងក្នុងចំណោមសិស្សទាំងដប់ពីរនាក់អំពីអ្នកណាដែលនឹងធំជាងគេ ហើយត្រង់ចំណុចនេះសាវ័កយ៉ូហានបង្ហាញពីឱកាសនោះ»។

យកសេចក្តីស្រឡាញ់ដ៏ទន់ភ្លន់របស់ព្រះគ្រីស្ទចំពោះពួកសិស្សមកអនុវត្តសម្រាប់យើងដែលហាក់ដូចនៅឆ្ងាយពីទ្រង់ លោកកាល់វិនមានប្រសាសន៍ថា៖ «ចូរយើងដឹងថាព្រះអង្គគឺមានព្រះទ័យយកចិត្តទុកដាក់ដល់យើង ព្រោះទ្រង់ស្រឡាញ់ពួកទ្រង់ដែលនៅលោកីយ។ ទ្រង់ក៏នៅតែមានអត្តចរិតដូចគ្នានោះនាពេលជួបវិប្បត្តិនៃការសុគតរបស់ទ្រង់ដែរ»។ ដូច្នេះ នៅពេលអ្នកមានអារម្មណ៍ឯកកោ ត្រូវបានគេបោះបង់ ត្រូវបានគេប្រមាថមើលងាយ សូមចងចាំពីការនេះថា ព្រះអង្គដែលមានសេចក្តីស្រឡាញ់ចំពោះយើងគឺមានអំណាចខ្លាំងជាងសេចក្តីស្លាប់នឹងរំដោះយើងឲ្យរួចរហូតដល់ទីបំផុតជាមិនខាន។

*ជីវិតមានពេញដោយក្តីទុក្ខនិងកង្វល់*
*ចិត្តនៅឯកកោនិងភ័យភិត*
*បន្ទុកផ្ទេរនៅកាល់វ៉ារី*
*ព្រះយេស៊ូវគង់ជិតបង្កើត។ (Burden Lifted at Calvary)*

**ការពិចារណា៖** យើងស្រឡាញ់ព្រះ ព្រោះទ្រង់បានស្រឡាញ់យើងជាមុន។

**ការអធិស្ឋាន៖** ព្រះអម្ចាស់អើយ យើងខ្ញុំស្គាល់សេចក្តីស្រឡាញ់ទ្រង់ច្បាស់នាលើឈើឆ្កាងនៃកាល់វ៉ារី។

ថ្ងៃទី ២៥ កញ្ញា
យ៉ូហាន ១៣:២-៣

*«...ព្រះយេស៊ូវបានជ្រាបថា ព្រះវរបិតាបានប្រគល់ការទាំងអស់មកក្នុងព្រះហស្តទ្រង់ ហើយថាទ្រង់មកពីព្រះ ក៏ត្រូវទៅឯព្រះវិញ»។*

## ការអធ្យាស្រ័យអ្វីហ្ន៎!

ខ២និងខ៣ គួរតែផ្ដល់ការយល់ដឹងអំពីអធ្យាស្រ័យរបស់ព្រះយេស៊ូវគ្រីស្ទ។ តើមានថ្នាក់ដឹកនាំណាម្នាក់អាចអត់ធន់នឹងជនក្បត់ម្នាក់ក្រោយពីបានរកឃើញគម្រោងការក្បត់របស់ជននោះដែរឬទេ? ខទី២ប្រាប់យើងថាយូដាស-អ៊ីស្ការីយ៉ុតពុំទាន់បានសម្រេចផែនការក្បត់ព្រះអម្ចាស់របស់គាត់នៅឡើយ ខណៈពេលអាហារពេលយប់មិនទាន់ចប់សព្វគ្រប់។ ព្រះអង្គដែលពិនិត្យមើលរាល់ចិត្តគំនិត និងមិនមើលតែអាការៈខាងក្រៅ ទ្រង់ជ្រាបដឹងពីគម្រោងការអាក្រក់ដោយពុំចាំចាច់ក្រឡេកមើល។ តើមិនមែនព្រះសង្គ្រោះ បង្ហើបប្រាប់ខ្លះៗពីគ្រោះថ្នាក់នៅពេលទ្រង់មានបន្ទូលនាចុងបញ្ចប់ការបង្រៀនដ៏វែងរបស់ទ្រង់អំពីនំបុ័ងជីវិត «តើខ្ញុំមិនបានរើសអ្នករាល់គ្នា ជាពួក១២នាក់ទេឬអី តែមានម្នាក់ក្នុងពួកអ្នករាល់គ្នាជាអារក្សវិញ? នេះគឺទ្រង់មានបន្ទូលពីយូដាស-អ៊ីស្ការីយ៉ុត ជាកូនស៊ីម៉ូន ដែលនៅក្នុងពួក១២នាក់នោះ ដ្បិតវារៀបនឹងបញ្ជូនទ្រង់ទៅ (យ៉ូហាន ៦:៧០-៧១)។

ថ្វីដ្បិតតែមានការបះបោរក្នុងចិត្តរបស់យូដាស ក៏ព្រះយេស៊ូវទ្រង់បន្តរក្សាភាពស្ងៀមស្ងាត់និងទ្រាំព្រះហឫទ័យលាងសម្អាតពួកសិស្សគឺជាជើងរបស់ពួកគេរួមទាំងសិស្សក្បត់ផងដែរ។ ការធានាពីព្រះវរបិតាពីអំណាចជាសាកលដែលបានប្រទានដល់ទ្រង់និងការជ្រាបដឹងនូវភាពជាព្រះរបស់ទ្រង់ ហើយនិងដំណើរនិវត្តន៍ទៅឯព្រះជាម្ចាស់វិញធានានូវសុវត្ថិភាពទ្រង់ពីការរំខានតូចតាចផ្សេងៗ។

បើមានមនុស្សណាម្នាក់ដែលអាចយល់ពីភាពស្ងៀមស្ងាត់តែបន្តិចរបស់ទ្រង់ នោះប្រាកដជាគ្មានអ្នកណាក្រៅពីដាវីឌជាបុព្វការី ជាមហារាជាដាវីឌនោះឡើយ។ ស្ដេចដាវីឌ ទ្រង់បានគ្រងរាជ្យលើ អ៊ីស្រាអែលប្រកបដោយសន្តិភាព ទោះបីមានផែនការក្បត់របស់យ៉ូអាបនិងអាហិតូផែល។ តើយើងអាចរៀនមេរៀនពីការអធ្យាស្រ័យរបស់ព្រះអម្ចាស់នៃយើងហើយទុកឱកាសឲ្យមនុស្សអាក្រក់ដែរឬទេ? សូម្បីតែនៅវេលាដែលហាក់ដូចជាទាល់ច្រកគ្មានសេចក្ដីសង្ឃឹម? កំណាព្យជនជាតិអង់គ្លេសពិតជាត្រូវមែន «*ធ្វើខុសជានិស្ស័យមនុស្ស អត់ទោសជានិស្ស័យព្រះ*»។

សូមអានទំនុកដំកើង៤១ដោយចិត្តទុកដាក់ ហើយស្វែងរកសម្រាប់ខ្លួនអ្នកនូវភាពខុសប្លែកគ្នានៃចិត្តសាស្ត្រដែលមានតួនាទីក្នុងជីវិតស្ដេចដាវីឌក្នុងចំណោមមិត្តសម្លាញ់និងសត្រូវក្នុងនគររបស់ទ្រង់។ ចូររៀនពីទ្រង់និងពីព្រះអម្ចាស់នៃយើងពីរបៀបស្វែងរកជនក្បត់។ តែសូមប្រយ័ត្នកុំឲ្យខ្លួនអ្នកក្លាយជាជនក្បត់។ នៅក្នុងក្រមច្បាប់មនុស្សជាតិ (*codified human law*) អំពើក្បត់ប្រឆាំងនឹងព្រះរាជាគឺត្រូវបានដាក់ជាបទល្មើសលេខ១។ ការក្បត់ប្រឆាំងនឹងមហាក្សត្រដ៏ជាព្រះគឺពិតជាអំពើបាបមិនអាចអត់ទោសបាន ដរាបណាមិនមានការថ្កោលទោសខ្លួនឯងដោយការធ្វើអត្តឃាត។

អ៎ូ ពិតជាការអធ្យាស្រ័យដ៏ការអធ្យាស្រ័យរបស់ព្រះអម្ចាស់ជាព្រះនៃយើងមែន!

**ការពិចារណា៖** «ធ្វើខុសជានិស្ស័យមនុស្ស អត់ទោសជានិស្ស័យព្រះ»។
**ការអធិស្ឋាន៖** ឱព្រះអង្គអើយ «សូមអត់ទោសសេចក្ដីកំហុសរបស់យើង ដូចជាយើងខ្ញុំបានអត់ទោស ដល់អ្នកដែលធ្វើខុសនឹងយើងខ្ញុំដែរ» (ម៉ាថាយ ៦:១២)។

ថ្ងៃទី ២៦ កញ្ញា

យ៉ូហាន ១៣:១៤-១៥ *«សូមកុំលាងត្រឹមតែជើងទូលបង្គំប៉ុណ្ណោះឡើយ គឺសូមលាងដល់ដៃទាំងក្បាលផងចុះ»។*

## សារៈសំខាន់ពីរយ៉ាងនៃការលាងសម្អាតជើង

«ការដែលខ្ញុំធ្វើ នោះអ្នកមិនយល់ក្នុងពេលឥឡូវនេះទេ តែទៅមុខទើបនឹងបានយល់វិញ» (ខ ៧)។ ដូចជាយើងបានពិនិត្យឃើញកាលពីមុនរួចហើយថាកិច្ចការដែលព្រះយេស៊ូវបានធ្វើនាពេលបណ្ដាលឲ្យពួកសិស្សទ្រង់ភ្ញាក់ផ្អើល គឺជាការលាងសម្អាតជើង ដែលតាមពិតពីដំបូងឡើយពួកគេគួរជាអ្នកធ្វើការនោះចំពោះព្រះអម្ចាស់។

ពេលយើងពិនិត្យព្រឹត្តិការណ៍បរិសុទ្ធពីចម្ងាយ យើងនឹងអាចយល់កាន់តែច្បាស់នូវសារៈសំខាន់របស់វា៖

(១). ពួកសិស្សដែលបានមកទុកចិត្តលើព្រះសង្គ្រោះបានលាងសម្អាតរួចជាស្រេចហើយ លើកលែងតែជើងរបស់គេប៉ុណ្ណោះ។ នេះប្រាប់ឲ្យដឹងពីការប្រឡាក់មិនស្អាតជាមួយនឹងលោកីយ៍ក្នុងជីវភាពប្រចាំថ្ងៃរបស់ពួកគេ។ យើងត្រូវការចូលមកឯព្រះយេស៊ូវ ដើម្បីលាងសម្អាតពីការប្រឡូកប្រឡាក់បែបនោះទុកជាការមិនស្អាតជាមុនសិននៅពេលយើងចូលមកឯតុនៃព្រះអម្ចាស់។ ការច្រណែន សេចក្ដីអំណួត ការសង្ស័យ និងការនិយាយដើមគេគឺជាអំពើបាបខាងឯចិត្តគំនិត ដែលពិសពុលជាងសេចក្ដីប៉ងប្រាថ្នារបស់សាច់ឈាមទៅទៀត។

(២). ពួកសិស្សដូចជានិស្សិតមហាវិទ្យាល័យ ជាអនុសេនីយត្រីដ៏ទុកចិត្តម្នាក់ដែលពេលនេះបានក្លាយទៅជាច្របូកច្របល់ដោយសារការផ្ដាច់ខ្លួនដូចជាយូដាស-អ៊ីស្ការីយ៉ុត។ ដូចនេះ ពួកគេគឺមិនទាន់ស្អាតនៅឡើយ។ យើងត្រូវការពារជានិច្ចនូវកូនទាហាននៃកងទ័ពរបស់ព្រះអម្ចាស់ដើម្បីកុំឲ្យគេរត់ចោលជួរ។ ដោយវិធីណា? តាមរយៈការលាងសម្អាតជើងឲ្យគ្នាទៅវិញទៅមក។ យើងគួរលាងជើងគ្នាទៅវិញទៅមកប្រសិនបើព្រះអម្ចាស់បានបន្ទាបខ្លួនលាងសម្អាតជើងពួកសិស្សទ្រង់ ។ យើងត្រូវឈានមករកសាមគ្គីគ្នាក្នុងពន្ធ័កិច្ចរបស់ពួកជំនុំ។ ចំពោះគណៈកម្មាធិការព្រះវិហារណាដែលនិយាយអាក្រក់ពីគ្រូគង្វាល ហើយនិងគ្រីស្ទបរិស័ទណាម្នាក់ដែលនិយាយបង្ខូចព្រះវិហារខ្លួនឯងដោយគ្មានមូលហេតុត្រឹមត្រូវគឺជាអំពើក្បត់។ សូមកុំឲ្យយើងក្លាយទៅជាមិនស្មោះត្រង់ចំពោះអ្នកដែលយើងបម្រើក្នុងនគររបស់ព្រះឡើយ។

លោកស៊ីម៉ូន-ពេត្រុស ទោះបីជាមិនយល់ពីសារៈសំខាន់នៃពាក្យបន្ទូលរបស់ព្រះយេស៊ូវ ក៏ពាក្យរបស់គាត់គឺល្អត្រឹមត្រូវនៅពេលគាត់មានប្រសាសន៍ថា៖ «សូមកុំលាងត្រឹមតែជើងទូលបង្គំប៉ុណ្ណោះឡើយ គឺសូមលាងដល់ដៃទាំងក្បាលផងចុះ» (ខ ៩)។ ចូរយើងបន្ថែម «ទាំងចិត្ត និងពោះវៀនខ្ញុំផង»។ តើអ្នកបានលាងដោយលោហិតនៃកូនចៀមនៃព្រះហើយឬនៅ?

*ព្រះអង្គមានព្រះចេស្ដាអាចប្រោសអ្នកបាន*
*លោហិតទ្រង់អាចសំអាត..ចិត្តអ្នកពុំខាន*
*ព្រះទ័យស្រឡាញ់នឹងមកពោរពេញចិត្តអ្នក*
*ឲ្យឃើញថាការចុះចូលជានឹងស្រួលពាក់*។ (*ទំនុកដំកើងលេខ ១៦២*)

**ការពិចារណា៖** ដៃស្អាត ចិត្តបរិសុទ្ធ ជាតម្រូវការដ៏ចាំបាច់ដើម្បីបម្រើព្រះដ៏បរិសុទ្ធ។

**ការអធិស្ឋាន៖** ឈាមទ្រង់ក៏លាងខ្ញុំអោយឥតសៅហ្មង សរសើរព្រះនាមទ្រង់!

## អំពើក្បត់របស់យូដាសជាប្រផ្នូលក្នុងជីវិតរបស់ដាវីឌ

ស្តេចដាវីឌ ជាបុព្វការីជនរបស់ព្រះយេស៊ូវគ្រីស្ទ នៅក្នុងករណីជាច្រើនបានសម្តែងប្រាប់លក្ខណៈជានិម្មិតរូបពីព្រះបុត្រាដ៏អស្ចារ្យរបស់ទ្រង់។ នៅពេលព្រះយេស៊ូវជាព្រះអម្ចាស់នៃយើងត្រូវបានយូដាសក្បត់ ដែលគាត់ជាបេឡាធិការនិងជាអ្នកម្នាក់ក្នុងចំណោមសិស្សទាំងដប់ពីរនាក់ ស្តេចដាវីឌក៏ត្រូវ បានមិត្តសម្លាញ់របស់គាត់និងជាទីប្រឹក្សាឈ្មោះអ័ហ៊ីតូផែលក្បត់ទ្រង់ដែរ។

តើដាវីឌបានអានទំនុកដំកើង ៤១ ដែរឬទេ? តើអ្នកមិនដឹងពីខ ១៨ «ប៉ុន្តែបទគម្ពីរដែលថា អ្នកដែលបរិភោគនំបុ័ង ជាមួយនឹងទូលបង្គំនោះបានលើកកែងជើងទាស់នឹងទូលបង្គំវិញ ពាក្យនោះត្រូវបានសំរេច» គឺសំដៅទៅលើទំនុកដំកើង៤:១៩? ខណៈពេលដាវីឌត្អូញត្អែដល់ព្រះជាម្ចាស់ ក្នុងទំនុកដំកើងនេះអំពីសត្រូវរបស់ទ្រង់ ជាក់ស្តែងទ្រង់បានលើកយកករណីលោកអ័ហ៊ីតូផែលនៅក្នុងខនេះ (ម៉ាតជូ ហិនរី)។

តើអ័ហ៊ីតូផែលគឺជាអ្នកណា? ចំពោះដាវីឌគាត់ជាខ្សែរាជវង្សគឺ ដូចជាប្រធានាធិបតី និកហ្សុន។ ២ សាំយូអែល ១៦:២៣ ចែងពីអ័ហ៊ីតូផែល «ឯគំនិតរបស់អ័ហ៊ីតូផែល ដែលសំដែងមកនៅគ្រានោះ ក៏ដូចជាអ្នកណាបានទូលសួរចំពោះហើយ ឯការដែលលោកជួយគំនិត ដល់ទាំងដាវីឌ នឹងអាប់សាឡុំមផង ក៏យ៉ាងនោះទាំងអស់»។

នៅពេលអាប់សាឡុមបះបោរទាស់នឹងដាវីឌជាបិតាខ្លួន អ័ហ៊ីតូផែលបានចូលរួមគាំទ្រកូនបះបោរនេះ។ «ប៉ុន្តែបទគម្ពីរដែលថា អ្នកដែលបរិភោគនំបុ័ង ជាមួយនឹងទូលបង្គំនោះបានលើកកែងជើងទាស់នឹងទូលបង្គំវិញ» តើព្រលឹងវិញ្ញាណនឹងគ្រាំគ្រាយ៉ាងណានៅគ្រាដាវីឌឃើញថាខ្លួនគាត់ហាក់ដូចជាត្រូវបានគេចាក់ចំកណ្តាលខ្នង! តើជាការគ្រាំគ្រាខាងផ្នែកព្រលឹងវិញ្ញាណយ៉ាងណាដែរក្នុងករណីព្រះអម្ចាស់នៃយើងពេលយើងអានយ៉ូហាន ១៣:២១ជាថ្មីម្តងទៀត។

តើហេតុដូចម្តេចបានជាសិស្សត្រូវក្បត់គ្រូរបស់ខ្លួន? អាថ៌កំបាំងដ៏ជ្រៅនេះគឺប្រាប់ជាលក្ខណៈស្រយោលនៅក្នុងខ១៦។ នៅពេលសិស្សម្នាក់បានព្យាយាមចង់ធ្វើ «ធំជាង» គ្រូរបស់ខ្លួន។ នៅពេលឆន្ទៈរបស់ខ្លួនឡើងខ្ពស់ជាឆន្ទៈនៃព្រះអម្ចាស់របស់ខ្លួន។ តើអ្នកប្រតិកម្មបែបណាចំពោះពាក្យណែនាំរបស់ថ្នាក់លើរបស់អ្នក? តើអ្នកធ្វើការយ៉ាងដូចម្តេចដែរជាមួយនឹងចៅហ្វាយរបស់អ្នក? នៅក្នុងព្រះវិហារ តើអ្នកបំពេញកិច្ចការព្រះអម្ចាស់ជាមួយនឹងគ្រូគង្វាលរបស់អ្នក ជាមួយនឹងចាស់ទុំ អ្នកគ្រប់គ្រងតាមផ្នែកណាមួយ និងអ្នកដែលមានវ័យចំណាស់ក្នុងការងារយ៉ាងដូចម្តេចដែរ? នេះគឺជាសំណួរមួយដែលជារឿយៗត្រូវបានសួរលក្ខណៈជាសម្ងាត់ដល់មជ្ឈការ (អ្នកអព្យាក្រិត) អំពីបុគ្គលដែលស្វែងរកការងារជាមួយនឹងគ្រឹះស្ថាននានា។ ការរឹងមានៈនឹងបណ្តាលទៅអំពើក្បត់! សូមកុំក្លាយទៅជាអ័ហ៊ីតូផេល។ កុំឲ្យធ្វើជាយូដាស! «បាវមិនមែនធំជាងចៅហ្វាយទេ ហើយអ្នកបំរើក៏មិនធំជាងអ្នកដែលប្រើដែរ» (ខ ១៦)។

នៅក្នុងទំនុកដំកើង ៥៥ ដាវីឌមានបន្ទូលបន្ថែមពីជនក្បត់ថា៖ «មិនមែនជាខ្មាំងសត្រូវដែលបកកេរខ្ញុំយ៉ាងនោះខ្ញុំនឹងធន់ទ្រាំបាន ក៏មិនមែនជាអ្នកស្អប់ខ្ញុំដែលលើកខ្លួនទាស់នឹងខ្ញុំ នោះខ្ញុំនឹងពួនខ្លួនឲ្យរួចពីគេ។ គឺជាអ្នកឯងវិញ ជាមនុស្សស្មើគ្នានឹងខ្ញុំ ជាភឿន ហើយជាសំឡាញ់ស្និទ្ធស្នាលនឹងខ្ញុំ...។ មាត់គេរតលជាងខ្លាញ់ តែចិត្តគេមានពេញដោយការចំបាំងវិញ វាចារគេទន់ល្ងន់ជាងប្រេង ប៉ុន្តែពាក្យទាំងនោះសុទ្ធតែជាដាវហូតស្រាប់ (ខ ១២, ១៣, ២១)។

**ការពិចារណា៖** ជំនឿគ្រីស្ទបរិស័ទត្រូវតែក្តៅងំដូចជារងើកធ្យូង មិនត្រូវក្តៅដូចរងើកភ្លើងសំបើងឡើយ។
**ការអធិស្ឋាន៖** ព្រះវរបិតាអើយ សូមឲ្យខ្ញុំស្មោះត្រង់នឹងទ្រង់ទាំងពាក្យសម្តីនិងចិត្តគំនិតផងដែរ។

## ព្រះយេស៊ូវបន្ទាបអង្គទ្រង់តែដើម្បីជ័យជំនះ

សេចក្តីសប្បុរសដ៏អស្ចារ្យនៃព្រះយេស៊ូវគ្រីស្ទគឺត្រូវបានសម្តែងឲ្យឃើញកាន់តែច្បាស់នៅពេលនិងបន្ទាប់ពីការលាងសម្អាតជើងរបស់សាវកទាំងអស់ រួមទាំងសិស្សក្បត់ដែរ។ ព្រះអង្គបានប្រទាននំបុ័ងមួយចំណិតដល់យូដាស។ នំបុ័ងមួយចំណិតជ្រលក់ក្នុង «ទឹកជ្រលក់» (ទឹកជ្រលក់ធ្វើពីផ្លែឈើក្រៀមកិនលាយជាមួយនឹងទឹកខ្មេះ)។ វាគឺជាទំនៀមទំលាប់ពីបុរាណក្នុងការសម្តែងនូវសេចក្តីសប្បុរសដ៏ពិសេសនៅពេលម្ចាស់ផ្ទះចាប់យកអាហារជូនភ្ញៀវ (សូមមើល ១ សាំយូអែល ៩:២១-២៤) ដែលប្រៀបដូចជាជនជាតិចិនចាប់យកសាច់មួយដុំនឹងចង្កឹះជូនដល់មិត្តសម្លាញ់របស់គាត់ដូច្នោះដែរ។ ដូច្នេះនៅពេលព្រះអម្ចាស់នៃយើងបានប្រទាននំបុ័ងមួយចំណិតដល់យូដាស នោះគឺជាទង្វើនៃក្តីសប្បុរសជាចុងក្រោយរបស់ទ្រង់។ ព្រះយេស៊ូវបានបន្ទាបខ្លួនសម្រាប់ជ័យជំនះ។

បណ្ឌិត ដេវីឌ ស្មីត បានផ្តល់សេចក្តីអត្ថាធិប្បាយថា៖ «ព្រះអង្គបានមានបន្ទូលប្រាប់សិស្សក្បត់ថាគាត់នៅតែជាមនុស្សជាទីស្រឡាញ់ដល់ព្រះទ័យទ្រង់ដដែល ហើយពេលនេះទ្រង់ចង់ឲ្យគាត់បានប្រែចិត្ត ប្រយោជន៍ឲ្យគ្រប់ទាំងអំពើបាបនឹងត្រូវបានអត់ទោស។ តែគួរឲ្យស្តាយ! ការទទួចឲ្យប្រែចិត្តឥតទទួលបាននូវផលផ្លែអ្វីសោះ។ យូដាសបានទទួលនូវក្តីស្រឡាញ់ពីព្រះហស្តគ្រូដោយគ្មានបែរក្រោយ ហើយសេចក្តីស្រឡាញ់នោះជាការបោះត្រាពីនូវវិនាសកម្មរបស់គាត់។ វាបានកើតឡើងចំពោះរូបគាត់ដូចជាបានកើតឡើងចំពោះតារាបង្ហាញម៉ូឌ ហ្វ្រានសីស ស្ពីរ៉ា (*Francis Spira*) នាគ្រាគាត់បានបិទការទទួចហៅនិងទីសម្គាល់នៃព្រះវិញ្ញាណនៅពេលចុះហត្ថលេខាបដិសេធជំនឿ។ «ក្រោយមកគាត់បានសារភាពថា ខ្ញុំបានមានអារម្មណ៍ «របួសនៅក្នុងមនសិការរបស់ខ្ញុំដែលខ្ញុំមិនបានជាសះស្បើយចាប់តាំងពីពេលនោះមក។ មនសិការរបស់ខ្ញុំមិនដែលនៅជាម្ចាស់លើខ្លួនឯងឡើយចាប់តាំងពីព្រឹកដ៏អពមង្គលនោះ ការអាក្រក់នេះបានធ្វើឲ្យចិត្តទៅជាក្រៀមស្វិត»។ ហើយថ្វីត្បិតតែវាបានកើតមានយ៉ាងដូច្នេះដល់ជនក្បត់ដែលបានប្រមាថដល់ព្រះវិញ្ញាណបរិសុទ្ធនៃព្រះគុណ។ ព្រលឹងរបស់គាត់បានវិនាសអន្តរាយ»។ នេះគឺជាអ្វីដែលយ៉ូហានចង់មានន័យនៅពេលគាត់កត់ត្រាថា៖ បន្ទាប់ពីជ្រលក់នំបុ័ង នោះសាតាំងក៏បានសណ្ឋិតក្នុងគាត់។

អ្នកដែលខ្លាចស្លាប់នឹងស្លាប់មួយរយដង! អ្នកដែលបានត្រៀមខ្លួនដើម្បីស្លាប់ ហើយស៊ូឲ្យខ្លួនគាត់ត្រូវឲ្យគេក្បត់រហូតដល់ស្លាប់ គាត់នឹងមិនដែលស្លាប់ឡើយ! នេះគឺជាជ័យជំនះរបស់ទ្រង់ដែលជាអ្នកបានបន្ទាបខ្លួនតែដើម្បីជ័យជំនះ។ នេះហើយជាសិរីរុងរឿងរបស់ទ្រង់ និងតាមរយៈសិរីរុងរឿងទ្រង់នេះព្រះវរបិតាក៏បានទទួលនូវសិរីរុងរឿងផងដែរ។ នៅក្នុងការស្ម័គ្រចិត្តសុគតរបស់ព្រះគ្រីស្ទនៅលើឈើឆ្កាង ការផ្លាស់ប្រែដ៏អស្ចារ្យបានកើតមានឡើង ដូចជាកាល់វិនលោកមានប្រសាសន៍ថា «ការផ្តន្ទាទោសនៃមនុស្សទាំងអស់គឺត្រូវបានសម្តែងឲ្យឃើញច្បាស់ អំពើបាបត្រូវបានបំបាត់ចោល សេចក្តីសង្គ្រោះត្រូវបានស្តារឡើងវិញសម្រាប់មនុស្ស ជាសង្ខេបពិភពលោកទាំងមូលគឺត្រូវបានតាំងឡើងវិញនិងគ្រប់យ៉ាងក៏ត្រូវបានធ្វើឲ្យមានរបៀបរៀបរយផងដែរ។ ព្រះគ្រីស្ទបានសន្និដ្ឋានថាទ្រង់នឹងឈ្នះនូវជ័យជំនះដ៏មហាអស្ចារ្យតាមរយៈការសុគតរបស់ទ្រង់ ពីព្រោះគោលបំណងដ៏សំខាន់របស់ទ្រង់នៅក្នុងការនេះគឺដើម្បីថ្វាយសិរីរុងរឿង ដល់ព្រះវរបិតា។» ហាឡេលូយ៉ាព្រោះតែឈើឆ្កាង! ក៏ប៉ុន្តែចូរយើងគ្រប់រូបរៀនពីព្រះសង្គ្រោះដែលបានជាប់ឆ្កាងរបស់យើងដើម្បីធ្វើជាសេចក្តីសប្បុរសដល់អ្នកដែលជាសត្រូវរបស់យើងផងដែរ។

**ការពិចារណា៖** ចូរប្រយត្ន័នឹងបាបប្រឆាំងនឹងព្រះវិញ្ញាណបរិសុទ្ធ។

**ការអធិស្ឋាន៖** ឱព្រះវរបិតាអើយ សូមទ្រង់សម្លាប់និស្ស័យចាស់ខ្ញុំហើយឲ្យខ្ញុំរស់តាមនិស្ស័យថ្មីវិញ។

ថ្ងៃទី ២៩ កញ្ញា
យ៉ូហាន ១៣:៣៣-៣៨

*«...ត្រូវឲ្យស្រឡាញ់គ្នា ដូចជាខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ»។*

## ពេត្រុសជា ជាសាវ័កទុកចិត្តខ្លួនឯងខ្លាំងពេក

មានសុភាសិតចិនមួយបានពោលថា «ដូចជាផ្លូវឆ្ងាយស្ទង់ពីកម្លាំងសេះ ដូច្នេះការរាប់អានមិត្តសម្លាញ់យូរអង្វែងក៏មែងយល់ពីសន្តានចិត្តដែរ»។ យើងបានភ្លក់នូវរសជាតិនៃភាពល្វីងជូចត់ក្នុងជីវិតរបស់យូដាស ដែលអាកប្បកិរិយារបស់គាត់បង្ហាញឲ្យឃើញតាមរយៈអំពើក្បត់របស់គាត់ចំពោះព្រះអម្ចាស់នាការបរិភោគអាហារពេលយប់ចុងក្រោយនោះ។ ឥឡូវនេះយើងនឹងឃើញពីពេត្រុសជាមនុស្សទុកចិត្តខ្លួនឯង ជាអ្នកក្លាហាន ដឹកនាំសិស្សនៅសល់ទាំងដប់មួយនាក់ ដែលបានប្រែចិត្តត្រឡប់មកព្រះវិញ។ តើអ្នកគឺជាពេត្រុស?

ចូរយើងត្រឡប់ទៅដើមដំបូងវិញ «...នោះព្រះយេស៊ូវទ្រង់ជ្រាបថា ពេលកំណត់ដែលទ្រង់ត្រូវចេញពី លោកីយនេះទៅឯព្រះវរបិតាវិញ បានមកដល់ហើយ ដូច្នេះដែលទ្រង់បានស្រឡាញ់ដល់ពួកទ្រង់នៅក្នុងលោកីយនេះ នោះទ្រង់ក៏ចេះតែស្រឡាញ់គេ ដរាបដល់ចុងបំផុត» (១៣:១)។ យូដាសមកដល់វេលានេះបានចាកចេញទៅទាំងយប់ ព្រះយេស៊ូវទ្រង់កាន់តែបង្ហាញនូវក្តីស្រឡាញ់ដ៏ស្រទន់ដល់ពួកសិស្សដែលនៅសល់។ តែការយកព្រះទ័យទុកដាក់របស់ ទ្រង់ចំពោះគេគឺសម្រាប់សុខមាលភាពរបស់គេបន្ទាប់ពីទ្រង់នឹងយាងចាកចេញទៅ ប្រយោជន៍ឲ្យគេបានស្រឡាញ់គ្នាទៅវិញទៅមក។

ឥឡូវខណៈពេលព្រះគ្រីស្ទសម្តែងអត្តសញ្ញាណនៃសេចក្តីស្រឡាញ់អំពីសាវ័ករបស់ទ្រង់នាពេលអនាគតពេត្រុសបានក្រោកឈរឡើងនាឱកាសនោះដើម្បីសម្តែងនូវភក្តីភាពរបស់គាត់នឹងគ្រោះថ្នាក់ដែលនឹងកើតមានឡើងចំពោះរបស់គ្រូគាត់។ គាត់ដូចជាសិស្សដទៃទៀតដែរបានដឹងថា ព្រះអម្ចាស់របស់ខ្លួនកំពុងឈានមកដល់ វេលាមានវិបត្តិ ជាវេលានៃការចាប់ខ្លួននិងការសុគត។ នៅក្នុងខណៈពេលសម្រេចចិត្តដ៏ចាំបាច់ គាត់បានថ្វាយខ្លួនត្រៀម ដើម្បីស្លាប់ជាមួយគ្រូ។ តើនោះមិនមែនជាបទពិសោធន៍របស់យើងជាអ្នកដែលធ្វើតាមអារម្មណ៍របស់យើង? សូមកុំសូវរងារខ្លាំងពេក! នៅពេលព្រះយេស៊ូវព្យាករណ៍ទុកជាមុនថាពេត្រុសនឹងបដិសេធទ្រង់បីដងមុនពេលមាន់រងាវជាសញ្ញា ដូចនេះយើងត្រូវតែរំឭកពីការទុកចិត្តខ្លួនឯងហួសហេតុពេកដែរ។

ខ្ញុំបានស្គាល់ចាស់ទុំម្នាក់ដែលបានស្រឡាញ់ព្រះអម្ចាស់របស់គាត់យ៉ាងខ្លាំងហើយនិយាយយ៉ាងក្លៀវក្លាដើម្បីបុព្វហេតុរបស់ទ្រង់នាពេលស្រុកមានសន្តិភាព។ នាអំឡុងពេលជប៉ុនគ្រប់គ្រងប្រទេសសឹង្ហបុរីចាស់ទុំរូបនេះត្រូវបានគេផែកខ្លួននាពេលគាត់ដើរឆ្លងកាត់អ្នកយាមជនជាតិជប៉ុន។ ខិត្តប័ណ្ណជាច្រើនត្រូវបានគេរកឃើញនៅនឹងខ្លួនរបស់គាត់។ នៅពេលគេសួរបើសិនគាត់ជាគ្រីស្ទបរិស័ទ គាត់ប្រកាសបដិសេធយ៉ាងខ្លាំងៗថាគាត់មិនមែនជាគ្រីស្ទបរិស័ទឡើយ។ ពេត្រុសអើយ សូមកុំសូវរងារខ្លាំងពេក!

**ការពិចារណា៖** «...*តើអ្នកនឹងប្តូរជីវិតជំនួសខ្ញុំឬ?...*» (យ៉ូហាន ១៣:៣៨)។
**ការអធិស្ឋាន៖** ព្រះអម្ចាស់អើយ សូមឲ្យខ្ញុំមានចិត្តក្លាហាន ដូចជាពួកដានីយ៉ែល។

ថ្ងៃទី ៣០ កញ្ញា
យ៉ូហាន ១៤

## ជំពូកទី ១៤

### ចំពោះថូម៉ាសនិងអ្នកស្វែងរកសេចក្ដីសង្គ្រោះ ព្រះយេស៊ូវគ្រីស្ទ ជាផ្លូវ ជាសេចក្ដីពិត និងជាជីវិត

ខណៈពេលជិតយប់ហើយវេលារំលងអធ្រាតខិតឈានមកដល់ ក្រុមសាវ័ក (លើកលែងតែយូដាស)មានចិត្ត រំខានដោយការព្រួយបារម្ភកាន់តែខ្លាំងឡើងៗ។ ដើម្បីសម្រាលនូវសេចក្ដីភ័យខ្លាចទាំងឡាយរបស់គេ ព្រះអម្ចាស់នៃ យើងបានកំសាន្តចិត្តគេដោយសេចក្ដីអធិប្បាយនេះពីបន្ទប់រៀបចំបុណ្យរំលង។

ថ្វីដ្បិតព្រះអង្គនឹងត្រូវចាកចេញពីពួកសិស្សរបស់ទ្រង់នាពេលដ៏ខ្លី គង់តែទ្រង់នឹងមិនទុកឲ្យពួកគេនៅដោយ គ្មានការកំសាន្តចិត្តដូចកូនកំព្រាវង្វេងកណ្ដោចកណ្ដែងនោះឡើយ។ ព្រះអង្គនឹងយាងត្រឡប់ទៅឯព្រះវរបិតាទ្រង់វិញ ហើយទ្រង់នឹងយាងត្រឡប់មកទទួលពួកគេទៅឯលំនៅដ៏ប្រសើរដែលទ្រង់នឹងរៀបចំទុកសម្រាប់ពួកគេ។ នៅក្នុង ការអធិប្បាយនេះព្រះយេស៊ូវដឹកនាំពួកគេចូលទៅរកសេចក្ដីពិតដ៏ខ្ពស់ឧត្ដម ដោយមានមេរៀនអនុវត្តន៍ជាច្រើនទុកជា ការបំភ្លឺចិត្តរបស់ក្រុមសាវ័កនិងចិត្តរបស់យើងផងដែរ។

(១). ដំណើរយាងមកជាលើកទីពីររបស់ទ្រង់
(២). ភាពជាមាគ៌ាតែមួយទៅកាន់ព្រះជាម្ចាស់
(៣). ភាពរួមគ្នាតែមួយនឹងព្រះវរបិតា
(៤). ការបញ្ជូនព្រះវិញ្ញាណបរិសុទ្ធនៃទ្រង់
(៥). សេចក្ដីសុខសាន្តនៃទ្រង់ដ៏ប្រសើរជាងលោកីយ
(៦). ការស្ដាប់បង្គាប់នៃទ្រង់ចំពោះព្រះវរបិតា

ជារឿយៗយើងឮដំណឹងល្អ យ៉ូហាន ១៤:១-៦ អាននាកម្មវិធីបុណ្យសពទុកជាការលើកទឹកចិត្តដល់សមាជិក គ្រួសារដែលកំពុងកាន់ទុក្ខ។ យើងស្ដាប់ខទាំងនោះជាច្រើនដងរហូតដល់យើងស្ទើរតែទន្ទេញចាំមាត់។ ចូរយើងយកចិត្ត ទុកដាក់ឲ្យបានច្រើនបន្ថែមទៀតនូវបំណែក(ខគម្ពីរ) ដែលនៅសល់ក្នុងជំពូកនេះ។

ជាធម្មតា សាវ័កពេត្រុសជាអ្នកដែលក្រោកឈរឡើងនិយាយ ឬសួរសំណួរជាច្រើន។ ដោយទើបតែបានប្រាប់ ពីដំណើរដែលគាត់នឹងបដិសេធព្រះអម្ចាស់ខ្លួនចំនួនបីដងនាពេលប្រឈមមុខនឹងសត្រូវរបស់គាត់ ហើយដោយពាក្យ នោះជាប្រផ្នូលអាក្រក់ លោកពេត្រុសក៏នៅស្ងៀម ។

តើអ្នកអាចប្រាប់ឈ្មោះសាវ័កបីនាក់ដែលនឹងនិយាយបានទេលើកនេះ? តើយូដាស មិនមែនអ៊ីស្ការីយ៉ុត ជាអ្នក ណា? គាត់គឺជាអ្នកនិពន្ធសំបុត្រយូដាស ជាអ្នកដែលត្រូវហៅថា ថាដេ និងលេបេ (ម៉ាថាយ ១០:៣)។

**ការពិចារណា៖** តើព្រះយេស៊ូវជាអ្នកណាសម្រាប់អ្នក?
**ការអធិស្ឋាន៖** ឱព្រះវរបិតាអើយ សូមអរព្រះគុណទ្រង់សម្រាប់ការសន្យានឹងយាងមកទទួលយើងខ្ញុំ។

## ✍ កំណត់ត្រាមេរៀនផ្សេងៗពី អ.អ.រ

The Gospel of Life ([illegible])-A5_ata.indd 107 2021-06-30 12:30:27 PM




ពេលសាកលវិទ្យាល័យជាន់ខ្ពស់និងមហាវិទ្យាល័យព្រះគម្ពីរនៅគ្រប់ទីកន្លែងប្រាស់ចាកចេញពីសេចក្តីជំនឿនាសម័យចុងក្រោយនេះមហាវិទ្យាល័យព្រះគម្ពីរ ហ្វាអ៊ីស្ទីន **(Far Eastern Bible College)** នៅតែបន្តឈររឹងមាំ ឥតរង្គើរ នៅលើថ្មដាជាគ្រឹះរឹងមាំ ដ៏ជាព្រះអម្ចាស់យេស៊ូវគ្រីស្ទនៃយើង និងនៅ លើព្រះបន្ទូលដ៏បរិសុទ្ធ ជាពាក្យដែលព្រះវិញ្ញាណបណ្តាលឲ្យតែង ឥតភាន់ច្រឡំ ឥតកំហុស និងអធិរក្សទុកយ៉ាងល្អសុក្រិត។

អែហ្វ អ៊ី ប៊ី ស៊ី (FEBC) ប្រកាន់ជំហរតាម «ដំណឹងល្អបែបប្រវត្តិសាស្ត្រ» ជា «សេចក្តីជំនឿដែលបានប្រគល់ មកពួកបរិសុទ្ធ១ដងជាសំរេច»តយុទ្ធនឹងគោល លទ្ធិសាតាំងដែលបច្ចុប្បន្នកំពុងជ្រាបហូរហៀរក្នុងបណ្តាពួកជំនុំ ជាលទ្ធិមានដូចជា៖ លទ្ធិសេរីនិយម លិទ្ធិសម័យនិយម លទ្ធិដំណឹងល្អសម័យនិយម លទ្ធិការិស្មាទិក លទ្ធិពួកជំនុំរួបរួមនិយម លទ្ធិរ៉ូម៉ាំងកាតូលិក និងលទ្ធិអាថ៌កំបាំងសម័យទំនើបនិយម ជាដើម។ល។

តើអ្នកមិនអាចមកសិក្សានៅ អែហ្វ អ៊ី ប៊ី ស៊ី? អញ្ចឹងសូមអនុញ្ញាតឲ្យ អែហ្វ អ៊ី ប៊ី ស៊ី មកឯលោកអ្នកវិញ! សិក្សាដើម្បីទទួលវិញ្ញាបនប័ត្រចំណេះដឹងផ្នែកសាសនា **(CertRK)** មិនថាអ្នករស់នៅទីណាឡើយ។ ទទួលបាននូវ វិញ្ញាបនប័ត្រនេះតាមប្រពន្ធ័សិក្សាតាមអ៊ីធឺណែត! មុខវិជ្ជាជាច្រើនចាប់ផ្តើមបង្រៀននៅខែ មករានិងខែ កក្កដា ជារៀងរាល់ឆ្នាំ។ សម្រាប់ព័ត៌មានបន្ថែមសូមចូលទៅក្នុងគេហទំព័រមហាវិទ្យាល័យ។

ដើម្បីទទួលបាននូវការបង្ហាត់បង្រៀនដ៏ត្រឹមត្រូវតាមបទគម្ពីរ បែបប្រ៉ូតេស្តង់
និងវិជ្ជាខ្ពង់ខ្ពស់បែបចលនាកែទម្រង់ សូមចូលរួមសិក្សានៅ

# មហាវិទ្យាល័យព្រះគម្ពីរ ហ្វាអ៊ីស្ទីន

**(FAR EASTERN BIBLE COLLEGE)**

អាស័យដ្ឋាន៖ **9A Gilstead Road, Singapore 309063**
**E-mail: febc@febc.edu.sg**
**Website: http://www.febc.edu.sg**
ទំនាក់ទំនងនៅកម្ពុជា **+85512383513**
**+85569567990**